គណៈកម្មាធិការ
សហប្រតិបត្តិការ
ដើម្បីកម្ពុជា
Cooperation Committee
for Cambodia
Comité de Coopération
pour le Cambodge
CCC

# ការស្រាវជ្រាវខ្នាតតូច

## ជំហានទាំង១០នៃការវិភាគ

## បោះពុម្ពផ្សាយលើកទី ២



គំរោងវិភាគបញ្ហាអភិវឌ្ឍន៍ (អេឌីអាយ)

គណៈកម្មាធិការ សហប្រតិបត្តិការ ដើម្បីកម្ពុជា (ស៊ីស៊ីស៊ី)

២០០៦

Cooperation Committee for Cambodia
Comité de Coopération pour le Cambodge

# ការស្រាវជ្រាវខ្នាតតូច

## ជំហ៊ានទាំង១០នៃការវិភាគ

### បោះពុម្ពផ្សាយលើកទី ២

គំរោងវិភាគបញ្ហាអភិវឌ្ឍន៍ (អេឌីអាយ)

គណៈកម្មាធិការ សហប្រតិបត្តិការ ដើម្បីកម្ពុជា (ស៊ីស៊ីស៊ី)

២០០៦

ISBN - 13:  978 – 99950 – 874 – 1 - 8

# ការស្រាវជ្រាវខ្នាតតូច

## ជំហានទាំង១០នៃការវិភាគ

បោះពុម្ពផ្សាយលើកទី ២

គំរោងវិភាគបញ្ហាអភិវឌ្ឍន៍ (អេឌីអាយ)

គណៈកម្មាធិការ សហប្រតិបត្តិការ ដើម្បីកម្ពុជា (ស៊ីស៊ីស៊ី)

២០០៦

# សេចក្ដីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណ ចំពោះអ្នកពាក់ព័ន្ធសំខាន់ៗជាច្រើនដែលបានរួមចំណែកដោយផ្ទាល់ ឬមិនផ្ទាល់ដល់ការរៀបចំឯកសារនេះ។ នៅក្នុងចំណោមអ្នកទាំងនោះមាន សិក្ខាកាមជាច្រើននៅក្នុងវគ្គរៀនសូត្ររបស់ CCC-ADI និង សិក្ខាសាលា/វគ្គបណ្ដុះបណ្ដាលផ្សេងទៀតដែលអ្នកនិពន្ធបានធ្វើការសំរបសំរួល។ សំណួរនិងកង្វល់របស់ពួកគេបានធ្វើឱ្យមានការយកចិត្តទុកដាក់ទៅលើបញ្ហាសំខាន់ៗ ដែលត្រូវបានលើកយកមកបរិយាយនៅក្នុងសៀវភៅនេះ ។

សូមថ្លែងអំណរគុណផងដែរចំពោះអ្នកនិពន្ធដើមនៃសៀវភៅនេះ មានអ្នកស្រី អាង សូផា លោក សេង សារ៉ុធ លោក អឿ អ៊ីល និង លោក ដេវីដ សាមវេប័រ។ កិច្ចខិតខំរួមគ្នាក្នុងការបញ្ចូលគ្នានូវឯកសារមុនៗ ដែលមានចំណងជើងដូចគ្នាគឺ "ការស្រាវជ្រាវខ្នាតតូច" ជំហ៊ានទាំង ១០ សំរាប់ការវិភាគ បោះពុម្ពផ្សាយនៅ ខែ ធ្នូ ឆ្នាំ ២000 បានបើកច្រកឱ្យមានការស្រាវជ្រាវផ្នែកសង្គម ក្នុងចំណោមបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលជាច្រើននៅក្នុងប្រទេសកម្ពុជា និងបាននាំឱ្យមានលើកនូវសំណួរ និងកង្វល់ថ្មីៗ ដែលឯកសារនេះបានលើកឡើង ។

ជាចុងក្រោយ សូមអរគុណជាពិសេសចំពោះក្រុម CCC–ADI មានអ្នកស្រី អាង សូផា លោក គង់ សៀកលី លោក អឿ អ៊ីល និងលោកបណ្ឌិត ចន ម៉ាកខិនខ្រូ ដែលបានផ្ដល់ឱកាសឱ្យអ្នកនិពន្ធក្នុងការរៀបចំបន្ថែមលើសៀវភៅដើម ការរួមចំណែកប្រកបដោយអត្ថន័យដល់ការធ្វើពង្រាងលើឯកសារនេះ ព្រមទាំងពិនិត្យ និងបញ្ជាក់ពីសារៈប្រយោជន៍នៃចំណុចបន្ថែមទៅលើឯកសារដើម ។

**ប្រវត្តិអ្នកនិពន្ធ**



លោកស្រីបណ្ឌិត រ៉េបេកា ខាថាឡា ឈ្មោះហៅក្រៅ ភីម) ជាអ្នកស្រាវជ្រាវផ្នែកអភិវឌ្ឍន៍ម្នាក់ ដែលមានបទពិសោធន៍ក្នុងការងារនេះជិត ២0 ឆ្នាំមកហើយ។ លោកស្រីបណ្ឌិត ភីម បានមកធ្វើការនៅក្នុងប្រទេសកម្ពុជានៅខែមករា ឆ្នាំ១៩៩៨។ គាត់បានធ្វើការរយៈពេលពីរឆ្នាំកន្លះជាអ្នកសំរបសំរួលការស្រាវជ្រាវ និងកសាងសម្ថភាពនៅក្នុងគំរោងស្រាវជ្រាវស្ដីអំពីភាពងាយរងគ្រោះនៃសេដ្ឋកិច្ច វប្បធម៌ និងយុទ្ធសាស្រ្ដដោះស្រាយ (SCVCS) របស់អង្គការ AFSC-UNICEF។ គាត់បានធ្វើការងារស្រដៀងគ្នានេះ ដែរឱ្យគំរោងផ្សេងៗជាច្រើនរបស់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្ដរជាតិ ស្ថាប័នរដ្ឋាភិបាលនានានៅក្នុងប្រទេសកម្ពុជា ព្រមទាំងក្រុមហ៊ុនដែលមានមូលដ្ឋាននៅបរទេសផងដែរ។ ការងារដំបូងរបស់គាត់ជាមួយគំរោងអេឌីអាយ របស់អង្គការ ស៊ីស៊ីស៊ី នៅឆ្នាំ ២00១ គឺសំរបសំរួលវគ្គស្រាវជ្រាវពិសេសមួយដល់អតីតសិក្ខាកាម អេឌីអាយ និងសរសេររបាយការណ៍ស្រាវជ្រាវស្ដីពី ការបែងចែកដីធ្លីខ្នាតតូចនៅកម្ពុជា: បទពិសោធន៍ករណី សិក្សាចំនួន៣។ នៅឆ្នាំ ២00៤ គាត់បានសំរបសំរួលការវិភាគទិន្ន័យបែបបរិមាណដល់ការសិក្សារបស់ក្រុមអេឌីអាយ ស្ដីអំពីផលប៉ះពាល់នៃឧស្សាហកម្មកាត់ដេរមកលើ ជីវភាពរស់នៅរបស់ប្រជាជននៅជនបទៈបទពិសោធន៍របស់កម្មការិនីរោងចក្រកាត់ដេរ និងគ្រួសាររបស់គេនៅខេត្តព្រៃវែង។

ការដាក់ប្រភពសំរង់ឯកសារនេះដែលត្រឹមត្រូវគឺៈ Catalla, Rebecca F. 2006 "ការស្រាវជ្រាវខ្នាតតូច" ជំហ៊ានទាំង ១០ នៃការវិភាគ ដែលបានបោះពុម្ពផ្សាយលើកទី ២ នៅទីក្រុងភ្នំពេញ ដោយគំរោងវិភាគបញ្ហាអភិវឌ្ឍន៍(ADI) នៃអង្គការគណៈកម្មាធិការសហប្រតិបត្តិការ ដើម្បីកម្ពុជា (CCC)។

# មាតិការឿង


**ផ្នែកទី ១: សេចក្តីផ្តើម** ........ ១

ចំណាប់អារម្មណ៍ស្តីអំពីសៀវភៅនេះ ........ ៣

លក្ខណៈទូទៅនៃជំហ៊ានទាំង១០នៃការវិភាគ ........ ៥

*ហេតុអ្វីបានជាយើងធ្វើការស្រាវជ្រាវ ហើយជាការស្រាវជ្រាវប្រភេទណា?* ........ ៥

*ការគិតពិចារណា និងការស្រាវជ្រាវ* ........ ១៣

*គុណតម្លៃនៃអ្នកស្រាវជ្រាវ* ........ ១៤

ជំហ៊ានទាំង១០នៃការវិភាគ និងការពន្យល់នៅក្នុងឧបករណ៍គិតគូរតាមលំដាប់លំដោយ ........ ១៦

**ផ្នែកទី ២: ការរៀបចំការស្រាវជ្រាវ** ........ ១៩

**ជំហ៊ានទី ១: កំណត់ប្រធានបទ គោលបំណង និងឯកតានៃការវិភាគជាមួយអ្នកពាក់ព័ន្ធ** ........ ២១

តើអ្នកមានប្រធានបទអ្វី? កំណត់រកបញ្ហានៃការស្រាវជ្រាវ ........ ២១

សរសេរការពិពណ៌នាអំពីបញ្ហា និងសំនួរគន្លឹះ/ស្រាវជ្រាវ ........ ២៤

កំណត់រកឯកតានៃការវិភាគ ........ ៣២

**ជំហ៊ានទី ២: ធ្វើផែនការប្រមូលពត៌មានពីប្រភពផ្សេងៗ** ........ ៣៩

កំណត់រកពតិមានដែលត្រូវការ ........ ៤១

កំណត់រកប្រភពពតិមាន ........ ៤៦

វិធីជ្រើសរើសសំណាក និងទំហំសំណាក ........ ៥២

រៀបចំឧបករណ៍ប្រមូលទិន្នន័យ ........ ៦១

ត្រៀមរៀបចំវិភាគទិន្នន័យ ........ ៦៨

**ផ្នែកទី ៣: ការអនុវត្តន៍នៅតាមមូលដ្ឋាន និង ការវិភាគទិន្នន័យ** ........ ៧៥

**ជំហ៊ានទី ៣: ការប្រមូល រៀបចំចំណាត់ថ្នាក់ និងរៀបចំចងក្រងពត៌មាន** ........ ៧៧

ក្រមសីលធម៌នៅក្នុងការសិក្សាស្រាវជ្រាវ ........ ៧៧

ការស្វែងយល់អំពីអត្រានៃការឆ្លើយតប ........ ៧៨

បច្ចេកទេសសំភាសន៍ និងកត់ត្រា ........ ៧៩

ដំណើរការបញ្ចូល និងសង្ខេបទិន្នន័យ ........ ៨៣

រៀបចំទំរង់នៃរបាយការណ៍ ........ ៩៥

**ជំហ៊ានទី ៤: ពិពណ៌នានូវលទ្ធផលរកឃើញរបស់អ្នក ហើយភ្ជាប់គ្នារវាងផ្នែកផ្សេងៗ** ........ ៩៩

កំណត់រកលំនាំ/និន្នាការ និងផ្នែកសំខាន់ៗ ........ ១០១

ភ្ជាប់ទំនាក់ទំនងគ្នារវាងការសង្កេត និងលំនាំផ្សេងៗទៀតដែលបានដឹង ........ ១០៦

**ជំហានទី ៥: កំណត់រកបុព្វហេតុឬសគល់ បញ្ហាគន្លឹះ និងសរសេរការវិភាគរបស់អ្នក** ..... ១០៩
ស្វែងយល់ពីទំនាក់ទំនងនៅក្នុងលំនាំដែលត្រូវបានសង្កេតឃើញ ..... ១១១
ការភ្ជាប់ទំនាក់ទំនងគ្នា/ភាពខុសគ្នា និងបុព្វហេតុនៃការសង្កេតឃើញ ..... ១១៦
ឧបករណ៍ និងបច្ចេកទេសដើម្បីធ្វើការភ្ជាប់ទំនាក់ទំនងផ្សេងៗ ..... ១១៨
ការទាញយកនូវបញ្ហាដែលជាប់ពាក់ព័ន្ធ ..... ១២៤
**ជំហានទី ៦: ការរៀបចំសេចក្តីសន្និដ្ឋាន** ..... ១២៧
ទាញយកសេចក្តីសន្និដ្ឋានពីលទ្ធផលរកឃើញ ..... ១២៩
រៀបចំសេចក្តីសន្និដ្ឋាននៃការសិក្សាស្រាវជ្រាវទាំងមូល ..... ១៣១
**ជំហានទី ៧: ការរៀបចំអនុសាសន៍** ..... ១៣៣
ការកំណត់រកអនុសាសន៍ ..... ១៣៥
រៀបចំកំណត់បញ្ហាដែលពាក់ព័ន្ធ ..... ១៣៧

**ផ្នែកទី ៤: សរសេរ និងផ្សព្វផ្សាយរបាយការណ៍** ..... ១៣៩
**ជំហានទី ៨: ការសរសេររបាយការណ៍** ..... ១៤១
ពិនិត្យមើលឡើងវិញ និងកែសំរួលទំរង់របាយការណ៍ ..... ១៤១
សរសេររបាយការណ៍ និងផ្នែកសំខាន់ខ្លះៗ ..... ១៤១
បញ្ជីត្រួតពិនិត្យសំរាប់កែលំអររបាយការណ៍ពង្រាង ..... ១៤៦
**ជំហានទី ៩: ឆ្លុះបញ្ចាំងលើលទ្ធផលរកឃើញជាមួយអ្នកពាក់ព័ន្ធ** ..... ១៤៩
**ជំហានទី ១០: ផ្សព្វផ្សាយលទ្ធផលរកឃើញ** ..... ១៥៣

**ឯកសារពិគ្រោះ** ..... ១៥៧

# **បញ្ជីនៃប្រអប់**


**ប្រអប់ ១.** ស្វែងយល់ពីលទ្ធភាពអាចធ្វើការស្រាវជ្រាវបាន ............ ២២
**ប្រអប់ ២.** ឧទាហរណ៍មួយនៃការពិពណ៌នាអំពីបញ្ហា ............ ២៤
**ប្រអប់ ៣.** ឧទាហរណ៍មួយនៃសំណួរស្រាវជ្រាវ ............ ២៩
**ប្រអប់ ៤.** ឧទាហរណ៍មួយនៃការកំណត់សំណាកជាទ្រឹស្តី ............ ៥៣
**ប្រអប់ ៥.** សំណាកនៃប្រក្រតីទិនសំរាប់សំភាសន៍ ............ ៧០
**ប្រអប់ ៦.** ការយល់ពីស្ថិតិដែលជាតួលេខសង្ខេបសំរាប់ទិន្នន័យ ............ ៨៧


# **បញ្ជីនៃរូបភាព**


**រូបទី ១.** ការស្រាវជ្រាវនៅក្នុងបរិបទនៃវដ្តរបស់កម្មវិធី/គំរោង ............ ៨
**រូបទី ២.** ជំហ៊ានទាំង១០នៃការស្រាវជ្រាវ និងឧបករណ៍សំរាប់គិតគូរតាមលំដាប់លំដោយ ............ ១៦
**រូបទី ៣.** កំរិតនៃការវាស់វែង ............ ៤៤
**រូបទី ៤.** ការពន្យល់បង្ហាញតាមវិធីចំរុះ (Triangulation) ............ ៥១
**រូបទី ៥.** ហេតុផលនៃការកំណត់សំណាកបែបបរិមាណ ............ ៥៥
**រូបទី ៦.** ការបង្ហាញតាមទំរង់ដ្យាក្រាម សំរាប់ការកំណត់សំណាកទៅតាមទីកន្លែងប្រមូលផ្តុំ ............ ៥៨
**រូបទី ៧.** ការសួរសំណួរ ............ ៦៦
**រូបទី ៨.** គំរូនៃ Pie Chart ............ ៩២
**រូបទី ៩.** ឧទាហរណ៍នៃការទាញចេញនូវចំណុចសំខាន់ៗ ............ ១០២
**រូបទី ១០.** ឧទាហរណ៍នៃការវិភាគតាមបែបប្រៀបធៀបទៅលើសេចក្តីសង្កេតឃើញ ............ ១១២
**រូបទី ១១.** ឧទាហរណ៍នៃការវិភាគដោយចងក្រង និងតាមដាននូវការសង្កេត ............ ១១៤
**រូបទី ១២.** ស្វែងយល់ពីទំនាក់ទំនងរវាងអង្គការមិនមែនរដ្ឋាភិបាល និងក្រុមប្រឹក្សាឃុំតាមរយៈដ្យាក្រាមស្ថាប័ន ..... ១១៩
**រូបទី ១៣.** ឧទាហរណ៍នៃដ្យាក្រាមស្តីពីបណ្តាញ ............ ១២០
**រូបទី ១៤.** ម៉ាទ្រិចស្តីពីចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និង ឧបសគ្គ ............ ១២១
**រូបទី ១៥.** ឧទាហរណ៍នៃដ្យាក្រាមស្តីពីហេតុនិងផលនៃការធ្វើចំណាកស្រុកតាមរដូវ ............ ១២៣
**រូបទី ១៦.** ការលាតត្រដាងនៃឧបករណ៍វិភាគ Force-Field ............ ១២៣
**រូបទី ១៧.** ឧទាហរណ៍នៃវិធីទាញយកនូវបញ្ហាដែលពាក់ព័ន្ធ ............ ១២៦

## បញ្ជីនៃតារាង


**តារាងទី ១.** ភាពខុសគ្នារវាងវិធីតាមគុណភាព និងបរិមាណ ........ ១១

**តារាងទី ២.** ទំរង់នៃសំណួរស្រាវជ្រាវ ហើយនិងវិធីសាស្ត្រស្រាវជ្រាវដែលគេអាចនឹងយកមកប្រើ ........ ២៦

**តារាងទី ៣.** កំណត់ចំណាំខ្លីៗស្តីឯកតានៃការវិភាគ ........ ៣៧

**តារាងទី ៤.** កំរិត និងទំហំនៃការវិភាគ ........ ៤៦

**តារាងទី ៥.** វិធីសាស្ត្រប្រមូលទិន្នន័យរួមខ្លះនៅក្នុងការស្រាវជ្រាវផ្នែកសង្គម ........ ៤៩

**តារាងទី ៦.** ទំរង់នៃរបាយការណ៍ ........ ៩៦

**តារាងទី ៧.** ខ្លឹមសាររួមនៃរបាយការណ៍ស្រាវជ្រាវ និងការស្រាវជ្រាវស្តីពីការប្រើថ្នាំញៀនរបស់ CCC-ADI ...... ១៤២


## បញ្ជីនៃឧបសម្ព័ន្ធ


**ឧបសម្ព័ន្ធ ១:** ការសិក្សាស្រាវជ្រាវរបស់ក្រុម ADI ........ ១៦៣

**ឧបសម្ព័ន្ធ ២:** សទ្ទានុក្រម ........ ១៦៤

**ឧបសម្ព័ន្ធ ៣:** ទំហំ ឬជ្រុងនៃការវិភាគ ........ ១៦៧

**ឧបសម្ព័ន្ធ ៤:** វិធីសាស្ត្រខ្លះនៃការរៀនសូត្រ និងធ្វើសកម្មភាពតាមការចូលរួម ........ ១៦៩

**ឧបសម្ព័ន្ធ ៥:** ការជ្រើសរើសសំណាកតាមវិធីបែងចែកជាស្រទាប់ពីរដំណាក់ការ ........ ១៧១

**ឧបសម្ព័ន្ធ ៦:** ឯកសារដែលត្រូវបានជ្រើសរើសសំរាប់ការអានជាបន្តទៀត ........ ១៧៤

**ឧបសម្ព័ន្ធ ៧:** សំណួរដែលគេតែងតែសួរញឹកញាប់ ........ ១៧៥


## អក្សរកាត់

| | |
|---|---|
| ADI | គំរោងវិភាគបញ្ហានៃការអភិវឌ្ឍន៍ |
| CCC | គណៈកម្មាធិការ សហប្រតិបត្តិការ ដើម្បីកម្ពុជា |
| FGD | ការពិភាក្សាក្រុមតូចៗ |
| PRA/PLA | ការវាយតំលៃស្ថានភាពនៅជនបទតាមលក្ខណៈចូលរួម/សកម្មភាព និងការឆ្លុះបញ្ចាំង និងធ្វើសកម្មភាព ។ តាមលក្ខណៈចូលរួម/ការរៀនសូត្រ និងធ្វើសកម្មភាពតាមលក្ខណៈចូលរួម |

# ផ្នែកទី ១

# សេចក្ដីផ្ដើម

**ចំណាប់អារម្មណ៍ស្ដីអំពីសៀវភៅនេះ** ........ ៣

**លក្ខណៈទូទៅនៃជំហានទាំង១០នៃការវិភាគ** ........ ៥

*ហេតុអ្វីបានជាយើងធ្វើការស្រាវជ្រាវ ហើយជាការស្រាវជ្រាវប្រភេទណា?* ........ ៥

*ការគិតពិចារណានិងការស្រាវជ្រាវ* ........ ១៣

*គុណតម្លៃនៃអ្នកស្រាវជ្រាវ* ........ ១៤

**ជំហានទាំង១០នៃការវិភាគ និងការពន្យល់នៅក្នុងឧបករណ៍គិតគូរតាមលំដាប់លំដោយ** ........ ១៦

# សេចក្តីផ្តើម

## ចំណាប់អារម្មណ៍ស្តីអំពីសៀវភៅនេះ

នេះជាសៀវភៅស្តីពីវិធីសាស្ត្រធ្វើការស្រាវជ្រាវខ្នាតតូចមួយដើម្បីស្វែងយល់ឬវិភាគបញ្ហាមួយ ។ សៀវភៅនេះត្រូវបានសរសេរឡើងសំរាប់បុគ្គលិកនៃអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនៅក្នុងប្រទេសកម្ពុជា ហើយនិងអ្នកដែលតែងតែមានការពាក់ព័ន្ធនៅក្នុងការវាយតំលៃស្ថានភាពថ្មីៗ ការគ្រោងរៀបចំគំរោងថ្មីៗ ដោះស្រាយបញ្ហារបស់អង្គការ និង/ឬវាយតំលៃការងារក្នុងគំរោង/កម្មវិធីរបស់គេ ។ ស្ថានភាពទាំងអស់នេះ ទាមទារឱ្យមានការសិក្សា និងការវិភាគ ដែលនេះជាការបើកច្រកសំរាប់ការតាក់តែង និងពង្រីកបន្ថែមនូវឯកសារនេះ ។ អ្វីដែលសៀវភៅនេះលើកឡើងគឺជាការស្រាវជ្រាវខ្នាតតូច និងគោលការណ៍នៃការដោះស្រាយបញ្ហាដែលគេអាចយកទៅប្រើនៅក្នុងការសិក្សាស្វែងយល់ ឬពិនិត្យលើបញ្ហានៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ឬរហូតដល់ថ្នាក់អន្តរជាតិ ។

សៀវភៅនេះមិនមែនជាសៀវភៅស្តីពីការស្រាវជ្រាវសំរាប់ស្ថាប័នសិក្សាស្រាវជ្រាវជាន់ខ្ពស់នោះទេ ។ បើសំរាប់ស្ថាប័នសិក្សាស្រាវជ្រាវជាន់ខ្ពស់នោះ ឯកសារនេះនឹងត្រូវពង្រីកបន្ថែម និងលំអិតជាងនេះ ។ សៀវភៅនេះ ក៏មិនមែនសំរាប់ការធ្វើផែនការគំរោង ការតាមដាននិងវាយតំលៃដែរ ទោះបីជាវិធីសាស្ត្រដែលបានរៀបរាប់នោះ គេអាចយកទៅប្រើនៅត្រង់ផ្នែកណាមួយនៅក្នុងវដ្តនៃគំរោង ឬនៅពេលណាដែលគេត្រូវការពត៌មានបន្ថែម មុនពេលធ្វើការសំរេចចិត្តក្តី ។ ផ្ទុយទៅវិញ សៀវភៅនេះមានបំណងដើរតួជាឯកសារយោង ឬឯកសារណែនាំសំរាប់អ្នកស្រាវជ្រាវដែលទើបនឹងចាប់ផ្តើមធ្វើការងារសិក្សាស្រាវជ្រាវ ឬអ្នកធ្លាប់ធ្វើការងារស្រាវជ្រាវហើយ តែត្រូវការពង្រឹងបន្ថែមលើចំណេះដឹង និងបទពិសោធន៍របស់គេ ។ ទោះបីជាទស្សនៈស្តីពីការស្រាវជ្រាវគោលការណ៍ និងដំណើរការ ត្រូវបានលើកឡើងដើម្បីឱ្យស្រួលយល់ក្តី តែសៀវភៅនេះមិនមែនចង់មើលស្រាលលើការពិបាកនៅក្នុងការស្រាវជ្រាវនោះទេ ហើយក៏មិនមែនចង់ឱ្យគេយល់ឃើញថា ការស្រាវជ្រាវគឺជាដំណើរការដែលគេធ្វើទៅដោយមិនគិតគូរ ឬដោយត្រង់ៗគ្មានភាពបត់បែននោះដែរ ។ ការស្រាវជ្រាវគឺជាដំណើរការដែលមានភាពបត់បែន ហើយគិតនិងធ្វើម្តងហើយម្តងទៀត ដែលនោះជាការងារទាមទារអោយអ្នកស្រាវជ្រាវត្រូវចេះមានគំនិតច្នៃប្រឌិតដោយខ្លួនឯងនៅក្នុងការប្រើប្រាស់ ដំណើរការ និងជំហ៊ាននានានៅក្នុងការស្រាវជ្រាវរបស់គេ ដើម្បីរកឱ្យឃើញចំលើយចំពោះសំណួរ និង/ឬសេចក្តីត្រូវការពត៌មាន ។

អង្គការគណៈកម្មាធិការ សហប្រតិបត្តិការ ដើម្បីកម្ពុជា (CCC) បានពិនិត្យមើលឡើងវិញលើខ្លឹមសារនៃសៀវភៅនេះ ដោយផ្អែកលើវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់មកដែលសំរបសំរួលដោយគំរោង ADI ចាប់តាំងពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០៥ ។ សៀវភៅនេះប្រើប្រាស់បទពិសោធន៍នានា និងសំណួរដែលលើកឡើងដោយសិក្ខាកាមនៅក្នុងពេលដែលគេធ្វើការស្រាវជ្រាវខ្នាតតូច ឯកសារខ្លីៗដែលចែកជូនសិក្ខាកាមនៅក្នុងពេលដែលគេកំពុងរៀនសូត្រ រួមជាមួយនឹងឯកសារយោងដទៃទៀត ដែលអាចផ្តល់ជាប្រយោជន៍ដល់អ្នករៀនសូត្រឬស្រាវជ្រាវជាន់ខ្ពស់ ក៏ដូចជាអ្នកធ្វើការងារផ្នែកអភិវឌ្ឍន៍សង្គម ។ លើសពីនេះទៀត សៀវភៅនេះលើកឡើងនូវឧទាហរណ៍នៃ ការសិក្សាស្រាវជ្រាវដែលបានធ្វើជាមួយនឹងសិក្ខាកាមនៅក្នុងវគ្គរៀនសូត្ររបស់ ADI ទៅលើបញ្ហាអភិវឌ្ឍន៍ និងបញ្ហាក្នុងសង្គមមួយចំនួនដូចជា ការឆ្លើយតបរបស់ក្រុមជនជាតិដើមភាគតិចទៅនឹងការថយចុះ

ធនធានធម្មជាតិ អំពើហិង្សានៅក្នុងគ្រួសារ ការចេញទៅប្រកបការងារនៅប្រទេសថៃនិងព្រំដែនកម្ពុជា-ថៃ ការបែងចែកដីធ្លីក្នុងទ្រង់ទ្រាយតូចៗ ។ល ។ ឧបសម្ព័ន្ធ ១ ជាបញ្ជីនៃប្រធានបទស្រាវជ្រាវដែលក្រុម ADI និងសិក្ខាកាមចូលរួមនៅក្នុងវគ្គសិក្សាដែលបានធ្វើការស្រាវជ្រាវចាប់តាំងពីឆ្នាំ ២០០១ មក ។ សទ្ទានុក្រមនៅក្នុងឧបសម្ព័ន្ធ ២ គឺជាការបន្ថែមលើសៀវភៅនេះ ដើម្បីណែនាំដល់អ្នកស្រាវជ្រាវថ្មីៗ ដែលមិនទាន់យល់ច្បាស់ពីពាក្យពេជន៏ដែលគេប្រើនៅក្នុងការស្រាវជ្រាវផ្នែកសង្គម ។ ឧបសម្ពន្ធ័៣-៧ គឺជាឯកសារថ្មីផងដែរ សំរាប់ជួយអ្នកអានបន្ថែមទៀតដែលទាក់ទង នឹងទស្សនះការស្រាវជ្រាវ ក៏ដូចជាឧបករណ៏និងបច្ចេកទេស ។

ពិតមែនហើយថា ផ្នែកខ្លះនៃសៀវភៅនេះមិនមែនមានប្រយោជន៏សំរាប់គ្រប់ស្ថានភាពទេ តែគេសង្ឃឹមថាអ្នកធ្វើការនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលដែលមានបទពិសោធន៏ និងអ្នកប្រើប្រាស់សៀវភៅនេះផ្សេងទៀត ពិតជាអាចជ្រើសយកគំនិតដែលមានប្រយោជន៏ ផាត់ចោលគំនិតផ្សេងទៀតដែលមិនមានប្រយោជន៏ ហើយកែសំរួលសមស្របទៅតាមស្ថានភាព ឬបញ្ហានៅក្នុងការស្រាវជ្រាវដែលមានលក្ខណៈប្លែកៗរបស់គេ ។ សូមអានសៀវភៅនេះទាំងមូល ឬរំលងទៅផ្នែកណាដែលពាក់ព័ន្ធទៅនឹងសេចក្តីត្រូវការរបស់អ្នក ។ យើងសូមស្វាគមន៏ជានិច្ច ចំពោះមតិកែលំអរលើឯកសារនេះ ។

# លក្ខណៈទូទៅនៃជំហ៊ានទាំង ១០ នៃការវិភាគ

## ហេតុអ្វីបានជាយើងធ្វើការស្រាវជ្រាវ ហើយការស្រាវជ្រាវប្រភេទណា?

*...កន្លែងនៃការស្រាវជ្រាវនៅក្នុងការធ្វើផែនការគំរោង/កម្មវិធី ការអនុវត្តន៍ និងការតាមដាន ...យល់ដឹងពីការស្រាវជ្រាវ និងវាយតំលៃ ....កំណត់ពីភាពខុសគ្នារវាងវិធីសាស្ត្រប៉ែបគុណភាពនិងវិធីសាស្ត្រប៉ែបបរិមាណ ...... រួមបញ្ចូលវិធីសាស្ត្រនានា .....ការគិតពិចារណានិងការស្រាវជ្រាវ ...គុណតំលៃរបស់អ្នកស្រាវជ្រាវ ។*

ការស្រាវជ្រាវគឺជាការងារដែលមានធ្វើនៅក្នុងអ្វីដែលយើងធ្វើរាល់ថ្ងៃ ។ យើងប្រមូលពតិមាន និងបញ្ចូលទិន្នន័យ ដែលយើងទទួលបានពីបុគ្គលម្នាក់ៗ ឬរួមជាមួយនឹងគ្រួសារ/មិត្តភក្តិ នៅពេលយើងចង់ស្វែងរកចំលើយទៅនឹងសំណួរដែលបានចោទឡើង ដូចជា តើមានសាលាមួយណាល្អសំរាប់ចូលរៀនបន្តនៅមហាវិទ្យាល័យ? តើទុនវិនិយោគអ្វីខ្លះដែលនឹងនាំអោយមានផលចំណេញច្រើនបំផុត? តើភោជនីយដ្ឋានណាខ្លះដែលមានម្ហូបឆ្ងាញ់ ហើយមានតំលៃថោកសមរម្យ? តើមន្ទីរពេទ្យណា ដែលគ្រួសារឬមិត្តរបស់យើងអាចទៅរកព្យាបាលនៅពេលឈឺ ឬត្រូវការព្យាបាលជាបន្ទាន់?.... ។ល ។

ការស្រាវជ្រាវនៅក្នុងផ្នែកអភិវឌ្ឍន៏សង្គមក៏ត្រូវមានការចោទជាសំណួរ និងស្វែងរកពតិមានបែបហ្នឹងដែរសំរាប់ជួយយើងឱ្យយល់ពីហេតុការណ៍ ឬបញ្ហាដើម្បីយើងអាចរៀបចំការឆ្លើយតបបាន ។ នៅក្នុងបរិបទនេះ ការស្រាវជ្រាវគឺជាប្រភពនៃចំណេះដឹងលើបញ្ហាដែលគេត្រូវដឹង ហើយវាគឺជាមូលដ្ឋានសំរាប់ធ្វើការសំរេចចិត្តឱ្យបានល្អ មិនថាទាក់ទងនឹងការរៀបចំទស្សនៈនៃគំរោងថ្មីមួយ ឬការពិនិត្យមើលឡើងវិញលើអន្តរាគមន៍របស់គំរោង ឬកម្មវិធីមួយទេ ។

### កំណត់និយមន័យនៃការសិក្សាស្រាវជ្រាវ (Defining research)

ការស្រាវជ្រាវគឺជាការសិក្សាស្វែងយល់ ដែលមានលក្ខណៈហ្មត់ចត់ ដើម្បីស្វែងរកចំលើយទៅនឹងបញ្ហា[១] មួយ ។ គោលបំណងគឺប្រហែលចង់រកមើលពតិមានថ្មី (រកមើលទិន្នន័យ) និង/ឬបកស្រាយទំនាក់ទំនងនៅក្នុងចំណោមផ្នែកនានានៃបញ្ហាណាមួយដែលកំពុងតែត្រូវបានសិក្សា (វែកញែកតាមទ្រឹស្តី) ។ មានហេតុផលទូទៅចំនួនបី ដែលធ្វើឱ្យគេធ្វើការស្រាវជ្រាវ[២]:

១. ជា *ការសិក្សាបែបរុករក* ឬដើម្បីធ្វើឱ្យគេស្គាល់ជាដំបូងលើប្រធានបទ ។ វិធីនេះគឺគេធ្វើជាតួយ៉ាងនៅពេលដែលអ្នកស្រាវជ្រាវពិនិត្យអ្វីដែលថ្មីគួរជាទីចាប់អារម្មណ៍ ឬនៅពេលដែលប្រធានបទនៃការសិក្សានៅមានលក្ខណៈថ្មី ។ វាក៏មានភាពសមរម្យផងដែរសំរាប់ហេតុការណ៍ឬបញ្ហាសង្គមដែលនៅរ៉ាំរ៉ៃ ដូចជា ការប្រើប្រាស់ថ្នាំញៀន ការរំលោភផ្លូវភេទ ។ល ។ ការសិក្សាស្រាវជ្រាវបែបរុករក ជាធម្មតា ត្រូវបានគេអនុវត្តក្នុងគោលបំណងបី (ក) ដើម្បីបំបាត់ចំងល់និងបំពេញតាមចំណង់ដែលចង់ដឹងអោយបានច្បាស់ថែមទៀតរបស់អ្នកស្រាវជ្រាវ (ខ) ដើម្បីតេស្តមើលលើលទ្ធភាពនៃការធ្វើការសិក្សាស្រាវជ្រាវ ស៊ីជំរៅថែមទៀត និង (គ) ដើម្បីតាក់តែងវិធីសាស្ត្រសំរាប់ប្រើនៅក្នុងការសិក្សាលើកក្រោយ ។ ការសិក្សាបែបនេះមានតំលៃនៅក្នុងការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រសង្គម ពីព្រោះវាមានសារៈសំខាន់ចាំបាច់នៅពេលណាដែលគេសិក្សាស្រាវជ្រាវលើផ្នែកសង្គម ពីព្រោះវាតែងតែផ្តល់នូវចំណេះដឹងថ្មីៗទៅលើប្រធានបទនៃការស្រាវជ្រាវ ។

[១] Burns, Robert B. 2000. *Introduction to Research Methods*. London: Sage Publication, p.3.
[២] ផ្នែកនេះដកស្រង់ពី Babbie, Earl. 1998. *The Practice of Social Research*. Eighth Edition. Belmont, CA: Wadsworth Publishing Company, pp. 90-92.

*ការសិក្សាស្រាវជ្រាវរបស់CCC-ADI ស្តីពីការប្រើប្រាស់គ្រឿងញៀនជាបញ្ហាសង្គម គឺជាឧទាហរណ៏បញ្ជាក់ទៅលើការសិក្សាស្រាវជ្រាវបែបរុករក ។ ឆ្លើយតបទៅនឹងការសង្កេតឃើញថា ការប្រើប្រាស់គ្រឿងញៀនមានការកើនឡើង នៅក្នុងចំណោមយុវជនខ្មែរពីគ្រប់ស្រទាប់ទាំងអស់ ។ សិក្ខាកាមនៅក្នុងវគ្គបណ្តុះបណ្តាលជំនាន់ទី១៣ ហើយនិងក្រុម ADI បានពិនិត្យមើលនិន្នាការនៃរឿងនេះក្នុងចំណោមយុវវ័យនៅតាមភូមិចំនួនបី ដែលបានជ្រើសរើសនៅក្នុងខេត្តបាត់ដំបងស្ថិតនៅភាគពាយ័ព្យនៃប្រទេស ។ សំណួរដែលគេចោទសួរគឺថាតើការប្រើប្រាស់គ្រឿងញៀននៅក្នុងចំណោមយុវវ័យ មានការកើនឡើង ថយចុះ ឬមិនមានការប្រែប្រួល ហេតុផលនៃនិន្នាការនោះ លក្ខណៈទូទៅរបស់អ្នកប្រើប្រភេទថ្នាំដែលគេប្រើ ហើយនិងសំណួរប្រហាក់ប្រហែលដទៃទៀតដែលជួយឱ្យគេយល់ពីបញ្ហានេះ ។*

២. សំរាប់ ***ការសិក្សាបែបពិពណ៌នា*** ឬដើម្បីរៀបរាប់ពីស្ថានភាព និងព្រឹត្តិការណ៏ ។ គោលបំណងសំខាន់នៃការសិក្សាផ្នែកអភិវឌ្ឍសង្គមជាច្រើនគឺដើម្បីរៀបរាប់ពីស្ថានភាពនិងព្រឹត្តិការណ៏នានា ។ នៅពេលធ្វើការសិក្សាបែបនេះ អ្នកស្រាវជ្រាវសង្កេតរួចហើយរៀបរាប់នូវអ្វីដែលគេបានសង្កេតឃើញ ។ ការនេះទាមទារអោយមានការប្រកាន់ជំហ៊ានដោយប្រយ័ត្នប្រយែង ពីព្រោះចាំបាច់ត្រូវមានភាពត្រឹមត្រូវច្បាស់លាស់ បើគេប្រៀបធៀបទៅនឹងការស៊ើបអង្កេតធម្មតា ។ ការអង្កេតផ្នែកសេដ្ឋកិច្ចសង្គម ឬផ្នែកប្រជាសាស្ត្រនៅថ្នាក់ជាតិ ច្រើនតែស្ថិតនៅក្នុងចំណោមការសិក្សាស្រាវជ្រាវបែបរៀបរាប់ពីព្រោះវាប្រាប់ពីលក្ខណៈទូទៅនៃប្រជាជន ។ ការសិក្សាស្រាវជ្រាវអំពីវប្បធម៌ប្រពៃណីរបស់មនុស្ស (Ethnographic study) ក៏ស្ថិតនៅក្នុងចំណាត់ប្រភេទនៃការសិក្សានេះដែរ ពីព្រោះវាផ្តល់ពត៌មានច្រើន និងលំអិតអំពីបុគ្គល និងក្រុមមនុស្ស ។

*ការសិក្សាស្រាវជ្រាវរបស់CCC-ADI ស្តីពីការបែងចែកដីធ្លីក្នុងទ្រង់ទ្រាយតូចនៅក្នុងប្រទេសកម្ពុជា គឺជាការសិក្សាបែបពិពណ៌នា ។ ដោយត្រូវបានរៀបចំនិងអនុវត្តនៅក្នុងឆ្នាំ ២០០៣ សំរាប់ការពិភាក្សាដែលមានជាបន្តបន្ទាប់ស្តីពីសម្បទានដីសង្គមកិច្ច ។ ការធ្វើអង្កេតមានបំណងរៀបរាប់គំរោងបែងចែកដីធ្លីចំនួនបីប្រភេទខុស១គ្នា នៅក្នុងចំណោមប្រជាជនក្រីក្រនៅតាមតំបន់ដែលត្រូវបានកំណត់នៅក្នុងខេត្តចំនួនបី ហើយពិនិត្យមើលលើកត្តាដែលធ្វើឱ្យមានជោគជ័យបញ្ហា និង/ឬបរាជ័យរបស់គំរោងនោះ ។ ជាផ្នែកមួយនៃគោលបំណងបែបរៀបរាប់ការអង្កេតនោះស្វែងយល់ពីលក្ខណៈនៃគំរោងបែងចែកដីធ្លីដែលមានដូចជាការពាក់ព័ន្ធរបស់មន្ត្រីរដ្ឋាភិបាល (ទាក់ទងនឹងការដែលថាអ្នកទទួលផលទទួលបាន/បាត់បង់ដីធ្លី) ការផ្សព្វផ្សាយពតិមានស្តីពីការបែងចែកដីធ្លី ថាតើគេមានអនុវត្តតាមគោលការណ៏ណែនាំឬយន្តការដែរឬទេ វិធីសាស្ត្រដែលគំរោងបង្កើនការចូលរួមរបស់ប្រជាជន ទំហំនិងប្រភេទដីដែលត្រូវបានបែងចែក ហើយនិងបញ្ហានៅក្នុងគំរោងបែងចែកដីធ្លី ។*

៣. ដើម្បី ***រកមើលសេចក្តីពន្យល់*** (និងដើម្បីផ្តល់អនុសាសន៏/ដំណោះស្រាយ) ។ នៅក្នុងការធ្វើការសិក្សាមួយ ដែលមានគោលបំណងស្វែងរកសេចក្តីពន្យល់ អ្នកស្រាវជ្រាវចាប់ពន្យល់ពីបាតុភូត និងព្រឹត្តិការណ៏សង្គម ។ គាត់ជជីកសួរថា ហេតុអ្វីក៏សាច់រឿងកើតឡើងរបៀបហ្នឹង កត្តាដែលកំណត់ឬជួយនាំឱ្យមានការកើតឡើងនូវបញ្ហាសង្គមនោះ (រួមទាំងផលវិបាកផងដែរ) ហេតុផលដែលក្រុមមនុស្សមួយក្រុមមានអាកប្បកិរិយា ខុសពីក្រុមមនុស្សមួយក្រុមទៀតនៅក្នុងសង្គម ។ល ។ ការកំណត់ពីទំនាក់ទំនងរវាង និងក្នុងចំណោមកត្តានានាដែលត្រូវបាន ជជីករកមើលក៏ជាផ្នែកមួយនៃការខិតខំដើម្បីផ្តល់សេចក្តីពន្យល់ចំពោះបញ្ហាផ្នែកសង្គម ដែលកំពុងត្រូវបានវិភាគ ។

*ការសិក្សារបស់ CCC-ADI ដែលផ្តោតទៅលើឧស្សាហកម្មកាត់ដេរ និងផលប៉ះពាល់របស់វាទៅលើជីវភាពរស់នៅរបស់ប្រជាជននៅជនបទ គឺជាការសិក្សាមួយទៀតរបស់ CCC-ADI ដែលផ្តល់ឧទាហរណ៏នៃការស្រាវជ្រាវ បែបពន្យល់ ។ នៅក្នុងវគ្គសិក្សាជាន់ខ្ពស់ជំនាន់ទី១នោះ សិក្ខាកាមនិងក្រុមADI ពិនិត្យហេតុផលថា*

*ហេតុអ្វីក៏កម្មករដែលមកពីភូមិដែលត្រូវបានជ្រើសរើសនៅក្នុងខេត្តព្រៃវែងនោះ ធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញ ដើម្បីរកការងារធ្វើនៅក្នុងរោងចក្រកាត់ដេរ ដោយរួមទាំងស្ថានភាពដោយឡែកៗ នៅក្នុងតំបន់ជនបទដែលនាំឱ្យកម្មកររោងចក្រកាត់ដេរធ្វើចំណាកស្រុក វាយតំលៃពីផលប៉ះពាល់នៃការងារនៅក្នុងរោងចក្រកាត់ដេរទៅលើជីវភាពរស់នៅតាមជនបទ យេនឌ័រនិងទំនាក់ទំនងរបស់កម្មករកាត់ដេរនៅក្នុងគ្រួសារ កំណត់ពីផលប៉ះពាល់នៃកម្មកររោងចក្រកាត់ដេរទៅលើការរៀបចំពលករទូទាំងប្រទេស ។ តាមពិតទៅការសិក្សានេះពន្យល់ពីការដែលការងារនៅក្នុងរោងចក្រកាត់ដេរនៅក្នុងទីក្រុងបានកំណត់រូបរាងនៃរចនាសម្ព័ន្ធសង្គមនៅតាមជនបទ (នោះគឺទំរង់បែបផែននៃជីវភាពរស់នៅ និងការងារយេនឌ័រនិងទំនាក់ទំនងក្នុងគ្រួសារ) ព្រមទាំងកម្មករជារួមនៅក្នុងប្រទេសកម្ពុជា ។*

***ពិតមែនហើយថា វាជាការមានប្រយោជន៍ ដែលគេកំណត់ពីភាពខុសគ្នារវាងគោលបំណង(Purpose) ទាំងបីនៃការស្រាវជ្រាវ តែគេក៏គួរកត់សំគាល់ផងដែរថា ការសិក្សាភាគច្រើនតែងតែរួមបញ្ចូលផ្នែកទាំងបីនោះ។*** *នៅក្នុងឧទាហរណ៏ខាងលើស្ដីពីការស្វែងយល់លើការប្រើប្រាស់គ្រឿងញៀន លក្ខណៈការសិក្សាបែបពន្យល់នោះ បង្ហាញពីនិន្នាការនៅក្នុងការប្រើប្រាស់គ្រឿងញៀននៅក្នុងចំណោមយុវវ័យ ។ វាមានលក្ខណៈរៀបរាប់ ពីព្រោះវាបានរៀបរាប់ពីចរិកលក្ខណៈរបស់អ្នកប្រើប្រាស់ថ្នាំញៀន និងលក្ខណៈនៃការប្រើប្រាស់ថ្នាំញៀននៅក្នុងចំណោមពួកគេនោះ ។ គេក៏បានដាក់បញ្ចូលនូវផ្នែកស្រាវជ្រាវបែបពន្យល់ដែរ ដោយការសិក្សានោះពិនិត្យទៅលើបុព្វហេតុ និងផលវិបាកនៃការប្រើប្រាស់ថ្នាំញៀននៅក្នុងសំណាកដែលបានធ្វើការសិក្សា ។*

## ការស្រាវជ្រាវ និងវដ្តនៃកម្មវិធី/គំរោង

គោលបំណងនៃការស្រាវជ្រាវដូចដែលបានរៀបរាប់ខាងលើនេះមានប្រយោជន៏ជាក់ស្ដែងនៅក្នុងវដ្តនៃកម្មវិធី/គំរោងស្ដីពីអន្តរាគមន៏លើការអភិវឌ្ឍន៏សង្គម (រូបទី១) ។ នៅក្នុងដំណាក់កាលធ្វើផែនការ ការស្រាវជ្រាវមាន សារៈសំខាន់ដោយអ្នកជំនាញផ្នែកអភិវឌ្ឍធ្វើការអង្កេតជាមូលដ្ឋាន ការសិក្សាទៅលើលទ្ធភាពដំណើរការទៅបាន ការប៉ាន់ប្រមាណពីសេចក្ដីត្រូវការ ឬការសិក្សាបែបស្វែងយល់ដទៃទៀតដែលមានទំរង់ដូចនៅក្នុងវិធីសាស្ត្រនៃការវាយស្ថានភាពជនបទដោយមានការចូលរួម (PRA)[៣] (ឧទាហរណ៏ ការធ្វើផែនទីភូមិ ការវិភាគលើជីវភាពរស់នៅ ការពិភាក្សារបស់ក្រុមមនុស្សសំខាន់ ។ល។) គោលបំណងគឺដើម្បីកំណត់ពតិមានដែលនឹងជួយដល់អ្នកកាន់គំរោង/កម្មវិធី នៅក្នុងការរៀបចំតាក់តែងកម្មវិធីនិងផ្នែកអន្តរាគមន៏របស់កម្មវិធីនោះ ដើម្បីអាចឆ្លើយតបប្រកបដោយប្រសិទ្ធភាព ចំពោះស្ថានភាពដែលត្រូវការការពិនិត្យដោះស្រាយ ។

នៅពេលដែលកម្មវិធី/គំរោងត្រូវបានគេដំណើរការទៅគេបន្តប្រមូលពតិមាន បញ្ចូលទិន្នន័យ និងវិភាគ ពតិមានជាប្រចាំក្នុងគោលបំណងត្រួតពិនិត្យតាមដាន ។ ការធ្វើដូច្នេះគឺដើម្បីកំណត់ឱ្យដឹងថា តើគំរោង/កម្មវិធី ដំណើរការទៅមុខដល់ណា និងដើម្បីស្វែងយល់ដំណើរការនៃការអនុវត្តន៏គំរោង ។ សកម្មភាពនេះគឺគេអាច ធ្វើតាមលក្ខណៈជាប្រព័ន្ធផ្លូវការ និងមិនផ្លូវការ (ឧទាហរណ៏ តាមរយៈការចុះទៅមើលដោយមានឬមិនមានការគ្រោងជាផែនការ និងការឆ្លុះបញ្ចាំងរវាងបុគ្គលិកគំរោងជាមួយនឹងអ្នកទទួលផល ដើម្បីពិនិត្យមើលថា តើគេបានសំរេចគោលដៅជាមួយនឹងធនធានដែលគេបានកំណត់មកនោះដែរឬទេ) ។ នៅពាក់កណ្ដាលដំណើរការនៃគំរោងការស្រាវជ្រាវដែលត្រូវបានគ្រោងរៀបចំដោយប្រុងប្រយ័ត្នតាមរយៈការវាយតំលៃ អាចត្រូវបានគេធ្វើឡើងដើម្បីពិនិត្យថា តើគេបានសំរេចគោលបំណងរបស់គំរោងហើយឬនៅ ដើម្បីពិនិត្យមើលឱកាស និងឧបសគ្គរបស់គំរោង និង/ឬ ដើម្បីកំណត់ថាតើគួរចេញវិធានការថ្មីៗចំពោះស្ថានភាពដែលកំពុងតែប្រែប្រួលនោះដែរឬទេ ។

[៣] នៅក្នុងពេលថ្មីៗនេះត្រូវបានគេហៅថា វិធីសាស្ត្ររៀនសូត្រ និងធ្វើសកម្មភាពតាមលក្ខណៈចូលរួម (PLA)

នៅពេលដែលកម្មវិធី/គំរោងជិតចប់ ជាថ្មីម្តងទៀត ការស្រាវជ្រាវមានតួនាទីមួយនៅពេលដែលការវាយតំលៃចុងក្រោយត្រូវបានធ្វើ។ ពត៌មានដែលត្រូវបានប្រមូលនិងបញ្ចូលទិន្នន័យច្រើនតែមានគោលបំណងសំរាប់វាស់ស្ទង់មើលលើផលប៉ះពាល់នៃ គំរោង ដោយរួមទាំងភាពសមស្រប ឬភាពមានប្រយោជន៍នៃគោលបំណង និងការរៀបចំគំរោង ប្រសិទ្ធភាព និងនិរន្តភាព ព្រមទាំងបទពិសោធន៍នៃការរៀនសូត្រ ។

**រូបទី១: ការស្រាវជ្រាវនៅក្នុងបរិបទនៃវដ្តរបស់គំរោង/កម្មវិធី**




សំណួរមួយដែលអាចលេចចេញពីចំណុចនេះគឺៈ តើការស្រាវជ្រាវខុសគ្នាពីការវាយតំលៃយ៉ាងដូចម្តេច? និយមន័យមួយនៃការវាយតំលៃគំរោង/កម្មវិធីលើកឡើងថា "ការវាយតំលៃគឺជាការប្រមូលពត៌មានទៅតាមលំដាប់លំដោយស្តីពីសកម្មភាព លក្ខណៈនិងលទ្ធផលនៃកម្មវិធី សំរាប់ប្រើប្រាស់ដោយមនុស្សក្នុងក្រុមណាមួយ ដើម្បីកាត់បន្ថយភាពមិនច្បាស់លាស់ បង្កើនប្រសិទ្ធិភាព ហើយធ្វើការសំរេចចិត្តទាក់ទងនឹងអ្វីដែលកម្មវិធីទាំងនេះកំពុងតែធ្វើនិងមានឥទ្ធិពលទៅលើ"(Patton, 1987:14)។ តាមពិតទៅ ការវាយតំលៃនៅតាមដំណាក់កាលផ្សេងៗនៃកម្មវិធី/គំរោងធ្វើឱ្យគេអាចប្រើប្រាស់ពត៌មានបានភ្លាមៗសំរាប់បំរើគោលបំណងដែលដៅលើសកម្មភាពមួយៗ។ លក្ខណៈដែលដៅលើសកម្មភាពរបស់ការវាយតំលៃកម្មវិធីគឺជាលក្ខណៈដោយឡែកមួយរបស់វាដែលខុសពីការស្រាវជ្រាវជាមូលដ្ឋានតាមលក្ខណៈវិទ្យាសាស្ត្រ។ Patton (1987:14) បានកត់សំគាល់ដោយខ្លីលើចំណុចនេះ នៅពេលគាត់សង្កេតឃើញថាការស្រាវជ្រាវត្រូវបានគេធ្វើ "ដើម្បីស្វែងរកចំណេះដឹងថ្មី តេស្តលើទ្រឹស្តីបញ្ជាក់លើការពិតអ្វីមួយនិងកំណត់យកជាលក្ខណៈទូទៅ "ក្នុងរយៈពេលកំណត់មួយ។ ផ្ទុយទៅវិញ ការវាយតំលៃត្រូវបានធ្វើ "ដើម្បីប្រាប់ឱ្យដឹងពីសកម្មភាពបំភ្លឺលើការជ្រើសរើស កាត់បន្ថយភាពមិនប្រាកដប្រជា ហើយផ្តល់ពត៌មានស្តីពីកម្មវិធី និងគោលនយោបាយនៅក្នុងព្រំដែននៃបរិបទពេលវេលា ទីកន្លែង គុណតំលៃ និងនយោបាយ"។ ភាពខុសគ្នានេះ ជាញឹកញាប់ត្រូវបានគេពន្យល់ច្បាស់ដោយយោលទៅលើការដែលថាការវាយតំលៃកម្មវិធីប្រើវិធីសាស្ត្រស្រាវជ្រាវផ្នែកសង្គម ដើម្បីរកបានពត៌មាន

ដែលគេត្រូវការបើនិយាយឱ្យចំគឺ ការគ្រោងរៀបចំលើការស្រាវជ្រាវ និងការប្រមូលទិន្នន័យរួមទាំងបច្ចេកទេសនិងវិធី នៅក្នុងការវិភាគទិន្នន័យ ។

## ការបង្ហាញពីភាពខុសគ្នារវាងវិធីសាស្ត្រ (APPROACHES) នានាក្នុងការស្រាវជ្រាវ

អ្នកស្រាវជ្រាវថ្មីៗ និងអ្នកស្រាវជ្រាវដែលមានបទពិសោធន៍ជាញឹកញាប់ច្រើនតែប្រឈមនឹងស្ថានភាពគ្មានច្រកចេញថា តើគេកំពុងតែធ្វើការសិក្សាតាមបែបគុណភាពឬបរិមាណ ឬមួយថាតើអ្វីដែលគេមានគឺជាទិន្នន័យបែបបរិមាណឬគុណភាព ។ ប្រការសំខាន់គឺភាពខុសគ្នាស្ថិតនៅត្រង់ផ្នែកទស្សនៈ និងការសន្មតនៃវិធីសាស្ត្រទាំងពីរនេះ ដែលមានន័យថាអាស្រ័យលើវិធីប្រមូលទិន្នន័យ និងការសង្កេត/ករណីប៉ុន្មានដែលគួរធ្វើ (តារាងទី ១) ។ ទោះបីជាមានភាពខុសគ្នាយ៉ាងនេះក្តី ក៏អំណះអំណាងនិងទំលាប់ធ្វើដែលមានរហូតមកដល់ពេលនេះបានជំរុញឱ្យប្រើវិធីទាំងពីរយ៉ាងនេះនៅក្នុងការស្រាវជ្រាវ ដែលប្រើប្រាស់យុទ្ធសាស្ត្រច្រើនពីព្រោះមិនមានវិធីសាស្ត្រណាអាចឆ្លើយបានទៅនឹងសំណួរទាំងអស់ ហើយផ្តល់ការយល់ដឹងទៅលើបញ្ហាទាំងអស់បានទេ (Burns, 2000:11) ។

**ការស្រាវជ្រាវបែបបរិមាណ** (ត្រូវបានគេស្គាល់ផងដែរថាជារបៀបវិទ្យាសាស្ត្របែបបុរាណឬការស្រាវជ្រាវជាមូលដ្ឋាន/តាមធម្មតា) ផ្តើមចេញពីទស្សនៈថាចំណេះដឹងបែបវិទ្យាសាស្ត្រគឺជាចំណេះតែម្យ៉ាងដែលគេអាចយកជាការបាន[៤] (Neuman, 2000:7) ។ នៅក្នុងវិធីនេះ ការលើកហេតុផលតាមបែបវិទ្យាសាស្ត្រគឺផ្អែកលើវិធីទូលាយឆ្ពោះមកកាន់ភាពជាក់លាក់ (Deduction) និងសម្មតិកម្មតាមបែបវិទ្យាសាស្ត្រដែលអាចបង្ហាញថាមិនពិត ។ អ្នកស្រាវជ្រាវចង់បានភាពមិនលំអៀងច្បាស់លាស់ចំពោះឥរិយាបទរបស់គេអំពីប្រធានបទណាមួយ ការប្រមូលទិន្នន័យនិងការធ្វើពិសោធន៍ទៅលើទិន្នន័យ ។ គេច្រើនសង្កត់ធ្ងន់លើការគ្រប់គ្រងលក្ខខ័ណ្ឌស្រាវជ្រាវ ដើម្បីកាត់បន្ថយឱ្យបានច្រើនបំផុតនូវភាពលំអៀង និងលក្ខណៈគំរាមកំហែងដល់ភាពត្រឹមត្រូវនៃលទ្ធផលរកឃើញ និងសង្កត់ធ្ងន់ទៅលើការប្តេជ្ញាចិត្ត ចំពោះការរៀបចំតាក់តែងការស្រាវជ្រាវដែលត្រូវបានធ្វើមុនពេលចុះទៅកាន់មូលដ្ឋានស្រាវជ្រាវ (Lewis-Beck et al, 2004:893-894) ។

ដូច្នេះការស្រាវជ្រាវបែបបរិមាណមានលក្ខណៈជាការទាញយកសំណាកដែលពីសំណាកនោះអ្នកស្រាវជ្រាវចង់ទាញការសន្និដ្ឋានពីព្រោះថាគេមិនអាចប្រមូលទិន្នន័យស្តីពីមនុស្សទាំងអស់បានទេ ។ ការស្រាវជ្រាវបែបនេះ ទាមទារការជ្រើសរើសសំណាកសមស្រប ការជ្រើសរើសសំណាកចៃដន្យតាមបែបស្ថិតិ (Statistical Random Sample) និងទាមទារឱ្យមានការប្រើប្រាស់ទំរង់បញ្ចូលទិន្នន័យដែលអនុញ្ញាតិឱ្យអ្នកស្រាវជ្រាវទាញការសន្និដ្ឋានលើទំនាក់ទំនងរវាងអថេរ ឬបញ្ហាផ្សេងៗដែលកំពុងត្រូវបានពិនិត្យ ដើម្បីទាញការសន្និដ្ឋានទៅលើចំនួនសំណាក (Lewis-Beck et al, 2004:896) ។ ដូច្នេះ ដូចយើងដឹងតាមរយៈឈ្មោះវាហើយ ការស្រាវជ្រាវផ្អែកបរិមាណ នាំមកនូវលទ្ធផលដែលចេញពីការគណនាទៅលើបរិមាណជាច្រើន ពោលគឺភាគច្រើនសុទ្ធតែជាតួលេខ ។ បើនិយាយអោយស្រួលយល់បំផុត ការស្រាវជ្រាវបែបបរិមាណគឺជា ការរាប់ និងវាស់វែងអ្វីៗច្រើនយ៉ាង (Berg, 1989:2) ។

[៤] ទស្សនៈនេះត្រូវបានគេហៅថាវិជ្ជមាននិយម ដែលសំដៅទៅលើការយកវិធី និងគោលការណ៍នៃវិទ្យាសាស្ត្រធម្មជាតិ សំរាប់សិក្សាលើអាកប្បកិរិយារបស់មនុស្សឬសំរាប់ការសិក្សាបាតុភូតសង្គម (Berg, 1989:9; Burns, 2000:4)

ចំណុចខ្លាំងសំខាន់ៗនៃការសិក្សាស្រាវជ្រាវបែបបរិមាណ ស្ថិតនៅត្រង់ចំណុចខាងក្រោមនេះ (Neuman, 2000:9):

- ភាពសុក្រិត្យ (Accuracy) និងការត្រួតត្រាបាន (Control) ។ ការត្រួតត្រាបាន សំដៅលើការកំណត់សំណាក និងការគ្រោងរៀបចំស្រាវជ្រាវ ព្រមទាំងភាពច្បាស់លាស់នៃរង្វាស់ជាបរិមាណ និងជារង្វាស់ដែលគួរឱ្យទុកចិត្តបាន ។
- ការពន្យល់ពីហេតុនិងផល អាចធ្វើទៅបានលុះត្រាតែធ្វើការធ្វើពិសោធន៍ (នោះគឺការកំណត់ស្ថានភាព[៥] "សំរាប់ការត្រួតត្រាបាន" និង "សំរាប់ការធ្វើពិសោធ៍") (Experimental/Treatment Situation)
- សម្មតិកម្ម ត្រូវបានធ្វើពិសោធន៍ ឬតេស្តសាកល្បងមើលតាមរយៈវិធីសាស្រ្តទូលាយឆ្ពោះទៅរកភាពជាក់លាក់ (Deductive approach) និងការយកទិន្នន័យបែបបរិមាណ មកធ្វើវិភាគតាមលក្ខណៈស្ថិតិ ។

[៥] ក្នុងការស្រាវជ្រាវបែបពិសោធន៍មើលនៅក្នុងការអភិវឌ្ឍន៍សង្គម ស្ថានភាព "គ្រប់គ្រង" ចង់សំដៅទៅលើតំបន់ក្បែរៗខាង ឬភូមិដែលមិនមានសកម្មភាពរបស់គំរោង/កម្មវិធី ចំណែកឯស្ថានភាព "នៃការធ្វើពិសោធន៍" គឺតំបន់ក្បែរខាង ឬភូមិដែលនៅទីនោះ សកម្មភាពអន្តរាគមន៍ត្រូវបានគេគ្រោងផែនការ និងអនុវត្តន៍។ ស្ថានភាពនេះកើតមានឡើងនៅពេលដែលគេមានការខិតខំ ដើម្បីធ្វើការប្រៀបធៀបការផ្លាស់ប្តូរ (ឬកង្វះការផ្លាស់ប្តូរ) ទាំងនៅក្នុងតំបន់ក្បែរខាង ទាក់ទងនឹងផ្នែកពិសោធន៍ និងការគ្រប់គ្រងដូចជាគំរោង/កម្មវិធីផ្នែកអនាម័យនិងទឹក ។

**តារាងទី ១: ភាពខុសគ្នារវាងវិធីសាស្ត្រមែបគុណភាពនិងវិធីសាស្ត្រមែបបរិមាណ**

| គុណភាព | បរិមាណ |
|---|---|
| ***ការសន្មត*** *(Assumptions)* | |
| ការពិតត្រូវបានកំណត់ជាលក្ខណៈសង្គម | ការពិត និងទិន្នន័យមានលក្ខណៈពិតមិនលំអៀង ។ |
| អថេរស៊ាំញ៉ាំនិងអថេរវេញប្រទាក់គ្នា(Variable interwoven) | អថេរនានាអាចត្រូវបានកំណត់និងវាស់វែងបាន ។ |
| ពិបាកឱ្យគេវាស់វែង | អ្វីដែលកើតឡើងត្រូវបានមើលទៅតាមទស្សនៈរបស់អ្នក ខាងក្រៅ |
| អ្វីដែលកើតឡើងត្រូវបានកំណត់ទៅតាមទស្សនៈរបស់អ្នកដែល | ភាពមិនប្រែប្រួលនៃស្ថានភាពពិតនៃជីវិត ។ |
| មានបទពិសោធន៍ ឬចាស់ទុំ | |
| គុណភាពនៃជីវិតដ៏រស់រវើក (Dynamic quality to life) | |
| ***គោលបំណង*** *(Purpose)* | |
| បកស្រាយ | ភាពច្បាស់លាស់ |
| កំណត់ទៅតាមបរិបទ | អាចនិយាយសំដៅស្ថានភាពរួមបាន |
| យល់ពីទស្សនៈរបស់អ្នកដទៃ | ការពន្យល់ទំនាក់ទំនងរវាងហេតុផល |
| ***វិធីសាស្ត្រ*** *(Method)* | |
| ការប្រមូលទិន្នន័យតាមរយៈការសង្កេតរបស់អ្នកចូលរួមការ | ការធ្វើតេស្តមើលនិងវាស់វែង |
| សំភាសន៍ដែលមិនមានរៀបរយ | ចាប់ផ្តើមជាមួយនឹងសម្មតិកម្ម *(Hypothesis)* ហើយនិងទ្រឹស្តី |
| សន្និដ្ឋានដោយមានសម្មតិកម្ម និងទ្រឹស្តីដែលកើតមានឡើង | ការភ្ជាប់ទំនាក់ទំនង និងការត្រួតត្រាបាន |
| តាមភាពជាក់ស្តែង | ការផ្តើមចេញពីភាពទូលាយទៅកាន់ភាពជាក់លាក់ |
| និងការរៀបរាប់ | និងការធ្វើពិសោធន៍ |
| ការលេចចេញនូវស្ថានការណ៍ថ្មីៗ | ការវិភាគប្រើស្ថិតិ |
| ផ្តើមចេញពីភាពជាក់លាក់មកភាពទូលាយ | របាយការណ៍ជាលក្ខណៈស្ថិតិ |
| ការវិភាគទិន្នន័យតាមខ្លឹមសារនៃអ្នកផ្តល់ព័ត៌មាន | សំណេរដែលសំដៅទៅរកស្ថានភាពរួម |
| ទិន្នន័យត្រូវបានរាយការណ៍តាមភាសារបស់អ្នកផ្តល់ព័ត៌មាន | |
| សំណេរមានលក្ខណៈរៀបរាប់ | |
| ***តួនាទីរបស់អ្នកស្រាវជ្រាវ*** | |
| អ្នកស្រាវជ្រាវជាឧបករណ៍សំរាប់ប្រមូលព័ត៌មាន | អ្នកស្រាវជ្រាវប្រើប្រាស់ឧបករណ៍ផ្លូវការ |
| ការចូលរួមដោយអ្នកស្រាវជ្រាវផ្ទាល់ | មិនចាំបាច់ចុះទៅស្រាវជ្រាវផ្ទាល់ |
| ការយល់ស្ថានភាពអោយច្បាស់ | មានទិសដៅច្បាស់លាស់ |

ប្រភព Brown, L. David and Rajesh Tandon (1983); Narayan, Deepa (1996), Burns (2000)

*ការស្រាវជ្រាវបែបគុណភាព* គឺជាពាក្យដែលគេប្រើសំរាប់យុទ្ធសាស្ត្រមួយចំនួនក្នុងការអង្កេតដែលមានបំណង ស្វែងយល់ពីការយល់ដឹង បទពិសោធន៍ ការបកស្រាយ និងបង្កើតឱ្យមានពិភពផ្នែកសង្គម (Lewis-Beck et al, 2004:893) ។ ដោយមានឬសគល់ចេញពីទស្សនៈវិជ្ជាមួយចំនួនហើយនិងប្រពៃណីរបស់មនុស្សយូរអង្វែង ការស្រាវជ្រាវនេះតាមធម្មតារួមមានការកំណត់ទស្សនៈយល់ឃើញរបស់មនុស្ស ឬអ្វីដែលគេច្រើនហៅថាទស្សនៈរបស់អ្នកសំដែង (Lewis-Beck et al, 2004:893; Mason, 1996:4) ។ វាច្រើនតែត្រូវបានសំគាល់ដោយលក្ខណៈកំណត់ខ្លះ ដូចជាការកំណត់ទិសទៅតាមករណីរបស់វា (Case orientation) ការចាប់អារម្មណ៍លើបរិបទ វប្បធម៌និងប្រវត្តិសាស្ត្រ ហើយនិងការឆ្លុះបញ្ចាំងទៅលើខ្លួនឯងវិញ (Reflexivity) ។ ការឆ្លុះបញ្ចាំងលើខ្លួនឯង នេះចង់និយាយសំដៅទៅរកសមត្ថភាពរបស់អ្នកស្រាវជ្រាវនៅក្នុងការឆ្លុះបញ្ចាំងជាលំអិតទៅលើតួនាទីរបស់គេផ្ទាល់នៅក្នុងដំណើរការស្រាវជ្រាវ ពិសេសនៅត្រង់ថា គេនាំមកនូវភាពលំអៀងនៅក្នុងករិតណាមួយចូលទៅក្នុងស្ថានភាពនៃការស្រាវជ្រាវពីព្រោះថា ពួកគេគឺចុះទៅកាន់មូលដ្ឋានសកម្មក្នុងដំណើរការស្រាវជ្រាវ ហើយថាអ្នកស្រាវជ្រាវត្រូវផ្តោតជាសំខាន់ចំពោះចំណេះដឹង និងភស្តុតាងដែលប្រមូលបានមកពីមូលដ្ឋានផ្ទាល់ (Mason, 1996:6) ។

មិនដូចស្ថានភាពនៃការស្រាវជ្រាវបែបបរិមាណទេ គំរោងស្រាវជ្រាវបែបគុណភាពសង្កត់ធ្ងន់លើ "ធម្មជាតិនិយម (Naturalism)" ឬលើការសង្កេតលើអ្វីដែលកើតឡើង ដោយមិនមានការសំរបសំរួលលើលក្ខខ័ណ្ឌណាមួយ និងការតាក់តែងនិងសំអិតសំអាងជាបន្តដល់ការគ្រោងរៀបចំការស្រាវជ្រាវក្រោយពីចុះដល់មូលដ្ឋាននៃការសិក្សាទេ (Lewis-Beck et al, 2004:894) ។ ចំណុចនេះស្នើឡើងថាវិធីនេះទាមទារឱ្យមានមនុស្ស ដែលចេះ "គិតនិងធ្វើតាមបែបយុទ្ធសាស្ត្រ" ប្រកបដោយការចេះបត់បែនតាមកាលៈទេសៈ និងភាពច្នៃប្រឌិតនៅតាមមូលដ្ឋានដើម្បី "រួមបញ្ចូលគ្នានូវប្រាជ្ញាទស្សនៈបច្ចេកទេស និងការប្រតិបត្តិជាក់ស្តែង (ក្រមសីលធម៌)" (Mason, 1996:2) ។ វាយ៉ាងដូច្នេះពីព្រោះអ្នកស្រាវជ្រាវបែបគុណភាពមិនយកទៅជាមួយខ្លួនគេនូវប្លង់នៃការស្រាវជ្រាវទេ នៅក្នុងការធ្វើការងារស៊ើបអង្កេតរបស់គេ ។ ដូច្នេះ គេត្រូវគិត "ដោយមិនមានជំនួយ" (Mason, p. 165) ។ ដូចគ្នាច្រើនទៅនឹងអ្នកស្រាវជ្រាវបែបបរិមាណ អ្នកស្រាវជ្រាវបែបគុណភាពត្រូវមានក្រមសីលធម៌ និងការតស៊ូនៅក្នុងការងាររបស់គេ ។ ប្រការនេះមានសារៈសំខាន់ជាពិសេសសំរាប់អ្នកស្រាវជ្រាវបែបគុណភាព ពីព្រោះតែទំនាក់ទំនងដែលគេកសាងឱ្យមានជាមួយនឹងអ្នកផ្តល់ចំលើយឱ្យគេ និងត្រូវផ្តល់ការពន្យល់ទាក់ទងនឹងផ្នែកសង្គម ដែលគេអាចពន្យល់ជាទំរង់ទូទៅតាមបែបណាមួយបាន ។

តំលៃនៃការសិក្សាបែបគុណភាពស្ថិតនៅត្រង់សមត្ថភាពរបស់គេនៅក្នុងការ (Marshall and Rossman, 1989:46; Burns, 2000:13):

- ប្រើវិធីសាស្ត្រដកស្រង់គំនិតពីប្រភពផ្សេងៗ (Eclectic methodologies) ការសន្មតសម្មតិកម្មដោយសេរី *(Hypothesis free orientation)* ហើយទទួលយកទាំងស្រុងអ្វីទាំងអស់ដែលបានកើតចេញមក ។
- ស្វែងយល់ឱ្យបានស៊ីជំរៅទៅលើភាពសាំញ៉ាំ និងដំណើរការដើម្បីអាចដោះស្រាយឱ្យជ្រះស្រឡះនូវទំនាក់ទំនងក្រៅផ្លូវការ និងមិនមានរចនាសម្ព័ន្ធ និងដំណើរការក្នុងអន្តរាគមន៍របស់គំរោង/កម្មវិធី ។
- ធ្វើឱ្យអ្នកស្រាវជ្រាវអាចយល់ថែមទៀតពីទស្សនៈមនុស្សនៅទីកន្លែង ដែលអ្នកជ្រាវធ្វើការសិក្សាស្រាវជ្រាវ ។

ភាពខុសគ្នារវាងទិន្នន័យបែបបរិមាណ និង ទិន្នន័យបែបគុណភាព នៅក្នុងការស្រាវជ្រាវផ្នែកសង្គម គឺជាភាពខុសគ្នារវាងទិន្នន័យជាតួលេខ និងទិន្នន័យមិនមែនជាតួលេខ (Babbie, 1998:36) ។ នៅពេលអ្នកណាម្នាក់និយាយថា ជីវិតរបស់គាត់

មានការពិបាក មានន័យថា គាត់កំពុងតែប្រាប់អំពីទិន្នន័យទាក់ទងនឹងគុណភាព ។ នៅពេលអ្នកនិយាយថា គាត់ស្ថិតនៅក្នុងលំដាប់លេខ ៩ នៅលើរង្វាស់លេខពី១ ដល់ ១០ នោះមានន័យថា អ្នកកំពុងតែកំណត់បរិមាណទៅលើការនិយាយ/ទិន្នន័យបែបគុណភាព ។ ដូច្នេះ គេគួរកត់ចំណាំថា រាល់ការសង្កេត (ឬពតិមានណាមួយ) តាំងពីដំបូងគឺសុទ្ធតែមានទ្រង់ទ្រាយជាគុណភាព មិនថាវាជាការជួបប្រទះនូវការលំបាករបស់មនុស្ស ការកំណត់ទីតាំងនៅលើរង្វាស់អ្វីមួយ ឬគំនូសដែលបានគូសនៅក្នុងបញ្ជីសំណួរនោះទេ ។ ទាំងនេះមិនមានលក្ខណៈជាបរិមាណ ឬជាលេខនោះទេ តែពេលខ្លះវាជាការមានប្រយោជន៍ បើគេ ***បង្វែរ*** វាឱ្យទៅជាទំរង់តួលេខ (Babbie, 1998:36) ។

*វិធីមួយនៃការស្រាវជ្រាវមិនមែនសុទ្ធតែល្អឬអន់ជាងវិធីមួយទៀតនោះទេ ។ វិធីទាំងពីរអាចតំណាងឱ្យ ទស្សនៈខុសគ្នាតែវិធីទាំងពីរនេះគឺជាមធ្យោបាយសមស្របនៃការស្រាវជ្រាវ ហើយអាចបំពេញបន្ថែមគ្នា និងផ្តល់ការឆ្វេងយល់ឃើញផ្សេងទៀតទៅក្នុងអាកប្បកិរិយារបស់មនុស្ស ។*

ការកំណត់បរិមាណ ច្រើនតែធ្វើអោយការសង្កេតរបស់យើងមានភាពច្បាស់លាស់ ។ វាថែមទាំងធ្វើឱ្យមានភាពងាយស្រួលនៅក្នុងការបញ្ចូលគ្នា និងសង្ខេបទិន្នន័យ ។ តាមរបៀបនេះវាបើកចំហលទ្ធភាពនៃការវិភាគលើស្ថិតិរាប់ពីចំនួនគិតជាមធ្យមជាធម្មតា រហូតដល់រូបមន្តសាំញ៉ាំ និងគំរូគណិតវិទ្យា (Babbie, 1998:37) ។ ផ្ទុយទៅវិញ ទិន្នន័យបែបគុណភាពផ្តល់នូវភាពស៊ីជំរៅ និងសេចក្តីលំអិតបន្ថែម ហើយមានអត្ថន័យជ្រាលជ្រៅជាងទិន្នន័យបរិមាណ ។ ជាការល្អដែលថា គេមិនចាំបាច់ជ្រើសរើសរវាងទិន្នន័យទាំងពីរនេះទេ ថាតើមួយណាប្រសើរជាង ឬសមស្របជាងសំរាប់ការស្រាវជ្រាវផ្នែកសង្គម ពីព្រោះថាទាំងពីរនេះ សុទ្ធតែជាឧបករណ៍មានប្រយោជន៍ និងសមស្របសំរាប់ការស្រាវជ្រាវ (Babbie, 1998:38; Mason, 1996:4) ។ អ្នកជំនាញក្នុងការស្រាវជ្រាវផ្នែកទាំងពីរនេះ បញ្ជាក់ទៅលើការយល់ឃើញថាស្ថានភាព និងប្រធានបទនៃការស្រាវជ្រាវខ្លះសមស្របបំផុតសំរាប់ការអង្កេតបែបគុណភាព ចំណែកខ្លះទៀតសមស្របសំរាប់ការអង្កេតបែបបរិមាណ ហើយបញ្ជាក់ថាវិធីទាំងពីរនេះ ចាំបាច់ទាមទារឱ្យមានជំនាញ និងដំណើរការខុសគ្នា ។ ប៉ុន្តែអ្វីដែលសំខាន់បំផុតសំរាប់ការដាក់បញ្ចូលគ្នានូវវិធីនានា (និងវិធីសាស្ត្រ) គឺការត្រូវកំណត់ឱ្យបានច្បាស់នូវអ្វីដែលកំពុងតែត្រូវបានសំរេចនៅក្នុងការធ្វើដូច្នេះ ។

## **ការគិតពិចារណា និងការស្រាវជ្រាវ** (Critical thinking and research)

ការគិតពិចារណានៅក្នុងបរិបទនៃការស្រាវជ្រាវ គឺជាសមត្ថភាពនៅក្នុងការពិនិត្យគ្រប់ជំហ៊ាននៃសកម្មភាពស្រាវជ្រាវ កំណត់ទំនាក់ទំនងពីចំនុចមួយទៅចំនុចមួយទៀតហើយវាយតំលៃទិន្នន័យដែលប្រមូលបាន បញ្ចូលទិន្នន័យ និងបកស្រាយរកមើលភាពច្បាស់លាស់ ភាពពេញលេញ និងភាពស៊ីគ្នា ។ បើនិយាយអោយខ្លី ការគិតគូរពិចារណា មានលក្ខណៈជាគោលជំហរចោទសួរ ឬដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យម៉ត់ចត់នូវអ្វីៗទាំងអស់ដែលយើងធ្វើ ពេលយើងធ្វើការស្រាវជ្រាវដើម្បីធ្វើរបាយការណ៍ស្រាវជ្រាវបែបវិភាគនិងពេញលេញ ។ ការគិត-ពិចារណានេះចាប់ផ្តើមពីការរៀបចំការអង្កេតនៅពេលដែលប្រធានបទត្រូវបានជ្រើសរើស ហើយវិភាគរកមើលប្រយោជន៍និងការរួមចំណែករបស់វាដល់ការបង្កើតចំណេះដឹង តើអ្នកណាជួយធ្វើការស្រាវជ្រាវនេះ តើការស្រាវជ្រាវនេះត្រូវការធនធានអ្វីខ្លះ និងតើប្រធានបទដែលត្រូវបានកំណត់ នឹងត្រូវបានវិភាគយ៉ាងដូចម្តេច ។ នៅពេលដែលវិធីសាស្ត្រប្រមូលទិន្នន័យត្រូវបានរៀបចំតាក់តែងសំរាប់កំណត់ប្រធានបទ បញ្ហាស្រាវជ្រាវ និងភាពច្បាស់លាស់នៃសំណួរដែលត្រូវបានសួរទាក់ទងនឹងអ្វីដែលគេស្វែងរកត្រូវបានគេលើកយកមកលាតត្រដាងនៅពេលអ្នកស្រាវជ្រាវធ្វើពង្រាងដោយប្រយ័ត្នប្រយែងលើចំណុចសំខាន់ៗដែលការប្រមូលទិន្នន័យត្រូវផ្តោតទៅលើ ។

ការចោទសួរស្តីពីវិធីសាស្ត្រប្រមូលពត៌មានអាចត្រូវបានគេបង្ហាញនៅក្នុងដំណាក់កាលនៃការប្រមូល ទិន្នន័យនៃការស្រាវជ្រាវ ។ ទស្សនៈស្តីពីការឆ្លុះបញ្ចាំងលើខ្លួនឯងនៅក្នុងការសិក្សាស្រាវជ្រាវបែបគុណភាពកំណត់ច្បាស់បំផុតនូវអ្វីដែលគេចង់បាននៅក្នុងដំណាក់កាលនេះ ។ ពោលគឺថា នៅពេលដែលគេចូលរួមនៅក្នុងការធ្វើការអង្កេត អ្នកស្រាវជ្រាវត្រូវដឹងពីការលំអៀងដែលខ្លួនគេអាចមាន ឬឥទ្ធិពលដែលគេបញ្ចូលដោយមិនដឹងខ្លួនទៅក្នុងដំណើរការសំភាសន៍ ។ ចំណុចនេះ គេមើលឃើញច្បាស់នៅពេលដែលអ្នកស្រាវជ្រាវនិយាយជាមួយនឹងអ្នកឆ្លើយ ពិសេសនៅក្នុងការបង្កើតឱ្យមានអារម្មណ៍ថា អ្នកឆ្លើយត្រូវផ្តល់ពត៌មានដែលគេចង់បាន ឬអារម្មណ៍ថា អ្នកស្រាវជ្រាវមានចំណេះដឹងច្រើនជាងអ្នកដែលត្រូវបានគេសំភាសន៍ជាមួយ ទាក់ទងនឹងស្ថានភាពថ្មី ។ នេះអាចនាំឱ្យមានការមិនទុកចិត្ត ឬការរារែកនៅក្នុងការចែករំលែកពត៌មាន ។ ប្រការនេះលេចឡើងផងដែរនៅក្នុងវិធីសាស្ត្រ ដែលអ្នកស្រាវជ្រាវសួរស្ទាបស្ទង់រកពត៌មានសំរាប់បំភ្លឺនិងបំពេញចន្លោះខ្វះខាតនៅក្នុងចំលើយ ។

នៅក្នុងការបញ្ចូល និងបកស្រាយទិន្នន័យ ការគិតគូរពិចារណាមានសារៈសំខាន់ផងដែរ ដោយសារអ្នកស្រាវជ្រាវត្រូវពិនិត្យម៉ត់ចត់លើការងាររបស់គេ ដើម្បីសង្ខេបលើពត៌មានដែលត្រូវបានប្រមូលមក ដើម្បីធ្វើយ៉ាងណាឱ្យបទបង្ហាញទាំងមូលស៊ីគ្នានឹងគោលបំណងជាក់លាក់របស់ការសិក្សាស្រាវជ្រាវ ។ វាត្រូវតែមាន ដូច្នេះ នៅពេលដែលគេពិនិត្យមើលថាតើត្រូវធ្វើយ៉ាងម៉េចល្អដើម្បីផ្តុំទិន្នន័យហើយសង្ខេបវាដើម្បីឱ្យអ្នកប្រើប្រាស់ងាយយល់ ហើយនៅពេលដែលគេមើលឃើញលំនាំបែបផែននៅក្នុងទិន្នន័យ-មិនថាការបង្ហាញជាតារាង ឬបង្ហាញជាករណីសិក្សាឡើយ-និងស្វែងយល់មើលថា តើលក្ខណៈអ្វីខ្លះដែលមានសារៈសំខាន់នៅក្នុងរូបភាពរួមដែលត្រូវបានគេបង្ហាញ ។

សេចក្តីដូចខាងលើនេះចង់បង្ហាញថា ការដែលគេត្រូវគិតគូរពិចារណាបង្ខំឱ្យអ្នកស្រាវជ្រាវលើកឡើងដដែលៗច្រើនដងរវាងដំណាក់កាលស្រាវជ្រាវរបស់គាត់ដែលគេត្រូវបកស្រាយ និងវិភាគជាប្រចាំព្រមទាំងរកមើលសេចក្តីពន្យល់ពីសកម្មភាពដែលគេកំពុងតែធ្វើ និងពត៌មានដែលគេទទួលបាន ។ វាមានន័យផងដែរថាជាការកំណត់ ឬរកមើលនិងស្វែងយល់លើជំរើសនានា-មិនថាជាការប្រមូលនិងចំរាញ់ទិន្នន័យឬជាការជីកកកាយរកមើលនិន្នាការដែលលេចចេញច្បាស់និងមិនច្បាស់ ព្រមជាមួយនឹងការរកមើលសេចក្តីពន្យល់ចំពោះលក្ខណៈដែលគេបានសង្កេតឃើញនៅក្នុងទិន្នន័យនោះទេ ។

## គុណតំលៃរបស់អ្នកស្រាវជ្រាវ **(Researcher’s values)**

គេបានកត់សំគាល់ឃើញនៅក្នុងផ្នែកដើមថា រាល់ការសង្កេត (ឬផ្នែកនៃពត៌មានណាមួយ) មានលក្ខណៈជាគុណភាពតាំងពីដំបូង រាប់ទាំងការពិបាកដែលមនុស្សម្នាក់បានជួបប្រទះ ទីតាំងដែលបានដៅលើគំនូសក្រិត ឬគំនូសដែលគេគូសនៅក្នុងបញ្ជីសំណួរក្តី (Babbie,1998:36) ។ ចំណុចនេះបង្ហាញថារបៀបដែលយើងប្រមើលមើលទៅស្ថានភាព ហេតុការណ៍ ឬរឿងអ្វីមួយត្រូវបានកំណត់លក្ខណៈដោយទស្សនៈឬជំនឿរបស់យើង ហើយទស្សនៈនិងជំនឿនេះគឺជាផលនៃបទពិសោធន៍ ចំណេះដឹងដែលទទួលបាន និងបរិយាកាសសង្គមរបស់យើង ។ អ្វីដែលមានជាប់នៅក្នុងទស្សនៈទាំងនេះគឺ គុណតំលៃដែលយើងមាន ។ គុណតំលៃនេះធ្វើឱ្យប្រតិកម្មភ្លាមៗរបស់យើងមានលក្ខណៈវិជ្ជមាន (គឺ លើកទឹកចិត្ត ឬស្ទាបស្ទង់) ឬមានលក្ខណៈអវិជ្ជមាន (គឺភាពមិនរវីរវល់ ឬខ្វះការចាប់អារម្មណ៍) ឬសូម្បីការបង្ហាញពីដំណើរជីវិតដែលមានការលំបាករបស់នរណាម្នាក់ក្តី ។

គុណតំលៃឬការវិនិច្ឆ័យបែបនេះ ដោយរួមទាំងការសន្មត់របស់យើង ចាំបាច់ត្រូវតែមានពីព្រោះវាឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈចំណូលចិត្តរបស់យើងទៅលើការស្រាវជ្រាវ មិនថាជាវិធីបែបគុណភាព ឬបរិមាណ ឬវិធីទាំងពីរនេះទេ ។ ចំណូលចិត្តនេះឃើញមាននៅក្នុងបញ្ហាស្រាវជ្រាវ ឬប្រធានបទដែលយើងចាត់ទុកថា មានតំលៃសំរាប់ធ្វើការសង្កេតស្រាវជ្រាវ (Burns,

2000:10) ឬនៅក្នុងសំណួរស្រាវជ្រាវដែលយើងគិតថាមានសារៈសំខាន់ត្រូវពិនិត្យមើល ។ គេឃើញវាច្បាស់ផងដែរនៅក្នុងការជ្រើសរើសរបស់យើងលើអ្នកផ្តល់ពត៌មាននៅតាមមូលដ្ឋាន (នៅពេលយើងប្រើវិធីសាស្ត្របែបគុណភាព) និងនៅក្នុងរបៀបដែលពេលខ្លះយើងសួរដោយតាមធម្មតា និងកត់ចំលើយទុក ជាជាងខំប្រឹងស្តាប់អ្វីដែលអ្នកឆ្លើយនិយាយ និងនៅក្នុងរបៀបដែលយើងបកស្រាយនិងរាយការណ៍ពីលទ្ធផលរកឃើញរបស់យើង ។ គេអាចមើលឃើញចំណូលចិត្តរបស់អ្នកស្រាវជ្រាវតាមរយៈវិធីស្រាវជ្រាវ ដែលគាត់ជ្រើសរើសយក ពិសេសត្រង់ថា តើការស្រាវជ្រាវនោះធ្វើសំរាប់នរណាហើយការស្រាវជ្រាវនោះនឹងត្រូវបានគេប្រើយ៉ាងដូចម្តេចពីព្រោះថាតួអង្គ និងអ្នកដែលត្រូវមានការពាក់ព័ន្ធអាចមានតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការស្រាវជ្រាវទាំងមូល ។ អ្នកដែលចូលចិត្តប្រើវិធីជាលក្ខណៈចូលរួមអាចបំផុសដៃគូនៅតាមអង្គការ និងតាមមូលដ្ឋានរបស់គេឱ្យចូលរួមក្នុងការងារនេះដែលធ្វើឱ្យដៃគូរបស់គេមើលទៅមានការគ្រប់គ្រងលើការងារអភិវឌ្ឍន៍របស់ខ្លួន ឬក្លាយទៅជាតួអង្គផ្នែកអភិវឌ្ឍន៍ដែលមានការប្តេជ្ញាចិត្តដោយខ្លួនឯង ។

អ្នកស្រាវជ្រាវបែបបរិមាណដែលប្រកាន់និន្នាការតាមបែបបូរាណអះអាងថា ការស្រាវជ្រាវផ្នែកសង្គមគួរតែមានភាពមិនលំអៀងហើយមិនគួរមានការទាក់ទងនឹងគុណតំលៃទេ ។ ការកំណត់យ៉ាងនេះមានឫសគល់នៅក្នុងការប្រើវិធីសាស្ត្រនិងគោលការណ៍នៅក្នុងវិទ្យាសាស្ត្រធម្មជាតិនៅក្នុងការសិក្សាពីអាកប្បកិរិយារបស់មនុស្ស ឬបាតុភូតសង្គម ។ ការខិតខំធ្វើឱ្យមានការស្រាវជ្រាវដែលមានភាពមិនលំអៀងហើយមិនមានទាក់ទងនឹងគុណតំលៃនៅតែមានឥទ្ធិពលនៅពេលសព្វថ្ងៃនេះ នៅក្នុងចំណោមអ្នកស្រាវជ្រាវផ្នែកសង្គមខ្លះ តែមានការអះអាងថា ភាពមិនលំអៀងដូច្នេះប្រហែលមិនអាចមានទៅកើតទេពីព្រោះមួយចំណែកធំនៃអ្វីដែលការស្រាវជ្រាវផ្នែកសង្គមផ្តោតទៅលើមានបរិបទសង្គមហើយថា "មនុស្សគិតនិងរៀនមានការយល់ដឹងពីខ្លួនគេ និងអតីតភាពរបស់គេ មានទឹកចិត្តនិងហេតុផល" (Neuman, 1998:64) ។ អ្វីដែលមានសារៈសំខាន់ចាំបាច់សំរាប់ធ្វើការស្រាវជ្រាវផ្នែកសង្គមគឺការទទួលស្គាល់របស់អ្នកស្រាវជ្រាវលើគុណតំលៃ ដែលគេអាចនឹងនាំយកចូលទៅក្នុងការងារស្រាវជ្រាវ និងការដឹងថា តើគុណតំលៃទាំងនេះអាចមានឥទ្ធិពលយ៉ាងដូចម្តេចទៅលើដំណើរការស្រាវជ្រាវ និងលទ្ធផលរកឃើញ និងថាតើដើម្បីគោលបំណងអ្វីដែលគុណតំលៃទាំងនេះកំណត់លើការរៀបចំការងារស្រាវជ្រាវ ។

# ជំហ៊ានទាំង១០ នៃការវិភាគ និងឧបករណ៍សំរាប់គិតគូរតាមលំដាប់លំដោយ

ដោយបានកំណត់ទស្សនៈ គោលការណ៍ និងកង្វល់សំខាន់ៗនៅពីក្រោយការធ្វើការស្រាវជ្រាវផ្នែកសង្គមផ្នែកជាបន្តបន្ទាប់នៃសៀវភៅនេះបង្ហាញនូវជំហ៊ានផ្សេងៗ ដែលត្រូវបានគេប្រើសំរាប់វិភាគបញ្ហាក្នុងការស្រាវជ្រាវ ហើយធ្វើរបាយការណ៍ស្រាវជ្រាវអោយបានល្អ ។ ជំហ៊ានទាំងនេះមិនថ្មីហើយក៏មិនពិបាកដែរ បើសិនជាយើងភ្ជាប់វាទៅនឹងវិធីដែលយើងស្វែងរកចំលើយចំពោះសំណួរដែលយើងប្រឈមមុខនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើង ។ បញ្ហាគឺនៅត្រង់ការចេះដាក់ការរៀបចំតាក់តែងរបស់យើងឱ្យមានលក្ខណៈល្អ ដោយប្រមូលពត៌មានសំខាន់ៗនិងមានប្រយោជន៍ទាំងអស់ ជៀសវាងចំលើយដែលស្រួល ឬចំលើយដែលគ្រាន់តែដើម្បីយកស្រួល ហើយទទួលស្គាល់ថា បញ្ហាស្រាវជ្រាវខ្លះអាចមានភាពស្មុគស្មាញជាងបញ្ហាដទៃទៀត ។ ជាមួយនឹងការស្រាវជ្រាវ អ្នកណាក៏អាចកែលំអរជំនាញនៅក្នុងការគិតគូរនិងវិភាគរបស់គេដែរ ។ ចូរចាំថា ទោះបីជាយើងប្រមូលបានហេតុការណ៍ពិតទាំងអស់ក្តី ក៏នៅតែមិនទាន់មានចំលើយដែលល្អឥតខ្ចោះដែរ ។ តែការស្រាវជ្រាវអាចបើកជំរើសសំរាប់អ្នក ឬអ្នកប្រើប្រាស់លើវាផ្សេងទៀតឱ្យធ្វើការស្វែងយល់ ។

ជំហ៊ានជាមូលដ្ឋានទាំង១០នៅក្នុងការរៀបចំការស្រាវជ្រាវដ៏ល្អមួយគឺមានបង្ហាញនៅក្នុងរូបទី ២ ។ ពិតមែនតែគេអាចនឹងចាត់ទុកដូចជាការដែលគេឡើងកាំជណ្តើរក្តីតែ "ឧបករណ៍សំរាប់គិតគូរតាមលំដាប់លំដោយ" ឬក្របខ័ណ្ឌក៏ត្រូវបានគេលើកបង្ហាញផងដែរ ដើម្បីជួយអ្នកស្រាវជ្រាវនៅក្នុងការធ្វើការឆ្លុះបញ្ចាំងលើអ្វីដែលគេចង់បាន ដើម្បីពិនិត្យនិងនាំយកមកនៅក្នុងអំឡុងពេលស្រាវជ្រាវ ។ ដូចជាជំហ៊ានទាំង ១០ ដែរ ឧបករណ៍សំរាប់គិតគូរនេះ គឺជាផ្នែកនៃវគ្គបណ្តុះបណ្តាលបន្តបន្ទាប់គ្នាដែលសំរបសំរួលដោយគំរោង ADI ជាពិសេសពីឆ្នាំ ២០០១ ដល់ឆ្នាំ ២០០៥ ។ គំរោងប្លង់ត្រូវបានលើកបង្ហាញឡើងតាមលក្ខណៈមួយ ដែលជំហ៊ានទីមួយៗដែលត្រូវគ្នាក៏ត្រូវមានភាពច្បាស់ ហើយជៀសវាងបានការច្រឡំនិងដើម្បីឱ្យអ្នកអានដឹងថា ទាំងសងខាងបោះជំហ៊ានស្របគ្នា ហើយមានបំណងទាញយកនូវចំណុចសំខាន់ៗ សំរាប់ការស្រាវជ្រាវមួយដែលមានប្រសិទ្ធភាពនិងមានប្រយោជន៍ ។ ភាពស្របគ្នារវាងទាំងពីរនេះ ត្រូវបានបញ្ជាក់បន្ថែមនៅក្នុងជំពូកបន្ទាប់នៃសៀវភៅនេះ ដែលនាំអ្នកពិនិត្យមើល ដំណើរការនៃការស្រាវជ្រាវ ហើយបង្កើនចំណេះដឹង ពេលវេលា ជំនាញនិងបទពិសោធន៍របស់អ្នក ។

**រូបទី ២: ជំហ៊ានទាំង១០នៃការវិភាគ និងឧបករណ៍សំរាប់គិតគូរតាមលំដាប់លំដោយ**

**ជំហ៊ានទាំង ១០ ក្នុងការវិភាគ**

១. កំណត់ប្រធានបទ គោលបំណង និងឯកតានៃការវិភាគជាមួយអ្នកពាក់ព័ន្ធ
២. ធ្វើផែនការដើម្បីប្រមូលពត៌មានពីប្រភពផ្សេងៗ
៣. ប្រមូល រៀបចំចំណាត់ថ្នាក់ និងរៀបចំចងក្រងពត៌មាន
៤. ពិពណ៌នានូវលទ្ធផលរកឃើញរបស់អ្នក ហើយភ្ជាប់រវាងផ្នែកផ្សេងៗ
៥. កំណត់រកបុព្វហេតុឫសគល់ បញ្ហាគន្លឹះ និងសរសេរការវិភាគរបស់អ្នក
៦. រៀបចំធ្វើសេចក្តីសន្និដ្ឋាន
៧. រៀបចំអនុសាសន៍ដែលដោះស្រាយនូវបុព្វហេតុជាឫសគល់ និងបញ្ហាគន្លឹះ
៨. សរសេររបាយការណ៍
៩. ធ្វើការឆ្លុះបញ្ចាំងលើលទ្ធផលរកឃើញជាមួយអ្នកពាក់ព័ន្ធ
១០. ផ្សព្វផ្សាយលទ្ធផលដែលរកឃើញ

| ជំហានទី ១ | | ជំហានទី ២ | | ជំហានទី ៣ | | ជំហានទី ៤, ៥, ៦, ៧ | ជំហានទី ៨ |
|---|---|---|---|---|---|---|---|
| ទិសដៅនៃការស្រាវជ្រាវ | សំណួរស្រាវជ្រាវសំខាន់ៗ/សំណួរគន្លឹះ | ពត៌មានដែលត្រូវការ | ប្រភពពត៌មាន | ឧបករណ៍/បច្ចេកទេសប្រមូលទិន្នន័យ | ការប្រមូលសរុបទិន្នន័យ | កំណត់រកចំណុចវិភាគ/ចំណុចសំខាន់ៗ | ការសរសេររបាយការណ៍ |

| ចំណុចសំខាន់ | ភាពដូចគ្នា/ខុសគ្នាទៅនឹងស្ថានភាពទូទៅ | មានការពន្យល់/រកមើលហេតុផល? (បាទ/ចាស ឬទេ) | តើមានការពន្យល់ដូចម្តេចខ្លះ? (បុព្វហេតុជាឫសគល់បញ្ហាគន្លឹះ) | បញ្ហាជាប់ពាក់ព័ន្ធ (Implications) សំរាប់គិតគូរ នៅលំដាប់ថ្នាក់រៀបចំគោលនយោបាយ និងកម្មវិធី | រៀបចំធ្វើសេចក្តីសន្និដ្ឋាន |
|---|---|---|---|---|---|
| តំណាងអោយចំណុចសំខាន់ៗ ឬលក្ខណៈពិសេសដែលលេចធ្លោនៅក្នុងលទ្ធផលរកឃើញ (ពិពណ៌នា តារាង-ក្រាហ្វិក) ដែលទាក់ទងនឹងគោលបំណងស្រាវជ្រាវ ឬសំណួរស្រាវជ្រាវសំខាន់ៗ ។ | • តើចំណុចសំខាន់មានទំនាក់ទំនងយ៉ាងណាទៅនឹងការសន្និដ្ឋានដែលមានស្រាប់?<br>• តើមានរបាយការណ៍ដែលស្ថានភាពដូចគ្នា និងខុសគ្នាផ្សេងៗដែលអ្នកបានប្រៀបធៀបទៅនឹងលទ្ធផលរកឃើញ?<br>• តើអ្នកមានឯកសារផ្សេងៗដែលអាចលើកយកមកពន្យល់បន្ថែមទៅលើលទ្ធផលរកឃើញ ឬ ការសន្និដ្ឋាន? | បើមាន ឬ មិនមានការពន្យល់ សូមសរសេរនៅក្នុងនេះថា បាទ/ចាស ឬ ទេ | • តើមានវិធីសាស្ត្រនៅក្នុងការស្រាវជ្រាវនេះដែលបញ្ជាក់/ផ្តល់ហេតុផលចម្លើយ/និន្នាការដែលរកឃើញនោះ?<br>• តើមានពិសោធន៍ផ្សេងៗទៀតដែលនាំឲ្យមានការពន្យល់នោះ?<br><br>ចំណាំ: មិនមែនគ្រប់ចំណុចសំខាន់ទាំងអស់ សុទ្ធតែមានមធ្យោបាយការពន្យល់នោះទេ ។ | • តើលទ្ធផលរកឃើញមានសារៈសំខាន់បែបណាចំពោះក្រុមមនុស្សដែលបានជ្រើសរើសយកមកធ្វើការស្រាវជ្រាវនោះ របៀបណា? តើលទ្ធផលរកឃើញដែលអាចត្រូវភ្ជាប់ទំនាក់ទំនងទៅនឹងការធ្វើសកម្មភាពជាក់ស្តែង និងការដាក់ចេញគោលនយោបាយ (ឡើងវិញ) បែបណាខ្លះ?<br>• តើលទ្ធផលដែលរកឃើញមានវិសាលភាពទូលំទូលាយ ចំពោះចំណេះដឹងដែលមានស្រាប់ ឬការកសាងចំណេះដឹងថ្មី? តើការរកឃើញនេះ បញ្ហាគួរតែធ្វើការស្រាវជ្រាវបន្ថែមទៀត ដែលមានមធ្យោបាយ អ្នកស្រាវជ្រាវ គួរតែស្វែងយល់បន្ត?<br><br>ចំណាំ: មិនមែនគ្រប់ចំណុចសំខាន់ទាំងអស់ មានមធ្យោបាយបញ្ហាជាប់ទាក់ទិននោះទេ | • ដោយផ្អែកលើទំនាក់ទំនងដែលបង្កើតរវាងចំណុចសំខាន់/និន្នាការនានាខាងលើ តើអ្នកអាចទាញសេចក្តីសន្និដ្ឋានបញ្ជាក់ទូទៅបែបណាខ្លះដែលស្របទៅនឹងសំណួរស្រាវជ្រាវ? |

# ផ្នែកទី ២

# ការរៀបចំការស្រាវជ្រាវ

## ជំហានទី ១ កំណត់ប្រធានបទ គោលបំណង និងឯកតានៃការវិភាគជាមួយអ្នកពាក់ព័ន្ធ


តើអ្នកមានប្រធានបទអ្វី? កំណត់រកបញ្ហានៃការស្រាវជ្រាវ ........ ២១

សរសេរការពិពណ៌នាអំពីបញ្ហា និងសំនួរគន្លឹះ/ស្រាវជ្រាវ ........ ២៤

កំណត់រកឯកតានៃការវិភាគ ........ ៣២

# ជំហានទី ១: កំណត់ប្រធានបទ គោលបំណង និងឯកតានៃការវិភាគ ជាមួយអ្នកពាក់ព័ន្ធ

*តើអ្នកមានប្រធានបទអ្វី? កំណត់បញ្ហានិងសារៈសំខាន់នៃការស្រាវជ្រាវ....កំណត់លទ្ធភាពអាចធ្វើការស្រាវជ្រាវបាន....សរសេរការពិពណ៌អំពីបញ្ហា និងសំណួរគន្លឹះស្រាវជ្រាវ....វែកញែកភាពខុសគ្នារវាងគោលបំណង (Purpose) និងទិសដៅ (Objective) នៃការស្រាវជ្រាវ ទិសដៅកម្មវិធី និងទិសដៅស្រាវជ្រាវ ។*

| ជំហានទី ១ | |
|---|---|
| បញ្ហាដែលចង់ធ្វើការស្រាវជ្រាវ / សំណួរទូទៅរបស់ការស្រាវជ្រាវ | សំណួរជាក់ស្តែងក្នុងការស្រាវជ្រាវ / ទិសដៅនៃការស្រាវជ្រាវ |
| | |
| | |
| | |



## តើអ្នកមានប្រធានបទអ្វី? កំណត់រកបញ្ហានៃការស្រាវជ្រាវ

ដំណើរការស្រាវជ្រាវចាប់ផ្តើមពីអ្នកស្រាវជ្រាវជ្រើសរើសប្រធានបទ-ជាផ្នែកទូទៅនៃការសិក្សា ឬបញ្ហា ដូចជាបញ្ហាដែលត្រូវបាននិយាយពីមុនៗមកលើភាពគ្មានដីធ្លី ការប្រើគ្រឿងញៀន ការប្រកបជីវភាពរស់នៅរបស់ប្រជាជន ឬអំពើហិង្សានៅក្នុងគ្រួសារ ។ ការជ្រើសរើសប្រធានបទ ឬបញ្ហាក្នុងការស្រាវជ្រាវអាស្រ័យលើហេតុផលមួយចំនួន ។ ចំណាប់អារម្មណ៍ផ្ទាល់ខ្លួនក៏ជាហេតុផលមួយដែរ ហើយប្រហែលជាអាស្រ័យទៅលើ ចំណេះដឹង បទពិសោធន៍របស់អ្នកស្រាវជ្រាវ និងកាលៈទេសៈ (Burns, 2000:27) ។ ការកំណត់ពីអត្ថប្រយោជន៍នៃលទ្ធផលរកឃើញរបស់ការស្រាវជ្រាវ ឬសារៈសំខាន់របស់វាគឺជាវិធីម្យ៉ាងទៀតដើម្បីកំណត់រកប្រធានបទ ព្រោះថា នេះជាការជួយជំរុញទឹកចិត្តក្នុងការស្រាវជ្រាវ ។ ការឆ្លុះបញ្ចាំងមើលអំពីលទ្ធភាពដែលអាចធ្វើទៅបាន ក៏ជាចំណុចមួយទៀតអាចជួយអោយអ្នកសំរេចចិត្តក្នុងការជ្រើសរើសប្រធានបទដែលត្រូវលើកយកមកសិក្សា ។ ទាំងអស់នេះ គឺជាហេតុផលសំខាន់សំរាប់ជ្រើសរើសបញ្ហាសំរាប់ស្រាវជ្រាវ ពីព្រោះទាំងនេះ គឺជាចំណុចដែលធ្វើឱ្យអ្នកស្រាវជ្រាវមានការចាប់អារម្មណ៍យកចិត្តទុកដាក់នៅក្នុងការបំពេញការងារស្រាវជ្រាវជានិច្ច ។

### កំណត់ពីសារៈសំខាន់នៃបញ្ហាស្រាវជ្រាវ

ការពន្យល់ពីសារៈសំខាន់នៃបញ្ហាដែលចង់ធ្វើការស្រាវជ្រាវ ជាប្រការគួរមានការយកចិត្តទុកដាក់ ពីព្រោះវាបំភ្លឺពីគោលបំណងនិងទឹកចិត្តក្នុងការធ្វើការងារនេះ ។ បើអ្នកស្រាវជ្រាវមិនយល់ពីមូលហេតុដែលត្រូវធ្វើការស្រាវជ្រាវទេ នោះនឹងមិនធ្វើឱ្យខ្លួនឯងដែលជាអ្នកស្រាវជ្រាវ ឬសាធារណៈមានការចាប់អារម្មណ៍នោះទេ ។ ខាងក្រោមនេះគឺជាវិធីផ្សេងៗដែលគេអាចបំភ្លឺពីគោលបំណងនៃការស្រាវជ្រាវ ឬសារៈសំខាន់របស់វា ដើម្បីជួយអោយអ្នកកំណត់អាទិភាពនៃបញ្ហាមួយសំរាប់យកមកធ្វើការស្រាវជ្រាវ ។

- *ពិនិត្យមើលលើឯកសារស្រាវជ្រាវដែលមានស្រាប់:* អ្នកស្រាវជ្រាវគួរចំណាយពេលមើលយ៉ាងឆាប់រហ័សតែបានទូលំទូលាយនូវពត៌មានដែលគេអាចរកបានដូចជា ឯកសារស្រាវជ្រាវផ្សេងៗ របាយការណ៍វាយតំលៃ របាយការណ៍ស្រាវជ្រាវខ្លីៗ អត្ថបទទស្សនាវដ្តីវិទ្យាសាស្ត្រ ។ល ។ ការពិនិត្យឯកសារដែលសិក្សាពីមុនៗ បង្កើតបានជាភស្តុតាងដែលបញ្ជាក់ពីផលប្រយោជន៍នៃការសិក្សាដែលអ្នកបានគ្រោងទុកសំរាប់អ្នកអនុវត្តន៍ និងអ្នករៀបចំគោលនយោបាយ និងការរួមចំណែកពង្រីកចំណេះដឹងបន្ថែម (Marshall and Rossman, 1989:31) ។

- *ធ្វើអោយអ្នកដែលមានការពាក់ព័ន្ធបានចូលរួមៈ* អ្នកដែលទទួលរងឥទ្ធិពលដោយបញ្ហាដែលលើកយកមកសិក្សានោះ គួរតែអោយគេជួយបញ្ចេញមតិ ទៅលើប្រភេទពតិមានណាដែលមានសារៈសំខាន់ដែលនាំអោយមានការការយល់ដឹងពីបញ្ហានោះកាន់តែច្បាស់ សហការីក៏អាចមានពតិមានសំខាន់ៗដែលគេទទួលបានពីបទពិសោធន៍របស់គេ ។ អ្នកជំនាញបច្ចេកទេស និងភ្នាក់ងារនៅតាមសហគមន៍ ជាទូទៅមិនកត់ត្រាទុកនូវសេចក្តីសង្កេតឃើញរបស់គេ ឬក៏សរសេររបាយការណ៏ទេ ដូច្នេះការយល់ដឹងរបស់គេត្រូវតែទាញ យកមកតាមរយៈសកម្មភាពបំផុសគំនិតនៅក្នុងពេលប្រជុំក្រៅផ្លូវការ សិក្ខាសាលាខ្លីៗ ឬកំរងសំណួរងាយៗ (Narayan, 1996:40) ។ ដំណើរការនេះធ្វើឱ្យការសិក្សាមានប្រយោជន៏ច្រើន នាំឱ្យមានការគាំទ្រ ការចាប់អារម្មណ៏ និងការចាប់ផ្តើមប្តេជ្ញាចិត្តចំពោះការស្រាវជ្រាវ និងលទ្ធផលរកឃើញជាបន្តបន្ទាប់មកទៀត ។
- *ភ្ជាប់ទំនាក់ទំនងរវាងមូលហេតុដែលអ្នកចង់ធ្វើការសិក្សាទៅនឹងលទ្ធផលៈ* ការលើកឡើងនូវគោលបំណងទូទៅតាមរយៈការឆ្លើយទៅនឹងសំណួរមួយចំនួនអាចជួយបំភ្លឺ និងបង្រួមទំហំនៃការងារ ។ សំណួរខ្លះដែលត្រូវសួរគឺៈ

  - តើលទ្ធផលរកឃើញគួរឆ្លើយតបទៅនឹងបញ្ហាដែលចង់ស្រាវជ្រាវតាមវិធីណាខ្លះទើបមានប្រយោជន៏?
  - តើនៅពេលចប់ការសិក្សាស្រាវជ្រាវ គេរំពឹងថានឹងបានពតិមានអ្វី?
  - តើនរណាទទួលបានផលប្រយោជន៏ពីការស្រាវជ្រាវនេះ?
  - តើគេទទួលបានផលប្រយោជន៏ពីការស្រាវជ្រាវនេះបានយ៉ាងដូចម្តេច?
  - តើបញ្ហាដែលធ្វើការស្រាវជ្រាវមានសារៈសំខាន់សមល្មមសំរាប់យើងចំណាយពេលដើម្បីវិភាគ និងស្វែងរកដំណោះស្រាយដែរឬទេ?

**កំនត់ពីលទ្ធភាពអាចធ្វើបាននៃការសិក្សាស្រាវជ្រាវ** *(Determining the Study's Feasibility)*

ដោយគោលបំណងនៃការស្រាវជ្រាវត្រូវបានកំណត់ច្បាស់ហើយនោះ ក៏វិតព្រំដែននិងទំហំនៃប្រធានបទក៏កាន់តែអាចកំណត់បានច្បាស់ថែមទៀត ។ អ្វីដែលមានសារៈសំខាន់នៅត្រង់នេះគឺ ការពិនិត្យមើលឧបសគ្គដែលអាចនឹងមានចំពោះការស្រាវជ្រាវ ដូចជាទាក់ទងនឹងការអាចចូលដល់តំបន់ដែលត្រូវសិក្សា បុគ្គលិក ធនធានថវិកា និងពេលវេលា ។ ប្រអប់ទី ១ បង្ហាញនូវបញ្ជីនៃអ្វីដែលត្រូវពិចារណានៅពេលធ្វើការត្រិះរិះទៅលើឧបសគ្គ ដែលអាចកើតមានចំពោះផែនការនៃការស្រាវជ្រាវដែលគេបានគ្រោងទុក ។

## ប្រអប់ទី ១. ស្វែងយល់ពីលទ្ធភាពអាចធ្វើការស្រាវជ្រាវបាន

**ការអាចចូលទៅដល់ទីតាំងស្រាវជ្រាវ**

- ✓ តើការសិក្សាត្រូវធ្វើនៅកន្លែងណា?
- ✓ តើទីតាំងដែលត្រូវចុះទៅសិក្សានោះមានផ្លូវទៅដល់ដែរឬទេ? តើគេអាចទៅដល់ដោយមធ្យោបាយអ្វី? តើបញ្ហាចុះទៅនេះមានផលយ៉ាងដូចម្តេចទៅលើរយៈពេលតាមការគ្រោងទុកនៃការសិក្សា?

### វែនកំនត់ផ្នែកបុគ្គលិក

- ✓ តើនរណាជាអ្នកធ្វើការសិក្សា/តើនរណាគួរចូលរួម? តើនៅក្នុងក្រុមអ្នកសិក្សាស្រាវជ្រាវគួរមានសមាជិកចំនួនប៉ុន្មាននាក់ ហើយតើគេមានតួនាទីរៀងៗខ្លួនយ៉ាងណា?
- ✓ បើសិនជាសមាជិកម្នាក់នៅក្នុងក្រុមអនុវត្តកម្មវិធីបានចូលរួម តើគេផ្តោតជាសំខាន់ទៅលើការសិក្សាទៅតាមរយៈពេលដែលបានកំណត់ ឬមួយក៏គេធ្វើការសិក្សានេះជាការបន្ថែមទៅលើការងារផ្សេងរបស់គេ?
- ✓ តើអ្នកក្រៅអាចចូលរួមនៅក្នុងការសិក្សាបានដែរឬទេ? តើគេមានជំនាញអ្វីខ្លះ?
- ✓ តើធនធានមនុស្សអ្វីខ្លះដែលមានដើម្បីជួយនៅក្នុងការរៀបចំផែនការនៃការសិក្សា?
- ✓ តើគេមានពេលប៉ុន្មានសំរាប់ការសិក្សា?
- ✓ តើមានបុគ្គលិកណាខ្លះសំរាប់ប្រមូលទិន្នន័យ ចុះទៅប្រមូលពតិមាននៅតាមមូលដ្ឋាន?
- ✓ តើមានបុគ្គលិកណាខ្លះសំរាប់វិភាគទិន្នន័យ?
- ✓ តើចាំបាច់ត្រូវធ្វើការវិភាគតាមកុំព្យូទ័រដែរឬទេ?
- ✓ តើមានមនុស្សសំរាប់ធ្វើការវិភាគទិន្នន័ដោយប្រើកុំព្យូទ័រដែរឬទេ?
- ✓ តើលទ្ធផលរកឃើញត្រូវផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយអ្វីខ្លះ?
- ✓ អ្នកណាសរសេររបាយការណ៍ ឬផ្តល់លទ្ធផលរកឃើញដល់អ្នកប្រើប្រាស់នានាៗ?
- ✓ តើនរណាចូលរួមនៅក្នុងការពិភាក្សាលទ្ធផល និងរៀបចំផែនការទៅតាមជំហ៊ានៗដើម្បីធ្វើការតាមដានជាបន្ត?

### វែនកំនត់ផ្នែកហិរញ្ញវត្ថុ

- ✓ តើមានថវិកាប៉ុន្មានសំរាប់ដំណាក់កាលនិមួយៗនៃការសិក្សា?
- ✓ តើទីកន្លែង និងសំភារៈអ្វីខ្លះដែលមានសំរាប់ដំណាក់កាលនិមួយៗនៃការសិក្សា?
  ដំណាក់កាលទាំងនេះរួមមានៈ (ក)-ធ្វើផែនការ (ខ)-ការបង្រៀនអ្នកចុះតាមមូលដ្ឋាន (គ)- ការរៀបចំឧបករណ៍/សេចក្តីណែនាំក្នុងការប្រមូលទិន្នន័យ (ឃ)-ការចុះប្រមូលទិន្នន័យ (ង)- ការបញ្ចូលនិងវិភាគទិន្នន័យ (ច)-ការសរសេររបាយការណ៍ និងមធ្យោបាយផ្សេងទៀតនៅក្នុងការផ្សព្វផ្សាយលទ្ធផលដែលរកឃើញ និង (ឆ)- ការពិភាក្សា និងការផ្សព្វផ្សាយលទ្ធផល ដើម្បីធ្វើផែនការសំរាប់ជំហ៊ានជាបន្ត ។

### វែនកំនត់ទាក់ទងនឹងពេលវេលា

- ✓ តើការសិក្សាមានក្របខ័ណ្ឌពេលវេលាយ៉ាងដូចម្តេច? តើត្រូវការពេលវេលាប៉ុន្មាន?
- ✓ តើការសិក្សាចាប់ផ្តើមនៅពេលណា? តើពេលណាដែលល្អជាងគេសំរាប់ធ្វើការសិក្សា?
- ✓ តើមានពេលវេលាប៉ុន្មានសំរាប់ចុះតាមមូលដ្ឋាន?
- ✓ តើត្រូវការពេលវេលាប៉ុន្មានសំរាប់វិភាគទិន្នន័យ?
- ✓ តើលទ្ធផលត្រូវសំរេចបាននៅពេលណា ហើយមានជាលក្ខណៈយ៉ាងដូចម្តេចសំរាប់អ្នកប្រើប្រាស់ប្រភេទផ្សេងៗ?

ដកស្រង់ពី Narayan, Deepa. 1996. *Toward Participatory Research*. World Bank Technical Paper No. 307 Washington, DC: The World Bank

## សរសេរការពិពណ៌នាអំពីបញ្ហា និងសំនួរគន្លឹះ/ស្រាវជ្រាវ

ការពិពណ៌នាអំពីបញ្ហានៅក្នុងការស្រាវជ្រាវគឺជាការពិពណ៌នាខ្លីមួយ ឬរៀបរាប់ទៅលើភាពខ្វះចន្លោះនៃចំណេះដឹង និងការយល់ឃើញ ជាពិសេសលើបញ្ហាដែលមានភាពចាំបាច់បំផុត ។ តាមធម្មតា ការពិពណ៌នានេះ បញ្ជាក់នូវបរិបទរួមនៃបញ្ហាដែលធ្វើការស្រាវជ្រាវ មូលហេតុដែលគេគួរលើកយកបញ្ហានោះមកសិក្សា (ពោលគឺ គោលបំណង និងសារៈសំខាន់) ដែលគេអាចកំណត់នៅក្នុងដំណើរការនៃការជ្រើសរើស ឬកំណត់អាទិភាពលើបញ្ហាស្រាវជ្រាវ និងសំណួរស្រាវជ្រាវដែលត្រូវគិតគូរ ។

បរិបទទូទៅនៃបញ្ហាស្រាវជ្រាវធ្វើឱ្យគេដឹងពីប្រវត្តិរបស់ប្រធានបទ ។ វាអាចគ្របដណ្តប់ទៅលើអ្វីដែលគេដឹងហើយតាមរយៈការពិនិត្យលើការសិក្សាដែលមានស្រាប់ (ឧទាហរណ៍ ស្ថិតិ និន្នាការដែលត្រូវបានគេសង្កេតឃើញ) ការពិភាក្សាដេញដោល (បើសិនមាន) ឬទស្សនៈយល់ឃើញផ្សេងៗដែលត្រូវបានលើកឡើងស្តីពីបរិបទនោះ ដែលកំនត់លក្ខខ័ណ្ឌដោយឡែកៗ នៃទីតាំងស្រាវជ្រាវ ។ បើប្រធានបទទាក់ទងនឹងគំរោងណាមួយនោះ ការរៀបរាប់ពីគំរោងនោះក៏ត្រូវស្ថិតនៅក្នុងផ្នែកនេះនៃសំណើសុំ/ផែនការ ឬរបាយការណ៍នៃការស្រាវជ្រាវ ។ សាវតានេះកំណត់របៀបនៃការសិក្សា ហើយចង្អុលឱ្យដឹងពីបញ្ហាឬប្រធានបទស្រាវជ្រាវ ដោយប្រៀបធៀបនឹងបរិបទក៏រិតទូលំទូលាយ ។ ខាងក្រោមនេះគឺជាការបំភ្លឺពីបរិបទទូលំទូលាយនៃបញ្ហាស្រាវជ្រាវ ។

### ប្រអប់ទី ២. ឧទាហរណ៍មួយនៃការពិពណ៌នាអំពីបញ្ហា

#### ការប្រើប្រាស់ថ្នាំញៀនជាបញ្ហាសង្គមៈ ទស្សនៈរបស់ប្រជាជនភូមិចំនួនបីនៅជាយក្រុងខេត្តបាត់ដំបង

**ការពិពណ៌នាអំពីបញ្ហា** នៅដើមឆ្នាំ ១៩៩០ ប្រទេសកម្ពុជាបានអនុវត្តសេដ្ឋកិច្ចទីផ្សារសេរី ហើយការផ្លាស់ប្តូរនេះធ្វើឱ្យមានការបើកចំហរទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសអាស៊ានដទៃទៀត ហើយបង្ករឱ្យមានផលវិបាកខ្លះនៅក្នុងប្រទេស ។ ក្នុងខណៈដែលការធ្វើពាណិជ្ជកម្មភាគច្រើនស្របច្បាប់ មានទំនិញមួយចំនួនបាននាំចូលឆ្លងកាត់ និងលក់នៅក្នុងប្រទេសកម្ពុជា ដែលគេមិនបានគិតថា ជាទំនិញខុសច្បាប់ ។ ចរាចរគ្រឿងញៀនខុសច្បាប់ ជាសកម្មភាពមួយគួរឱ្យកត់សំគាល់ ។ រហូតមកដល់ ពាក់កណ្តាលទស្សវត្សរ៏ឆ្នាំ ១៩៩០ ការប្រើប្រាស់គ្រឿងញៀនបានបង្កឡើងដោយជនជាតិបរទេស និងក្រុមអ្នកមានវ័យក្មេងមួយចំនួន ។ ទោះបីយ៉ាងណាក៏ដោយ នៅចុងទស្សវត្សរ៏ឆ្នាំ ១៩៩០ ការប្រើប្រាស់គ្រឿងញៀនបានរីករាលដាលយ៉ាងឆាប់រហ័សក្នុងចំណោមយុវវ័យកម្ពុជានៅគ្រប់ស្រទាប់ ។ ជាពិសេសគ្រឿងញៀនប្រភេទអាំហ្វេតាមីន ដែលជាទូទៅគេហៅថា យ៉ាម៉ា ។ នៅក្នុងសហស្សវត្សរ៏ថ្មីនេះ លំហូរនៃថ្នាំអាំហ្វេតាមីនចូលក្នុងប្រទេសកម្ពុជា មានចំនួនច្រើនគួរឱ្យកត់សំគាល់ ។ ក្រសួងការបរទេសអាមេរិកបានរាយការណ៍ថា ប្រទេសកម្ពុជាបាននាំចូលថ្នាំប្រភេទអាំហ្វេតាមីនចំនួនច្រើន នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះតាមច្រកនៃតំបន់ត្រីកោណមាស ។ ការិយាល័យអង្គការសហប្រជាជាតិ សំរាប់ត្រួតពិនិត្យគ្រឿងញៀន និងបទឧក្រិដ្ឋបានប៉ាន់ប្រមាណថាមានថ្នាំអាំហ្វេតាមីន ចំនួន ១០០,០០០ គ្រាប់បានហូរចូលក្នុងប្រទេសកម្ពុជារៀងរាល់ថ្ងៃ ក្នុងនោះមាន ៧៥ ភាគរយ ត្រូវបាននាំចេញទៅប្រទេសថៃ នេះមានន័យថា នៅសល់ ២៥ ភាគរយ (ប្រមាណជាង ៩.០០០.០០០) ទៀត បានចរាចរនៅក្នុងប្រទេសកម្ពុជា ក្នុងមួយឆ្នាំ នេះគ្រាន់តែជាស្ថិតិមកពីមួយប្រភពតែប៉ុណ្ណោះ ។ ថែមពីលើថ្នាំអាំហ្វេតាមីន ដែលបាននាំចូលពីព្រំដែនប៉ែកខាងជើងនៃប្រទេសកម្ពុជា ការិយាល័យអង្គការសហប្រជាជាតិ សំរាប់ត្រួតពិនិត្យគ្រឿងញៀន និងបទឧក្រិដ្ឋ បានរាយការណ៍ថា

ថ្នាំអាំហ្វេតាមីន គឺជាប្រភេទថ្នាំសំខាន់ជាងគេ ដែលកំពុងបន្តធ្វើចរាចរពីប្រទេសថៃចូលតាមខេត្តភាគខាងលិច និងខាងជើងនៃប្រទេសកម្ពុជា ។ ស្រុកនៅក្នុងខេត្ត បាត់ដំបង និងបន្ទាយមានជ័យត្រូវបានគេដឹងថាជាតំបន់ដែលចរាចរគ្រឿងញៀនច្រើន ។ ការិយាល័យអង្គការសហប្រជាជាតិ សំរាប់ត្រួតពិនិត្យគ្រឿងញៀន និងបទឧក្រិដ្ឋបានរាយការណ៍ផងដែរថា ការនាំចូលថ្នាំអាំហ្វេតាមីនពីប្រទេសថៃមកតំបន់ទាំងនេះ គឺមានរយៈពេលច្រើនឆ្នាំកន្លងមក ហើយចំណែកឯបរិមាណក៏មានការកើនឡើងដែរ នេះដោយសារតែមានតំរូវការខ្ពស់ក្នុងស្រុក ជាពិសេសនៅតំបន់ជាយក្រុង ។ ក្នុងនោះដែរ ការិយាល័យអង្គការសហប្រជាជាតិសំរាប់ត្រួតពិនិត្យគ្រឿងញៀន និងបទឧក្រិដ្ឋក៏បានបន្ថែមទៀតថា មានភស្តុតាងមួយចំនួនបញ្ជាក់ថា មានការកើនឡើងក្នុងការចរាចរជាតិគីមី សំរាប់ផលិតថ្នាំអាំហ្វេតាមីន នៅក្នុងប្រទេសកម្ពុជាផងដែរ ។ ក្រុងបាត់ដំបងមានទីតាំងនៅចំផ្លូវនៃការចរាចរគ្រឿងញៀន ។ ការសិក្សានេះ អេឌីអាយនឹងរៀបចំឡើងដើម្បីស្វែងយល់អំពីនិន្នាការនៃការប្រើប្រាស់គ្រឿងញៀន ក្នុងចំណោមយុវវ័យនៅក្នុងភូមិចំនួន ៣ ដែលស្ថិតនៅជាយក្រុងបាត់ដំបង ។ ការសិក្សាស្រាវជ្រាវក៏បានផ្តោតទៅលើមូលហេតុ និងផលវិបាកនៃការប្រើប្រាស់គ្រឿងញៀនក្នុងចំណោមយុវវ័យ និងពិនិត្យមើលផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀនទៅលើជីវភាពគ្រួសារ ព្រមទាំងវាយតំលៃផលប៉ះពាល់ទៅដល់ការរស់នៅរបស់សហគមន៍ ។

សំណួរស្រាវជ្រាវបញ្ជាក់លំអិតលើប្រធានបទដែលបានកំណត់ ក៏អាចជាផ្នែកមួយនៃការពិពណ៌នាអំពីបញ្ហាដែរ ទោះបីជាអ្នកខ្លះបកស្រាយវានៅក្នុងផ្នែកដោយឡែកមួយក្តី ។ សំណួរស្រាវជ្រាវគឺជាសំណួរដែលការសិក្សាស្រាវជ្រាវ ត្រូវបានបង្កើតឡើងដើម្បីពិនិត្យដោះស្រាយ ។ ទាំងនេះគឺជាសំណួរដែលអ្នកស្រាវជ្រាវចង់បានចំលើយ ហើយនៅក្នុងន័យនេះ វាគឺជាការស្តែងចេញនូវបញ្ហាដែលត្រូវការចំលើយ ឬដំណោះស្រាយ ។ វាឆ្លុះបញ្ចាំងឱ្យឃើញពីសារៈសំខាន់នៃការអង្កេតតាមការគ្រោងទុក ហើយមិនដូចទៅនឹងសំណួរដែលគេសួរនៅក្នុងបទសំភាសន៍ទៅកាន់អ្នកផ្តល់ចំលើយ នោះទេ (Mason, 1996:15) ។

ជាញឹកញាប់ បញ្ហាស្រាវជ្រាវមានលក្ខណៈជាសំណួរ - ភាគច្រើនគឺ "អ្វី" "ដូចម្តេច "ហេតុអ្វី" -ពីព្រោះថា ការធ្វើដូច្នេះ មានន័យថាដាក់បញ្ហាឱ្យគេអាចធ្វើអង្កេតបាន ហើយការអង្កេតនេះធ្វើឱ្យគេអាចកំណត់បានពីលក្ខណៈនិងទំហំនៃបញ្ហានោះ (Yin, 1994:5; Lewis-Beck et al, 2004:966-967) ។ ការប្រើប្រាស់ សំណួរបែបនេះ បង្កឱ្យគេមានការជ្រើសរើស ចំណុចដែលត្រូវផ្តោតការយកចិត្តនិងជួយតំរង់ទិសនៃការសិក្សា កំណត់ព្រំដែនរបស់វា សំរេចបាននូវលទ្ធភាពអាច ចាត់ចែងបាន ហើយនិងការរំពឹងទុកជាមុនទៅលើលទ្ធផលជោគជ័យ (Lewis-Beck et al, 2004:967) ។ សំណួរស្រាវជ្រាវចំនួនមួយ ឬច្រើនបង្កើតបានជាគ្រឹះសំរាប់រៀបចំគំរោងស្រាវជ្រាវ ។ ការជ្រើសរើសសំណួរ និងការកំណត់ពាក្យពេចន៍ របស់វាកំណត់ពីហេតុអ្វីខ្លះ វិសាលភាព និងវិធីដែលគេសិក្សាបញ្ហានោះ ។ អ្នកស្រាវជ្រាវបែបបរិមាណ នៅពេលខ្លះរៀបចំសំណួរស្រាវជ្រាវតូចៗរបស់គេនៅក្នុងសម្មតិកម្ម ដែលមានន័យថាជាការប្រមើលមើលជាមុននូវទំនាក់ទំនងរវាងធាតុមួយទៅនឹងធាតុមួយទៀត ដែលគេត្រូវសង្កេតមើលនៅក្នុងដំណើរការស្រាវជ្រាវដែលបានគ្រោងទុក (ឧទាហរណ៍ ថាតើលក្ខណៈរបស់គ្រួសារ នឹងប៉ះពាល់ទៅដល់ការប្រើថ្នាំញៀនរបស់កុមារក្នុងភាពវិជ្ជមាន ឬអវិជ្ជមាន) ។ តារាងទី ២ ខាងក្រោមនេះផ្តល់ សេចក្តីរៀបរាប់ពីទំរង់រួមនៃសំណួរ ដែលត្រូវបានគេប្រើក្នុងការធ្វើពង្រាងលើសំណួរស្រាវជ្រាវ និងវិធីសាស្ត្រស្រាវជ្រាវដែលគេចង់បាន ។

## តារាងទី ២. ទំរង់នៃសំណួរស្រាវជ្រាវ ហើយនិងវិធីសាស្ត្រស្រាវជ្រាវដែលគេអាចនឹងយកមកប្រើ

| ទំរង់នៃសំណួរស្រាវជ្រាវ | បរិយាយ | វិធីសាស្ត្រដែលគេអាចនឹងប្រើ |
|---|---|---|
| "អ្វី" | ▪ ទាមទារចំលើយរៀបរាប់ ។<br>▪ ត្រូវបានសំដៅលើការរៀបរាប់លក្ខណៈ និងភាពជាក់លាក់នៃស្ថានភាពសង្គមដូចជា ចំពោះបុគ្គល (ឧទាហរណ៍ ចេះអក្សរ ធៀបជាមួយនឹងអ្នកមិនចេះអក្សរ មានការងារធ្វើជាមួយនិងគ្មានការងារធ្វើ ។ល។) ក្រុមមនុស្សគ្រប់ប្រភេទនៅក្នុងសង្គម (ឧ. សមាគមមនុស្សចាស់ ក្រុមមនុស្សប្រចាំសង្កាត់/ក្រុម ។ល។) និងដំណើរការក្នុងសង្គម (ឧ. ការប្រវាស់ដៃចំណាកស្រុក តាមរដូវកាលដើម្បីរកការងារធ្វើ ។ល។)<br>▪ តាមធម្មតា ត្រូវសួរមុនឈានដល់សំណួរ "ហេតុអ្វី" ។ | ▪ ការអង្កេត<br>▪ ករណីសិក្សា/ការរៀបរាប់ផ្ទាល់មាត់ពីប្រវត្តិ<br>▪ ការវិភាគលើឯកសារតំកល់/ឯកសារសំខាន់ (ពោលគឺទាញយកប្រយោជន៍ពីឯកសារ ឬកំណត់ត្រាផ្សេងៗ) ។ |
| "ហេតុអ្វី" | ▪ សួររកបុព្វហេតុ ឬហេតុផលចំពោះចរិកលក្ខណៈ ឬបែបផែននៃអាកប្បកិរិយា ។<br>▪ ទាក់ទងនឹងការស្វែងយល់ ឬការពន្យល់ពីទំនាក់ទំនងរវាងព្រឹត្តិការណ៍នានា ឬស្ថិតនៅក្នុងរង្វង់សកម្មភាពសង្គម និងដំណើរការសង្គម ។<br>▪ តាមធម្មតា ត្រូវសួរមុនឈានដល់សំណួរ "ដូចម្តេច" | ▪ ការស្រាវជ្រាវបែបធ្វើពិសោធន៍ (ជាមួយនឹងក្រុមដែលត្រូវកំណត់ទុកសំរាប់ប្រៀបធៀប)<br>▪ ការអង្កេត<br>▪ ករណីសិក្សា |
| "ដូចម្តេច" | ▪ ទាក់ទងនឹងការពន្យល់ ការនាំមកនូវការផ្លាស់ប្តូរព្រមទាំងលទ្ធផលជាក់ស្តែង និងអន្តរាគមន៍ ។ | ▪ ការស្រាវជ្រាវបែបធ្វើពិសោធន៍ (ជាមួយនឹងក្រុមដែលត្រូវកំណត់ទុកសំរាប់ប្រៀបធៀប)<br>▪ ការអង្កេត<br>▪ ករណីសិក្សា |

ប្រភព ៖ Lewis-Beck et al, 2004: 966-967; Yin, 1994:4-8

សំណួរស្រាវជ្រាវអាចមានសំណួររួម ឬទូទៅចំនួនមួយ ឬពីរដែលត្រូវបានគេរៀបចំឱ្យលំអិត ឬជាសំណួរតូចៗតទៅទៀត ។ ការរកមើលកូនសំណួរទាំងនេះ អាចចាប់ផ្តើមដោយអ្នកស្រាវជ្រាវបំផុសគំនិតនៅលើបញ្ជីនៃសំណួរដែលមានទំនាក់ទំនងគ្នាជាលំដាប់លំដោយ ដែលគេអាចធ្វើការកែប្រែឱ្យល្អថែមទៀត ឬក៏កាត់បន្ថយបាននៅពេលគេគិតពិចារណាទៅលើវិធីសាស្ត្រ និងវិធីសាស្ត្រស្រាវជ្រាវ រួមទាំងបញ្ហាពាក់ព័ន្ធទៅនឹងអ្វីដែលអាចធ្វើបានជាក់ស្តែង ទាក់ទងនឹងក្រមសីលធម៌ និងខាងនយោបាយ ។ អ្នកស្រាវជ្រាវប្រហែលជាអាចនឹងសួរខ្លួនឯងនូវសំណួរដូចខាងក្រោមនេះ នៅក្នុងដំណើរការបង្កើតសំណួរស្រាវជ្រាវ (Mason, 1996:17):

- តើខ្ញុំមានភាពច្បាស់លាស់ទេ ពីសារៈសំខាន់នៃការអង្កេតរបស់ខ្ញុំ? តើអ្វីដែលខ្ញុំចង់ពន្យល់ ឬស្វែងរក? តើសំណួរស្រាវជ្រាវរបស់ខ្ញុំបញ្ជាក់ ឬបង្ហាញពីបញ្ហាទាំងនេះច្បាស់លាស់ដែរឬទេ?
- តើសំណួរស្រាវជ្រាវរបស់ខ្ញុំស្របគ្នា ហើយមានការទាក់ទងគ្នាទេ? តើពេលដាក់បញ្ចូលគ្នាសមស្របទេ?
- តើសំណួរស្រាវជ្រាវរបស់ខ្ញុំមានអត្ថន័យស៊ីគ្នាទេ? តើអ្នកផ្សេងពីខ្ញុំ អាចយល់វាបានទេ?
- តើសំណួរស្រាវជ្រាវរបស់ខ្ញុំអាចនាំឱ្យមានចំលើយល្អ ហើយមានអត្ថន័យគួរជាទីចាប់អារម្មណ៍ឬទេ?
- តើសំណួរស្រាវជ្រាវរបស់ខ្ញុំមានភាពបើកចំហគ្រប់គ្រាន់ សំរាប់បើកឱ្យមានការសួរបន្តនូវអ្វីដែលខ្ញុំចង់សួរបានទេ? តើសំណួរនេះអាចធ្វើឱ្យខ្ញុំអាចបង្កើតសំណួរបន្ថែមទៀត នៅដំណាក់ការក្រោយទៀតបានទេនៅពេលខ្ញុំធ្វើការវិភាគលើទិន្នន័យ?
- តើសំណួររបស់ខ្ញុំមិនចំលងតាមសំណួររបស់គេ ហើយសមនឹងយកទៅសួរដែរឬទេ?
- តើនៅដំណាក់កាលនេះ ខ្ញុំសួរសំណួរស្រាវជ្រាវចំនួនប៉ុណ្ណឹងល្មមទេ?

សំណួរស្រាវជ្រាវគឺជាឆ្អឹងខ្នងនៃការតាក់តែងរៀបចំការស្រាវជ្រាវ ។ ដូច្នេះ សំណួរទាំងនេះត្រូវមានភាពច្បាស់លាស់ ពីព្រោះវានឹងបង្ហាញនូវទំនាក់ទំនងទៅនឹងអ្វីនិងរបៀបដែលអ្នកស្រាវជ្រាវធ្វើការអង្កេត ។ វាជាយាន្តដែលអ្នកស្រាវជ្រាវពឹងទៅលើ ដើម្បីធ្វើឱ្យគាត់អាចធ្វើដំណើរចេញពីចំណុចរួមនៃការស្រាវជ្រាវឆ្ពោះទៅរកចំណុចជាក់លាក់ផ្តោតមួយៗនៃការស្រាវជ្រាវ (Mason, 1996:16) ហើយនិងវិធីសាស្ត្ររួមសំរាប់ប្រមូល និងវិភាគទិន្នន័យ ។ គឺដោយសារហេតុផលនេះហើយដែលអ្នកស្រាវជ្រាវផ្តែកសង្គមបានកត់សំគាល់ ដំណាក់កាលនេះមានសារៈសំខាន់បំផុត ហើយប្រហែលជាផ្នែកដែលពិបាកជាងគេនៅក្នុងការរៀបចំតាក់តែងការស្រាវជ្រាវ (Lewis-Beck et al, 2004:966) ។ ដើម្បីងាយយល់សេចក្តីណែនាំខាងលើនេះ ប្រអប់ទី ៣ លើកឡើងនូវសំណួរស្រាវជ្រាវខ្លះដែលត្រូវបានរៀបចំឡើង សំរាប់ការសិក្សាខាងលើអំពីការប្រើប្រាស់គ្រឿងញៀន ។

## ការពិនិត្យមើលឯកសារស្រាវជ្រាវកន្លងមក (Reviewing the Literature)

អ្នកស្រាវជ្រាវគួរពិចារណាលើការលទ្ធផលស្រាវជ្រាវដែលមានគេបានធ្វើរួចហើយ ព្រោះថា ជារួមវានឹងជួយអោយគំរោងស្រាវជ្រាវមួយដំណើរការល្អបាន ហើយបើនិយាយពីភាពជាក់លាក់វិញនោះ ការធ្វើដូច្នេះនិងជួយអោយបង្កើតបាននូវសំណួរស្រាវជ្រាវល្អៗ ។ គេត្រូវការអានអ្វីដែលមានសរសេរទាក់ទងនឹងប្រធានបទរបស់ខ្លួន ដើម្បីជៀសវាងការធ្វើជាន់គ្នាដដែលៗ ។ ការអានឯកសារសិក្សាមុនៗដែលមានការពាក់ព័ន្ធ អាចធ្វើឱ្យគេមានការយល់ដឹងដែលអ្នកស្រាវជ្រាវមិនអាចគិតដល់ ។ គោលបំណងដោយឡែកផ្សេងទៀតនៃការពិនិត្យ ឯកសារសិក្សាមុនៗត្រូវបានគេរៀបរាប់ដូចខាងក្រោមនេះ (Neuman, 2000:446):

- ដើម្បីស្តែងឱ្យឃើញចំណេះដឹងរួមរបស់អ្នកស្រាវជ្រាវដែលទាក់ទងនឹងប្រធានបទ ហើយដើម្បីធ្វើឱ្យមានការជឿជាក់ចំពោះលទ្ធផលស្រាវជ្រាវរបស់ខ្លួន ។ ការបានពិនិត្យមើលឯកសារសិក្សាមុនៗជាការប្រាប់ទៅអ្នកអានថា អ្នកស្រាវជ្រាវ

យល់ដឹងពីប្រធានបទដែលត្រូវធ្វើអង្កេត/ពន្យល់ ហើយមានការយល់ច្បាស់ពីបញ្ហាចំបងៗនៅជុំវិញប្រធានបទ ។ វាថែមទាំ បង្កើនទំនុកចិត្តរបស់អ្នកអាន ទៅលើសមត្ថភាព ក្នុងនាមជាអ្នកមានវិជ្ជាជីវៈ ភាពប៉ិនប្រសព្វ និងសាវតារបស់អ្នកស្រាវជ្រាវ ។

- ដើម្បីបង្ហាញផ្លូវនៃការស្រាវជ្រាវមុនៗ និងរបៀបដែលគំរោងរបស់ខ្លួនដែលបំរុងនឹងស្រាវជ្រាវ មានការទាក់ទងគ្នាបែបណានោះ ។ ការពិនិត្យឯកសារមានស្រាប់ ក៏បង្ហាញពីការអភិវឌ្ឍន៍ចំណេះដឹងទៅលើប្រធានបទណាមួយ ហើយដាក់ផែនការដែលបានគ្រោងទុក/ការស្រាវជ្រាវនោះអោយស្ថិតនៅក្នុងបរិបទមួយ ព្រមទាំងបង្ហាញឱ្យឃើញពីទំនាក់ទំនងរបស់វា ដោយធ្វើការផ្សារភ្ជាប់ទៅនឹងចំណេះដឹងរួម ។
- ដើម្បីបញ្ចូលគ្នា និងសង្ខេបនូវអ្វីដែលគេដឹងអោយចូលទៅក្នុងប្រធានបទដែលនឹងត្រូវយកមកសិក្សា។ ការពិនិត្យការសិក្សាដែលមានគេធ្វើរួចហើយ ធ្វើឱ្យអ្នកស្រាវជ្រាវអាចធ្វើសំយោគលទ្ធផលនៃការសិក្សាទាំងនោះ ។ ចំណុចត្រូវស្របគ្នានិងចំណុចមិនស្របគ្នានៅក្នុងការសិក្សាកន្លងមកទាំងនេះ ត្រូវបានលើកឡើងដោយរួមទាំងអ្វីដែលគេដឹងកន្លងមក ។
- ដើម្បីរៀនសូត្រពីអ្នកដទៃ និងបំផុសរកនូវគំនិតថ្មីៗ ។ ការអានឯកសារសិក្សាមុនៗ ជួយឱ្យគេមើល ឃើញភាពខ្វះចន្លោះផ្នែកចំណេះដឹង ហើយបង្ហាញពីដំណើរការបច្ចេកទេស និងរបៀបគ្រោងរៀបចំការស្រាវជ្រាវដែលគេគួរយកជាគំរូតាម ដើម្បីឱ្យអ្នកស្រាវជ្រាវអាចផ្តោតការយកចិត្តទុកដាក់បានល្អ ទៅលើ ការពិពណ៌នាអំពីបញ្ហារបស់ខ្លួន និងមានយល់ដឹងថ្មីៗ ។

ហេតុផលច្រើនជាងគេចំពោះការសរសេរសំរង់ឯកសារសិក្សាមុនៗ ទាក់ទងនឹងគោលបំណងទីពីរនៃការបង្កើតឱ្យមានការទាក់ទងទៅនឹងការពង្រីងចំណេះដឹងរួម (Neuman, 2000: 446) ។ ការសរសេរនេះ គេច្រើនតែដាក់នៅខាងដើមនៃសំណើសុំស្រាវជ្រាវឬរបាយការណ៍ស្រាវជ្រាវ ហើយជួយកំណត់សារៈសំខាន់ និងផលប្រយោជន៍នៃសំណួរស្រាវជ្រាវ ។ វាជាការបកស្រាយប្រាប់អ្នកអាន អោយយល់ពីគំរោងស្រាវជ្រាវដែលអ្នកចង់ធ្វើអំពីភាពស្របគ្នាទៅនឹងរូបភាពរួម និងបញ្ហាពាក់ព័ន្ធសំរាប់ជួយបន្ថែមដល់ចំណេះដឹងជាទូទៅ ។ ការត្រួតពិនិត្យឯកសារមានស្រាប់ ជួយអោយការស្រាវជ្រាវដែលគ្រោងនឹងធ្វើ អាចពង្រីកបន្តទៅលើគំនិតដែលមានស្រាប់ឬផ្តោតទៅរកបញ្ហាឬជំលោះណាមួយដែលការស្រាវជ្រាវមុនៗមិនបានគ្របដណ្តប់ ។ ក្រៅពីនេះ វាអាចជួយដល់ការរៀបចំសម្មតិកម្ម ដែលជាប្រការសំខាន់សំរាប់ជួយដល់អ្នកស្រាវជ្រាវខិតខំរកមើលភស្តុតាង ឬពត៌មានដែលនឹងជួយលាតត្រដាងថាតើ តើវាស្របឬផ្ទុយគ្នាទៅនឹងសម្មតិកម្មដែលបានគ្រោងទុកនោះ ។ នៅក្នុងពេលធ្វើការវិភាគ គេអាចយកលទ្ធផលរកឃើញ មកសរសេរប្រៀបធៀបគ្នាដើម្បីមើលថា តើលទ្ធផលរកឃើញសមស្របឬខុសគ្នាពី លទ្ធផលស្រាវជ្រាវរបស់អ្នកឯទៀតដែលគេបានធ្វើកន្លងមកបែបណាខ្លះ ។

## ប្រអប់ទី៧: ឧទាហរណ៍មួយនៃសំណួរស្រាវជ្រាវ

### ការប្រើប្រាស់គ្រឿងញៀនជាបញ្ហាសង្គមៈ ទស្សនៈរបស់ភូមិបីនៅជាយក្រុងខេត្តបាត់ដំបង

**សំណួរគន្លឹះ**

***និន្នាការនៃការប្រើប្រាស់ថ្នាំញៀន***

១. នៅក្នុងពេល៥ឆ្នាំកន្លងទៅ ការប្រើប្រាស់ថ្នាំញៀននៅក្នុងចំណោមយុវវ័យមានការកើនឡើង ថយចុះ ឬមួយក៏នៅដដែល? តើហេតុអ្វីបានជាដូច្នេះ? តើអ្នកប្រើប្រាស់ថ្នាំញៀនស្ថិតនៅក្នុងក្រុមមនុស្សដែលមានអាយុប៉ុន្មាន? ភេទ? តើស្ថានភាពសេដ្ឋកិច្ច-សង្គមរបស់គេយ៉ាងដូចម្តេច?

២. តើថ្នាំប្រភេទអ្វីខ្លះដែលគេប្រើ? ប្រភេទថ្នាំគេប្រើពីមុន និងឥឡូវនេះ? តើអ្នកប្រើចាប់ផ្តើមប្រើនៅពេលណា? មូលហេតុដែលគេប្រើថ្នាំប្រភេទនេះ? តើថ្នាំនោះស្រួលរកដែរឬទេ? តើថ្នាំនោះថ្លៃប៉ុន្មាន? តើគេប្រើញឹកញាប់ដែរឬទេ? តើគេប្រើថ្នាំនៅពេលណា និងកន្លែងណា? តើគេមានលុយពីណាមកទិញថ្នាំញៀន? តើគេមានការងារធ្វើត្រឹមត្រូវ ដែរឬទេ? ជួញគ្រឿងញៀនឬ? លួចគេ? ធ្វើជាអ្នករកស៊ីផ្លូវភេទឬ?

***មូលហេតុ និងផលវិបាកនៃការប្រើប្រាស់ថ្នាំញៀន***

១. តើកាលៈទេសៈបែបណាដែលនាំឱ្យគេប្រើប្រាស់ថ្នាំញៀន? កាលៈទេសៈនៅក្នុងគ្រួសារ? ក្នុងចំណោមមិត្តភក្តិ? នៅសាលារៀន? នៅកន្លែងធ្វើការ? នៅពេលចេញទៅធ្វើការនៅតំបន់ឆ្ងាយ? រវាងមិត្តភក្តិប្រុសនិងស្រី? តើអ្វីដែលទាក់ទាញគេឱ្យប្រើប្រាស់ថ្នាំញៀន? តើអ្នកប្រើប្រាស់ថ្នាំញៀនបញ្ចុះបញ្ចូលឱ្យអ្នកផ្សេងប្រើដែរទេ?

២. តើមានអ្វីកើតឡើងចំពោះយុវវ័យ ដោយសារគេប្រើប្រាស់ថ្នាំញៀន? តើគ្រួសាររបស់គេនៅតែរាប់រកគេដែរឬទេ? តើអ្នកដទៃនៅក្នុងភូមិនៅតែរាប់រកគេដែរទេ? តើគេនៅតែទៅរៀនដែរឬទេ? តើគេធ្វើការដែរឬទេ? តើគេនៅតែចេញដើរលេងជាមួយនឹងមិត្តចាស់របស់គេ ឬគេដើរតែជាមួយនឹងអ្នកប្រើប្រាស់ថ្នាំញៀនដទៃទៀត? តើគេធ្លាប់ទទួលការចាប់ខ្លួនដែរឬទេ? តើគេមានសុខភាពយ៉ាងដូចម្តេច? តើគេមានការយល់ដឹងពីជំងឺអេដស៍ដែរឬទេ? តើគេប្រើម្ជុលទេ? តើគេប្រើស្រោមអនាម័យទេ?

៣. តើអ្នកប្រើថ្នាំញៀនបានព្យាយាមឈប់ប្រើថ្នាំញៀនដែរឬទេ? តើគេធ្លាប់ចូលទៅមជ្ឈមណ្ឌល ឬកម្មវិធីបន្សាបថ្នាំញៀន ដែរឬទេ? តើគេអាចឈប់ប្រើថ្នាំញៀនដោយមិនមានជំនួយផ្នែកវេជ្ជសាស្ត្រដែរឬទេ?

***ឥទ្ធិពលដែលមានទៅលើជីវិតគ្រួសារ***

១. តើស្ថានភាពផ្នែកសេដ្ឋកិច្ច និងសង្គមរបស់គ្រួសារអ្នកប្រើប្រាស់ថ្នាំញៀនមានលក្ខណៈយ៉ាងដូចម្តេច? សមាសភាពនៃសមាជិកគ្រួសារយ៉ាងដូចម្តេច? ឪពុកម្តាយបង្កើតឬឪពុកម្តាយចុង? តើឪពុកម្តាយទាំងពីរនាក់នៅផ្ទះទេ? តើអាយុ និង ភេទរបស់ក្មេងដែលរស់នៅក្នុងផ្ទះជាមួយ? ប្រភពចំណូលរបស់គ្រួសារមានអ្វីខ្លះ? តើគេមានចេញទៅធ្វើការនៅតំបន់ ផ្សេងដែរទេ? តើគ្រួសារមានជីវភាពធូរធារ មធ្យម ក្រ ឬក្រខ្លាំង?

២. តើនៅក្នុងគ្រួសារមានសមាជិកប៉ុន្មាននាក់ដែលប្រើថ្នាំញៀន? តើនៅពេលណាដែលគេចាប់ផ្តើមប្រើថ្នាំញៀន?

តើគេ ប្រើថ្នាំអ្វី? តើអ្វីដែលនាំឱ្យគេចាប់ផ្តើមប្រើថ្នាំញៀន? ដោយធ្វើការនៅឆ្ងាយពីភូមិ? ចេញដើរលេងជាមួយមិត្តនៅពេលយប់? ប្រើថ្នាំនៅសាលារៀន? តើឪពុកម្តាយមានបានដឹងថាការប្រើប្រាស់ថ្នាំញៀនគឺជាបញ្ហាមួយនៅក្នុងភូមិ មុនពេលកូនរបស់គេចាប់ផ្តើមប្រើថ្នាំញៀនទេ? តើឪពុកម្តាយបានយល់ពីផលវិបាកនៃការប្រើប្រាស់ថ្នាំញៀន មុនពេលកូនរបស់គេចាប់ផ្តើមប្រើថ្នាំញៀនទេ? តើនៅពេលនេះឪពុកម្តាយមានយល់ពីផលវិបាកនៃការប្រើគ្រឿងញៀន ដែរឬទេ?

៣. តើការប្រើប្រាស់ថ្នាំញៀនប៉ះពាល់ដល់អាកប្បកិរិយារបស់យុវវ័យយ៉ាងដូចម្តេច? តើគេមានអាកប្បកិរិយាបែបហិង្សាដែរឬទេ? បាត់បង់ការចេះស្រលាញ់ជីវិតដែរទេ? មានបញ្ហាសុខភាពដែរទេ? ចូលរួមនៅក្នុងការប្រព្រឹត្តបទល្មើសដែរឬទេ? តើការប្រើប្រាស់ថ្នាំញៀនប៉ះពាល់ដល់សមាជិកដទៃទៀតយ៉ាងដូចម្តេចនៅក្នុងគ្រួសាររបស់គេ? តើវាប៉ះពាល់ទំនាក់ទំនងនៃគ្រួសាររបស់គេជាមួយនឹងមនុស្សដទៃទៀតនៅក្នុងភូមិយ៉ាងដូចម្តេច? តើការប្រើប្រាស់ថ្នាំញៀនប៉ះពាល់ដល់ការប្រកបរបរចិញ្ចឹមជីវភាពរបស់គ្រួសាររបស់គេយ៉ាងដូចម្តេច? តើគេចំណាយថវិកាច្រើនលើ ការមើលជំងឺដែរឬទេ? តើគ្រួសាររបស់គេមិនសូវរកចំណូលបានច្រើន ឬធ្វើការមិនសូវកើតដែរឬទេ?

៤. តើឪពុកម្តាយអាចដោះស្រាយបាន ចំពោះការប្រើប្រាស់ថ្នាំញៀននៃកូនរបស់គេដែរឬទេ? តើគេបានធ្វើអ្វីខ្លះ? តើកូនរបស់គេអាចឈប់ប្រើប្រាស់ថ្នាំញៀនដោយមិនមានជំនួយពីគ្រូពេទ្យបានដែរឬទេ?

### *ឥទ្ធិពលដែលមានទៅលើការរស់នៅក្នុងសហគមន៍*

១. តើស្ថានភាពសេដ្ឋកិច្ច-សង្គមក្នុងភូមិយ៉ាងដូចម្តេច? តើគ្រួសារចំនួនប៉ុន្មានភាគរយដែលមានជីវភាពធូរធារ មធ្យម ក្រ ឬក្រខ្លាំង? តើអ្នកភូមិមានមុខរបរអ្វីខ្លះ? នៅក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ តើនៅក្នុងភូមិមានការផ្លាស់ប្តូរសំខាន់អ្វីខ្លះ? តើបញ្ហាធំៗមានអ្វីខ្លះ?

២. តើនៅក្នុងភូមិមានបញ្ហានៃការប្រើប្រាស់ថ្នាំញៀនដែរឬទេ? តើបញ្ហានេះបានចាប់ផ្តើមនៅពេលណា? តើនរណាខ្លះមានការពាក់ព័ន្ធ? តើគេចូលពាក់ព័ន្ធតាមរបៀបណា? តើមានហេតុផលយ៉ាងដូចម្តេច? តើភាគច្រើននៃគ្រួសាររបស់អ្នកប្រើប្រាស់ថ្នាំញៀនមានជីវភាពធូរធារ មធ្យម ក្រឬមួយក្រខ្លាំង? តើគេជាអ្នករស់នៅក្នុងភូមិយូរហើយ ឬមួយទើបតែមករស់នៅ?

៣. តើទិដ្ឋភាពអ្វីខ្លះនៃជីវិតរស់នៅក្នុងសហគមន៍ ដែលប៉ះពាល់ដោយការប្រើប្រាស់ថ្នាំញៀន? តើមានការប៉ះពាល់ដល់សន្តិសុខដែរឬទេ? តើមានកំណើននៃចោរកម្ម វាយតប់គ្នា សកម្មភាពរបស់ពួកបងធំ ឬការរំខានដល់ពិធីនៅក្នុងសហគមន៍ដែរឬទេ? តើមានការបោះបង់ចោលសាលាច្រើនទេ? តើឪពុកម្តាយមានការព្រួយបារម្ភថាកូនរបស់គេអាចក្លាយជាអ្នកប្រើថ្នាំញៀនទេ? តើមានកំណើនជំងឺអេដស៍ឬបញ្ហាសុខភាពដទៃទៀតទេ? តើមានក្មេងៗរត់ចោលផ្ទះទេ? តើមានផលវិបាកយ៉ាងដូចម្តេចទៅលើការរស់នៅរបស់គ្រួសារ? តើគ្រួសារនៃអ្នកប្រើប្រាស់ថ្នាំញៀនកាន់តែមិនសូវបានធ្វើការ ឬធ្លាក់ខ្លួនកាន់តែក្រទៅដែរឬទេ? តើមានផលប៉ះពាល់អ្វីខ្លះទៅលើសកម្មភាពអភិវឌ្ឍន៍សហគមន៍? តើការប្រើប្រាស់ថ្នាំញៀនប៉ះពាល់ដល់ការចូលរួមរបស់អ្នកប្រើប្រាស់ ឬសមាជិករបស់គ្រួសារគេ ក្នុងការចូលរួមសកម្មភាពអភិវឌ្ឍន៍សហគមន៍ដែរឬទេ?

៤. តើគេមានការឆ្លើយតបយ៉ាងដូចម្តេចទៅនឹងបញ្ហានេះ? ឪពុកម្តាយ? គ្រូ? អាជ្ញាធរមូលដ្ឋាន? នរគបាល? អង្គការមិនមែនរដ្ឋាភិបាល? តើគេត្រូវធ្វើអ្វីទៀត?

ដើម្បីធ្វើការពិនិត្យទៅលើឯកសារសិក្សាមុនៗដោយភាពហ្មត់ចត់ គួរចាប់ផ្តើមពីការមានគំនិតច្បាស់លាស់ទៅលើអ្វីដែលអ្នកស្រាវជ្រាវចង់រកមើលនោះគឺការរៀបចំអោយមានសំណួរស្រាវជ្រាវអោយច្បាស់លាស់ជាមុនសិន នោះអ្នកអាចអនុវត្តន៍សកម្មភាពខាងក្រោមនេះ ដើម្បីរកមើលឯកសារចាំបាច់ដើម្បីពិនិត្យមើល :

- រកមើលរបាយការណ៏ស្រាវជ្រាវ (រួមទាំងរបាយការណ៏កម្មវិធី ឯកសាររបស់រដ្ឋាភិបាល ។ល ។) នៅតាមបណ្ណាល័យរបស់អង្គការនានា ។
- សុំការជួយពីបុគ្គល ឬអង្គការដែលធ្វើការសិក្សាស្រាវជ្រាវ ពីព្រោះគេអាចជួយអ្នក ក្នុងការស្វែងរកនូវឯកសារដែលមានការពាក់ព័ន្ធ ។
- ស្រាវជ្រាវតាមវិបសាយ ពីព្រោះវាអាចនាំអ្នកទៅរកឯកសារដែលទាក់ទងនឹងបញ្ហាស្រាវជ្រាវរបស់អ្នក ។



**ការបែងចែករវាងគោលបំណងនៃការស្រាវជ្រាវ** (Research purpose) **ទិសដៅនៃការស្រាវជ្រាវ** (Research objective) **និងទិសដៅរបស់កម្មវិធី** (Program objective)

គោលបំណងនៃការស្រាវជ្រាវ ទិសដៅនៃការស្រាវជ្រាវ និងទិសដៅកម្មវិធីគឺជាពាក្យដែលអាចនាំឱ្យមានការច្រឡំ ពិសេសសំរាប់អ្នកស្រាវជ្រាវថ្មីដែលធ្លាប់តែធ្វើការងារក្នុងកម្មវិធីអភិវឌ្ឍន៍សង្គម ។ ដូចដែលត្រូវបាននិយាយនៅក្នុងផ្នែកខាងដើមរួចមកហើយ គោលបំណងស្រាវជ្រាវឆ្លើយតបទៅនឹងសំណួរថា "តើខ្ញុំធ្វើការងារនេះ ដើម្បីអ្វី?" (Mason, 1996:18). ចំលើយទៅនឹងសំណួរនេះ និយាយសំដៅទៅលើការខ្វះចន្លោះនៃចំណេះដឹង ដែលគេកំពុងតែខិតខំបំពេញ និងសំដៅលើការរួមចំណែកដល់ការបង្កើនចំណេះដឹងទូទៅទាក់ទងទៅនឹងសាច់រឿងណាមួយដែលអាចស្ថិតក្នុងក៏រិតទ្រឹស្តី គោលនយោបាយនិងការអនុវត្តន៍ជាក់ស្តែង រួមទាំងសំដៅទៅលើការទាមទារ ឬតស៊ូមតិ ដើម្បីនាំមកនូវការផ្លាស់ប្តូរផ្នែកសង្គម និងនយោបាយ ។ គំរោងស្រាវជ្រាវមួយអាចមានគោលបំណងលើសពីមួយ ហើយអ្នកដែលមានការពាក់ព័ន្ធមានការចាប់អារម្មណ៏ខុសៗគ្នាចំពោះគោលបំណងនៃការស្រាវជ្រាវ ។ អ្នកស្រាវជ្រាវផ្នែកសង្គម ប្រើពាក្យ "គោលបំណង" ក្នុងន័យដូចគ្នាទៅនឹងពាក្យថា "សារៈសំខាន់នៃការស្រាវជ្រាវ" ដែលបានលើកឡើងនៅផ្នែកខាងដើមនៃសៀវភៅនេះរួចហើយ ។

ទិសដៅនៃការសិក្សាស្រាវជ្រាវសំដៅលើសំណួរ/បញ្ហាស្រាវជ្រាវ *ជាក់លាក់ច្បាស់លាស់* (ជាជាងសំនួរ/បញ្ហាស្រាវជ្រាវទូទៅ) ដែលការសិក្សាចង់លើកយកមកពិនិត្យ ។ ជាញឹកញាប់ ការកំណត់ទិសដៅមានន័យថា ជាការកំណត់នូវភារកិច្ចដែលអ្នកត្រូវធ្វើក្នុងពេលស្រាវជ្រាវ ព្រមទាំងកំណត់នូវនូវលទ្ធផលរកឃើញមួយចំនួនដែលអ្នកអានរំពឹងចង់បានពីការស្រាវជ្រាវ ។ ចំណែកឯសំណួរ/បញ្ហាស្រាវជ្រាវទូទៅវិញ មិនអាចចាត់ទុកថាទិសដៅនៃការសិក្សាស្រាវជ្រាវនោះទេ ព្រោះវាមានលក្ខណៈទូទៅ ឬទូលំទូលាយពេក ហើយមិនធ្វើឱ្យគេឃើញពីរបៀបដែលគេធ្វើការបកស្រាយ និង/ឬវិភាគបែបណានោះទេ ។

ទិសដៅកម្មវិធីខុសពីទិសដៅនៃការស្រាវជ្រាវនៅត្រង់ថា ទិសដៅកម្មវិធីផ្តោតលើរបៀបដែលអ្នកជំនាញចង់ *ធ្វើអ្វីមួយដើម្បីអោយមាន*ការផ្លាស់ប្តូរ ។ ដូច្នេះ ទិសដៅកម្មវិធីគឺ គេទុកសំរាប់ធ្វើការជាគោលសំខាន់ ដើម្បីធ្វើការត្រួតពិនិត្យនិងវាយតំលៃ ហើយក៏គេអាចយកជាមូលដ្ឋានសំខាន់សំរាប់វាយតំលៃ ឬការរីកចំរើននៃគំរោង ឬកម្មវិធីណាមួយ (Feuerstein, 1986:22) ។ ទិសដៅកម្មវិធីមានចែកចេញជាកំរិតផ្សេងៗពីគ្នាដូចជា ទិសដៅអភិវឌ្ឍន៍ ទិសដៅបង្ហាញពីឥទ្ធិពល/ផលប៉ះពាល់របស់កម្មវិធី និងទិសដៅចំពោះមុខ (Dale, 2003:63) ។

## កំណត់ឯកតានៃការវិភាគ

ឯកតានៃការវិភាគជាទូទៅសំដៅទៅលើ **អ្វី ឬ អ្នកណា** ដែលអ្នកស្រាវជ្រាវធ្វើការសិក្សា (Babbie, 1998: 93; Lewis-Beck et al, 2004:1157) ។ តាមធម្មតា វាក៏ជាឯកតានៃការសង្កេតរបស់អ្នកស្រាវជ្រាវដែរ ឯកតានៃការវិភាគអាចជាបុគ្គលម្នាក់ ឬក្រុមមនុស្សមួយក្រុមក្នុងសង្គម អង្គការមួយ ហេតុការណ៍ បញ្ហា តួនាទី ទំលាប់អនុវត្តន៍..... ។ល ។ សំរាប់គេលើកយកមកពន្យល់ទាក់ទងទៅនឹងបញ្ហាស្រាវជ្រាវណាមួយ ។ ដូច្នេះឯកតានៃ ការវិភាគគឺមិនមែនជាប្រធានបទដែលអ្នកស្រាវជ្រាវធ្វើការសិក្សាទេ តែជាទំរង់នៃសេចក្តីយោង សំរាប់ការពិភាក្សាលើប្រធានបទណាមួយ ។ អ្នកស្រាវជ្រាវនិយាយយោងទៅរក "ករណី" មួយដែលគេបានខិតខំប្រមូលពតិមានបានមកនោះថា ជាឯកតានៃការវិភាគមួយ (Vogt, 1993:239) ។

ទោះបីជាយ៉ាងណា ឯកតានៃការវិភាគ *អាច* ខុសគ្នាពីឯកតានៃការសង្កេត (Lewis-Beck et al, 2004:1157) ។ ភាពខុសគ្នានេះអាចកើតឡើងនៅពេលអ្នកស្រាវជ្រាវបញ្ចូលគ្នានូវទិន្នន័យកំរិតបុគ្គល/ក្រុម ដើម្បីយកមករៀបរាប់បញ្ហាសង្គមមួយនៅក្នុងលំដាប់ថ្នាក់ប្រទេស ។ ឧទាហរណ៍ បើយើងពង្រីកការសិក្សាស្តីពីការប្រើប្រាស់គ្រឿងញៀនដល់លំដាប់ថ្នាក់ជាតិនោះលទ្ធផលរកឃើញនៅលំដាប់ថ្នាក់បុគ្គលទាក់ទងនឹងចំនួនយុវវ័យដែលប្រើគ្រឿងញៀន អាចត្រូវបានសង្ខេបដោយដាក់ជាពិន្ទុមធ្យម បន្ទាប់មកកំណត់យកពិន្ទុរួមនោះសំរាប់ប្រទេសទាំងមូល សំរាប់ប្រៀបធៀបជាមួយប្រទេសដទៃទៀតនៅក្នុងតំបន់អំពីនិន្នាការ នៃការប្រើថ្នាំញៀន ។ នៅក្នុងលក្ខណៈបែបនេះ ឯកតានៃការសង្កេតគឺជាបុគ្គល ប៉ុន្តែឯកតានៃការវិភាគគឺជាប្រទេស ។ ឧទាហរណ៍នេះបង្ហាញថា នៅពេលដែលគេពង្រីកឯកតានៃការវិភាគនោះ ឯកតាឬករណីតូចៗត្រូវតែក្លាយទៅឯកតាឬករណីធំ ពីព្រោះថាគេកំពុងតែឈានចូលទៅក្នុងលំដាប់ធំនៃអង្គការសង្គម ។

ដោយអាស្រ័យលើគោលបំណងនៃការស្រាវជ្រាវនិងពេលវេលាអំណោយផល អ្នកស្រាវជ្រាវអាចនឹងប្រើឯកតានៃការវិភាគលើសពីមួយក្នុងការស្វែងយល់បញ្ហាស្រាវជ្រាវរបស់គេ ។ ដូច្នេះ បើគេពិនិត្យគ្រួសារយកធ្វើជាឯកតាមួយនោះ បុគ្គលនៅក្នុងគ្រួសារគឺជាឯកតាតូចនៃការវិភាគដែលអ្នកស្រាវជ្រាវអាចពិនិត្យមើលនៅក្នុងពេលជាមួយគ្នានោះ ។ ឧទាហរណ៍ ចំណុចនេះគេមើលឃើញច្បាស់ នៅពេលគេសិក្សាវាយតំលៃសុខុមាលភាពគ្រួសារ (ឯកតានៃការវិភាគទីមួយគឺគ្រួសារ) និងពិនិត្យការរួមចំណែកនៃចំណូលរបស់សមាជិក ឬសកម្មភាព រកស៊ីរបស់គេដល់ស្ថានភាពគ្រួសារ (ឯកតានៃការវិភាគទី២គឺបុគ្គល) ។ បើមិនមានតំរូវការឱ្យធ្វើដូច្នេះ ក្នុងការស្រាវជ្រាវដោយឡែកណាមួយទេនោះ គេមិនចាំបាច់ប្រើឯកតានៃការវិភាគលើសពីមួយទេ ។

ទស្សនៈស្តីពីឯកតានៃការវិភាគត្រូវបានបំភ្លឺបន្ថែមនៅក្នុងការពិភាក្សាខាងក្រោម ទៅលើឯកតានៃការវិភាគជាច្រើនដែលគេច្រើនឃើញមានប្រើ ។

### បុគ្គល

ពតិមានដែលប្រមូលពីបុគ្គលដែលជាឯកតានៃការវិភាគ ច្រើនតែផ្តោតលើលក្ខណៈសម្បត្តិរបស់គេ ហើយមានគោលបំណងរៀបរាប់ពីមនុស្សដែលយើងកំពុងសិក្សា ។ លក្ខណៈសម្បត្តិរបស់មនុស្សម្នាក់ៗត្រូវបានគួបផ្សំ ជាមួយនឹងអ្នកដទៃទៀតនៅក្នុងសំណាកដើម្បីរកចំនួនមធ្យម ភាគរយ ឬរបាយប្រេកង់(ចំនួនដង) តារាង ឬទិន្នន័យសង្ខេបនៅក្នុងទំរង់លក្ខណៈណាមួយ ។ ឯកតានៃការវិភាគដែលជាបុគ្គលអាចត្រូវបានគេជ្រើសរើស សំណាកតាមរបៀបចៃដន្យ ឬដោយផ្អែកលើគោលបំណងអាស្រ័យទៅលើសំណួរស្រាវជ្រាវ និងទិសដៅនៃការស្រាវជ្រាវ ។

## ឧទាហរណ៍

នៅក្នុងការស្វែងយល់ពីស្ថានភាពការងាររបស់បុរស និងនារីនៅក្នុងរោងចក្រកាត់ដេរនៅភ្នំពេញ អ្នកស្រាវជ្រាវម្នាក់បានរៀបចំសំណួរស្រាវជ្រាវសំខាន់ៗ ដែលគាត់មានការចាប់អារម្មណ៍ទៅលើជាពិសេស (ឧទាហរណ៍ សំណួរទាក់ទងនឹងប្រវត្តិរបស់កម្មករ លក្ខខ័ណ្ឌការងារ និងប្រាក់កំរៃ) ។ ដូចនេះ សំណួរនិមួយៗ (ដែលមានគោលបំណងឆ្លើយនឹងសំណួរស្រាវជ្រាវសំខាន់ៗ) នៅក្នុងឧបករណ៏ប្រមូលទិន្នន័យ មានបំណងទាញយកពតិមានទាក់ទងនឹង **កម្មករនិមួយៗ**នៅក្នុងសំណាកដែលបានស្រាវជ្រាវ ។ នៅពេលសំភាសន៏បុគ្គលហើយ អ្នកស្រាវជ្រាវបូកសរុបពតិមាន ដើម្បីបានជាសេចក្តីសង្ខេប ដូចជាអាយុមធ្យម កំរិតវប្បធមិ រយៈពេលមធ្យមដែលបានធ្វើការនៅក្នុងរោងចក្រ ភាគរយនៃពួកគេដែលបានរៀបការហើយឬមិនទាន់រៀបការ ភាគរយនៃអ្នកទទួលប្រាក់កំរៃក្នុងចំណាត់ប្រភេទផ្សេងៗ ។ល ។ ទាំងអស់នេះ រៀបរាប់ពី**កម្មករម្នាក់ៗ**ដែលត្រូវបានស្រាវជ្រាវ ។ ការគិតជាមធ្យមភាគ និង គិតជាចំនួនដងគឺជាឧបករណ៏វិភាគពីរដែលប្រើ ដើម្បីពិពណ៌នាអំពីកម្មករ ។ ជាថ្មីម្តងទៀត ដោយអាស្រ័យលើគោលបំណងរបស់អ្នកស្រាវជ្រាវ គេអាចរៀបរាប់បន្ថែម ឬរៀបរាប់លំអិតលើពតិមានបរិមាណដោយរួមជាមួយនឹងករណីសិក្សា ឬរឿងរបស់បុគ្គលចំនួនពីរឬបីនាក់ ។ ករណីសិក្សាទាំងនេះ គេអាចរកបានតាមដំណើរការជ្រើសរើសសំណាកដែលមានច្រើនដំណាក់កាល (Muli-phase sampling procedure) ។

### *កំណត់សំគាល់*

ការសំភាសន៏ជាក្រុមតូច គឺមិនមែនជាបច្ចេកទេសប្រមូលពតិមានសមស្របទេ នៅពេលណាដែលគេប្រើឯកតានៃការវិភាគគឺជាបុគ្គលនោះ ។ មានហេតុផលច្រើនចំពោះរឿងនេះ ។ ទីមួយ ការសំភាសន៏ជាក្រុមគឺមិនមែនជាវេទិកាសំរាប់សុំពតិមានទាក់ទងនឹងមនុស្សម្នាក់ៗទេ (ឧទាហរណ៏ អាយុ កំរិតវប្បធមិ ។ល ។) ទីពីរ ក្នុងការសំភាសន៏ក្រុម អាចមានមនុស្សតែពីរបីនាក់និយាយតែឯង ហើយអ្នកដែលមានការអៀនប្រៀន យើងមិនទទួលបានពតិមានពីពួកគេទេ ។ ទីបី ពេលវេលារបស់អ្នកស្រាវជ្រាវ និងរបស់អ្នកចូលរួមក្នុងក្រុមតូច មិនសូវប្រើប្រាស់បានផលល្អទេ ពីព្រោះប្រភេទនៃទិន្នន័យដែលបានមកនោះ មិនធ្វើឱ្យគេអាចវិភាគទៅតាមលក្ខណៈខុសៗគ្នាពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់បានទេ ។

## ក្រុមមនុស្ស

ពតិមានដែលប្រមូលបានពីក្រុមមនុស្សដែលជាឯកតានៃការវិភាគ ច្រើនតែផ្តោតទៅលើចរិកលក្ខណៈរបស់ក្រុម ហើយមានបំណងរៀបរាប់ពីក្រុមមនុស្ស (ឧទាហរណ៏ គ្រួសារ ក្រុមក្មេងស្ទាវ ប្តីប្រពន្ធ ក្រុមមត្តិភក្តិ) ។ **ចំណុចយោងនៃសំណួរសំភាសន៍គឺក្រុមនោះតែម្តង** ។ បើអ្នកស្រាវជ្រាវប្រមូលទិន្នន័យបរិមាណ ធាតុសំខាន់ៗរបស់ក្រុមនិមួយៗ ដូចនៅក្នុងផ្នែកនិមួយៗនៃការវិភាគដែរ ត្រូវបានបូកបញ្ចូលជាមួយនឹងធាតុដទៃទៀតនៅក្នុងសំណាក ដើម្បីគណនារកមធ្យមភាគ ភាគរយ ឬរបាយចំនួនចំលើយ ។ ដូចគ្នានឹងឯកតានៃការវិភាគជាបុគ្គលដែរ ក្រុមមនុស្សអាចត្រូវបានកំណត់យកជា សំណាកដោយចៃដន្យ ឬសំណាកដែលកំណត់តាមគោលបំណង ដោយអាស្រ័យលើសំណួរស្រាវជ្រាវ ឬទិសដៅនៃការស្រាវជ្រាវ ។

### ឧទាហរណ៏

អង្គការមិនមែនរដ្ឋាភិបាលមួយដែលធ្វើការនៅក្នុងស្រុកមួយនៅក្នុងខេត្តកំពង់ធំ ចង់ផ្តល់ជំនួយដល់ភូមិនៅក្បែរខាងតំបន់ដែលអង្គការនោះធ្វើការ ។ អង្គការនោះបានឮពីភាពក្រីក្រនៅតាមភូមិជាប់នោះ តែមិនដឹងថា គេក្រយ៉ាងណា

ទេ ។ ដើម្បីដឹងពីការរិតជីវភាពរស់នៅរបស់អ្នកភូមិ និងរបៀបធ្វើយ៉ាងណា ដើម្បីជួយគេឱ្យបានល្អ អង្គការនោះសំរេចចិត្តធ្វើការសិក្សាកំណត់ទិន្នន័យដើម (Baseline study) ។ គេកំណត់គ្រួសារជាផ្នែកនៃការវិភាគដើម្បីស្វែងយល់រូបភាពរួមនៃស្ថានភាពក្រីក្រនៅលំដាប់ថ្នាក់នេះ ហើយដើម្បីដៅឱ្យចំគ្រួសារដែលក្រីក្រនោះ ។

សំណួរសំភាសន៍ច្បាស់លាស់ (ទាក់ទងនឹងសំណួរស្រាវជ្រាវគន្លឹះ - ឧទាហរណ៍ តើអ្នកណាជាអ្នកក្រនៅក្នុងភូមិ?) នៅក្នុងឧបករណ៍នៃការអង្កេត ចង់បានពត៌មានទាក់ទងនឹង **គ្រួសារនិមួយៗ** នៅក្នុងសំណាកនៃការសិក្សា ។ ឧទាហរណ៍ សំណួរដែលគេសួរនោះទាក់ទងនឹងយេនឌ័រ អាយុ និងការិតវប្បធម៌របស់មេគ្រួសារ និងសមាជិកដទៃទៀត លក្ខណៈពិសេសរបស់សមាជិកគ្រួសារ (ឧទាហរណ៍ មេគ្រួសារជាស្រ្តី មានសមាជិកគ្រួសារចាស់ជរា ឬពិការភាព) ទ្រព្យសម្បត្តិ ដែលមាន (ឧទាហរណ៍ ដីស្រែ សត្វចិញ្ចឹម) ផលិតកម្មកសិកម្ម និងសកម្មភាពរកចំណូល ទំលាប់ទាក់ទងនឹងផ្នែកសុខភាព ។ល ។

តាមពិតទៅ សំណួរទាំងអស់ មានលក្ខណៈជាការរៀបរាប់ពី **គ្រួសារ** ជាជាងរៀបរាប់ពីសមាជិកម្នាក់នៃគ្រួសារ ។ អ្នកឆ្លើយតបនៅក្នុងការសំភាសន៍ច្រើនមានការយល់ដឹងពីគ្រួសារ ពោលគឺសមាជិកគ្រួសារពេញវ័យដែលបានរស់នៅជាមួយនឹងគ្រួសារកន្លងមក ។ របាយចំនួនចំលើយ និងមធ្យមភាគ តារាងនិងទំរង់ផ្សេងទៀតនៃសេចក្តីសង្ខេបទិន្នន័យគឺជាឧបករណ៍វិភាគដែលត្រូវបានប្រើផងដែរ សំរាប់ធ្វើសេចក្តីរៀបរាប់ពីក្រុមគ្រួសារ ។ ដោយអាស្រ័យលើគោលបំណងនៃអ្នកស្រាវជ្រាវ គេអាចបំពេញបន្ថែមសេចក្តីឬរៀបរាប់លំអិតទៅលើពត៌មានបែបបរិមាណ ដោយមានការបន្ថែមករណីសិក្សា ឬគ្រួសារចំនួន២-៣ទៀត ។

***កំណត់សំគាល់***

ការសំភាសន៍ជាក្រុមតូច (Focus group) អាចធ្វើបានដោយយកគ្រួសារធ្វើជាឯកតានៃការវិភាគ ។ ឧទាហរណ៍ អ្នកស្រាវជ្រាវចង់ប្រៀបធៀបគ្រួសារដែលមានមុខរបរផ្សេងគ្នា (ឧទាហរណ៍ គ្រួសារធ្វើស្រែទំនាប ស្រែខ្ពស់ ស្រូវប្រដេញទឹក និងគ្រួសារនេសាទ និងកាប់ឈើ ។ល ។) ទៅតាមយុទ្ធសាស្រ្តចិញ្ចឹមជីវិតរបស់គេនៅក្នុងដំណាក់កាលខ្វះខាតស្បៀង ។ តំណាងរបស់គ្រួសារនានា អាចលើកឡើងពីបទពិសោធន៍របស់គេរៀងៗខ្លួន ហើយអ្នកស្រាវជ្រាវធ្វើសំយោគទៅលើការពិភាក្សានោះស្តីពី អ្វីដែលជាលក្ខណៈប្លែកសំរាប់គ្រួសារមួយ និងអ្វីដែលជាលក្ខណៈរួមរបស់គេ ។

## អង្គការ

ការធ្វើអង្កេតដោយយកអង្គការ (ពោលគឺ សកម្មភាពរួមដោយមានគោលដៅ សមាជិក និងភារកិច្ចត្រឹមត្រូវ) ជាឯកតានៃការវិភាគ ផ្តោតជាចាំបាច់ទៅលើទិន្នន័យដែលទាក់ទងនឹងលំដាប់ថ្នាក់អង្គការ (ឧទាហរណ៍ អង្គការមិនមែនរដ្ឋាភិបាល សមាគមន៍នៅតាមភូមិ សហករណ៍) ។ ដូចឯកតាវិភាគជាបុគ្គលនិងគ្រួសារដែរ ពត៌មានដែលប្រមូលបានត្រូវបានសង្ខេបដើម្បីរៀបរាប់ពីអង្គការដែលត្រូវបានស្រាវជ្រាវ ។ ឧទាហរណ៍ ចំណុចដោយឡែកៗដែលជាចំណុចសំខាន់សំរាប់ការស្រាវជ្រាវមានដូចជាកាលៈទេសៈនៃការបង្កើតអង្គការ របៀបដែលគេជ្រើសរើសនិងគ្រប់គ្រងសមាជិក យុទ្ធសាស្រ្តដែលគេអនុវត្តន៍ ដើម្បីសំរេចគោលដៅរបស់គេ និងបុព្វហេតុ នៃការរីកចំរើនរបស់អង្គការ ការផ្លាស់ប្តូរ និងការដួលរលំនៃអង្គការ (Lofland and Lofland, 1984:87-89) ។

### ឧទាហរណ៍

អ្នកស្រាវជ្រាវម្នាក់ចង់ពិនិត្យមើលអង្គការមិនមែនរដ្ឋាភិបាលមួយដែលកំពុងជួយដល់ស្ត្រីងាយរងគ្រោះ (ឧទាហរណ៍

ស្ត្រីរងគ្រោះដោយអំពើហិង្សា ស្ត្រីគ្មានផ្ទះសម្បែង ឬ "អ្នករស់នៅតាមចិញ្ចើមផ្លូវ") តាមរយៈការផ្តល់ទីជំរក និងដើម្បីទាញបាននូវកត្តានានារបស់អង្គការដែលរួមចំណែក ឬរាំងស្ទះដល់ការវិលត្រឡប់របស់ស្ត្រីទាំងនោះទៅរស់នៅក្នុងសង្គមដូចគេឯងបាន ។ ទិន្នន័យដែលគាត់សំរេចចិត្តប្រមូលទាក់ទងនឹងទិសដៅ/សំណួរស្រាវជ្រាវរបស់គាត់ រួមមានគុណតំលៃដែលអង្គការនោះមានចំពោះក្រុមគោលដៅរបស់គេ ទំហំទឹកប្រាក់ដែលអង្គការបានទទួលសំរាប់ធ្វើការងាររបស់ខ្លួន ចំនួនបុគ្គលិកជួយការងារ និងទំរង់នានានៃជំនួយដែលផ្តល់ទៅអោយនារី នៅក្នុងពេលគេកំពុងស្នាក់នៅក្នុងទីជំរក ។ល ។ និងរបៀបដែលកត្តាទាំងអស់នេះរួមផ្សំគ្នា និងកត្តានិមួយៗមានឥទ្ធិពលទៅលើទស្សនៈយល់ឃើញរបស់នារី និងអ្វីដែលនារីទាំងនោះនឹងធ្វើនៅពេលគេរស់នៅក្រៅទីជំរក ។ ការវិភាគផ្តោតទៅលើអង្គការ (នៅក្នុងឧទាហរណ៍នេះ គឺអង្គការមិនមែនរដ្ឋាភិបាល) យកធ្វើជាឯកតាមួយ ។ គាត់កំណត់អង្គការមិនមែនរដ្ឋាភិបាល យកធ្វើជាឯកតានៃការវិភាគ ដើម្បីបង្កើតជារូបភាពមួយនៃអ្វីដែលមាននៅក្នុងអង្គការហើយ ដែលអាចរួមចំណែក ឬរាំងស្ទះដល់ជំនួយក្នុងចំណោមក្រុមមនុស្សដែលងាយរងគ្រោះ ។

បន្ទាប់មក សំណួរសំភាសន៍ផ្តោតលើ**សមាសភាគរបស់អង្គការ**ជាជាងបុគ្គលិកនិមួយៗ ។ អ្នកឆ្លើយតបសំភាសន៍អាចមានបុគ្គលិកនីមួយៗនៅក្នុងលំដាប់ថ្នាក់ផ្សេងៗនៅក្នុងអង្គការ (ឧទាហរណ៍ អ្នកគ្រប់គ្រងកម្មវិធី អ្នកកាន់ផ្នែកហិរញ្ញវត្ថុ អ្នកបណ្តុះបណ្តាល និងស្ត្រីជាអ្នកទទួលផល ។ល ។) ប៉ុន្តែ ទំរង់នៃសេចក្តីយោង (frame of reference) នៅតែជាអង្គការដដែល ។ តួលេខសង្ខេបស្តីពីពត៌មានបែបបរិមាណ (តាមរយៈរបាយចំនួនចំលើយ និងចំនួនគិតជាមធ្យម) ក៏អាចត្រូវបានយកមកប្រើដែរ ។ អាស្រ័យលើទិសដៅនៃការស្រាវជ្រាវ អ្នកស្រាវជ្រាវអាចសំរេចបន្ថែមសេចក្តី ឬពន្យល់លំអិតលើពត៌មានបែបបរិមាណជាមួយនឹងករណីសិក្សា ឬរឿងដែលសង្កត់ទៅលើចំណុចខ្លាំង ឬចំណុចខ្សោយរបស់អង្គការដែលកំពុងត្រូវបានវិភាគ ។

***កំណាត់ចំណាំ:***

ការសំភាសន៍ជាមួយក្រុមគោលដៅណាមួយអាចធ្វើទៅបាន ដោយកំណត់យកអង្គការជាឯកតានៃការវិភាគ ។ នៅក្នុងឧទាហរណ៍ខាងលើនេះ សមាជិកបុគ្គលិកស្ត្រីដែលទទួលបានការជួយឧបត្ថម្ភ ប្រជាជនដែលរស់នៅក្បែរអង្គការ អាចជាក្រុមគោលដៅ នៅក្នុងការស្វែងយល់លក្ខណៈសម្បត្តិរបស់អង្គការដែលជួយឧបត្ថម្ភ ឬភាពរាំងស្ទះដល់ការងាររបស់អង្គការទៅលើក្រុមគោលដៅ ។

## ទីតាំងរស់នៅ (ភូមិ-ក្រុង-ខេត្ត)

តំបន់រស់នៅគឺជាដែនដីដែលត្រូវបានកំណត់តាមផ្នែកភូមិសាស្ត្រ និងសង្គមវិទ្យាដែលមានបុគ្គល គ្រួសារអង្គការ ផ្លូវការ ធនធានសំភារៈ ។ល ។ នៅពេលត្រូវបានប្រើធ្វើជាឯកតានៃការវិភាគ អ្នកស្រាវជ្រាវពិនិត្យទៅលើសមាសភាគទាំងអស់ ឬសមាសភាគខ្លះនៃតំបន់រស់នៅ (ឧទាហរណ៍ ភូមិ) ព្រមទាំងទំនាក់ទំនងទៅវិញទៅមក នៃសមាសភាគទាំងនេះ ដើម្បីពិនិត្យមើលដូចជា តើបញ្ហាស្រាវជ្រាវលេចចេញយ៉ាងដូចម្តេចនៅកំរិតថ្នាក់ភូមិ ។ ពត៌មានដែលបានមកពីប្រភពផ្សេងៗ (ឧទាហរណ៍ ការសំភាសន៍ជាមួយបុគ្គល គ្រួសារ និង/ឬក្រុម ឯកសារ) ត្រូវបានពិនិត្យមើល ដើម្បីយល់ពីដំណើរទាក់ទងនៃបញ្ហានៅលំដាប់ថ្នាក់តំបន់រស់នៅ ។

### ឧទាហរណ៍

ឧទាហរណ៍បំភ្លឺមួយនៃតំបន់រស់នៅ ដែលត្រូវបានយកធ្វើជាឯកតានៃការវិភាគគឺការសិក្សារបស់អង្គការសេវាសង្គម សំរាប់កម្ពុជា (SSC) ស្តីពីឥទ្ធិពលនៃជំលោះប្រដាប់អាវុធទៅលើធនធានសង្គម ។ ដោយកំណត់យកក៏រិតភូមិពីព្រោះនៅក្នុងលំដាប់ថ្នាក់នេះ គេងាយយល់ធនធានសង្គមបានច្បាស់លាស់ ក្រុមអ្នកស្រាវជ្រាវបានកំណត់យកភូមិជាឯកតានៃការវិភាគ ហើយប្រមូលនិងវិភាគអាំងឌីកាទ័រនៃផលប៉ះពាល់ ។ ដោយធ្វើការប្រៀបធៀបភូមិពីរពតិមានខ្លះដែលក្រុមអ្នកស្រាវជ្រាវបានប្រមូលបានរួមមាន ប្រវត្តិរបស់ភូមិ និងធនធានផ្នែកសង្គម (ឧទាហរណ៍ បណ្តាញក្រៅផ្លូវការទំលាប់ធ្វើកសិកម្មប្រវាស់ដៃ ទំលាប់ទាក់ទងនឹងឥណទានក្រៅផ្លូវការ ។ល ។) នៅក្នុងបរិបទនៃសកម្មភាព ប្រកបជីវភាពរស់នៅ សេវានៅតាមថ្នាក់ភូមិ (ឧទាហរណ៍ ការសិក្សាអប់រំជាមូលដ្ឋាន ការថែទាំសុខភាពបឋម សន្តិសុខ ។ល ។) ។

នៅក្នុងឧទាហរណ៍នេះ ប្រភពពតិមានរួមមានបុគ្គល (ឧទាហរណ៍ អ្នកដឹកនាំសំខាន់ៗ ក្រុមមនុស្សដែលមានមុខរបរផ្សេងៗ) ហើយនិងគ្រួសារ ។ ទោះបីជាយ៉ាងណា ការវិភាគលើកិច្ចសំភាសន៏ស្ថិតនៅក្នុងបរិបទថា តើបទពិសោធន៏របស់បុគ្គល និងគ្រួសារបង្ហាញឱ្យឃើញយ៉ាងដូចម្តេចពីការមានឬការមិនមានធនធានផ្នែកសង្គមនៅលំដាប់ថ្នាក់ភូមិ ។

### កម្មវិធី/គំរោង

ការសិក្សាដែលពិនិត្យទៅលើគំរោង/កម្មវិធី (ឧទាហរណ៍ កម្មវិធីឥណទាន គំរោងសហគ្រាសខ្នាតតូច វគ្គបណ្តុះបណ្តាល ។ល ។) ដែលជាឯកតានៃការវិភាគ ស្វែងយល់ទៅលើទិន្នន័យតាមរបៀបដូចដែលគេធ្វើនៅពេលគេប្រើគ្រួសារ ឬអង្គការធ្វើជាចំណុចផ្តោតសំខាន់ ។ **ពោលគឺចំណុចយោងនៃសំណួរសំភាសន៍ និងការវិភាគទិន្នន័យគឺកម្មវិធីដែលកំពុងត្រូវបានសិក្សាទៅលើ** ។ ប្រភពពតិមានគឺអ្នកដែលចូលរួមនៅក្នុងកម្មវិធី – ឧទាហរណ៍ អ្នកតាក់តែងរៀបចំនិងអនុវត្តន៏កម្មវិធី អ្នកទទួលផលនៅលំដាប់ថ្នាក់គ្រួសារនិងបុគ្គល រួមទាំងអ្នកផ្សេងដែលមិនអាចមានការពាក់ព័ន្ធឬប៉ុន្តែអាចមានមតិយោបល់ដល់កម្មវិធី ។ សេចក្តីសង្ខេបទិន្នន័យ បង្ហាញអំពីទិដ្ឋភាពផ្សេងៗនៃកម្មវិធីដែលកំពុងត្រូវបានវិភាគ ហើយឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលត្រូវបានលើកឡើង ។

### ឧទាហរណ៍ :

ឧទាហរណ៍ច្បាស់មួយដែលគេអាចគិតដល់នៅក្នុងករណីបែបនេះគឺការសិក្សាមួយរបស់សិក្ខាកាម CCC-ADI ស្តីពីការបែងចែកដីធ្លីឡើងវិញ ។ ត្រង់នេះ សិក្ខាកាមបានពិនិត្យលើការអនុវត្តន៏គំរោងបីនៅក្នុងគំរោងបែងចែកដីធ្លីឡើងវិញ (ដោយយកកម្មវិធីគឺជា ឯកតានៃការវិភាគ) ទាក់ទងនឹងអ្នកទទួលផល លក្ខណៈវិនិច្ឆ័យនៃការបែងចែកប្រភេទ និងទំហំនៃដីដែលចែកអោយ ។ល ។ ដើម្បីចេញជាមេរៀន និងអនុសាសន៏សំរាប់ការគិតគូរដែលនាំទៅរកការរួមចំណែកក្នុងការចេញជាអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ។ ការវិភាគលើកម្មវិធីរួមមានការពិនិត្យលើបទពិសោធន៏តាមរយៈករណីសិក្សាលើគំរោងមួយៗ ។ មេរៀន (រួមទាំងចំណុចខ្លាំងនិងចំណុចខ្សោយ) នៅក្នុងកម្មវិធីទាំងនេះ ត្រូវបានដកស្រង់និងបង្ហាញទៅអង្គការសំខាន់ៗដែលធ្វើការលើបញ្ហាសម្បទានដីសង្គមកិច្ច ។

តារាងទី ៣ ខាងក្រោមនេះផ្តល់នូវសេចក្តីសង្ខេបមួយនៃការពិភាក្សាខាងលើ ហើយចាប់យកសមាសធាតុសំខាន់ៗនៃឯកតានៃការវិភាគនិមួយៗ ។

**តារាងទី ៣: កំណត់ចំណាំខ្លីៗស្តីឯកតានៃការវិភាគ**

| ឯកតានៃការវិភាគ | ពត៌មានដែលប្រមូលបាន | វិធីវិភាគ |
|---|---|---|
| បុគ្គលម្នាក់ៗ | លក្ខណៈសម្បត្តិរបស់មនុស្សម្នាក់ៗ (ឧទាហរណ៍ អាយុ ភេទ កំរិតវប្បធម៌ ស្ថានភាពគ្រួសារ ឥរិយាបទ ពូជសាសន៍ សាសនា រូបសម្បត្តិ ។ល ។) | ត្រូវបានសង្ខេបដើម្បីរៀបរាប់ពីសិស្ស ឪពុកដែលនៅពោះម៉ាយ ស្ត្រី |
| ក្រុមមនុស្ស | លក្ខណៈរបស់ក្រុមមនុស្សនៅក្នុងសង្គម – ចំណុចយោងរបស់សំណួរគឺក្រុមដែលកំពុងត្រូវបានសិក្សា ។ ឧទាហរណ៍ខ្លះគឺលំនាំនៃភាពដឹកនាំ ការប្រែប្រួលនៃរចនាសម្ព័ន្ធគ្រួសារ ។ | ត្រូវបានសង្ខេបដើម្បីរៀបរាប់ពីគ្រួសារ ក្រុមបងធំនៅតាមផ្លូវ ប្តីប្រពន្ធ ក្រុមមិត្តសំលាញ់ ។ល ។ |
| អង្គការ | លក្ខណៈ/បញ្ហាទាក់ទងនឹងប្រធានបទ (ឧទាហរណ៍ របៀបចងក្រង ប្រភេទនៃការងារ ។ល ។) | ត្រូវបានសង្ខេបដើម្បីរៀបរាប់ និងវិភាគទៅលើអង្គការមិនមែនរដ្ឋាភិបាល សារជីវកម្ម និងសហគមន៍ |
| កម្មវិធី/គំរោង | លក្ខណៈ/បញ្ហាទាក់ទងនឹងផលប៉ះពាល់នៃការបរាជ័យ/ជោគជ័យ សកម្មភាពថ្មីៗ ដែលមានលក្ខណៈប្លែកគេ ។ល ។ | ត្រូវបានសង្ខេបដើម្បីរៀបរាប់ ឬវិភាគពីការអនុវត្តន៍បានល្អ ឬមិនបានល្អ ឬមេរៀននៅក្នុងការងារអភិវឌ្ឍន៍ជាមួយនឹងក្រុមដៃគូ ។ល ។ |
| ទំលាប់របស់សង្គម | លក្ខណៈ/បញ្ហាទាក់ទងនឹងគុណតំលៃ បទដ្ឋាន តួនាទី ការប្រតិបត្តិផ្នែកអភិវឌ្ឍន៍របស់អង្គការ NGOs/IOs ។ល ។) ឧទាហរណ៍មាន ដូចជាអាពាហ៍ពិពាហ៍ ទំលាប់ របស់គ្រួសារ ទំលាប់តាមព្រះពុទ្ធសាសនានៅកម្ពុជា គុណតំលៃដែលកំពុងមានការប្រែប្រួល ។ល ។) | ត្រូវបានសង្ខេបដើម្បីស្វែងយល់ ពន្យល់ វិភាគទៅលើលំនាំដែលកំពុងប្រែប្រួលឬកំពុងកើតមានជាទូទៅ ហើយនិងរបៀបដែលលំនាំទាំងនេះមានផលប៉ះពាល់ទៅលើសង្គម ។ល ។ |
| បញ្ហាសង្គម (ឧទាហរណ៍ ការប្រើថ្នាំញៀន ភាពគ្មានដីធ្លី អំពើហិង្សាក្នុងគ្រួសារ | ធាតុសំខាន់ៗ/លក្ខណៈសម្បត្តិ/ប្រភេទនៃបញ្ហាសង្គម (ឧទាហរណ៍ លំនាំនៃភាពគ្មានដីធ្លី អត្រាអ្នកកើតជំងឺអេដស៍ ចំនួនករណីអំពើហិង្សាក្នុងគ្រួសារ ។ល ។ | ត្រូវបានសង្ខេបដើម្បីកំណត់លក្ខណៈឬពិនិត្យកំរិតដែលបញ្ហាប៉ះពាល់ដល់ បុគ្គល គ្រួសារ សហគមន៍ ដើម្បីចេញជាយុទ្ធសាស្ត្រដោះស្រាយបញ្ហា ។ល ។ |

ជំពូក ២

## ជំហានទី ២: ធ្វើផែនការប្រមូលពត៌មានពីប្រភពផ្សេងៗ


កំណត់រកពត៌មានដែលត្រូវការ ........ ៤១

កំណត់រកប្រភពពត៌មាន ........ ៤៦

វិធីជ្រើសរើសសំណាក និងទំហំសំណាក ........ ៥២

រៀបចំឧបករណ៍ប្រមូលទិន្នន័យ ........ ៦១

ត្រៀមរៀបចំវិភាគទិន្នន័យ ........ ៦៤

# ជំហ៊ានទី ២ៈ ធ្វើផែនការប្រមូលពត៌មានពីប្រភពផ្សេងៗ

*កំណត់រកពតិមានដែលត្រូវការ...ប្រភេទទិន្នន័យដែលត្រូវប្រមូល...កំណត់ប្រភពពតិមាននិងវិធីប្រមូលទិន្នន័យ....បូកសរុបវិធីប្រមូលទិន្នន័យ...វិធីជ្រើសរើសសំណាកនិងទំហំសំណាក... ត្រៀមរៀបចំសំរាប់ការវិភាគទិន្នន័យ....*

| ជំហ៊ានទី ២ | |
|---|---|
| ពត៌មានដែលត្រូវការ | ប្រភពពត៌មាន |
| | |
| | |
| | |



## កំណត់រកពតិមានដែលត្រូវការ

ការរៀបចំផែនការសំរាប់ដំណាក់កាលប្រមូលពតិមាន គេធ្វើឡើងបន្ទាប់ពីប្រធានបទរួមត្រូវបានកែសំរួលរួចរាល់ ទើបគេរៀបចំអោយទៅជាសំណួរស្រាវជ្រាវ ឬទិសដៅស្រាវជ្រាវដែលមានលក្ខណៈចំៗ និងអាចយកទៅធ្វើបាន ។ ជាជំហ៊ានដំបូង អ្នកស្រាវជ្រាវត្រូវការកំណត់រកពតិមានដែលត្រូវការ ដោយយោងតាមសំណួរស្រាវជ្រាវដែលបានលើកឡើង ។ ពតិមានទាំងនេះ អាចរួមមានលក្ខណៈប្រជាសាស្ត្ររបស់គ្រួសារឬបុគ្គល (ដោយអាស្រ័យលើឯកតានៃការវិភាគដែលត្រូវបានកំណត់) សកម្មភាពដែលគ្រួសារ/បុគ្គលនោះចូលរួម កត្តានិងលក្ខខ័ណ្ឌដែលនាំដល់ការកើតមានឡើងនូវបាតុភូតសង្គម ឬឥទ្ធិពលដែលបានកើតចេញមកពីការធ្វើសកម្មភាព/ការងារអ្វីមួយ ទោះជាវិជ្ជមាន ឬអវិជ្ជមានក្តី ។ ការកំណត់ប្រភេទពតិមានទូទៅ នៅក្នុងវង្វង់នៃសំណួរស្រាវជ្រាវ នឹងបង្កលក្ខណៈងាយស្រួលដល់ការតាក់តែងសំណួរសំរាប់ដាក់បញ្ចូលទៅក្នុងឧបករណ៍ប្រមូលទិន្នន័យ ។

នៅក្នុងការកំណត់រកពតិមានដែលត្រូវការសំរាប់ការស្រាវជ្រាវ មានប្រការសំខាន់ខ្លះៗដែលចងចាំដូចខាងក្រោមនេះ (Narayan, 1996:43-45):

- **កំណត់លំដាប់អាទិភាពនៃពត៌មានដែលត្រូវការៈ** វាជាការល្អបើគេកំណត់លំដាប់ពតិមានអោយលំអិត និងចោទជាសំណួរដើម្បីជួយបំភ្លឺក្នុងការកំណត់អាទិភាព ។ ឧទាហរណ៍ "តើនៅពេលចប់ការសិក្សាខ្ញុំត្រូវដឹងអ្វីខ្លះ?" ឬ "តើអ្វីខ្លះដែលអាចរង់ចាំដឹងនៅពេលក្រោយ?" ។ ប្រកាសំខាន់ដែរនោះគឺ ត្រូវងាកទៅរក មើលសំណួរស្រាវជ្រាវ និងទិសដៅស្រាវជ្រាវ ដើម្បីផ្ទៀងផ្ទាត់មើលថា តើពតិមានដែលកំណត់នោះ ពិតជានាំអោយយើងអាចធ្វើការវិភាគលើទិន្នន័យឬយ៉ាងណានោះ ។
- **កំណត់កំរិតនៃភាពលំអិតៈ** ការសំរេចចិត្តដែលសំខាន់មួយទៀតគឺ ភាពស៊ីជំរៅនៃធាតុទាំងឡាយដែលគេលើកយកមកនិយាយ ។ ឧទាហរណ៍ តើវាគ្រប់គ្រាន់ទេ បើគ្រាន់តែដឹងពីប្រភពចំណូលសំខាន់របស់អ្នកផ្តល់ចំលើយ ឬតើពតិមានស្តីពីមុខរបរផ្សេងទៀតឬការងារតាមរដូវកាលទេ? ដូចដែលបាននិយាយ មកហើយថា ទិសដៅនិងសំណួរស្រាវជ្រាវជួយតំរង់ផ្លូវអ្នកស្រាវជ្រាវទាក់ទងនឹងថាតើត្រូវធ្វើលំអិតប៉ុនណា និងថាតើចំណុចលំអិតយ៉ាងដូចម្តេចដើម្បីជួយដល់ការវិភាគទិន្នន័យ ។

- កំណត់កំរិតនៃភាពសុក្រិត្យ ។ គេអាចសន្សំសំចៃលើពេលវេលា ថវិកានិងជៀសវាងបាននូវការឈឺក្បាលបើសិនជាកំរិតនៃភាពសុក្រិត្យ (Accuracy) ត្រូវគេកំណត់បានមុនការប្រមូលទិន្នន័យ ។ ឧទាហរណ៍ ការសិក្សាជាច្រើនខិតខំវាយតំលៃឱ្យបានសុក្រឹត្យពីកំរិតប្រាក់ចំណូលរបស់គ្រួសារ បើទោះបីជាការកំណត់កំរិតចំណូលជាការពិបាកខ្លាំងក្តី ។

អ្នកស្រាវជ្រាវនៅតែត្រូវការដឹងពីប្រភេទទិន្នន័យដែលគាត់ត្រូវប្រមូល ។ ផ្នែកបន្ទាប់ទៅនេះរៀបរាប់ពីលក្ខណៈទូទៅនៃបញ្ហានេះ ។

## ប្រភេទទិន្នន័យ និងកំរិតនៃការវាស់វែង (Type of data and levels of measurement)

ដូចដែលបានរៀបរាប់រួចមកហើយ ទិន្នន័យអាចមានជាលក្ខណៈបរិមាណ (ឧ. តួលេខ) ឬ គុណភាព (គ្មានតួលេខ) ។ ពត៌មានទាក់ទងនឹងបរិមាណឬតួលេខ សំដៅលើការវាស់ឬរាប់អ្វីមួយ ចំណែកឯទិន្នន័យគុណភាព សំដៅទៅលើទិដ្ឋភាពសង្គម (ឧទាហរណ៍ ការយល់ឃើញ ជំនឿ ឥរិយាបទ បុគ្គលិកលក្ខណៈ ។ល ។) តួនាទីនិងឋានៈនៅក្នុងសង្គម (ឧទាហរណ៍ អ្នកថែទាំ ឪពុកម្តាយ គ្រូបង្រៀន អ្នកដឹកនាំសហគមន៍ អ្នកមាន អ្នកក្រ អ្នកចេះអក្សរ ឬអ្នកមិនចេះអក្សរ ។ល ។) ដំណើរការសង្គម (ឧទាហរណ៍ យុទ្ធសាស្ត្រដោះស្រាយ ការជួយគ្នាទៅវិញទៅមក ឬការប្រវាស់ដៃគ្នា លំនាំនៃការធ្វើចំណាកស្រុកតាមរដូវកាល ។ល ។) ដូចបានកត់សំគាល់ខាងដើមផងដែរថា តាមធម្មតាគ្មានការសង្កេតឃើញរបស់យើងណាមួយមានជាលក្ខណៈបរិមាណ ឬតួលេខនោះទេ តែការបង្វែរវាឱ្យមានទំរង់ជាតួលេខដោយកំណត់តំលៃលើធាតុណាមួយ នោះទើបធ្វើឱ្យការសង្កេតរបស់យើងមានភាពច្បាស់ និងសំរួលដល់ការបូកបញ្ចូលគ្នានិងការវិភាគ ។ មកដល់ចំណុចនេះ អ្វីដែលគេគួដឹងគឺការប្រើប្រាស់ ពាក្យពេជន៍ដូចជា អថេរ (Variables) និងធាតុសំខាន់ៗ (Attributes) ។ **អថេរ** គឺជាសំណុំនៃធាតុជាច្រើនដែល ដែលអាចកំណត់តំលៃ ឬអាចបែងចែកទៅជាផ្នែកៗផ្សេងពីគ្នា (Lewis-Beck et al, 2004:1172) ។ ផ្ទុយទៅវិញ **ធាតុសំខាន់ៗ** គឺជាលក្ខណៈដែលអ្នកផ្តល់ចំលើយ ឬករណីដែលយើងធ្វើការស្រាវជ្រាវមានឬមិនមាន ។ ឧទាហរណ៍ យេនឌ័រ គឺជាអថេរ តែធាតុសំខាន់ៗនៃយេនឌ័រមានជា *ស្រី* និង *ប្រុស* ។

ករយល់ពាក្យទាំងពីរនេះពិតជាមានសារៈសំខាន់ ពីព្រោះគេអាចវាស់វែងវាតាមលំដាប់ខុសៗគ្នា ។ លំដាប់នៃការវាស់វែងដែលគេច្រើនប្រើ ជាពិសេសនៅក្នុងការស្រាវជ្រាវបែបបរិមាណ គឺមានដូចខាងក្រោមនេះ ហើយមានបង្ហាញនៅក្នុងរូបទី ៣ (Lewis-Beck, 2004; Babbie, 1998; Vogt, 1993; Agresti and Finlay, 1986):

១. រង្វាស់ជាសញ្ញាសំគាល់ (Nominal measures) សំដៅលើការកំណត់ចំណាត់ក្រុមនៅក្នុងអថេរ ហើយគ្រាន់តែផ្តល់ជាឈ្មោះ ឬផ្លាកសញ្ញាទៅលើលក្ខណៈផ្សេងៗ ។ ឧទាហរណ៍នៃរង្វាស់ជាសញ្ញាសំគាល់ដូចជា ភេទ (ប្រុស ស្រី) ស្ថានភាពគ្រួសារ (នៅលីវ រៀបការហើយ មេម៉ាយ/ពោះម៉ាយ លែងលះគ្នា) សាសនា (ព្រះពុទ្ធសាសនា សាសនាគ្រិស្ត សាសនាមិនជឿថាមានព្រះអាទិទេព ។ល ។) ។ អថេរជាសញ្ញាសំគាល់ ច្រើនតែមានលក្ខណៈជាគុណភាព ពីព្រោះតំលៃពីរដាច់ដោយឡែកពីគ្នា សំរាប់អថេរទាំងនេះមានលក្ខណៈជាគុណភាពជាជាងបរិមាណ ។ នេះត្រូវបានចាត់ទុកថា ជារង្វាស់ក្នុងកំរិតទាបជាងគេ ពីព្រោះការកំណត់បរិមាណរបស់វា គឺគ្រាន់តែបែងចែក ចំណាត់ថ្នាក់តាមក្រុម/ពួកតែប៉ុណ្ណោះ តែគេមិនអាចយកវាទៅប្រើសំរាប់គណនា បូក ឬដកបានទេ ។

២. រង្វាស់លំដាប់លេខរៀង (Ordinal Measure)ៈ គឺជាអថេរដែលអ្នកស្រាវជ្រាវរៀបតាមលំដាប់លំដោយសមស្រប ។ ទាំងនេះគឺជារង្វាស់ដែលធ្វើឱ្យយើងអាចនិយាយថា បុគ្គលម្នាក់មានធាតុអ្វីមួយ ច្រើនឬតិចជាងបុគ្គលម្នាក់ទៀត តែវាមិនបង្ហាញពីទំហំនៃចំណុចខុសគ្នារវាងបុគ្គលទេ ។ រង្វាស់តាមលំដាប់លេខរៀង គឺជាការប្រមូលផ្តុំនូវប្រភេទអ្វីមួយដែលមាន

លំដាប់លំដោយ តែបញ្ជាក់ពីកំរិតគុណភាព (ឧទាហរណ៍ ទីមួយ ទីពីរ ទីបី) ។ ឧទាហរណ៍ វណ្ណៈសង្គម ទីតាំងនៅលើឋានៈ ដែលវាស់តាមកំរិតគិរិយាបទ (ឧទាហរណ៍ មានកង្វល់ខ្លាំងបំផុត មានកង្វល់ខ្លាំង មានកង្វល់ខ្លះ ។ល ។) ការបែងចែក ទៅតាមកំរិតវប្បធម៌ (ឧទាហរណ៍ ពីអ្នកមានកំរិតវប្បធម៌ខ្ពស់បំផុតរហូតដល់អ្នកមានកំរិតវប្បធម៌ទាបបំផុត) ភាពខុសគ្នារវាងកំពស់ (ពីទាបជាងគេទៅដល់ខ្ពស់ជាងគេ) ។ល ។

៣ រង្វាស់*គិតតាមចន្លោះ* (Interval measure): សំដៅលើអថេរដែលក្នុងនោះ តំលៃគិតតាមលេខមានគម្លាតស្មើគ្នា ហើយមានន័យរបស់វា ។ សំរាប់រង្វាស់ប្រភេទនេះ គេកំណត់លេខលើវត្ថុ ឬហេតុការណ៍ដែលគេអាចបែងចែក រៀបលំដាប់ ហើយគេសន្មត់ថា មានចំងាយស្មើគ្នារវាងតំលៃនៅលើរង្វាស់ ។ ឧទាហរណ៍មួយចំណូលគិតជា ដុល្លារ ដែលក្នុងនោះបើមានចំណូល ១.000 ដុល្លារអាចអោយគេយល់ភ្លាម ។ លើសពីនេះទៀត គម្លាតរវាងអ្នកដែលមានចំណូល ១.000 ដុល្លារ និងអ្នកដែលមានចំណូល ១.00១ ដុល្លារ (គឺគម្លាតតែ ១ ដុល្លារ) គឺស្មើនឹងគម្លាររវាងអ្នកដែលមានចំណូល ៥៦៥ ដុល្លារ និងអ្នកដែលមានចំណូល ៥៦៦ ដុល្លារដែរ (នោះគឺគម្លាតតែ១ ដុល្លារ) ។ តំលៃនៃរង្វាស់ជាចន្លោះអាចមានសូន្យ តែការកំណត់នេះអាចអោយគេពិភាក្សាគ្នាបាន ហើយគេអាចបូក ឬដកបានដែរ ប៉ុន្តែមិនអាចគុណ ឬចែកបានទេ ។ តំលៃក៏ត្រូវបានគេប្រៀបធៀបគ្នាបានផងដែរ មិនត្រឹមតែមួយណាធំជាង ឬតូចជាង ឬមួយណាក្មេងជាង ឬចាស់ជាង ។ល ។ ប៉ុណ្ណោះនោះទេ តែក៏គិតទៅដល់កំរិតធំជាងប៉ុនណា ឬចាស់ជាងប៉ុនណាផងដែរ ។ ទាំងនេះក៏គេអាចបង្វែរអោយទៅជារង្វាស់លំដាប់ទាបដូចគ្នាទៅនឹងរង្វាស់ជាសញ្ញាសំគាល់ ឬរង្វាស់តាមលំដាប់លេខរៀងបានតែអត្ថន័យត្រូវបាត់អស់នៅពេលគេធ្វើដូច្នេះ ។

៤ រង្វាស់*ជារង្វាស់ផលធៀប* (Ratio measure) សំដៅលើអថេរដែលនៅក្នុងនោះតំលៃ/លេខដែលគេកំណត់សំរាប់វត្ថុអ្វីមួយ អាចត្រូវបានគេបែងចែករៀបតាមលំដាប់ ឬសន្មត់ថាមានចន្លោះស្មើគ្នារវាងចំណុចទាំងឡាយនៅលើរង្វាស់ ។ មានតែនៅក្នុងរង្វាស់ផលធៀបនេះទេ ទើបគេអាចនិយាយសំដៅលើខ្លឹមសារទាក់ទងនឹងសមាមាត្របាន ឬដែលអ្វីមួយច្រើនជាងពីរដង ឬតូចជាងបីភាគបួន ។ រង្វាស់នេះមានចំណុចដូចគ្នាទៅនឹងរវាងរង្វាស់គិតតាមចន្លោះច្រើន តែអ្វីដែលប្លែកញពីគេនោះគឺថា វាមានចំណុចសូន្យពិតប្រាកដដែលមិនអាចប្រកែកបាន ។ ឧទាហរណ៍ នៃរង្វាស់នេះគឺអាយុ រយៈពេលស្នាក់នៅកន្លែងណាមួយ ចំនួនអង្គការដែលចូលជាសមាជិក ចំនួនពេលទៅវត្តនៅថ្ងៃបុណ្យ ចំនួនដងនៃការរៀបអាពាហ៍ពិពាហ៍ ចំនួនមិត្តភក្តិដែលជាជនជាតិចាម ។ល ។

មានអថេរពីរដែលត្រូវបានគេប្រើ សំរាប់យោងទៅរកទិន្នន័យបែបបរិមាណ គឺអថេរ*ដាច់* និងអថេរ*ជាប់* ។ ***អថេរដាច់ៗ*** មានកន្សោមតំលៃដែលគេអាចរាប់បាន ។ ឧទាហរណ៍ ចំនួនកូននៅក្នុងគ្រួសារ ចំនួនប្រជាជននៅក្នុងភូមិ ចំនួនដងនៃការទៅពិនិត្យសុខភាពនៅមណ្ឌលសុខភាពក្នុងមួយឆ្នាំ ។ល ។ តែគេគួរកត់ចំណាំថា សំរាប់អថេរបែបនេះ ឯកតាជាមូលដ្ឋាននៃការវាស់វែងមិនអាចត្រូវបំបែកអោយទៅជាផ្នែកតូចតទៅទៀតទេ ។ ឧទាហរណ៍ គេមិនអាចនិយាយថា បុរស/ស្ត្រីម្នាក់មានកូន ២,៥ ទេ ។ ផ្ទុយទៅវិញ ***អថេរជាប់*** គឺជា អថេរដែលមានលក្ខណៈ ជាតំលៃតជាប់គ្នា ។ ឧទាហរណ៍ កំពស់ ទំងន់ អាយុ រយៈពេលសំរាប់អានសៀវភៅមួយក្បាល ។ល ។ ជាមួយនឹងអថេរជាប់ តែងតែមានតំលៃមួយទៀតនៅចន្លោះតំលៃពីរ ។

កំរិតលំដាប់នៃរង្វាស់រង្វាល់ គឺគេគួរដឹងពីព្រោះវាធ្វើឱ្យអ្នកស្រាវជ្រាវកំណត់ប្រភេទនៃទិន្នន័យដែលគាត់ប្រមូល ហើយកំណត់ទៅលើប្រភេទនៃការវិភាគរបស់គាត់ ។ ឧទាហរណ៍ បើក្នុងគ្រាដំបូង អ្នកស្រាវជ្រាវប្រមូលទិន្នន័យស្តីពី អាយុ ឬប្រាក់ចំណូលដែលត្រូវបានគេកំណត់ចំណាត់ក្រុមហើយ (ពោលគឺ តាមរង្វាស់លំដាប់លេខរៀង) នោះពត៌មានដែលបានមក មិនធ្វើឱ្យគាត់ដឹងពី

ចំណូលជាមធ្យម ឬអាយុជាមធ្យមឡើយ (ពីព្រោះ ទិន្នន័យតាមរង្វាស់លំដាប់លេខរៀង *មិនអាច*ឱ្យគេបង្វែរទៅជារង្វាស់បែបផលធៀប ឬរង្វាស់គិតតាមចន្លោះទេ) ។ ដូច្នេះ វាជាឧបសគ្គធ្វើមិនប្រាកដប្រជាសំរាប់ការវិភាគ និងជាឧបសគ្គដល់ការធ្វើការកំណត់លក្ខណៈរបស់បុគ្គល ឬប្រជាជនដែលកំពុងត្រូវបានសិក្សា។ ការយល់ពីកំរិតនៃរង្វាស់ថែមទាំងធ្វើឱ្យគេអាចដឹងថាគេមិនអាចគិតចេញជាចំនួនមធ្យមនៃយេនឌ័រ ឬចំនួនមធ្យមនៃការចូលសាសនាទេ។ តាមពិតទៅ ការដឹងពីគុណភាពនៃទិន្នន័យដែលយើងប្រមូល ថែមទាំងផ្តល់លទ្ធភាពទាក់ទងនឹងស្ថិតិបែបរៀបរាប់ដែលយើងប្រើនៅក្នុងការវិភាគទិន្នន័យដែរ ។

**រូបទី ៣ កំរិតនៃការវាស់វែង**

**ឧទាហរណ៍ រង្វាស់ជាសញ្ញាសំគាល់ : ភេទ**



**ស្ត្រី** **បុរស**

**ឧទាហរណ៍ រង្វាស់លំដាប់លេខរៀងៈ ភាពជឿជាក់លើសាសនា" តើអ្នកគិតថាសាសនាមានសារៈសំខាន់ដូចម្តេច? "**



**ឧទាហរណ៍ រង្វាស់គិតតាមចន្លោះ : IQ**




**ឧទាហរណ៍ រង្វាស់ជាផលធៀប: ចំនូល**




[a/] Adapted from Babbie, 1998:143

**កំរិត និង ទំហំ/ជ្រុងនៃការវិភាគ** (Levels and Dimensions of Analysis)

គេថែមទាំងអាចពិនិត្យទិន្នន័យទៅតាមលំដាប់ និងទំហំនៃការវិភាគ ។ ការវិភាគលើទិន្នន័យអាចមាន នៅកំរិតមីក្រូ ឬម៉ាក្រូ ។ មនុស្សម្នាក់កំពុងតែវិភាគទិន្នន័យកំរិត *ម៉ាក្រូ* នៅពេលដែលបណ្តុំ ឬចំនួនបូកបញ្ចូលគ្នានៃផ្នែកមួយៗ ដូចជាទីក្រុង ខេត្ត ឬជាតិ ក្លាយទៅជាឯកតានៃការវិភាគ ។ ការវិភាគទិន្នន័យកើតមាននៅកំរិត *មីក្រូ* នៅពេលដែលបុគ្គល គ្រួសារ ឬសង្កាត់ក្បែរខាង ។ល ។ ធ្វើជាឯកតានៃការវិភាគ ។ មិនមាននិយមន័យឱ្យប្រាកដដាច់ ណាត់ទេ ហើយគេអាចសំរេចវិភាគលំដាប់នៃការវិភាគរវាងកំរិតមីក្រូ និងកំរិតម៉ាក្រូ (Lewis-Beck, 2004:563) ។

ទំហំនៃការវិភាគមិនមែនជាទស្សនៈងាយយល់ទេ ។ តាមពិតទៅ វាបង្ហាញថាទិន្នន័យអាចប្រាប់ពីកង្វល់ ឬគុណភាពដែលគេអាចចាត់ចូលក្នុងជំពូកផ្នែកសង្គមវប្បធម៌ ច្បាប់និងនយោបាយ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ល ។ ការផ្តុំទិន្នន័យជាក្រុមៗបែបនេះច្រើនជារឿងទាក់ទងនឹងបរិបទដែលអាចផ្តល់ហេតុផលស្តីពីមូលហេតុដែលមនុស្សមានការយល់ឃើញបែបណាមួយ ឬមូលហេតុដែលគេប្រព្រឹត្តិបែបណាៗនោះ ។ ដោយត្រូវបានលើកឡើងតាមក្របខ័ណ្ឌរបស់ ADI នៅក្នុងសៀវភៅនេះដែលបោះពុម្ពនៅលើកទីមួយ បំណងគឺចង់ឱ្យអ្នកស្រាវជ្រាវចាំជានិច្ចនូវតួអង្គ និងកត្តាជាច្រើនដែលមានឥទ្ធិពលលើស្ថានភាពមួយក្នុងរូបភាពជាច្រើន និងតាមលំដាប់ថ្នាក់ផ្សេងៗនៃសង្គម ។ ប៉ុន្តែ ការលើកបញ្ហាឬវិភាគទិន្នន័យទាក់ទងនឹងកង្វល់ទាំងនេះ គួរចាប់ផ្តើមពីសំណួរ

ស្រាវជ្រាវ ឬរបៀបវារៈរបស់អ្នកស្រាវជ្រាវ ។ ឧបសម្ព័ន្ធ ៣ ផ្តល់សេចក្តីរៀបរាប់ត្រួស១ពីទំហំផ្សេង១នៃការវិភាគ ដូចមានបង្ហាញក្នុងតារាង ទី ៤ ។

**តារាងទី ៤. លំដាប់ និងទំហំនៃការវិភាគ**

| លំដាប់ថ្នាក់ ឯកតានៃការវិភាគ. | ទំហំ/ជ្រុងនៃការវិភាគ | | | | | |
|---|---|---|---|---|---|---|
| | សង្គម-វប្បធម៌ | នយោបាយ-ច្បាប់ | សេដ្ឋកិច្ច-ហិរញ្ញវត្ថុ | បច្ចេកទេស | ហេដ្ឋារចនាសម្ព័ន្ធ | បរិស្ថាន |
| ម៉ាក្រូ | | | | | | |
| ចំរុះជាតិ/តំបន់ | | | | | | |
| ថ្នាក់ជាតិ/តាមបណ្តា ប្រទេស | | | | | | |
| ថ្នាក់តំបន់ ( នៅ លំដាប់ថ្នាក់ប្រទេស | | | | | | |
| មីក្រូ | | | | | | |
| បុគ្គល | | | | | | |
| គ្រួសារ | | | | | | |
| សង្កាត់/ក្រុម | | | | | | |
| អង្គការ/សមាគមន៍/ក្រុម | | | | | | |
| សកម្មភាពសង្គម/ការប្រតិបត្តិក្នុងសង្គម ។ល។ | | | | | | |

a/លំដាប់មីសូ គឺ មេសូ (Meso) ត្រូវបានប្រើនៅក្នុងការវិភាគទៅលើបញ្ហា/កម្មវិធី ។ល។ ។ តាមធម្មតា មេសូ ផ្តោតលើលំដាប់ដែលធ្លាក់ចន្លោះលំដាប់ ម៉ាក្រូ និងមីក្រូ ដូចជាលក្ខណៈរបស់តំបន់ដែលមានការប៉ះពាល់ដល់លំដាប់មីក្រូ និងម៉ាក្រូ ។

## កំណត់រកប្រភពពត៌មាន

បន្ទាប់ពីកំណត់នូវពត៌មានដែលត្រូវការហើយ គេអាចត្រឡប់ទៅរកមើលប្រភពពត៌មាន ក្រៅពីឯកតាវិភាគដែលត្រូវបានកំណត់ ។ តើអ្នកណាមានចំលើយ ហើយតើអ្នករកគេឃើញដោយរបៀបណា? តើអ្នកត្រូវការធ្វើសំភាសន៍បុគ្គល/អ្នកផ្តល់ពត៌មានសំខាន់១ ឬក៏ការពិភាក្សាជាក្រុម?តើអ្នកណាជាបុគ្គល/អ្នកផ្តល់ពត៌មានសំខាន់១ទាំងនេះ និងតើនរណាខ្លះគួរចូលរួមនៅក្នុងក្រុមពិភាក្សា? តើប្រភពឬឯកសារបន្ទាប់បន្សំណាខ្លះដែលផ្តល់ទិន្នន័យ ហើយជួយកាត់បន្ថយពេលវេលាដែលចំណាយលើការសំភាសន៍? តើឯកសារបន្ទាប់បន្សំណាខ្លះដែលត្រូវមើល? តែអ្នកណាមានវាហើយមាននៅឯណា? តើភស្តុតាងអ្វីខ្លះទៀតដែលអ្នកត្រូវប្រមូលដើម្បីយល់បានពីស្ថានភាពពិត? តើអ្នកពាក់ព័ន្ធនិងអ្នកមិនពាក់ព័ន្ធណាខ្លះដែលត្រូវសំភាសន៍ ដើម្បីអ្នកអាចមានទស្សនៈដែលប្រកបដោយតុល្យភាព?

ការកំណត់ប្រភពពត៌មានមានការទាក់ទងនឹងវិធីប្រមូលទិន្នន័យ ។ ការកំណត់ប្រភពពត៌មានត្រូវទាក់ទងនឹងអ្វី និងអ្នកដែលផ្តល់ពត៌មានដែលគួរឱ្យទុកចិត្តបានជាងគេសំរាប់បំពេញតំរូវការពត៌មានដូចដែលត្រូវបានកំណត់មក ( សូមមើលផ្នែកដោយឡែកមួយស្តីពីភាពអាចទុកចិត្តបាន និងសុពលភាព) ។ ប្រភពពត៌មានខ្លះរួមមាន :

១. ឯកសារដែលមាននៅក្នុងបណ្ណាល័យ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងការិយាល័យរដ្ឋ ។
២. របាយការណ៍ ឬការអង្កេតទាក់ទងនឹងប្រធានបទ
៣. សមាជិកសហគមន៍/អ្នកមនុស្សមិនមែនជាសមាជិកសហគមន៍ (សំណាក)
៤. អ្នកដឹកនាំតាមផ្លូវការ/មិនតាមផ្លូវការ (ឧទាហរណ៍ គ្រូពេទ្យបូរាណ លោកសង្ឃ) នៅក្នុងសហគមន៍ សមាជិកចាស់ៗនៅក្នុងសហគមន៍ ។
៥. បុគ្គលិកអង្គការអន្តរជាតិ/អង្គការមិនមែនរដ្ឋាភិបាល សមាជិកអង្គការនៅតាមសហគមន៍
៦. តំណាងរបស់អាជ្ញាធរមូលដ្ឋានឬអាជ្ញាធរខេត្ត មន្ត្រីរដ្ឋាភិបាលនៅថ្នាក់ជាតិ



វិធីប្រមូលពត៌មានពីប្រភពខាងលើនេះ រួមមានការងារឯកសារ ការសំភាសន៍បុគ្គលការពិភាក្សាជាក្រុម ការសង្កេត ការនាំគ្នារិះរកគំនិត ការផ្ញើកំរងសំណួរ ការសន្ទនាក្រៅផ្លូវការ ករណីសិក្សាជាដើម (តារាងទី ៥) ។ ក្នុងរយៈពេល ១៥ ឆ្នាំចុងក្រោយនេះ វិធីប្រមូលទិន្នន័យរួមមានផងដែរ នូវវិធីដែលគេប្រើនៅក្នុងវិធីរៀនសូត្រ និងធ្វើសកម្មភាពដោយមានការចូលរួម (PLA) ។ ឧបសម្ព័ន្ធ ៤ មានសេចក្តីរៀបរាប់សង្ខេបលើបច្ចេកទេស និងឧបករណ៍មួយចំនួនដែលគេប្រើនៅក្នុងវិធីនេះ ដែលមានប្រយោជន៍ផងដែរនៅក្នុងដំណាក់កាលជាគន្លឹះនៃវដ្តរបស់កម្មវិធី/គំរោង ។ គេគួរកត់ចំណាំផងដែរថា អ្នកស្រាវជ្រាវអាចប្រើវិធីសាស្ត្រផ្សេងៗ បូកបញ្ចូលគ្នាដើម្បីប្រមូលទិន្នន័យដែលគេត្រូវការដើម្បីប្រមូលបានពត៌មានពីជ្រុងផ្សេងៗ និង/ឬដើម្បីផ្ទៀងផ្ទាត់ពត៌មាន ដែលប្រមូលបានពីប្រភពឯទៀត ។ ការប្រើវិធីច្រើនយ៉ាងនេះ ជាផ្លូវមួយដើម្បីសំរេចបានលទ្ធផលដែលបានការនិងគួរឱ្យទុកចិត្តបាន ។

## យល់ដឹងបញ្ហានៃភាពគួរឱ្យទុកចិត្តបាន និងសុពលភាព

ភាពអាចទុកចិត្តបាន និងសុពលភាពគឺជាគំនិតពីរនៅក្នុងការស្រាវជ្រាវផ្នែកសង្គម ដើម្បីធ្វើឱ្យទិន្នន័យដែលគេប្រមូលមកនោះមានគេជឿជាក់ ។ គំនិតទាំងពីរនេះទាក់ទងនឹងភាពច្បាស់លាស់ និងត្រឹមត្រូវនៃពត៌មាន ដែលប្រមូលបានមកដោយការប្រើឧបករណ៍ប្រមូលទិន្នន័យ ។

*ភាពអាចទុកចិត្តបាន*ទាក់ទងនឹងភាពស៊ីគ្នា ភាពអាចពឹងពាក់លើបាន ឬភាពសុក្រិត្យនៃឧបករណ៍ប្រមូលទិន្នន័យ ។ ការនេះមានន័យថា សំណួរនៅក្នុងឧបករណ៍ប្រមូលទិន្នន័យ នាំឱ្យមានចំលើយដែលមានភាពស៊ីគ្នា និង/ឬដូចគ្នា នៅពេលដែលគេសួរទៅអ្នកផ្តល់ចំលើយផ្សេងទៀត ហើយផ្តល់ភស្តុតាងដែលគេអាចទុកចិត្តបានទៅលើបញ្ហាដែលកំពុងត្រូវបានពិនិត្យ ។ ឧទាហរណ៍ នៅពេលដែលអ្នកស្រាវជ្រាវផ្នែកសង្គមនិយាយថា គាត់នឹងរៀបរាប់ពីសិទ្ធិទទួលបានដីធ្លីរបស់គ្រួសារនៅក្នុងកន្លែងស្រាវជ្រាវណាមួយ សំណួនៅក្នុងឧបករណ៍ប្រមូលទិន្នន័យគួរមានន័យដូចគ្នាសំរាប់អ្នកផ្តល់ចំលើយហើយធ្វើឱ្យគេផ្តល់ចំលើយដូចគ្នា ។ បើអ្នកផ្តល់ចំលើយពីរនាក់ យល់ថា សំណួរមួយឬពីរមានន័យខុសគ្នា នោះចំលើយរបស់គេ នឹងខុសគ្នា ហើយការនេះបង្ហាញថាឧបករណ៍មានបញ្ហា ដែលគេពិបាកទុកចិត្តបាន ។ ក្រៅពីនេះ ឧបករណ៍ត្រូវតែ*នាំឱ្យមានចំលើយដូចគ្នា* ពីអ្នកផ្តល់ចំលើយនៅក្នុងសំណាកទាំងមូល នៅពេលគេធ្វើការសំភាសន៍ពីរទៅបីលើកនៅក្នុងចំណោមអ្នកផ្តល់ចំលើយដដែលនោះ ។ រឿងធំដែលគេត្រូវគិតនៅក្នុងការកំណត់ភាពអាចទុកចិត្តបាននៃចំលើយគឺ ត្រូវសួរតែអំពីអ្វីដែលអ្នកផ្តល់ចំលើយដឹង ឬអ្វីដែលទាក់ទងនឹងខ្លួនគេ ។ បើអ្នកផ្តល់ចំលើយមិនបានឆ្លើយអ្វីដែលមានការទាក់ទង ឬចំលើយមិនសមស្របទៅនឹងសំណួររបស់យើងដើម្បីចង់ដឹងពីសិទ្ធិទទួលបានដីធ្លីរបស់គ្រួសារនោះ យើងប្រហែលជាបានជ្រើសរើសឧបករណ៍មិនត្រូវដើម្បីចង់ដឹងពីសិទ្ធិរបស់គេនោះ (ពោលគឺ វិធីបែបគុណភាពប្រហែលអាចសមស្របជាងការអង្កេត) ឬប្រហែលគាត់តែងសំណួរដែលអ្នកឆ្លើយអាចត្រឹមតែឆ្លើយថា "មិនដឹង" ឬផ្តល់ចំលើយដែលមិនមានការទាក់ទង ។ ទាក់ទងនឹងបញ្ហាដែលទាមទារឱ្យមានចំលើយបែបគុណភាព (ឧទាហរណ៍អំពើហឹង្សានៅក្នុងគ្រួសារ

ការមាក់ងាយ ចំពោះអ្នកមានជំងឺអេដស៍) គេអាចធានាបានច្រើននូវភាពអាចទុកចិត្តបាន បើសិនជាអ្នកស្រាវជ្រាវស្វែងរកប្រភពពត៌មានច្រើន ឬមានវិធីច្រើននៅក្នុងការប្រមូលទិន្នន័យ (Babbie, 1998:131; Mason, 1996:24) ។

សុពលភាព (Validity) ពាក់ព័ន្ធទៅនឹងភាពអាចទុកចិត្តបាន ពីព្រោះវាសុទ្ធតែស្តីពីឧបករណ៍ប្រមូលទិន្នន័យ ដែលយកទៅវាស់នូវអ្វីដែលគេត្រូវវាស់ ។ នេះមានន័យសំដៅលើភាពសមស្របភាពមានន័យ និងភាពមានប្រយោជន៍ នៃក្នុងការអោយអត្ថន័យអ្វីមួយយោងតាមទិន្នន័យរបស់យើង ។ ការនេះច្រើនតែទាក់ទងនឹងការបំបែកទស្សនៈរួមអោយទៅជាជាក់លាក់ (operationalisation) ដូចជាទាក់ទងនឹងការដែលសួរអំពីសិទ្ធិទទួលបានដីធ្លី មានការទាក់ទងនឹងសំណួរមួយចំនួនដែលលំអិតថា តើសិទ្ធិច្រើនប៉ុនណាដែលត្រូវបានគេកំណត់ ឬសង្កេតឃើញ (ឧ. តើវាគ្រាន់តែទាក់ទងត្រឹមតែកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ជាទូទៅទាក់ទងនឹងដីដែលកំពុងត្រូវបានប្រើឬ? តើវាទាក់ទងនឹងការដឹងពីទំហំ ឬប្រភេទដីដែលកំពុងត្រូវបានប្រើឬ? ។ល។) ដោយហេតុនេះ អ្នកស្រាវជ្រាវត្រូវគិតមើលថា តើវិធី ឬប្រភពទិន្នន័យណាមួយអាចបំភ្លឺដល់ទស្សនៈរបស់គាត់បានល្អប៉ុនណា (Mason, 1996:24) ។

តាមធម្មតា អ្នកស្រាវជ្រាវផ្នែកសង្គម សំដៅរកឧបករណ៍ប្រមូលទិន្នន័យដែលអាចទុកចិត្តបាន និងអាចមានសុពលភាព ដើម្បីធានាថា ទិន្នន័យរបស់គេមានគុណភាពនិងមានប្រយោជន៍ ។ ដើម្បីទៅគោលបំណងខាងលើនេះ ការប្រើប្រាស់វិធីចំរុះ ជាមូលដ្ឋានគ្រឹះសំខាន់ ។

**តារាងទី ៩. វិធីប្រមូលទិន្នន័យខ្លះដែលគេនិយមប្រើនៅក្នុងការស្រាវជ្រាវផ្នែកសង្គម**

| វិធីសាស្រ្ត | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| ១. ការពិនិត្យឯកសារ | • អាចរកបានតាមឯកសារបោះពុម្ព ឬតាមទិន្នសិ កាសែតវីដេអូ<br>• មានការប្រាប់ពីប្រវត្តិ និងទិន្នន័យស្ថិតិស្តីពីបញ្ហាដែលកំពុងត្រូវបានពិនិត្យ<br>• អាចបន្ថយបញ្ហារបស់អ្នកឆ្លើយទាក់ទងនិងការរំលឹកពីព្រឹត្តិការណ៍ | • ពេលខ្លះពិបាករកដោយសារភាពសំងាត់ដែលអង្គការត្រូវរក្សាឬការសំងាត់ជាផ្លូវការ (ឧទាហរណ៍ ឯកសារខ្លះរបស់រដ្ឋ)<br>• ត្រូវការពិនិត្យភាពត្រឹមត្រូវ ឬភាពពិតនៃឯកសារ ។ |
| ២. ការសំភាសជាបុគ្គល (ការសំភាសន៍ជាផ្លូវការ. ពាក់កណ្តាលផ្លូវការ) | • អាចប្រើជាមួយនឹងអ្នកចេះនិងអ្នកមិនចេះអក្សរ<br>• ធ្វើឱ្យអ្នកសំភាសន៍អាចប្រមូលពតិមានបានពេញលេញ<br>• ប្រមូលបានពតិមានប្លែកៗ<br>• អាចបត់បែនបាន — អាចសំរបទៅតាមភាពខុសគ្នារបស់បុគ្គល<br>• ផ្តល់ឱកាសឱ្យគេអាចសួរស្ទាបស្ទង់/បំភ្លឺចំលើយដែលមិនច្បាស់ឬត្រូវបានយល់ខុស<br>• អនុញ្ញាតិឱ្យមានការប្រមូលទិន្នន័យដោយប្រើវិធីច្រើនបែប – ដោយរួមទាំងការសង្កេត ការប្រើរូបភាព វីកាយវិការសំរាប់អ្នកមិនសូវចេះអក្សរ<br>• អាចកសាងនូវភាពជិតស្និទ្ធ និងការទុកចិត្តគ្នា ។ | • អាចមានការលំអៀងនៅក្នុងការជ្រើសរើសសំណួរ<br>• ត្រូវការថវិកា និងពេលវេលា<br>• ត្រូវការជំនាញនៅក្នុងការសំភាសន៍<br>• អាចធ្វើតែជាមួយនឹងអ្នកផ្តល់ចំលើយក្នុងចំនួនតិចក្នុងមួយថ្ងៃ<br>• អ្នកផ្តល់ចំលើយអាចឆ្លើយនូវអ្វីដែលអ្នកសំភាសន៍ចង់បាន<br>• អ្នកផ្តល់ចំលើយមិនអាចលាក់ឈ្មោះបានទេ ។ |
| ៣. ការពិភាក្សាក្រុមតូច | • បណ្តុះឱ្យមានស្មារតីក្រុមនៅពេលគេលើកឡើងពីកង្វល់រួម<br>• មានការនិយាយឆ្លើយឆ្លងទៅមក<br>• ផ្តល់ពេលឱ្យមានការពិភាក្សាស៊ីជំរៅ និងការសួរបញ្ជាក់ចំលើយដែលមិនច្បាស់<br>• អនុញ្ញាតិឱ្យមានការបញ្ចេញប្រតិកម្មទៅតាមការគិតឃើញ និងការប្រើប្រាជ្ញា ។ | • មិនមានការលាក់ការសំងាត់បានទេ<br>• បានលទ្ធផលល្អណាស់ បើសិនជាសមាជិកក្រុមទុកចិត្តគ្នា<br>• អាចនិយាយចាកប្រធាន បើមិនមានអ្នកសំរបសំរួលដែលមានជំនាញទេ<br>• ពិបាកតាមដាន ចំណើនរឿងនិយាយអ្វី<br>• ក្រុមឬបុគ្គលដែលគ្របលើគេអាចមានឱកាសបង្ខំឱ្យមានការ ទទួលយកគំណុចឬរបៀបវារៈណាមួយហើយអាចបង្កើតអោយ មានភាពតានតឹងនឹងគ្នា ។ |

២ ជំហាន

| វិធីសាស្ត្រ | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| ៤. ការសង្កេត | • អាចក្តាប់ពីកាយវិការ រូបរាង ។ល។<br>• អាចស្វែងយល់ការប្រាស្រ័យគ្នា<br>• មានភាពអាចបត់បែនបាន<br>• អាចប្រមូលទិន្នន័យប្លែកៗបាន<br>• មានលក្ខណៈអាចឱ្យគេឃើញរូបភាពរួម (Holistic) ។ | • ទៅតាមការយល់ឃើញ (Subjective)<br>• ត្រូវការពេលវេលា និងចំណាយប្រាក់ច្រើន<br>• ត្រូវការជំនាញ<br>• មិនអាចឱ្យគេដឹងពីអ្វីដែលគេកំពុងគិត<br>• អាចធ្វើបានតែចំពោះអ្នកផ្តល់ចំលើយក្នុងចំនួនតិចតួច<br>• វត្តមានរបស់អ្នកសង្កេតពីខាងក្រៅអាចធ្វើឱ្យអ្នកផ្តល់ចំលើយប្តូរអាកប្បកិរិយា<br>• ពិបាកស្រង់ពត៌មានពីហេតុការណ៍ដែលកើតឡើងនៅពេលជំណាលគ្នានោះ ។ |
| ៥. ការនាំគ្នាបំផុសគំនិត (Brainstorming) | • ធ្វើឱ្យអ្នកឆ្លើយអាចនិយាយចេញមកតាមចិត្តរបស់គេ<br>• ផ្តល់ចំលើយឆ្លើយតប/លទ្ធផលភ្លាមៗ<br>• មនុស្សមួយក្រុមប្រមូលពត៌មានបានក្នុងរយៈពេលខ្លី<br>• ផ្តល់ឱកាសបានស្តាប់ទស្សនៈរបស់អ្នកផ្សេងទៀត<br>• ស្រួលរៀបចំ ។ | • សមាជិកដែលស្ងៀមមិនសូវហ៊ាននិយាយ<br>• មិនអាចឱ្យគេដឹងបានថាតើយោបល់មួយតំណាងឱ្យមនុស្សចំនួនប៉ុន្មាននាក់<br>• មិនអាចរក្សាភាពអនាមិកបានទេ<br>• យោបល់ដែលលើកឡើងអាចមិនមានការបញ្ជាក់ដល់ពិតអោយដឹង<br>• ត្រូវការឯកទេស និងការបណ្តុះបណ្តាលលើការសំរបសំរួល ។ |
| ៦. កំរងសំណួរដែលត្រូវបានផ្ញើតាមប៉ុស្តិ៍ | • បានដល់អ្នកឆ្លើយច្រើនក្នុងរយៈពេលយ៉ាងខ្លី<br>• មិនចំណាយអស់សោហ៊ុយច្រើន<br>• អ្នកឆ្លើយមិនបាច់ប្រាប់ឈ្មោះក៏បាន<br>• ផ្តល់ឱកាសអ្នកផ្តល់ចំលើយឆ្លើយដោយមិនមានការខ្លាចរអែង<br>• ទិន្នន័យដែលស្រង់បានអាចសង្ខេបបានយ៉ាងងាយ<br>• អាចកែប្រែយ៉ាងស្រួលពីកម្មវិធីមួយទៅកម្មវិធី ។ | • ពិបាករៀបសំណួរដើម្បីកុំឱ្យមានការប៉ះពាល់ផ្នែកចិត្តសាស្ត្រ<br>• អ្នកផ្តល់ចំលើយប្រហែលមិនយកចិត្តទុកដាក់ច្រើនលើកំរងសំណួរ<br>• មិនសមស្របសំរាប់អ្នកមិនចេះអក្សរ<br>• ត្រូវរង់ចាំយូរដើម្បីទទួលកំរងសំណួរដែលផ្ញើត្រឡប់វិញ<br>• ពិបាកឆ្លើយសំណួរដែលមានភាពស្មុគស្មាញ<br>• អាចមានអត្រាការឆ្លើយសំនួរទាប ។ |

ប្រភព: Lewis-Beck, 2004; Gajanayake, S. J. និង Gajanayake. 1993:26:27

**វិធីចំរុះ** (Triangulation)

វិធីចំរុះសំដៅលើ "ការប្រើវិធីលើសពីមួយនៅក្នុងការពិនិត្យលើសំណួរស្រាវជ្រាវ ដើម្បីធានាឱ្យមានការទុកចិត្តច្រើនលើលទ្ធផលរកឃើញ" (Lewis-Beck et al, 2004:1142) ។ អ្នកស្រាវជ្រាវប្រើទំរង់ការនេះ ពីព្រោះការពឹងតែទៅលើវិធី ឬប្រភពតែមួយ អាចធ្វើឱ្យលទ្ធផលរកឃើញនោះ មានភាពលំអៀង ឬប្រាស់ចាកការពិត ។

វិធីចំរុះមានច្រើនបែប (Lewis-Beck et al, 2004:1142; Neuman, 2000:124-125) ដូចជា :

១. វិធីចំរុះនៃទិន្នន័យដែលក្នុងនេះ គេត្រូវការវាស់វែងច្រើនបែបយ៉ាងទៅលើបញ្ហា ព្រឹត្តិការណ៍ ឬបាតុភូត តែមួយដដែល ដើម្បីឱ្យអ្នកស្រាវជ្រាវអាចពិនិត្យមើលទិដ្ឋភាពខុស១គ្នារបស់វា ។

២. វិធីចំរុះនៃអ្នកសង្កេត សំដៅលើការប្រើអ្នកស្រាវជ្រាវលើសពីម្នាក់ ដើម្បីប្រមូលនិងបកស្រាយទិន្នន័យ ។

៣. វិធីចំរុះជាលក្ខណៈទ្រឹស្តី សំដៅទៅរកជាទ្រឹស្តីលើសពីមួយនៅក្នុងការបកស្រាយទិន្នន័យ ។

៤. វិធីចំរុះនៃវិធីសាស្ត្រស្រាវជ្រាវ សំដៅទៅរកការប្រើវិធីលើសពីមួយ ឬការបូកបញ្ចូលគ្នានូវវិធីច្រើន (ឧទាហរណ៍ ឧបករណ៍បែបបរិមាណ និងគុណភាព) សំរាប់ប្រមូលទិន្នន័យ ។ ការប្រើបែបនេះអាចធ្វើឡើងជាបន្តបន្ទាប់គ្នា ឬក្នុងពេលជាមួយគ្នាក៏បាន ។

**រូបទី ៤. ការពន្យល់បង្ហាញតាមវិធីចំរុះ** (Triangulation)



## វិធីជ្រើសរើសសំណាក និងទំហំសំណាក

ចំណុចសំខាន់មួយដែលគេត្រូវពិចារណានៅក្នុងការរៀបចំការសិក្សា គឺត្រូវកំណត់វិធីជ្រើសរើស និងចំនួនមនុស្សដែលត្រូវសំភាសន៍នៅក្នុងការសិក្សា ។ ត្រូវចាំថា សំណួរស្រាវជ្រាវកំណត់លើទំរង់ការដែលអ្នកស្រាវជ្រាវ ភ្ជាប់ប្រធានបទនិងសំណួរស្រាវជ្រាវរបស់គាត់ទៅនឹងវិធីដែលគាត់ស៊ើបអង្កេត ឬវិធីសាស្រ្តរួមសំរាប់ប្រមូល និងវិភាគទិន្នន័យ ។ ការដឹងវិធីសាស្រ្តរួមដែលត្រូវយកមកប្រើ ថែមទាំងកំណត់ដំណើរការជ្រើសរើសអ្នកឆ្លើយសំណួរ ពីព្រោះថា ការមិនមានធនធានច្រើននឹងរារាំងមិនឱ្យគេសិក្សាទៅលើមនុស្សទាំងអស់បានទេ ។ គេត្រូវកំណត់យកសំណាក ។ ទំរង់ការនៃការកំណត់សំណាកគំរូ អាចត្រូវបានបែងចែកជាពីរប្រភេទធំៗ គឺប្រភេទដែលធ្វើនៅក្នុងបរិបទ នៃ**ការសិក្សាបែបគុណភាព** និងប្រភេទដែលធ្វើនៅក្នុងបរិបទនៃស៊ើប**អង្កេតបែបបរិមាណ** ។ ការសំរេចថា យកមួយណាគឺអាស្រ័យលើទិសដៅស្រាវជ្រាវ និងសំណួរស្រាវជ្រាវ ។ សកម្មភាពស្រាវជ្រាវនៅក្នុងការអភិវឌ្ឍន៍សង្គម គឺគេច្រើនតែប្រើទាំងពីរ ។ យ៉ាងណាក្តី ការសិក្សាស្រាវជ្រាវបែបគុណភាព ក៏មានគេសិក្សាជាញឹកញាប់ដែរ ។ ដោយហេតុនេះ ទំរង់ការដែលលើកឡើងនៅក្នុងនេះទាក់ទងនឹងវិធីកំណត់សំណាក នៅក្រោមលក្ខខ័ណ្ឌទាំងពីរ នៅក្នុងការប្រមូលនិងវិភាគទិន្នន័យ ។

### ទំរង់ការកំណត់សំណាកសំរាប់ការស្រាវជ្រាវបែបគុណភាព[៦]

ការកំណត់សំណាក សំរាប់ការស្រាវជ្រាវបែបគុណភាព គឺការរកបានគំរូជាតំណាងផ្សេងៗដែលបង្កើតបានជាបញ្ហានៃការសិក្សាស្រាវជ្រាវ (ឬនៅក្នុងនេះត្រូវបានហៅថា បញ្ហា ឬប្រធានបទស្រាវជ្រាវ) ។ ពោលគឺថា អ្នកស្រាវជ្រាវកំណត់សំណាក *តាមទ្រឹស្តី* ឬពិនិត្យលើជ្រុងផ្សេងៗប្រកបដោយអត្ថន័យដែលជាមូលដ្ឋាននៃសំណួរ និងបញ្ហាស្រាវជ្រាវរបស់គាត់ ។ ការកំណត់សំណាកសំរាប់ការស៊ើបអង្កេតបែបគុណភាពដែលមានប្រសិទ្ធភាព គឺទាក់ទងរួមទៅនឹងទិដ្ឋភាពស៊ីជំរៅ នៃស្ថានភាពឬបញ្ហា ព្រមទាំងទាក់ទងនឹងការយល់ពីអាកប្បកិរិយា ហេតុការណ៍ ស្ថាប័ន និងដំណើរការជាមូលដ្ឋានដែលសង្កត់ធ្ងន់លើបញ្ហាដែលកំពុងត្រូវបានសិក្សា ។ ដូច្នេះ វាច្រើនមានបំណងកំណត់ជាក់លាក់ ហើយមានជាប់ហូរហែរនៅក្នុងដំណើរការសិក្សាទាំងមូល ដោយភ្ជាប់គ្នារវាងការវិភាគ និងការប្រមូលទិន្នន័យ ។ ទីកន្លែងនៃការសិក្សាក្នុងដែននៃសំណាក និងអ្នកដែលត្រូវឆ្លើយក្នុងការសំភាសន៍ត្រូវបានកំណត់ដោយគ្របដណ្តប់តំបន់អោយបានទូលំទូលាយ (Substantive areas) សំរាប់ការស្រាវជ្រាវ ។

អ្នកដែលទើបចាប់ផ្តើមធ្វើការផ្នែកស្រាវជ្រាវ ច្រើនលើកសំណួរធម្មតាៗថា "តើអ្នកប្រាប់គេដោយរបៀបណា នៅពេលអ្នកមានសំណាកគ្រប់គ្រាន់ហើយ?" ។ តែអ្នកស្រាវជ្រាវដែលមានបទពិសោធន៍នៅក្នុងការងារស្រាវជ្រាវបែបគុណភាព ច្រើនធ្វើតាមពាក្យទំនាមថា គាត់អាចនឹងបញ្ឈប់ការកំណត់សំណាក នៅពេលណាដែល គាត់មានការធុញថប់ (Lewis-Beck et al, 2004: 995) ។ នេះជាគំនិតស្តីពី "ភាពឆ្អែតឆ្អន់" ឬស្ថានភាពដែលអ្នកស្រាវជ្រាវលែងរកបានទិន្នន័យថ្មីៗពីអ្នកដែលគាត់ទាក់ទងសុំ ឬមួយក៏ "គាត់បានឮអស់ហើយ" ។ ភាពឆ្អែតឆ្អន់ ត្រូវបានគេនិយាយថាកើតមានឆាប់ នៅពេលដែលសំណាកគ្រប់គ្រាន់ ព្រមទាំងមានភាពសមស្របនិងនៅពេលដែលការសិក្សាមានការដៅចំជាពិសេស (លើចំណុចដែលត្រូវសិក្សា) ។ *ភាពគ្រប់គ្រាន់* មានន័យថា វាមិនគ្រប់គ្រាន់ទេ ដែលត្រឹមតែឮអ្វីមួយពីនរណាម្នាក់បានតែម្តងនោះ អ្វីដែលបានឮ គួរតែត្រូវបានផ្ទៀងផ្ទាត់ដោយអ្នកចូលរួមផ្សេងទៀត ក្នុងទំរង់ជារឿងផ្សេងទៀតដែលមានចំណុចប្រហាក់ប្រហែលគ្នាទៅនឹងអ្វីដែលបានឮពីដំបូង ។ ការផ្ទៀងផ្ទាត់ក៏គួរធ្វើតាមរយៈប្រភពផ្សេងទៀតដែរ ដូចជាឯកសារ ការសង្កេត ។ល ។ ចំណែកឯ *ភាពសមស្រប* ទាក់ទងនឹងការកំណត់ជ្រើសរើសមនុស្សដែលមានភាពសមស្របបំផុតឱ្យចូលរួមនៅក្នុងការសិក្សា ។

---

[៦] ឧទាហរណ៍ដែលបានលើកឡើងនៅក្នុងផ្នែកនេះ មិនផ្តោតលើការស្រាវជ្រាវផ្នែកគ្រឿងញៀន និងការស្រាវជ្រាវរបស់អេឌីអាយ ឯទៀតនោះទេ ដោយសារគេចង់បង្ហាញនូវវិធីនៃការជ្រើសរើសសំណាកសំរាប់ស្ថានការណ៍អោយបានច្រើនយ៉ាង ។

ការកំណត់សំណាក សំរាប់ការសិក្សាបែបគុណភាព មិនមានរបៀបជាការកំណត់សំណាកចៃដន្យទេ ព្រោះថា ការធ្វើដោយជ្រើសយកដោយចៃដន្យមានន័យថា ពលរដ្ឋរូបណាក៏មានសក្តានុពលចូលរួមនិងផ្តល់ពត៌មានក្នុងការសិក្សាបានដែរ (Lewis-Beck et al, 2004: 995) ។ មិនមែនគ្រប់គ្នាមានបទពិសោធន៍ដូចគ្នានៅក្នុងជីវិត របស់គេដែលធ្វើឱ្យអ្នកស្រាវជ្រាវមានការចាប់អារម្មណ៍នោះទេ ហើយដោយសារការយល់ដឹងពីប្រធានបទមិនមែនជាការធម្មតាក្នុងចំណោមមនុស្សទេនោះ ការប្រមូលទិន្នន័យអាចនាំឱ្យមានទិន្នន័យច្រើនពេកស្តីពីប្រធានបទ ដែលគេដឹងជាទូទៅ ហើយមិនប្រមូលបានទិន្នន័យគ្រប់គ្រាន់សំរាប់ប្រធានបទដែលគេមិនសូវដឹង ដែលការសិក្សាបែបគុណភាពច្រើនចង់ស្វែងយល់និងបើកកកាយ ។ លើសពីនេះទៀត ការកំណត់សំណាកដោយចៃដន្យមានឫសគល់នៅក្នុងវិធីបែបបរិមាណ ដូច្នេះវាចង់បានចំលើយពីសំណួរដែលគេអាចប្រើស្ថិតិដើម្បីផ្ទៀងផ្ទាត់មើល និងរៀបរាប់ពន្យល់ និងទស្សន៍ទាយលំនាំបែបផែន (Pattern) នៃអាកប្បកិរិយា ។

## ប្រអប់ទី ៤. ឧទាហរណ៍មួយនៃការកំណត់សំណាកជាទ្រឹស្តី

នៅក្នុងការពិនិត្យគំរោងបែងចែកដីធ្លីឡើងវិញនៅក្នុងប្រទេសកម្ពុជាសំរាប់ការសិក្សាតូចមួយ ក្រុមបុគ្គលិក CCC-ADI បានមើលឃើញថា មានបទពិសោធន៍ 'របស់កម្មវិធីមួយចំនួន' ស្តីពីបញ្ហានេះនៅតាមតំបន់ផ្សេងៗនៅក្នុងប្រទេសកម្ពុជា ។ បទពិសោធន៍បានបង្ហាញពីវិធីផ្សេងៗដែលតាមរយៈនេះ ប្រជាជននៅតាមជនបទមានលទ្ធភាពកាន់កាប់ដីធ្លី ហើយវាបង្ហាញលក្ខណៈដីដែលត្រូវបានចែកចាយ និង ឬប្រជាជនបានកាន់កាប់ (ឧទាហរណ៍ ដីដែលត្រូវបានយកគ្រាប់មីនចេញ ដីព្រៃលិចទឹក ដីដែលនៅទំនេរ ។ល ។) និងវិធីដែលផ្តល់មេរៀនស៊ីជំរៅល្អ ។ ក្រុមបុគ្គលិកមើលឃើញបទពិសោធន៍ និងពត៌មានដែលចេញមកពីបញ្ហានោះ តែទទួលស្គាល់ព្រំដែនរបស់ខ្លួនដែរ ។ ដូច្នេះ ក្រុមបានពិនិត្យបទពិសោធន៍និមួយៗរបស់កម្មវិធីទៅតាមវិធីបែងចែកដីធ្លីដែលត្រូវបានរៀបរាប់ស្ថានភាពដី និមួយៗដែលត្រូវបានលើកឡើងជាឧទាហរណ៍ ការស្រាវជ្រាវដែលបានធ្វើលើបទពិសោធន៍និមួយៗនោះ ប្រភេទនិងចំនួនគ្រួសារដែលទទួលរងការប៉ះពាល់ចំងាយនៃទីកន្លែងស្រាវជ្រាវនិមួយៗ និងការជួយដែលអ្នកស្រាវជ្រាវទទួលបានពីទីភ្នាក់ងារអនុវត្តន៍ ។ ដោយផ្អែកលើចំណុចអស់ទាំងនេះ ក្រុមបានជ្រើសយកកម្មវិធីចំនួនបី គឺមួយនៅសៀមរាប ស្តីពីស្ថានភាពដីដែលត្រូវបានដោះមីនចេញ និងកម្មវិធីបែងចែកដីឡើងវិញ ទាក់ទងនឹងអង្គការមិនមែនរដ្ឋាភិបាលមួយ មួយទៀតនៅខេត្តកំពង់ធំ ទាក់ទងនឹងការដែលប្រជាជននាំគ្នារានដីព្រៃដែលនៅទំនេរដើម្បីយកដី និងកម្មវិធីចុងក្រោយគឺនៅខេត្តបាត់ដំបង ទាក់ទងនឹងដីដែលត្រូវបានគេដោះយកគ្រាប់មីនចេញ ហើយត្រូវបានរដ្ឋផ្តល់ឱ្យជនភៀសខ្លួន និងអ្នកធ្លាប់នៅទីនោះពីមុនដែលត្រឡប់វិញ ។ ក្រោយពីកំណត់ទីតាំងសិក្សាស្រាវជ្រាវហើយ ក្រុមបានត្រិះរិះលើសំណួរស្រាវជ្រាវសំខាន់ៗ ហើយកំណត់បានអ្នកដែលត្រូវសំភាសន៍ជាមួយ និងវិធីធ្វើដូចម្តេច ដើម្បីប្រមូលពត៌មានចាំបាច់ឱ្យបានល្អ ។ ក្រុមគិតថា ការសំភាសន៍ជាក្រុម និងគ្រួសារ គឺជាវិធីសមស្របបំផុតសំរាប់ប្រមូលទិន្នន័យ បើគេពិចារណាលើឧបសគ្គទាំងអស់ដែលមាន ។ បន្ទាប់មក ក្រុមបានសុំឱ្យអង្គការដែលមានសកម្មភាពនាំមុខគេនៅក្នុងការបែងចែកដីធ្លីឱ្យចងក្រងក្រុម សំរាប់ធ្វើសំភាសន៍ ។ សំណើសុំនោះបញ្ជាក់ថា នៅក្នុងក្រុមត្រូវមានប្រធានភូមិ បុគ្គលសំខាន់ៗ ដែលមានការពាក់ព័ន្ធនៅក្នុងការបែងចែកដីធ្លី តំណាងរបស់គ្រួសារដែលជាអ្នកទទួលផលដោយផ្ទាល់ពីការបែងចែកដីធ្លី ។ ចំណែកឯការសំភាសន៍ជាគ្រួសារវិញ រួមមានអ្នកទទួលផលដោយផ្ទាល់ដើម្បីបានយល់ស៊ីជំរៅទៅលើទិដ្ឋភាពរួមនៃគ្រួសារដែលទទួលបានដី ។

ការឆ្លុះបញ្ចាំងលើបញ្ហាសិក្សាខាងលើនេះបង្ហាញថា មានកង្វល់ផ្សេងៗគ្នាដែលគេត្រូវពិចារណានៅក្នុងការស្វែងយល់ពីបញ្ហាបែងចែកដីធ្លី ។ ដូច្នេះសំណួរដែលគេត្រូវសួរនៅពេលកំណត់សំណាកបែបគុណភាព រួមមានដូចជា តើមានកង្វល់សំខាន់អ្វីខ្លះចំពោះរឿងនោះ? តើត្រូវនិយាយ/ស្រាវជ្រាវលើបទពិសោធន៍ក្នុងកំរិតណា? តើអ្នកណា អាចនិយាយពីបទពិសោធន៍ផ្សេងៗបានទេ? តើបទពិសោធន៍អ្វី និងអ្នកឆ្លើយសំភាសន៍ណាខ្លះអាចឱ្យគេបញ្ចូលបាន ដោយយោលទៅលើកំរិតពេលវេលា បុគ្គលិក និងថវិកាដែលមាន?

ការពិនិត្យដោយប្រយ័ត្នលើសំណួរស្រាវជ្រាវ គឺជាគន្លឹះនៃទំរង់ការកំណត់សំណាកនៅក្នុងការសិក្សាបែបគុណភាព ។ កត្តាផ្សេងទៀតក៏រួមចំណែកដល់ការសំរេចចិត្ត លើការប្រើបច្ចេកទេសកំណត់សំណាកបែបគុណភាពដែរ ។ ដូចត្រូវបានកត់ចំណាំមកហើយ ការនេះរួមមានកំហិតផ្នែកថវិកា បុគ្គលិក និងពេលវេលា ព្រមទាំងការមិនមានអ្នកឆ្លើយតបសំភាសន៍មួយចំនួនផង ។ អ្នកទាំងនេះអាចមានដូចជា :

- អ្នកធ្វើចំណាកស្រុកដើម្បីរកការងារធ្វើ
- អ្នករកស៊ីផ្លូវភេទ
- ស្ត្រីលក់ស្រាបៀរ និងស្ត្រីខារ៉ាអូខេ
- គ្រួសារដែលមានកុមារធ្វើការលក់កំលាំងពលកម្ម
- ក្មេងរស់នៅតាមចិញ្ចើមថ្នល់នៅភ្នំពេញ
- ស្ត្រីដែលទទួលរងនូវការវាយដំ ឬអំពើហឹង្សានៅក្នុងគ្រួសារ
- បុរសជាមេគ្រួសារដែលមានប្រពន្ធច្រើន ។
- ។ល។

នៅក្នុងករណីណាមួយខាងលើនេះ អ្នកស្រាវជ្រាវអាចសំរេចប្រើវិធីកំណត់សំណាកគំរូដូចខាងក្រោមនេះ :

***សំណាកផ្អែកលើឱកាស*** *(Opportunity sampling)*

គេច្រើនប្រើសំណាកនេះ នៅពេលអ្នកស្រាវជ្រាវមិនមានអ្វីជាជំរើសផ្សេងទៀត ជាពិសេសដោយសារមិនសូវមានថវិកា ។ ឧទាហរណ៍ សិស្សដើម្បីបំពេញការទាមទាររបស់សាលាត្រូវការអង្កេតទៅលើចំនួនដងរបស់គ្រួសារនៅក្នុងការចូលហាងនៅចុងសប្តាហ៍ ។ ដោយសារគេមិនសូវមានធនធាននោះ គេអាចកំណត់សំណាក និងសំភាសន៍ជាមួយសិស្សគ្នាឯង អ្នកជិតខាង ឬ អ្នកដើរតាមផ្លូវ ។

***សំណាកផ្អែកលើគោលបំណង ឬការវិនិច្ឆ័យ*** *(Purposive or judgmental sampling)*

ទំរង់ការនេះមានសំណាកដែលត្រូវបានជ្រើសឡើង តាមការគិតគូរដោយអ្នកស្រាវជ្រាវ ព្រោះអ្នកស្រាវជ្រាវគិតថាក្រុមមានលក្ខណៈខ្លះដែលជាលក្ខណៈតំណាងរបស់មនុស្សទាំងមូល (នៅតំបន់ណាមួយ) ។ ឧទាហរណ៍ ដើម្បីកំណត់ពីការមានការជួយគាំទ្រផ្នែកស្ថាប័ននៅក្នុងកម្មវិធីឥណទាននៅក្នុងខេត្ត អង្គការមិនមែនរដ្ឋាភិបាលខ្លះ ដែលត្រូវជ្រើសរើស ឬអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលមានការពាក់ព័ន្ធនៅក្នុងកម្មវិធី ឬគំរោងដែលផ្តល់ជំនួយឥណទាន ឬជំនួយឥណទានខ្នាតតូចប្រហែលគេត្រូវសំភាសន៍ជាមួយ ។

ចំណុចមិនល្អមួយនៅក្នុងការប្រើវិធីនេះគឺថា គេមិនអាចធ្វើការសន្និដ្ឋានអំពីប្រជាជនទាំងមូលដែលត្រូវបានសិក្សានោះទេ ។ ម្យ៉ាងទៀត លទ្ធផលរកឃើញប្រហែលមានភាពត្រឹមត្រូវសំរាប់សំណាក ប៉ុន្តែអាចមិនពិតចំពោះអ្នកផ្សេងទៀតដែលតំណាងឱ្យក្រុមណាមួយដែលគេទាញសំណាកបែបបំណងកំណត់ ។

***ការកំណត់សំណាកផ្អែកលើការចង្អុលបង្ហាញបន្តគ្នា*** *(Snowball sampling)*

ទំរង់ការនេះគឺជាបច្ចេកទេសមួយទៀតសំរាប់ការស្រាវជ្រាវ ។ ពីដំបូង មិត្តភក្តិ មនុស្សស្គាល់គ្នា ឬមនុស្សដែលមិនស្គាល់គ្នាអាចត្រូវបានសួរឱ្យកំណត់សំណាកគោលដៅ (target sample) ថាមាននៅកន្លែងណា ពេលរកឃើញហើយ អ្នកឆ្លើយតបសំភាសន៍នឹងត្រូវបានសួរថា តើសំណាកឯទៀតនៅកន្លែងណា ។ បច្ចេកទេសនេះមានប្រយោជន៍ ជាពិសេស នៅពេលអ្នកស្រាវជ្រាវចង់រកនិងសំភាសន៍មនុស្សដែលមានលក្ខណៈខុសប្លែកគេ ហើយដែលពួកគេស្គាល់គ្នាគេ ។ ឧទាហរណ៍ គេអាចប្រើបច្ចេកទេសនេះនៅក្នុងចំណោមអ្នករកស៊ីផ្លូវភេទ អ្នកលក់កាំភ្លើង និងស្ត្រីដែលធ្លាប់ត្រូវបានគេជួញដូរ ។

***ទំរង់ការនៃការកំណត់សំណាកនៅក្នុងការសិក្សាបែបបរិមាណ*** *(Sampling procedures in quantitative studies)*

ការកំណត់សំណាកបែបបរិមាណមានបំណងរកមើល*លក្ខណៈដែលអាចយកធ្វើជាតំណាង* ឬជ្រើសយក មនុស្សមួយក្រុមតូចធ្វើជាតំណាងនៃលក្ខណៈរបស់មនុស្សនៅកន្លែងណាមួយ (ឧទាហរណ៍ អាយុ ភេទ ជនជាតិ មុខរបរ ។ល ។) (Mason, 1996:91) ។ លំនាំបែបផែនទិន្នន័យដែលប្រមូលបានពីក្រុមតំណាងតូចនេះ បន្ទាប់មកត្រូវបានរាយការណ៍ថាជាតំណាងត្រឹមត្រូវរបស់មនុស្សទាំងមូលនៅកន្លែងណាមួយ ដែលគេបានដកយកសំណាក (ឧទាហរណ៍ ២៥ ភាគរយនៃគ្រួសារនៅក្នុងប្រទេសកម្ពុជាមានស្ត្រីជាមេគ្រួសារ) ដូចមានបង្ហាញក្នុងរូបទី ៥ ។ ការកំណត់សំណាកបែបបរិមាណ តាមធម្មតាត្រូវបានគេប្រើនៅក្នុងការស្រាវជ្រាវបែបអង្កេត (Survey research) ។

**រូបទី ៥. ហេតុផលនៃការកំណត់សំណាកបែបបរិមាណ**




(ប្រភព: Neuman, 2000: 202, 218 )

ចំណុចស្នូលនៃការកំណត់សំណាកនៅក្នុងការសិក្សាបែបបរិមាណ ឬការស្រាវជ្រាវបែបអង្កេតគឺការកំណត់ សំណាកតាមលក្ខណៈចៃដន្យ ។ មូលដ្ឋាននៃការធ្វើដូច្នេះគឺ**ការមានឬលទ្ធភាពនៃការបង្កើតគ្រោងសំណាក**ដែលគេកំណត់ឱ្យងាយយល់ថា **ជាបញ្ជី** នៃអ្វីដែលនឹងត្រូវយកធ្វើជាសំណាក ។ ឧទាហរណ៍ :

បញ្ជីសិស្សទាំងអស់ដែលរៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
បញ្ជីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនៅក្នុងប្រទេសកម្ពុជា
បញ្ជីកសិករនៅក្នុងភូមិមួយ
បញ្ជីនៃប្រជាជនខ្មែរដែលមានរថយន្ត
បញ្ជីហាងលក់ទូរស័ព្ទដៃ
បញ្ជីកម្មកររោងចក្រកាត់ដេរនៅភ្នំពេញ
បញ្ជីជនបរទេសដែលធ្វើការនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនៅក្នុងប្រទេសកម្ពុជា ។

**ការកំណត់សំណាកមានប្រយោជន៍តែនៅពេលណាគេអាចទទួលបានបញ្ជីនៃអ្វីដែលត្រូវសិក្សា ។** ទាក់ទងនឹងចំណុចនេះ វាជាការមានប្រយោជន៍ បើគេចុះមើលមុនពេលប្រមូលទិន្នន័យទៅកាន់ទីកន្លែងដើម្បីទទួលបានបញ្ជី ដែលគួរឱ្យទុកចិត្តបាន ដូចជាបានពីប្រធានភូមិ ។ ការចុះបែបនេះផ្តល់ឱកាសឱ្យគេអាចធ្វើបញ្ជីដែលត្រូវការពិសេស នៅពេលដែលបញ្ជីនេះមិនទាន់ត្រូវបានរៀបចំនៅឡើយ ។ ការចុះទៅបែបនេះក៏ធ្វើឱ្យអ្នកស្រាវជ្រាវអាចកំណត់កត្តា ដែលអាចជួយជំរុញ ឬបង្អាក់ការរាំងស្ទះដល់ការប្រមូលទិន្នន័យ ។ ការនេះអាចកំណត់សារឡើងវិញនូវទំហំនៃការងាររបស់គាត់ ។ គេគួរចាំផងដែរថា អាចមានករណីដែលគេមិនអាចរកបញ្ជីដ៏គួរឱ្យទុកចិត្តបាននៃអ្នកឆ្លើយតប ដោយសារបញ្ហាស្រាវជ្រាវមានលក្ខណៈរសើបពេក (ឧទាហរណ៍ អំពើហឹង្សានៅក្នុងគ្រួសារ អ្នកកើតជំងឺអេដស៍ នៅក្នុងភូមិ) ។ នៅក្នុងស្ថានភាពបែបនេះ វិធីនៃការកំណត់សំណាក ជាលក្ខណៈយល់ឃើញ (Subjective) (ឧទាហរណ៍ បែបពីតូចទៅធំទៅៗ) មានភាពសមរម្យជាង ។ ខាងក្រោមនេះគឺសេចក្តីរៀបរាប់ខ្លីៗនៃទំរង់ការខុសៗគ្នា ដែលនៅក្នុងនោះការស្រាវជ្រាវឈានដល់ការជ្រើសរើសយកឯកតាបុគ្គល (Individual Unit) ដែលត្រូវដាក់បញ្ចូល ។

***ការកំណត់សំណាកចៃដន្យធម្មតា*** *(Simple random sampling)*

ធ្វើបញ្ជីនៃអ្វីដែលនឹងត្រូវបានយកធ្វើជាសំណាក ។ ឧទាហរណ៍ ធ្វើបញ្ជីនៃអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុកនៅក្នុងសៀវភៅមគ្គុទេសក៏របស់ CCC ។ សរសេរឈ្មោះទាំងអស់នៅក្នុងបញ្ជីដាក់លើក្រដាសតូចៗ មូរក្រដាសកុំឱ្យគេឃើញឈ្មោះ ដាក់ក្រដាសមូរនោះនៅក្នុងប្រអប់ឬមួក ហើយយកក្រដាសមួយម្តងៗ រហូតបានចំនួនក្រដាសដែលគេចង់បាន ។

***ការកំណត់សំណាកជាស្រទាប់ថ្នាក់*** *( Stratified or strata sampling)*

ការកំណត់សំណាកជាស្រទាប់ថ្នាក់មានន័យថា អ្នកស្រាវជ្រាវទទួលបានសំណាកពីក្រុមតូចៗ ឬស្រទាប់ថ្នាក់នៅក្នុងចំណោមមនុស្ស[៧] ដែលត្រូវបានសិក្សា ។ ដើម្បីសំរេចការនេះទៅបាន គេកំណត់ក្រុមតូចៗ/ស្រទាប់ថ្នាក់/លំដាប់ថ្នាក់ ដែលត្រូវបានសិក្សា និងនៅក្នុងក្រុមតូចៗទាំងនេះ កំណត់សំណាកដោយប្រើទំរង់ការនៃការកំណត់ សំណាកចៃដន្យធម្មតា ដូចដែលរៀបរាប់មកខាងលើនេះ ។ ឧទាហរណ៍ ការគ្រោងរៀបចំការកំណត់សំណាកជាពីរស្រទាប់ថ្នាក់ទៅលើការសិក្សាមួយ នៅក្នុងចំណោម

[៧] ប្រជាជននៅក្នុងដែនស្រាវជ្រាវសំដៅលើក្រុមមនុស្ស (ឬស្ថាប័នព្រឹត្តិការណ៍ ឬប្រធានបទផ្សេងទៀតនៃការសិក្សា) ដែលគេចង់រៀបរាប់ឬបរិយាយជាលក្ខណៈទូទៅ ។ ដើម្បីនិយាយជាលក្ខណៈទូទៅចំពោះក្រុមមនុស្សណាមួយទៅបាន គេច្រើនតែកំណត់យកសំណាកដែលមានបំណង**តំណាងឱ្យ**មនុស្សមួយក្រុម (Vogt, 1993) ។

និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ទាក់ទងនឹងការរំពឹងទុកលើការងារនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលរួមមាន ៖

១. កំណត់ស្រទាប់ថ្នាក់ទីមួយ ឬអនុក្រុមនៃបុរស និងនារីនៅក្នុងបញ្ជីនៃសិស្សនៅក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។
២. ជ្រើសរើសនិស្សិតដែលកំពុងសិក្សានៅក្នុងឆ្នាំទីបី និងទីបួន (បើសិនជាក្រុមដោយឡែកមួយដែលអ្នកចង់សំភាសន៍ជាមួយ) ។
៣. ធ្វើការកំណត់សំណាកចៃដន្យចេញពីបញ្ជី (ផ្តុំជាក្រុមតាមជេនឌ័រ និងឆ្នាំសិក្សា) ដោយប្រើទំរង់ការដូចមានកត់សំគាល់ខាងលើ ។

នៅក្នុងឧបសម្ព័ន្ធទី ៥ បង្ហាញឧទាហរណ៍នៃការកំណត់សំណាកជាស្រទាប់ថ្នាក់មានពីរដំណាក់កាលសំរាប់ការអង្កេតជាមូលដ្ឋានមួយនៅក្នុងប្រទេសកម្ពុជា ។

***ការកំណត់សំណាកចៃដន្យជាប្រព័ន្ធ*** *( Systematic random sampling)*

នៅក្នុងវិធីនេះ គ្រប់សមាសភាគតាមចំនួន ( nth = ទីnដង) ក្នុងបញ្ជីត្រូវបានជ្រើសរើស (តាមរបៀបជាប្រព័ន្ធ) សំរាប់ដាក់បញ្ចូល ។ ឧទាហរណ៍ បើបញ្ជីមាន ១០០០ សមាសភាគ ហើយគេត្រូវការសំណាក ចំនួន ១០០ ដែលនោះក្នុង ១០ សមាសភាគ គេជ្រើសរើសយកសំណាកចំនួន ១ ។ ដើម្បីជៀសវាងការលំអៀងរបស់អ្នកស្រាវជ្រាវ សមាសភាគដំបូងគួរតែគេជ្រើសរើសដោយចៃដន្យ ។ ការធ្វើដូច្នេះ ត្រូវបានគេស្គាល់ថាជាសំណាកតាមប្រព័ន្ធដោយមានការចាប់ផ្តើមដោយចៃដន្យ ។

ការអនុវត្តន៍លើការកំណត់សំណាកនេះ ដូចជាការសិក្សាមួយទៅលើការធ្វើចំណាកស្រុកទៅរកការងារធ្វើ នៅប្រទេសថៃ នៅភូមិប៉ោយប៉ែត ។ ដោយប្រជាជននៅតំបន់នេះមានការដើរហើរច្រើន និងពិបាកនៅក្នុងការរកបានបញ្ជីដែលគួរឱ្យទុកចិត្តបាននៃគ្រួសារ គេអាចជ្រើសរើសផ្ទះតាមសមាមាត្រ ៥ម្តង ឬ១០ម្តង (ជាឧទាហរណ៍) ដើម្បីរកមើលពីការពឹងអាស្រ័យរបស់គ្រួសារលើការចេញទៅធ្វើការ នៅតំបន់ព្រំដែនថៃដើម្បីចិញ្ចឹមជីវិត ។

តាមរបៀបម្យ៉ាងទៀត **បើសិនជារកបានបញ្ជីដែលអាចទុកចិត្តបាន** អ្នកស្រាវជ្រាវអាចជ្រើសរើសតាមចំនួនរាល់ចំនួន...ម្តង១នៃគ្រួសារ ( nth household) ចេញពីបញ្ជីបន្ទាប់ពីចាប់ផ្តើមដោយចៃដន្យ (នោះគឺសំរេច លើគ្រួសារទី ១ ទី ៥ ទី ៧ ជាចំណុចចាប់ផ្តើម បន្ទាប់មកមើលតាមបញ្ជីថែមទៀត ដូចជាកំណត់ថាចំនួន១០។ នៅក្នុងបញ្ជី) ។ ក្រោយពីហ្នឹងមករាល់គ្រួសារទី១០នៅក្នុងបញ្ជី (១០ម្តង១) គឺជាផ្នែកមួយនៃសំណាក ។ ដូច្នេះ បើចាប់ពីដំបូងគេជ្រើសរើសគ្រួសារទី ៧ នោះគ្រួសារទី ១៧ ២៧ ៣៧....១២៧ គឺជាផ្នែកនៃសំណាក ។ ដើម្បីកំណត់រាល់ចំនួន n ដែលត្រូវយកធ្វើជាសំណាកចូរចែកចំនួនប្រជាជនទាំងមូលជាមួយនឹងទំហំនៃសំណាកដែលគេចង់ **បើសិនជា** គេដឹងចំនួនប្រជាជន ។

ជាទូទៅ ការកំណត់សំណាកតាមប្រព័ន្ធ និងចៃដន្យទាមទារឱ្យមានបញ្ជី ។ តែការនេះត្រូវសំរួលតាមស្ថានភាព ដូចជាស្ថានភាពដែលរៀបរាប់នៅក្នុងឧទាហរណ៍ខាងលើនេះនៅពេលដែលគេមិនអាចរកបញ្ជីបានទេ ។

***ការកំណត់សំណាកទៅតាមទីកន្លែងប្រមូលផ្តុំ*** *( Cluster sampling)*

បើសិនជាចំណុចផ្តោតនៃការសិក្សាត្រូវបានកំណត់ហើយដូចជា លក្ខណៈផ្នែកសេដ្ឋកិច្ចសង្គមរបស់គ្រួសារនៅភ្នំពេញ នោះសំណាកនឹងចេញមកពីប្រជាជននៅក្នុងក្រុង (រូបទី ៦) ។ ការកំណត់សំណាកតាមទីកន្លែងប្រមូល ផ្តុំ មានភាពសមស្រប

បំផុតក្នុងករណីបែបនេះ ។ ការនេះត្រូវបានធ្វើដោយទាញយកប្រយោជន៍ពីទីកន្លែងផ្តុំគ្នា ដែលបានកំណត់រួចជាស្រេច ដែលនៅក្នុងករណីនេះ អាចជាសង្កាត់ឬឃុំដែលប្រជាជនរស់នៅ ( អ្នកអាចធ្វើផងដែរ នៅតាមដងផ្លូវ ឬទៅតាមខ័ណ្ឌ ) ។ កំណត់សង្កាត់ដែលអ្នកទាញសំណាកចេញមក រួចហើយទៅយកបញ្ជីនៃប្រជាជននៅពីទីស្នាក់ការសង្កាត់ និងកំណត់សំណាកដែលចង់បានពីសង្កាត់និមួយៗ ដោយធ្វើតាមទំរង់ការកំណត់សំណាកចៃដន្យធម្មតា ដូចដែលមានរៀបរាប់ខាងលើ ។

**រូបទី ៦. ការបង្ហាញតាមទំរង់ផ្សាក្រាម សំរាប់ការកំណត់សំណាកទៅតាមទីកន្លែងប្រមូលផ្តុំ**

(Schematic Illustration of Cluster Sampling)




ដោយសារសង្កាត់ជាបណ្តុំធំពេកសំរាប់ឱ្យគេជ្រើសរើសយក អ្នកស្រាវជ្រាវចង់ឈានមួយជំហ៊ានទៀត ដោយកំណត់យកភូមិនៅក្នុងសង្កាត់/ឃុំ រួចហើយទៅទាក់ទងប្រធានភូមិសុំរកបញ្ជី ។ ការកំណត់សំណាកជាបណ្តុំថ្នាក់មានភាពសមស្របសំរាប់ប្រជាជននៅភ្នំពេញ ពីព្រោះមនុស្សដែលរស់នៅភ្នំពេញមិនមានការចុះបញ្ជីពេញលេញទេ ហើយប្រជាជនរស់នៅលើតំបន់ធំៗ ។ គេក៏អាចកំណត់សំណាកចៃដន្យជាប្រព័ន្ធផងដែរ នៅក្នុងវិធីកំណត់សំណាកជាបណ្តុំថ្នាក់នេះ ជាពិសេសដោយសារគ្រួសាររស់នៅក្នុងតំបន់អ្នកក្រីក្រ ( ពោលគឺតំបន់អានាធិបតេយ្យ ) ដែលអាចមិនមាននៅក្នុងបញ្ជីរបស់ប្រធានភូមិ ។

ការកំណត់សំណាកជាបណ្តុំថ្នាក់ ដែលមានដំណាក់កាលច្រើនក៏គេអាចធ្វើផងដែរ ។ ឧទាហរណ៍ បើគេចង់ធ្វើការវិភាគបែបប្រៀបធៀបនៃការប្រើជាតិគីមីតាមតំបន់នៅក្នុងចំណោមកសិករក្នុងប្រទេសកម្ពុជា ជាដំបូងគេកំណត់តំបន់នៅក្នុងប្រទេសកម្ពុជាដែលត្រូវសិក្សា( ឧទាហរណ៍ ពាយ័ព្យ ឦសាន្ត និរតី ។ល ។) រួចហើយកំណត់ខេត្ត ដើម្បីកំណត់សំណាកនៅក្នុងតំបន់មួយ បន្ទាប់មកស្រុក ឃុំ ភូមិ ចុងក្រោយគឺកសិករ ។ ចូរចាំថា នៅគ្រប់លំដាប់ថ្នាក់ឬស្រទាប់ថ្នាក់ ទំរង់ការកំណត់សំណាកដោយចៃដន្យធម្មតាដូចបានកត់សំគាល់ខាងលើ គេត្រូវតែធ្វើតាម ។

***ការកំណត់សំណាកតាមច្រើនលំដាប់*** *( Multi phase sampling)*

វិធីកំណត់សំណាកនេះត្រូវមានការបំបែកជាធាតុតូចៗ ( Subset) នៃសំណាកពីខាងដើម ក្នុងការសិក្សា ។ ឧទាហរណ៍ បើសិនជាក្រោយពីសំភាសន៍បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជាជនជាតិខ្មែរ អ្នកស្រាវជ្រាវចង់ពិនិត្យស៊ីជំរៅទៅលើគោលដៅរបស់បុគ្គលិកទាំងនេះគាត់នឹងកំណត់សំណាកថ្មី ដោយឡែកពីសំណាក ដែលត្រូវបានប្រើនៅក្នុងកិច្ចសំភាសន៍លើកមុន ។ នៅពេលនេះទៀត ទំរង់ការគឺធ្វើតាមវិធីសាស្ត្រកំណត់សំណាកដោយចៃដន្យធម្មតា ។ ចំណុចជាកង្វល់មួយដែលគេគួរដឹងនៅក្នុងទំរង់ការដែលរៀបរាប់ខាងលើនេះគឺថា *ការកំណត់សំណាកជាមួយនឹងការជំនួស* (Sampling with replacement) ។ ការនេះបង្ហាញថា គេអាចជ្រើសយកអ្នកឆ្លើយ 'ប៉ុរ៉ុង' ក្នុងចំនួនកំណត់ដែលត្រូវបានជ្រើសរើសផងដែរ តាមរបៀបចៃដន្យនៅក្នុងករណីដែលថា អ្នកឆ្លើយសំភាសន៍ដែលត្រូវបានកំណត់បែរជាមិនមានវត្តមានតាមពេលកំណត់សំរាប់ការប្រមូលទិន្នន័យ[៨] ។ ដូច្នេះ បើសិនអ្នកស្រាវជ្រាវបានកំណត់ទំហំសំណាកត្រឹម២៥ នាក់ក្នុងមួយភូមិ គាត់ត្រូវបង្កើនចំនួនយ៉ាងតិច៥នាក់ទៀត (ដោយអាស្រ័យលើការប្រមាណរបស់គាត់ ថាតើមានមនុស្សប៉ុន្មាននាក់ដែលអវត្តមាននៅពេលដល់ថ្ងៃសំភាសន៍ ដើម្បីប្រមូលទិន្នន័យ) នៅក្នុងដំណើរនៃការជ្រើសរើសដោយចៃដន្យនូវអ្នកឆ្លើយសំភាសន៍របស់គាត់ ដើម្បីធានាឱ្យមានសំណាកចំនួន ២៥ នាក់ដូចដែលគាត់ចង់បាន ។ ការអវត្តមានរបស់អ្នកឆ្លើយសំភាសន៍ អាចកើតមាននៅពេលដែលគេចេញទៅធ្វើការឆ្ងាយតាមរដូវ ឬចេញទៅធ្វើស្រែចំការឆ្ងាយវិលល្ងាច ឬក៏មិននៅក្នុងភូមិដោយសារហេតុផលផ្សេងទៀត ។

**កំណត់ទំហំនៃសំណាក**

ជាទូទៅ បើសំណាកធំកាលណាគឺល្អកាលនោះ ពីព្រោះកាលណាសំណាកធំ ការលំអៀងក៏មានតិចដែរ ។ ប៉ុន្តែនេះមិនមែនមានន័យថា ធានាបានលទ្ធផលត្រឹមត្រូវនោះទេ ។

ពិតជាមិនមានគោលកំណត់ច្បាស់ណាមួយជាប្រាកដនៅក្នុងការកំណត់ទំហំសំណាកទេ ។ មានវិធីចំនួនពីរ **ដែលគេត្រូវបង្ការ** នៅក្នុងការសំរេចទំហំនៃសំណាកគឺ (Fowler, 1993:35):

- ធ្វើការបញ្ជាក់ពីការចែកនៃចំនួនប្រជាជនដែលត្រូវបញ្ចូលជាសំណាក ។
- កំណត់ទំហំសំណាកដោយផ្អែកលើការយល់ថា "វាជាវិធីធម្មតាចំពោះការសិក្សាពីប្រជាជន" ។
- ធ្វើការបញ្ជាក់ពីកំរិតត្រឹមត្រូវដែលចង់បានចាប់ពីពេលចាប់ផ្តើមដំបូងនៃការសិក្សាទៅ ។

ជាធម្មតា ទាក់ទងនឹងរឿងនេះ គឺជារឿងដែលមាន**លក្ខណៈធ្វើជាតំណាងឱ្យបាន** (Representativeness) ។ ថាតើសំណាករបស់អ្នកតំណាងបានល្អប៉ុនណាដល់បណ្តាបុគ្គល គ្រួសារ ក្រុម (ភូមិ/សហគមន៍) ដែលអ្នកកំពុងតែសិក្សា គឺមានសារៈសំខាន់ជាងចំនួនដែលអ្នកទទួលបានទៅទៀត ។ វាយ៉ាងដូច្នេះ ដោយសារសំណាករបស់អ្នក ដូចដែលមាននិយាយនៅក្នុងរូបទី ៥ គឺជារូបភាព តូចមួយដែលអ្នកកំពុងសិក្សា ។

[៨] គេគួរកត់ចំណាំថា ពាក្យនេះមានន័យផ្សេងនៅក្នុងការធ្វើស្ថិតិនៃការគ្រោងរៀបចំការកំណត់សំណាក ។

អ្នកធ្វើការអភិវឌ្ឍន៏ ក៏ប្រើរូបមន្តមួយដែរ ដើម្បីកំណត់ទំហំនៃសំណាក ទៅលើទស្សនៈ ដែលទាក់ទងទៅនឹងការសិក្សា។ ខាងក្រោមនេះគឺជារូបមន្តមួយបែបដែលត្រូវបានប្រើក្នុងការស្រាវជ្រាវ យ៉ាងហោចចំនួនពីរនៅកម្ពុជា[៩] តែគេគួរស្វែងរកជំនួយពីអ្នកស្ថិតិ ឬអ្នកណាដែលដឹងស្ថិតិនៅពេលត្រូវកែសំរួលតួលេខ (Fink and Kosecoff, 1985:62) ។

**ការចំណាំលើការកំណត់សំណាកៈ**

បើអ្នករៀបចំស្លសម្លមួយឆ្នាំងតូច អ្នកអាចដឹងរសជាតិដោយភ្លក់ មួយស្លាបព្រា (នោះគឺកំណត់សំណាក) ។ នៅពេលអ្នករៀបចំ ស្លសម្លមួយឆ្នាំងធំវិញនោះ អ្នកអាចប្រើស្លាបព្រាដដែលដើម្បីដួសសម្លមកភ្លក់ ពោលគឺអ្នកមិនចាំបាច់ប្រើស្លាបព្រាដែលធំជាង នេះដោយសារតែស្លក្នុងឆ្នាំងធំនោះទេ ។

$N = (z/e)^2 (P) (1-p)$

N = ទំហំនៃសំណាក

z = ពិន្ទុស្តង់ដារស្របទៅនឹងក៏រិតជឿជាក់ដែលត្រូវបានផ្តល់ឱ្យ (ភាពប្រាកដលើស្ថិតិដែលត្រូវបានជ្រើសរើសយក)

e = សមាមាត្រនៃក៏រិតលំអៀងនៃសំណាក ។

p = អត្រាប៉ាន់ប្រមាណនៃករណី

តាមការកំណត់ ចំពោះក៏រិតទុកចិត្តចំនួន ៩0 ភាគរយ z=១.៦៥, ចំពោះ ៩៥ ភាគរយ z = ១.៩៦ ចំពោះ ៩៩ ភាគរយ z = ២.៥៨។ ជាទំលាប់ ក៏រិតលំអៀងដែលគេអាចទទួលយកបានគឺនៅចន្លោះតំលៃបូក ឬ ដក 0.១0 (១0 ភាគរយ) ។

ឧទាហរណ៏ ដើម្បីប្រមាណសំណាកគំរូមួយសំរាប់ការសិក្សាមួយទៅលើគ្រួសារដែលមានសមាជិកធ្វើការជាកម្មកររោងចក្រកាត់ដេរ យើងអាចនិយាយថា សមាមាត្រ p=0.២៥ ប្រសិនបើ ២៥ ភាគរយនៃគ្រួសារក្នុងភូមិជាកម្មករកាត់ដេរ ។ ដោយប្រើក៏រិតទុកចិត្តចំនួន ៩៥ ភាគរយ ដែលមាន z = ១.៩៦ ហើយនិងក៏រិតលំអៀង ចំនួន 0.១0 នោះ អ្នកអាចគណនាទំហំសំណាកដូចខាងក្រោមនេះ:

$N = (1.96/0.10)^2 \times 0.25 \times 0.75$

$N = (19.6)^2 \times (0.1875)$

$N = 72$

ដូច្នេះទំហំសំណាកចំនួន ៧២ គ្រួសារដែលមានសមាជិកគ្រួសារធ្វើការនៅក្នុងរោងចក្រកាត់ដេរ បង្កើតក៏រិតលំអៀងនៅក្នុងរង្វង់ក្បែរៗ 0.១0 ជាមួយនឹងក៏រិតនៃការទុកចិត្តមាន ៩៥ ភាគរយ ចំពោះប្រជាជនដែលមាន ២៥ ភាគរយនៃគ្រួសារមានសមាជិកម្នាក់ដែលធ្វើជាកម្មកររោងចក្រកាត់ដេរ ហើយមាន ៧៥ ភាគរយ ដែលមិន មានសមាជិកធ្វើការនៅក្នុងរោងចក្រកាត់ដេរ ។

[៩] ការសិក្សាស្រាវជ្រាវទាំងពីរនេះគឺ *Norheast Cambodia Child Survival Project Baseline Survey on Knowledge, Practice and Coverage* របស់អង្គការដៃគូសំរាប់ការអភិវឌ្ឍ នៅភ្នំពេញ ហើយនៅក្នុងឆ្នាំ ២00៤ គឺការវាយតំលៃកម្មវិធីអនាម័យ និងទឹក *(Water and Hygiene Program Evaluation)* ។ ការសិក្សាទាំងពីរនេះប្រើកត្តាប្រែប្រួលបន្តិចបន្តួចលើរូបមន្តនេះ ។

## រៀបចំឧបករណ៍ប្រមូលទិន្នន័យ (Designing the Data Collection Instruments)

ការរៀបសំណួរ ហើយផ្គុំគ្នានៅក្នុងឧបករណ៍ប្រមូលទិន្នន័យសំរាប់ការអង្កេតមួយ ជាទូទៅមានន័យថា គិតគូរធ្វើយ៉ាងណាដើម្បីឱ្យសំណួររបស់យើងនាំមកនូវទិន្នន័យតាមសេចក្តីត្រូវការពត៌មានរបស់យើង ហើយដែលបន្ទាប់មកត្រូវបានបូកសរុបដើម្បីឆ្លើយតបនឹងសំណួរ/ទិសដៅស្រាវជ្រាវរបស់យើង ។ ការនេះមានន័យថាត្រូវត្រិះរិះលើរបៀបរៀបឃ្លោងឃ្លានៃសំណួរ ពាក្យណាដែលត្រូវប្រើ តើសំណួរបិទ ឬបើកប៉ុន្មានដែលត្រូវប្រើ ។ល ។ ទាំងនេះគឺជាចំណុចដែលត្រូវពិចារណា ពីព្រោះភាពមានប្រយោជន៍ និងជំនឿដែលគេមានចំពោះពត៌មានរបស់យើង អាស្រ័យលើការដែលថា តើសំណួររបស់យើងនាំមកនូវរង្វាស់ត្រឹមត្រូវ និងគួរឱ្យទុកចិត្តបានប៉ុនណា ។

**សំណួរដែលល្អមានលក្ខណៈដូចខាងក្រោមនេះ :**

- ដំណើរការផ្ទេកសំណួរ និងចំលើយរបស់អ្នកស្រាវជ្រាវត្រូវបានសរសេរទាំងស្រុង ដូចនេះសំណួរត្រូវរៀបចំជាស្រេចសំរាប់អ្នកឆ្លើយតបសំភាសន៍ក្នុងការឆ្លើយសំណួររបស់យើង ។
- សំណួរត្រូវអោយអ្នកឆ្លើយទាំងអស់យល់ក្នុងន័យដូចៗគ្នា ។ល
- គ្រប់ប្រភេទនៃចំលើយទាំងអស់ដែលទទួលបានពីការសួរត្រូវតែឱ្យអ្នកឆ្លើយសំភាសន៍ទាំងអស់ដឹង និងប្រាកដក្នុងចិត្តគ្រប់គ្នា

ការរៀបចំសំណួរគួរពិចារណាទៅលើចំណុចជាកង្វល់មួយចំនួន ដូចមានរៀបរាប់ខ្លីខាងក្រោមនេះ :

### ១. ប្រភេទសំណួរ

***សំណួរបើក*** *(Open-ended questions)*

ត្រូវបានគេហៅផងដែរថាជាសំណួរបែបគុណភាព ដែលសំណួរនេះចង់និយាយទៅលើសំណួរបើកដែល ប្រភេទបញ្ហាត្រូវបានផ្តល់ដោយអ្នកឆ្លើយតបសំភាសន៍ជាជាងដោយអ្នកស្រាវជ្រាវ ឬអ្នកសួរសំភាសន៍ (Lewis-Beck et al, 2004: 768) ។ ចំលើយចំពោះសំណួរបើក ប្រហែលរៀបរាប់ទស្សនៈរបស់អ្នកឆ្លើយសំភាសន៍ ហើយធ្វើឱ្យអ្នកស្រាវជ្រាវទទួលបានចំលើយដែលគេមិនរំពឹងទុកមុន ។ សំណួរប្រភេទនេះមានភាពសមស្របផងដែរនៅពេលដែលបញ្ជីនៃចំលើយដែលគេអាចនឹងផ្តល់ឱ្យវែង ដែលគេមិនអាចយកមកបង្ហាញបាន ។ បញ្ហានេះធ្វើឱ្យអ្នកឆ្លើយតបសំភាសន៍ផ្តល់ចំលើយពីគំនិតរបស់ខ្លួនផ្ទាល់ ។

***សំណួរបិទ*** *(Close-ended questions)*

សំណួរបិទ គឺជាសំណួរដែលមានចំណាត់ប្រភេទនៃចំលើយច្បាស់លាស់សំរាប់អ្នកឆ្លើយ ។ ប្រភេទ ឬជំរើសទាំងនេះនៃចំលើយគួរតែមានភាពពេញលេញ និងដាច់ៗពីគ្នា (ពោលគឺមិនមានន័យជាន់គ្នា) ។ ឧទាហរណ៍ អ្នកឆ្លើយតបសំភាសន៍អាចផ្តល់ចំលើយច្រើនទៅលើប្រភេទសំណួរខ្លះ ដូចជាទាក់ទងនឹងប្រភពចំណូល សំខាន់ជាងគេរបស់គ្រួសារនៅគ្រប់រដូវកាល ទីផ្សារដែលអ្នកឆ្លើយតបសំភាសន៍អាចលក់ភោគផលរបស់គេ ប្រភេទនៃអនុផលព្រៃឈើដែលគេរកបានពីព្រៃក្បែរខាង ។ល ។ អត្ថប្រយោជន៍នៃការប្រើសំណួរបិទគឺៈ

ក) អ្នកឆ្លើយសំភាសន៍ផ្តល់ចំលើយដែលគួរឱ្យទុកចិត្តនៅពេលត្រូវបានផ្តល់ឱ្យនូវជំរើសផ្សេងៗ

ខ) អ្នកស្រាវជ្រាវអាចធ្វើបានប្រាកដនៅក្នុងការបកស្រាយអត្ថន័យរបស់ចំលើយ និង

គ) នៅពេលណាមាន ចំលើយសំរាប់ឱ្យគេជ្រើសរើសយក នឹងមានមនុស្សគ្រប់ចំនួនឆ្លើយ ដែលនេះគឺជាមូលដ្ឋាននៃការវិភាគ ។

***សំណួរជជីក*** (Probe questions)

ជាទូទៅ អ្នកស្រាវជ្រាវប្រើសំណួរប្រភេទនេះដើម្បីបានចំលើយពេញលេញទៅនឹងសំណួរ ។ វាជាសំណួរឬឃ្លាដែលមិនមានលក្ខណៈបង្គាប់ ហើយត្រូវបានប្រើដើម្បីលើកទឹកចិត្តឱ្យអ្នកឆ្លើយសំភាសន៍ ផ្តល់ភាពលំអិតនូវចំលើយរបស់គេ ។ គេត្រូវចាំថា ការជជីកត្រូវតែមានលក្ខណៈអព្យាក្រឹត្យ ។ ទោះជាយ៉ាងណាក៏ដោយ វាមិនត្រូវប៉ះពាល់ដល់ចំលើយរបស់អ្នកឆ្លើយតបសំភាសន៍ដែលនឹងត្រូវឆ្លើយជាបន្តបន្ទាប់នោះទេ ។

សំណួរជជីកគួរបញ្ចូលទៅក្នុងឧបករណ៍សំភាសន៍ ១ិនតរេវីរ៏ិ នសតរុមនេតជ នៅពេលណាដែលអ្នកសួរសំភាសន៍គិតទុកមុនថានឹងស្វែងរកពត៌មានស៊ីជំរៅ ។ យុទ្ធសាស្ត្រនេះមានផលល្អពីរ :

- វាធ្វើឱ្យអ្នកមានពេលច្រើនសំរាប់តាក់តែងការជជីកបានល្អនិងមានភាពអព្យាក្រឹត្យបំផុត
- អ្នក និងអ្នកស្រាវជ្រាវជាមួយ អាចប្រើរបៀបជជីកដូចគ្នានេះ នៅពេលត្រូវការ ។

## ២. លំអៀងដែលច្រើនមាននៅក្នុងការរៀបចំសំណួរ

***សំណួរនាំមុខ*** (Leading questions)

សំណួរនាំមុខ គឺជាសំណួរដែលប្រាប់អ្នកពីអ្វីដែលអ្នកជឿថាជាចំលើយដែលអ្នកចង់បាន ។ ជាទូទៅសំណួរបែបនេះគួតែគេជៀសវាង ទោះបីជាម្តងម្កាលគេត្រូវសួរសំណួរនេះក្តីដើម្បីឱ្យគេចាប់ផ្តើមនិយាយពីសាច់ការ ដោយជៀសវាងការមិនមាន លក្ខណៈមិនគួរសម ឬសមស្រប ១ណោរាយាន្ឡ ១៩៩៦៊៧៣ជ ។

**ឧទាហរណ៍:**

| | *ត្រូវសួរជាជំនួសវិញ* |
|---|---|
| តើអ្នកមិនគិតទេឬថា....? | តើវាមិនទំនងទេឬថានឹង......? |
| តើអ្នកគិតយ៉ាងដូចម្តេចអំពី....? | តើអ្នកទំនងជាគិតដូចម្តេច.......? |

### សំណួរដែលរៀបមិនបានល្អ

- *ពាក្យពេចន៍មិនគ្រប់* (ឧទាហរណ៍នៃឃ្លាសំណួរមិនពេញ)

| *មិនល្អ* | *គ្រាន់បើជាង* |
|---|---|
| អាយុប៉ុន្មាន? | គិតមកត្រឹមថ្ងៃខួបកំណើតលើកចុងក្រោយតើអ្នកមានអាយុប៉ុន្មាន? |
| ហេតុផលអ្វីទៅពិនិត្យសុខភាពលើកចុងក្រោយ? | តើអ្នកមានបញ្ហាអ្វីផ្នែកសុខភាពឬមានហេតុផលអ្វី ដែលធ្វើឱ្យអ្នកទៅពិនិត្យសុខភាពក្នុងពេលថ្មីៗនេះ? |



- *ការប្រើពាក្យតាមការជ្រើសរើស (មិនចាំបាច់)* (Optional wording)

ពេលខ្លះ គេត្រូវប្រើពាក្យដែលគេអាចជ្រើសរើស សំរាប់កាលៈទេសៈខុសៗគ្នារបស់អ្នកឆ្លើយសំភាសន៍។ ប៉ុន្តែមិនមែនមានន័យថា អ្នកស្រាវជ្រាវមិនចាំបាច់សរសេរសំណួរនោះទេ។ ពាក្យទាំងនេះ (តាមធម្មតាដាក់នៅក្នុងវង់ក្រចក) ត្រូវបានប្រើនៅពេលណាត្រូវការ ហើយបើមិនត្រូវការទេគេលុបចោល ។

**ឧទាហរណ៍ :**

តើមាននរណាវាយធ្វើបាបអ្នក (ឬនរណាម្នាក់រស់នៅទីនេះជាមួយអ្នក) ដោយប្រើកាំភ្លើងនៅក្នុងរយៈពេល ៦ ខែកន្លងមកនេះដែរឬទេ?
តើអ្នក (ប្រុស/ស្រី) បានរាយការណ៍ពីការវាយប្រហារនេះទៅនគរបាលឬទេ?

- *ពាក្យដែលរៀបមិនល្អ*

សំណួរត្រូវតែរៀបដោយធ្វើយ៉ាងណាឱ្យអ្នកឆ្លើយទាំងអស់យល់បានដូចគ្នា។ ជៀសវាងការប្រើពាក្យដែលមនុស្សទូទៅមិនយល់ ឬប្រើទស្សនៈ ឬពាក្យដែលអាចមានន័យច្រើនយ៉ាង ។

**ឧទាហរណ៍ :**

កាលពីឆ្នាំទៅ តើអ្នកបានជួបឬនិយាយជាមួយនឹងវេជ្ជបណ្ឌិតប៉ុន្មានដងអំពីសុខភាពរបស់អ្នក?
តើកាលពីម្សិលមិញ អ្នកមានស្រស់ស្រូបអាហារពេលព្រឹកដែរឬទេ?

- *សំណួរដែលមិនច្បាស់*

ត្រូវឱ្យអ្នកឆ្លើយសំភាសន៍មានការយល់ដូចគ្នាលើអ្វីដែលកំណត់ថាជាចំលើយគ្រប់គ្រាន់ទៅនឹងសំណួរ ។

| *សំណួរមិនច្បាស់* | *សំណួរច្បាស់* |
|---|---|
| តើនៅពេលណាដែលអ្នកចូលរៀន? | តើនៅពេលអ្នកចាប់ផ្តើមចូលរៀន អ្នកមានអាយុប៉ុន្មាន? |

បើសំណួរច្បាស់នោះគេអាចទទួលបានទិន្នន័យដែលមានភាពអាចប្រៀបធៀបគ្នាជានិច្ច ។

ទាក់ទងនឹងរឿងនេះផងដែរគឺសំណួរថា "ហេតុអ្វី" ។ ស្ទើរតែគ្រប់សំណួរទាំងនេះចោទជាបញ្ហាឡើង ។ នេះដោយសារគំរោងនៃសេចក្តីយោង (Frame of Reference) របស់គេមានឥទ្ធិពលលើការឆ្លើយរបស់គេ ។ ឧទាហរណ៍ "ហេតុអ្វីក៏អ្នកបោះឆ្នោតឱ្យបេក្ខជន **ក**?" សំណួរនេះអាចនាំឱ្យគេឆ្លើយថាៈ ក) ចំណុចខ្លាំងរបស់ បេក្ខជន **ក**, ខ) ចំណុចខ្សោយរបស់បេក្ខជន **ខ** គ) អ្នកឆ្លើយសំភាសន៍ប្រើលក្ខណៈវិនិច្ឆ័យណាមួយ ("ម្តាយរបស់ ខ្ញុំគឺជាអ្នកដែលមានជំនឿយ៉ាងខ្លាំងលើគណៈបក្សប្រជាជន") ។ វិធានការដែលល្អជាងនេះគឺបញ្ជាក់ឱ្យច្បាស់ពីចំណុចផ្តោតរបស់ចំលើយ ។

**ឧទាហរណ៍ :**

តើលក្ខណៈអ្វីខ្លះរបស់បេក្ខជន **ក** ដែលធ្វើឱ្យអ្នកបោះឆ្នោតជូនគាត់ ជាជាងជូនបេក្ខជន **ខ**?

ឧទាហរណ៍ខ្លះស្តីពីចំណុចពិភាក្សាខាងលើគឺមានដូចខាងក្រោមនេះ :

| | | |
|---|---|---|
| សំណួរបិទ | សំណួរ : | តើអ្នកបានរស់នៅទីនេះយូរហើយឬ? |
| | ចំលើយ : | បាទ/ចាស៎ តាំងពីកើតមក ។ |
| សំណួរបើក | សំណួរ : | តើអ្នករកស៊ីអ្វី? |
| | ចំលើយ : | ខ្ញុំធ្វើស្រែ |
| សំណួរជជីក | សំណួរ : | មានអ្វីទៀតទេ? |
| | ចំលើយ: | ខ្ញុំចិញ្ចឹមមាន់ និងដាំបន្លែខ្លះដែរ ។ |
| សំណួរបិទ | សំណួរ : | តើជ្រូកនៅក្រោមតុនេះជារបស់អ្នកឬ? |
| | ចំលើយ : | ត្រូវហើយ |
| សំណួរនាំមុខ | សំណួរ : | មនុស្សចាស់ទៅវត្តច្រើនជាងមនុស្សក្មេង មែនទេ? |
| | ចំលើយ : | មែនហើយ ។ សាសនាសំខាន់ណាស់សំរាប់មនុស្សចាស់ ។ ក្មេងៗរវល់រកស៊ី ។ |
| សំណួរបិទ | សំណួរ : | តើអ្នកទៅវត្តញឹកញាប់ទេ? |
| | ចំលើយ : | ទេ |
| សំណួរជជីក | សំណួរ : | ហេតុអ្វីក៏មិនញឹកញាប់? |
| | ចំលើយ : | ដោយសារខ្ញុំរវល់ការងារស្រែចំការពេក ។ |
| សំណួរនាំមុខ | សំណួរ : | តែអ្នកនឹងទៅញឹកញាប់ទេ បើអ្នកមានពេលនោះ? |
| | ចំលើយ : | មែនហើយ |
| សំណួរបើក | សំណួរ : | តើអ្នកធ្វើអ្វីនៅពេលអ្នកឈឺ? |
| | ចំលើយ : | ខ្ញុំទៅរកគ្រូខ្មែរ ។ |
| សំណួរនាំមុខ | សំណួរ : | តើកូនស្រីរបស់អ្នកជាអ្នកមើលថែទាំអ្នកនៅពេលអ្នកឈឺឬ? |
| | ចំលើយ : | ស្ទើរគ្រប់ពេល តែនៅពេលវាមិននៅ អ្នកជិតខាងរបស់ខ្ញុំជួយខ្ញុំ ។ |

### ៣. សំណួរដែលប្រើបច្ចេកទេសតាមកំរិតខ្នាត (Questions using scaling techniques)

សំណួរដែលប្រើវិធីកំរិតខ្នាតធ្វើទៅតាមទំរង់ការដែលដាក់លេខឱ្យរបស់ ឬលក្ខណៈនៃរបស់ហេតុការណ៍ ឬបាតុភូត។ សំណួរបែបនេះត្រូវបានគេប្រើដើម្បីកំណត់បរិមាណទៅលើបាតុភូតដែលគេមិនអាចរាប់ដោយផ្ទាល់បាន ដូចជា ទស្សនៈ ឥរិយាបទ ភាពធ្ងន់ធ្ងរនៃស្ថានភាព។ល។(Lewis-Beck et al, 2004:999)។ ទិន្នន័យដែលប្រមូលបានច្រើន តែមានជាលក្ខណៈលំដាប់លេខរៀង (Ordinal) ពីព្រោះការជ្រើសរើសចំលើយអាចរៀបទៅតាមលំដាប់សំខាន់តិចជាងគេរហូតដល់លំដាប់សំខាន់ជាងគេបំផុត ឬដោយផ្អែកតាមកំរិតខ្លាំងនៃអារម្មណ៍ដែលមើលឃើញ (ឧទាហរណ៍ "មិនយល់ស្របយ៉ាងខ្លាំង" "មិនយល់ស្រប" "យល់ស្រប" "យល់ស្របយ៉ាងខ្លាំង" ទៅលើអំពើហឹង្សានៅក្នុងគ្រួសារ)។ នៅពេលប្រើបច្ចេកទេសកំរិតខ្នាត ត្រូវតែមានភាពខ្ជាប់ខ្ជួនពីខាងក្នុងនៃអ្វីដែលគេយកធ្វើ ជាអាំងឌីកាទ័រនៃអថេរ ឬបញ្ហាដែលគេចង់បានទិន្នន័យរបស់វា ។

### ៤. សំណួរងាយប៉ះពាល់អារម្មណ៍ (Sensitive questions)

អង្គហេតុ ឬព្រឹត្តិការណ៍ដែលមានលក្ខណៈខ្លះដែលមនុស្សមិនចូលចិត្ត ដូចជាអំពើហឹង្សានៅក្នុងគ្រួសារ ការរំលោភផ្លូវភេទ ជំងឺអេដស៍/កាមរោគ តាមធម្មតាមិនសូវគេរាយការណ៍ប្រាប់បានត្រង់ឬអស់សេចក្តីទេនៅក្នុងកិច្ចសំភាសន៍។ ការស្រាវជ្រាវមានលក្ខណៈរសើបនៅពេលដែលវាប៉ះចំទៅលើទិដ្ឋភាពនៃជីវិតដូចជារឿងរាវទាក់ទងផ្លូវភេទ ការស្លាប់ព្រាត់ប្រាស់គ្នា ឬជំនឿផ្ទាល់ខ្លួន ការពិបាកចិត្ត ឬភាពសក្ការៈ (Lewis-Beck et al, 2004:1022)។ បើអ្នកស្រាវជ្រាវរំពឹងឱ្យគេឆ្លើយលើអ្វីដែលជាការអាម៉ាស់ឬខុសច្បាប់នោះ គាត់ត្រូវខិតខំខ្លាំង ដើម្បីធ្វើឱ្យអ្នកឆ្លើយសំភាសន៍ជឿថា ការឆ្លើយនោះមិននាំរឿងធំដុំទេ។ ជំហានខ្លះដែលត្រូវពិចារណាបើសិនជាគេចង់សួរសំណួររសើប (Fowler, 1993:89-90; Lewis-Beck et al, 2004:1022)៖

- តស៊ូបង្កើនការទុកចិត្តរបស់អ្នកឆ្លើយ ហើយធ្វើឱ្យគេអាចទទួលយកបាន ។
- កុំមានអារម្មណ៍វាយតំលៃថាយ៉ាងនេះល្អ យ៉ាងនោះមិនល្អ។ សង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃភាពត្រឹមត្រូវភាពពិត។ អ្នកឆ្លើយសំភាសន៍ត្រូវដឹងថា ទោះបីជាចំលើយរបស់គេមានភាពអវិជ្ជមានក្តីក៏ត្រូវបានឱ្យតំលៃ ឬសំខាន់ដែរ ។
- ការលាក់ការសំងាត់ និងភាពអនាមិក។ ការសន្យាពីការលាក់ការសំងាត់ និងការមិនបញ្ចេញឈ្មោះទាក់ទងនឹងចំលើយក្នុងការអង្កេត ដែលគេបានធ្វើនៅពេលជួបដំបូង ឬនៅក្នុងលិខិត (បើមាន) ច្រើនជួយធ្វើឱ្យអ្នកឆ្លើយសំភាសន៍មានការទុកចិត្ត។ បើមានការចុះហត្ថលេខាធានានោះរឹតតែល្អ ។

### *ទំរង់របស់សំណួរ (Format and Layout of Questions)*

តាមធម្មតា គេសួរសំណួរដែលស្រួល និងត្រង់ៗជាមុន។ សំណួរដែលទាមទារឱ្យមានការគិតច្រើន ឬសំណួររសើបច្រើនតែគេដាក់នៅកណ្តាល ឬនៅផ្នែកខាងក្រោយនៃបទសំភាសន៍។ គោលដៅគឺដើម្បីធ្វើយ៉ាងណាឱ្យដំណើរការនៃការសួរឆ្លើយមានភាពងាយស្រួល។ វិធានទូទៅខ្លះដែលជួយឱ្យសំរេចបានលើការនេះគឺ (Lewis-Beck et al, 2004:518-519; Feuerstein, 1986:83-85)៖

- បញ្ចូលសេចក្តីផ្តើមខ្លីដែលជួយអ្នកសួរសំភាសន៍ឱ្យបំភ្លឺអំពីការសិក្សាស្រាវជ្រាវទៅអ្នកឆ្លើយ ហើយធានាចំពោះគេនូវការសំងាត់ទាក់ទងនឹងពត៌មានដែលគេផ្តល់ឱ្យ ។

- ញែកឱ្យដាច់ពីគ្នារវាងអ្វីដែលគេនឹងអានទៅកាន់អ្នកឆ្លើយតបសំភាសន៍ និងសេចក្តីណែនាំសំរាប់អ្នកស្រាវជ្រាវ ។ ទំលាប់ដែលគេច្រើនធ្វើគឺប្រើអក្សរធំចំពោះសេចក្តីណែនាំសំរាប់អ្នកស្រាវជ្រាវ និងអក្សរតូចសំរាប់សំណួរដែលត្រូវអានឱ្យលឺ ឱ្យអ្នកឆ្លើយតបសំភាសន៍ស្តាប់ ។
- កំណត់វិធីសាស្ត្រឱ្យបានច្បាស់ទាកទងនឹងសំណួរដោយរំលងចោលសំណួរដែលមិនមានការទាក់ទង សំរាប់អ្នកឆ្លើយសំភាសន៍ខ្លះ ។ សេចក្តីណែនាំគួរផ្អែកលើចំលើយពិសេសដោយឡែកហើយប្រាប់ទៅអ្នកសួរសំភាសន៍ថា តើសំណួរបន្ទាប់ទៀតត្រូវសួរត្រង់ណា ។
- ដាក់ពាក្យបន្ថែមដែលមិនចាំបាច់ខ្លាំងនៅក្នុងវង់ក្រចក (របស់គាត់ ប្តី/ប្រពន្ធ កូនស្រី/កូនប្រុស ។ល។)
- ពិនិត្យមើលអោយប្រាកដថា សំណួរទាំងអស់ សេចក្តីផ្តើមចំពោះសំណួរ និយមន័យនិងសេចក្តីពន្យល់ សុទ្ធតែត្រូវបានសរសេរចូល ។
- ជៀសវាងឃ្លាបដិសេធពីរដងនៅក្នុងសំណួរ ។ ជៀសវាងសំណួរដែលមានចំលើយនៅលើគោក (សូម មើលរូប ទី ៧) ។
- សំណួរមួយគួរតែបញ្ជាក់ពីគំនិតមួយបានហើយ ។
- ទុកកន្លែងសំរាប់សរសេរថា ៉មិនមានការទាក់ទង៉ ៉មិនមានចំលើយ៉ អត់ដឹង៉ ។ល ។ ការធ្វើដូច្នេះ បំភ្លឺថា ហេតុអ្វីក៏ទិន្នន័យលើរឿងខ្លះអាចបាត់ ហើយថែមទាំងធ្វើឱ្យមានភាពងាយស្រួលដល់ការវិភាគទិន្នន័យ ។

**រូបទី ៧. ការសួរសំណួរ**




***កំណត់រយៈពេលទៅលើឧបករណ៍អង្កេត*** *(Length of Survey Instrument)*

លក្ខណៈវិនិច្ឆ័យសំរាប់រយៈពេលនៃការសំភាសន៍ គួរមាននិយាយផងដែរពីការចំណាយ (ពេលគឺការធ្វើដំណើរ និងពេលវេលា ចំនួនអ្នកត្រូវសំភាសន៍ក្នុងមួយថ្ងៃ ប្រាក់ឧបត្ថម្ភសំរាប់ការស្រាវជ្រាវ ។ល ។) ឥទ្ធិពលដែល មានទៅលើអត្រាអ្នកឆ្លើយសំភាសន៍ (ឬចំនួនអ្នកដែលស្ម័គ្រចិត្តមកឆ្លើយសំភាសន៍ធៀប នឹងចំនួនដែលត្រូវបាន កំណត់មក) ហើយព្រំដែននៃសមត្ថភាព និងឆន្ទៈឆ្លើយសំណួរ (Fowler, 1993:103) ។ តាមការធ្វើកន្លងមក ដែលគេរកឃើញថា មានប្រសិទ្ធភាពគឺការសំភាសន៍គួរកំណត់រយៈពេលពីមួយម៉ោង ទៅមួយម៉ោងកន្លះ ។

## ***ការចុះធ្វើតេស្តជាមុន*** *(Field Pre-Test)*

ការចុះធ្វើតេស្តជាមុនលើឧបករណ៍នៃការអង្កេតមានបំណងរកមើលថា តើគោលការណ៍ណែនាំលើការប្រមូលទិន្នន័យ និងសំណួរមានដំណើរការយ៉ាងដូចម្តេចនៅក្នុងលក្ខខ័ណ្ឌមែនទែន (Fowler, 1993:100) ។ ទោះបី អ្នកស្រាវជ្រាវខិតខំរៀបចំឧបករណ៍ប្រមូលទិន្នន័យដោយប្រយ័ត្នយ៉ាងណាក៏ដោយ ក៏តែងនៅមានខុសខ្លះមិនខាន ។ អត្ថប្រយោជន៍នៃការធ្វើតេស្តជាមុនគឺមានដូចខាងក្រោមនេះ (McDermot & Sarvela, 1999:156-157; Feuerstein, 1986:86):

- វាអាចផ្តល់ពតិមានដែលអ្នកស្រាវជ្រាវមិនបានគិតដល់ពីដើមមក ដូច្នេះវាជួយអ្នកស្រាវជ្រាវនៅក្នុងការពង្រីក ឬបង្រួមទំហំនៃការសិក្សា ។
- វាអាចកំណត់ភាពសមស្របទៅតាមលក្ខណៈនៃទំរង់ការ និងឧបករណ៍ប្រមូលទិន្នន័យ ។
- វាអាចកំណត់បានថា តើការសំភាសន៍ត្រូវការពេលវេលាប៉ុន្មានដើម្បីសំភាសន៍អ្នកឆ្លើយក្នុងសំណាក ហើយប្រាប់ពីពេលល្អបំផុតសំរាប់ធ្វើការសំភាសន៍ ។

ដោយមានប្រយោជន៍សំរាប់ការអង្កេតធំៗ សំណាកនៃការធ្វើតេស្តជាមុនត្រូវបានជ្រើសរើសចេញពីគំរោងនៃការកំណត់សំណាក ហើយត្រូវបានគេកំណត់ធ្វើនៅក្នុងចំណោមអ្នកឆ្លើយក្នុងចំនួនមិនជាច្រើនដោយប្រើទំរង់ការប្រមូលទិន្នន័យដែលត្រូវបានកំណត់សំរាប់ការសិក្សា ។ ប៉ុន្តែបើការអនុវត្តន៍ដូច្នេះមិនកើតនោះ ការជ្រើសរើសអ្នកឆ្លើយត្រូវតែផ្អែកតាមការមើលឃើញថាស្រួល ឬអ្នកឆ្លើយណាដែលអាចរកបាន ទោះបីជាយ៉ាងណា អ្នកដែលត្រូវបានជ្រើសរើស គួរប្រមើលមើលសំណាកទៅតាមលក្ខណៈដែលត្រូវបានសិក្សា (Lewis-Beck et al, 2004:853) ។

ការធ្វើតេស្តសាកល្បងលើឧបករណ៍អង្កេត ច្រើនតែនាំទៅរកការកែប្រែសំណួរ ការប្រើពាក្យលំដាប់លំដោយ រយៈពេលនៃបទសំភាសន៍ ។ល ។ អាចថាសំណួរខ្លះត្រូវដកចេញ ហើយសំណួរខ្លះទៀតត្រូវថែម ។ បើធនធានអនុញ្ញាតិអោយវាមានប្រយោជន៍ដែលគេសាកល្បងឧបករណ៍ម្តងទៀតក្រោយពីមានការកែសំរួលហើយ ព្រោះថា នេះជាឱកាសតែមួយគត់ដែលគេមានមុនពេលចុះប្រមូលទិន្នន័យយកមែនទែន ។

**ការរំលឹក:** *ត្រូវធ្វើតេស្តសាកល្បងជាមុនលើ ឧបករណ៍របស់អ្នកជាមួយនឹងក្រុមមនុស្សដែលមាន លក្ខណៈប្រហាក់ប្រហែលនឹងក្រុមមនុស្សដែលអ្នកត្រូវធ្វើការប្រមូលទិន្នន័យជាក់ស្តែង ។*

បើការធ្វើតេស្តសាកល្បងត្រូវធ្វើនៅកន្លែងដូចគ្នាជាមួយនឹងកន្លែងដែលនឹងត្រូវស្រាវជ្រាវ ។ ការចុះទៅកន្លែងនោះ អាចផ្តល់ឱកាសឱ្យយើងរកបានបញ្ហា ដែលគួរឱ្យទុកចិត្តពីអាជ្ញាធរមូលដ្ឋាន សំរាប់ការកំណត់សំណាក ។ អ្នកដែលទើបតែបានចាប់ផ្តើមរៀនធ្វើការស្រាវជ្រាវផ្នែកសង្គម គួរចាំផងដែរថា សំណួរគោលសំរាប់ការស្រាវជ្រាវបែបគុណភាព**មិន**ត្រូវបានតេស្តសាកល្បងទេ ដោយសារសំណួរក្នុងការស្រាវជ្រាវបែបគុណភាព ដូចដែលមានរៀបរាប់ខាងដើមរួចហើយថា អាចមានការប្រែប្រួលនៅពេលការប្រមូលទិន្នន័យដំណើរការ ហើយមិនមានសំណួរ ់ស្តង់ដា ់ (Standardisation) ដែលមានចំលើយដូចការស្រាវជ្រាវបែបបរិមាណនោះទេ ។

## ត្រៀមរៀបចំវិភាគទិន្នន័យ (Preparing Data Analysis)

ការរៀបចំសំរាប់ការវិភាគទិន្នន័យចាប់ផ្តើម នៅពេលដែលអ្នកស្រាវជ្រាវត្រិះរិះលើវិធីរកទិន្នន័យសំរាប់សំណួរ និងគោលបំណងស្រាវជ្រាវរបស់គាត់ ពីព្រោះគាត់ត្រូវគិតជាមុនពីវិធីដែលគាត់ប្រមូលចំណេះដឹង និងភស្តុតាងបែបនេះ (Mason, 1996: 19) ។ នៅក្នុងការស្រាវជ្រាវបែបគុណភាព គេត្រូវបន្តធ្វើការឆ្លុះបញ្ចាំងនេះ តាំងពីពេលចុះទៅមូលដ្ឋានដែលជាតំណាក់ការប្រមូលពតិមាន រៀបចំពតិមានតាមលំដាប់ ផ្តុំតាមក្រុម១ ហើយនិងភ្ជាប់គ្នា ព្រមទាំងត្រូវព្យាយាមស្វែងរកភាពស៊ីជំរៅ អោយស្របតាមគោលដៅរបស់ខ្លួនដែលជាញឹកញាប់ចង់ពង្រីក ការយល់ដឹង ឬ ចំណេះដឹងទៅលើប្រធានបទដែលកំពុងត្រូវបានសិក្សាស្រាវជ្រាវ ។

នៅក្នុងការស្រាវជ្រាវបែបបរិមាណ ការរៀបចំបែបនេះមានទំរង់បីខុសគ្នាៈ កំណត់កូដជាមុនលើសំណួរបិទ (Pre-coding the closed-ended questions) រៀបចំតារាងងាយសំរាប់បូកទិន្នន័យ និងប្រព័ន្ធទិន្នន័យ នៅក្នុងកុំព្យូទ័រ (Dummy database) ។

### ១. កំណត់លេខកូដជាមុនលើសំណួរបិទ និងសំណួរបើក

កូដគឺជា បណ្តុំនៃវិធានដែលបកប្រែចំលើយទៅជាលេខ និងពីលេខទៅចំលើយ (Fowler, 1993:125) ។ វាមានន័យថា ចំលើយទាំងអស់ទៅនឹងសំណួរបិទដោយមានជំរើស/ចំណែកថ្នាក់នៃចំលើយត្រូវបានគេដាក់លេខមួយឱ្យ ហើយលេខកូដនិមួយ១អាចនិយាយបានថាតាងឱ្យចំលើយនោះ ។ កូដមួយ១ត្រូវតែដាច់ពីគ្នា ឬអាចតំណាងឱ្យតែចំលើយមួយតែប៉ុណ្ណោះ ហើយមិនអាចប្រើ នៅក្នុងពេលជាមួយគ្នាសំរាប់ប្រភេទចំលើយមួយទៀតទៅនឹងសំណួរដដែលនោះទេ ។ ការវិភាគទិន្នន័យតាមកុំព្យូទ័រច្រើនប្រើកូដជាលេខជាជាងជាអក្សរ ។

ការកំណត់លេខកូដជាមុន គឺជាការងារដែលអ្នកស្រាវជ្រាវធ្វើ នៅពេលដែលគាត់រៀបចំជាមុន តាមភាព សមស្របលើកូដជាលេខសំរាប់ប្រភេទ ឬជំរើសមួយ១នៃចំលើយទៅនឹងសំណួរ *នៅមុន* ការប្រមូលទិន្នន័យ ។ បំណងគឺដើម្បីសំរួលដល់ការបញ្ចូល និងរៀបចំទិន្នន័យ ពិសេសបើអ្នកស្រាវជ្រាវត្រូវធ្វើការវិភាគទិន្នន័យតាមរយៈកម្មវិធីកុំព្យូទ័រ ដូចជា Microsoft Access, Excel ឬ Statistical Package for Social Science (SPSS) ។ នៅក្នុងពេលប្រមូលទិន្នន័យលេខកូដសំរាប់សំណួរនិមួយ១ត្រូវបានគេគូស ឬគូរជារង្វង់ដើម្បីកំណត់ថាជាចំលើយរបស់អ្នកឆ្លើយសំភាសន៍ ។ លេខកូដទាំងនេះ ឬចំនួនត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីកុំព្យូទ័រនៅក្នុងការបង្កើតតារាងទិន្នន័យ ។

ការកំណត់លេខកូដសំរាប់ប្រភេទនៃចំលើយ នាំឱ្យអ្នកស្រាវជ្រាវនឹកដល់អ្វីដែលគាត់ដឹងស្តីពីកំរិតរង្វាស់ ។ អថេរជាសញ្ញាសំគាល់ (Nominal variables) មិនចាំបាច់គេរៀបលំដាប់របស់វាក៏បានដែរមានន័យថា ចំលើយចំពោះសំណួរដែលត្រូវឆ្លើយថាចាស់/បាទឬទេ សំណួរទាក់ទងនឹងយេនឌ័រ (ស្រី/ប្រុស) ក្រុមជនជាតិ (ខ្មែរ ចាម កម្ពុជាក្រោម ។ល។) មិនមែនជាកូដដែលបញ្ជាក់ពីគុណភាពថាមួយណាល្អជាងឬសំខាន់ជាងមួយណានោះទេ ។ ដូច្នេះ សំណួរដែលតំរូវឱ្យឆ្លើយថា បាទ/ចាស់ អាចមានកូដ "១" ឬ "២" មានន័យថា អាចយកបានតែមួយទេ (ដូច្នេះ គេមិនអាចរើសយកលេខកូដ "១" និង "២" នៅក្នុងពេលជាមួយគ្នាបានទេ) ។ ទំរង់ការនេះប្រើចំពោះអថេរដែលមិនមានបែងចែកកំរិតនៃសារៈសំខាន់ផង និងការជ្រើសរើសចំលើយដូចជា "មិនទាក់ទង" "មិនមាន ចំលើយ" "មិនមានមតិ" "អត់ដឹង" ដែលអាចមានលេខកូដជាលេខពីរទៅបីខ្ទង់ ដូចជា ៧៧ ៨៨ ៩៦ ៩៧ ៩៨ ៩៩ ។ល។ ប៉ុន្តែ គេគួរប្រើលេខកូដទាំងនេះដោយប្រុងប្រយ័ត្ន ពីព្រោះអាចមានសំណួរខ្លះទៀតដែលនាំឱ្យមានចំលើយ ប្រហែលគ្នានេះ (ឧទាហរណ៍ អាយុ) ។ នៅក្នុងករណីបែបនេះ អ្នកស្រាវជ្រាវអាចជៀសវាងការ

ប្រើលេខកូដជាន់គ្នាយ៉ាងដូច្នេះបាន ដោយកំណត់កូដផ្សេងទៀត (ឧទាហរណ៍ ប្រើលេខដែលមានបីខ្ទង់) ដើម្បីបង្ហាញជំរើសលើចំលើយដោយឡែកទាំងនេះ ។ កូដដែលត្រូវបានកំណត់សំរាប់ចំលើយប្រភេទនេះ ក៏គួរតែគេប្រើដោយខ្ជាប់ខ្ជួននៅក្នុងឧបករណ៍ ប្រមូលទិន្នន័យទាំងមូល ដើម្បីកាត់បន្ថយនូវលំអៀងនៅពេលបញ្ចូលទិន្នន័យ ។

សំណួរដែលផ្តោតលើកំរិតនៃសារៈសំខាន់ (នោះគឺខ្នាត ឬអថេរលំដាប់លេខរៀង អាចឱ្យគេតំរៀបលំដាប់បាន ពីព្រោះចំណែកថ្នាក់នៃចំលើយអាចត្រូវបានកំណត់លំដាប់បាន ។ ឧទាហរណ៍នៃសំណួរបែបនេះ មានដូចជាសំណួរដែលកំណត់ក្រុមអាយុ (ក្រោម ១៩ ឆ្នាំ ពី ១៩ឆ្នាំដល់២៨ ឆ្នាំ ពី ២៩ឆ្នាំ ដល់ ៣៣ឆ្នាំ ពី៣៤ ឆ្នាំដល់ ៣៨ ឆ្នាំ និងចាប់ពី ៣៩ឆ្នាំឡើងទៅ) ក្រុមទំហំគ្រួសារ (ឧទាហរណ៍ គ្រួសារដែលមានតែមនុស្សម្នាក់ គ្រួសារដែលមាន សមាជិកពី ២នាក់ ដល់ ៤នាក់ ពី ៥នាក់ ដល់ ៧នាក់ ចាប់ពី ៨នាក់ឡើងទៅ) ក្រុមកំរិតនៃការសិក្សា (មិនបាន ចូលសាលារៀន ថ្នាក់អក្ខរកម្ម ពីថ្នាក់ទី ១ ដល់ទី ៣ ពីទី៤ ដល់ ទី៦ ពីទី៧ ដល់ទី ៩ ពីទី ១០ ដល់ទី ១២) ។ល។ នៅក្នុងករណីបែបនេះ ចំលើយដែលគេអាចនឹងឆ្លើយមានគុណភាពតិច ឬច្រើនជាងគុណភាពក្នុងចំណែកថ្នាក់ ។ ដូច្នេះ ការជ្រើសរើសបែបនេះលើចំលើយមានទៅតាមលំដាប់ដែលក្នុងនោះគេអាចដឹងពីកំរិតនៃទំហំ ។

ម្យ៉ាងវិញទៀត សំណួរដែលសួររកចំនួនជាក់ច្បាស់ (ច្រើនតែជារង្វាស់នៃកំរិតចន្លោះ ឬអនុបាត មិនទាមទារលេខកូដទេ ។ ពោលគឺថា សំណួរស្តីពីអាយុ ចំនួនកូន ចំនួនឆ្នាំរស់នៅក្នុងភូមិ ចំនួនឆ្នាំធ្វើការនៅក្នុងរោងចក្រកាត់ដេរ ។ល។ គ្រាន់តែទាមទារចំលើយដែលឆ្លុះបញ្ចាំងចំនួន/តួលេខជាក់ស្តែង ។ ជានិច្ចកាល គេគួរសួររក ចំនួនជាក់ស្តែងលើសំណួរប្រភេទនេះ ពីព្រោះការធ្វើដូច្នេះជួយឱ្យគេងាយគិតជាមធ្យម និងសេចក្តីសង្ខេបផ្សេងទៀតលើស្ថិតិ ជាងការសុំចំលើយដែលផ្អែកតាមការកំណត់ជាក្រុម ។

ធម្មតាសំណួរបើកមិនត្រូវបានគេកំណត់លេខកូដជាមុនទេដោយមានហេតុផលច្បាស់ ។ ដោយសារអ្នកឆ្លើយអាចផ្តល់ចំលើយបានក្នុងកំរិតលើប្រភេទសំណួរបែបនេះ នោះការដាក់លេខកូដឱ្យចំលើយទាំងនេះ មានធ្វើក្រោយពីទិន្នន័យត្រូវបានប្រមូលរៀបជាបញ្ជី ហើយពិនិត្យមើលឡើងវិញ ។ ចំលើយដែលស្រដៀងគ្នាត្រូវបាន ផ្តុំជាក្រុមៗរួចហើយត្រូវបានគេកំណត់កូដឱ្យ ។ ដូច្នេះ ការកំណត់កូដច្រើនតែប្រើជាមួយនឹង សំណួរបិទទេ ។

ប្រអប់ទី ៥ៈ បង្ហាញតារាងពេលវេលាសំភាសន៍ ឬកំរងសំណួរដែលឆ្លុះបញ្ចាំងលើសេចក្តីខាងលើនេះ ។

## ២. ការរៀបចំតារាងសំរាប់ប្លុកទិន្នន័យ (Preparing Dummy Tables)

តារាងសំរាប់ប្លុកទិន្នន័យ គឺជាតារាងទទេ (ឬគ្មាននិយាយអ្វី) ដែលគេរៀបចំមុនពេលប្រមូលទិន្នន័យ ហើយគេដាក់ទិន្នន័យចូលទៅក្នុងនោះ នៅពេលដែលទិន្នន័យត្រូវបានប្រមូល និងបញ្ចូលរួច (Vogt, 1993:75) ។ តារាងនេះគ្រាន់តែបង្ហាញឈ្មោះដែលរៀបរាប់ពីអថេរសំរាប់រាប់ប្រេកង់ និងភាគរយនិងតួលេខសង្ខេបដទៃទៀត (ដូចជាចំនួនមធ្យម) ត្រូវបានលើកបង្ហាញ ។ ឧទាហរណ៍នៃតារាង ចំនួនបីខាងក្រោមនេះផ្អែកលើកការសិក្សានៅឆ្នាំ ២០០៥ របស់ CCC - ADI ទៅលើ *ផលប៉ះពាល់នៃឧស្សាហកម្មកាត់ដេរទៅលើជីវភាពរស់នៅតាមជនបទ* ។

## ប្រអប់ ៥.  សំណាកនៃប្រក្រតីទិនសំរាប់សំភាសន៍

<table>
<tr><td>សេចក្តីផ្តើម</td><td>បញ្ជីសំណួរសំភាសន៍ផ្ទាល់  ជាមួយកម្មកររោងចក្រកាត់ដេរ<br><br>ជំរាបសួរ! ខ្ញុំឈ្មោះ......ខ្ញុំធ្វើការជាអ្នកស្រាវជ្រាវជាមួយនឹងក្រុម ដែលកំពុងតែធ្វើការសិក្សាទៅលើអ្នកដែលធ្វើចំណាកស្រុកមកធ្វើការជាកម្មកររោងចក្រនៅភ្នំពេញ និងគ្រួសាររបស់គេនៅព្រៃវែង ។ ការសិក្សាមានបំណងពិនិត្យមើលបទពិសោធន៍របស់កម្មកររោងចក្រកាត់ដេរ និងការរួមចំណែកនៃឧស្សាហកម្មកាត់ដេរដល់ជីវភាពរស់នៅ របស់គ្រួសារកម្មករ ។ គេរំពឹងថា ការសិក្សានេះនឹងផ្តល់អនុសាសន៍ថា តើធ្វើយ៉ាងដូចម្តេច ដើម្បីលើកកំពស់លក្ខខ័ណ្ឌការងាររបស់កម្មកររោងចក្រកាត់ដេរ ការជួយដល់ជីវភាពរស់នៅរបស់គ្រួសាររបស់គេនៅព្រៃវែងជាមួយនឹងលុយដែលត្រូវបានផ្ញើរមកឱ្យដោយសមាជិកជាកម្មករកាត់ដេរ ។<br><br>យើងមានសំណួរមួយចំនួនដែលយើងចង់សួរអ្នក ប៉ុន្តែ សូមជឿថាចំលើយរបស់អ្នកគឺយើងមិនឱ្យអ្នកណាដឹងទេ ។ ក្នុងការសំភាសន៍ យើងមានកត់ទុក នូវចំលើយខ្លះរបស់អ្នក ។ តើអ្នកមានពេលជួយយើងនៅក្នុងការសិក្សារបស់យើងដែរឬទេ?</td></tr>
<tr><td>អ្នកឆ្លើយ/ទីកន្លែង</td><td>អត្តសញ្ញាណ<br><br>ថ្ងៃខែឆ្នាំ :...........................................<br>អ្នកសំភាសន៍: .....................................<br>ឈ្មោះកម្មករដែលត្រូវសំភាសន៍ :.............................................<br>ស្រុក :..................ឃុំ :.............................ភូមិ : ...................<br>ចំនួនកម្មករ :....................................................</td></tr>
<tr><td>កំណត់ប្រភេទនៃចំលើយ (លេខ ១ និង ២ គឺជាលេខកូដ)<br><br>ចំលើយដែលឆ្លុះបញ្ចាំងពីចំនួនឆ្នាំពិតប្រាកដនៃការសិក្សាអប់រំហើយ និងលេខកូដ (0)</td><td>ប្រវត្តិ<br>១.០១ ភេទអ្នកដែលត្រូវបានសំភាសន៍<br>១ ប្រុស<br>២ ស្រី<br><br>១.០២ អាយុរបស់កម្មករដែលត្រូវបានសំភាសន៍:  ....................ចូរសរសេរចំនួនពិត<br><br>១.០៣ កំរិតវប្បធម៌របស់កម្មករដែលត្រូវបានសំភាសន៍<br>..................... សរសេរថ្នាក់ដែលរៀនដល់<br>0   មិនបានចូលសាលា/មិនមានការទាក់ទង</td></tr>
</table>

| | |
|---|---|
| ចំណែកថ្នាក់នៃចំលើយ និងកូដរបស់វា (១ ២ ៣ និង ៤ គឺជាកូដ) | ១.០៤ ស្ថានភាពអាពាហ៍ពិពាហ៍របស់កម្មករដែលត្រូវបានសំភាសន៍:<br>១ មានប្តី/ប្រពន្ធ<br>២ មេម៉ាយ/ពោះម៉ាយ<br>៣ បែកគ្នា/លែងគ្នា<br>៤ នៅលីវ (មិនដែលរៀបការ) |
| ចំលើយដែលឆ្លុះបញ្ចាំងពីចំនួនពិតប្រាកដនៃកូដជាជាងលេខកូដ និងកូដ (៩៦) | ១.០៥ ចំនួនកូនរបស់កម្មករដែលត្រូវបានសំភាសន៍<br>........................សរសេរចំនួនពិត<br>៩៦ មិនមានការទាក់ទង |
| ចំណែកថ្នាក់នៃចំលើយ (១ ២ និង ៩៦ គឺជាកូដ) | ១.០៦ បើមានប្តី/ប្រពន្ធ តើប្តីប្រពន្ធនោះនៅជាមួយនឹងអ្នកនៅភ្នំពេញឬទេ?<br>១ នៅជាមួយ<br>២ មិននៅជាមួយទេ<br>៩៦ មិនមានការពាក់ព័ន្ធ |

តារាងបូកសរុបជាឧទាហរណ៍ទី ១. ហេតុផលដែលកម្មករធ្វើចំណាកស្រុកពីខេត្តព្រៃវែងមកធ្វើការនៅភ្នំពេញ ខែកញ្ញា-តុលា ឆ្នាំ ២០០៤ (*ផ្អែកតាមកំរងសំណួរសំរាប់កម្មករម្នាក់ៗ*)

| ហេតុផល | ចំនួន | ភាគរយ |
|---|---|---|
| ហេតុផលទី ១ហេតុផលទី ២ | | |
| ហេតុផលទី ៣ | | |
| សរុប | | |

តារាងបូកសរុបជាឧទាហរណ៍ទី ២ លក្ខណៈខ្លះរបស់គ្រួសារដែលមានសមាជិកធ្វើជាកម្មករកាត់ដេរនៅភ្នំពេញ ខែកញ្ញា-តុលា ឆ្នាំ ២០០៤(*ផ្អែកតាមកំរងសំណួរសំរាប់គ្រួសារកម្មករកាត់ដេរ-មិនប្រើនៅក្នុងរបាយការណ៍ចុងក្រោយទេ*)

| លក្ខណៈ | មធ្យម |
|---|---|
| ចំនួនមធ្យមនៃសមាជិកគ្រួសារដែលអាចធ្វើការចិញ្ចឹមជីវភាពបាន | |
| ចំនួនមធ្យមនៃអ្នកធ្វើការរបស់គ្រួសារដែលនៅពេលនេះកំពុង ធ្វើការនៅតំបន់ឆ្ងាយពីផ្ទះ | |
| ចំនួនមធ្យមនៃអ្នកចេញទៅធ្វើការដែលធ្វើការជាកម្មករកាត់ដេរ | |

តារាងបូកសរុបជាឧទាហរណ៍ទី ៣ៈ ការតំរៀបលំដាប់នៃប្រភពចិញ្ចឹមជីវភាពនៅក្នុងឃុំចំនួនពីរនៅព្រៃវែង ខែកញ្ញា-តុលា ឆ្នាំ ២០០៤ (*ផ្អែកតាមកំរងសំណួរសំរាប់គ្រួសាររបស់កម្មករកាត់ដេរ*)

| ប្រភពចំណូល | សំខាន់ជាងគេ | | សំខាន់ទី ២ | | សំខាន់ទី ៣ | | សំខាន់ទី ៤ | | សំខាន់ទី ៥ | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| ប្រភពចំណូលទី ១ | | | | | | | | | | |
| ប្រភពចំណូលទី ២ | | | | | | | | | | |
| ប្រភពចំណូលទី ៣ | | | | | | | | | | |
| សរុប | | | | | | | | | | |

ការរៀបតារាងសរុបទិន្នន័យគួរតែធ្វើតាមពតិមាន ដែលធ្វើឱ្យអ្នកស្រាវជ្រាវអាចឆ្លើយសំណួរស្រាវជ្រាវ និងគោលបំណងស្រាវជ្រាវដែលគាត់បានបញ្ជាក់ ។ បើសិនជាគេមិនចងចាំវាទេនោះ គេអាចនឹងបង្កើតតារាងច្រើន ហើយក្រោយមកមិនប្រើវា នៅពេលគេពុំមានពេលវេលាហើយធ្វើឱ្យគេមិនអាចទាញយកទិន្នន័យដែលគេត្រូវប្រើដើម្បីបំពេញតារាង ហើយធ្វើមិនឱ្យគេអាចបកស្រាយ/សរសេរចេញនូវចំនុចសំខាន់ៗនៃតារាងទាំងនេះទេ ។

## ៣. **រៀបចំប្រព័ន្ធទិន្នន័យក្នុងកុំព្យូទ័រ** (Preparing ‘dummy’ database)

ប្រព័ន្ធទិន្នន័យក្នុងកុំព្យូទ័រ គឺជាបណ្តុំនៃទិន្នន័យដែលត្រូវបានរៀបចំឡើង សំរាប់ការទាញយកទិន្នន័យមកប្រើប្រាស់រហ័សទាន់ចិត្តតាមរយៈកុំព្យូទ័រ ហើយវាច្រើនតែជាការប្រមូលផ្តុំនៃកំណត់ត្រាជាច្រើនដែលគេបញ្ចូលទុកពីមុនដោយឡែកពីគ្នា (Vogt, 1993:59) ។ តាមធម្មតា វាត្រូវបានបង្ហាញតាមតារាងម៉ាទ្រិចជាជួរផ្តេក និងបញ្ឈរ ។ ជួរផ្តេកនីមួយៗតំណាងឱ្យកំណត់ហេតុមួយៗ (ពោលគឺថាទិន្នន័យទាំងអស់ដែលទាក់ទងនឹងបុគ្គល ករណី ឬកិច្ចសំភាសន៍នីមួយៗ) ឬអ្នកឆ្លើយម្នាក់ចំណែកជួរបញ្ឈរទាក់ទងនឹងសំណួរនីមួយៗ (ឬហៅម្យ៉ាងទៀតថា អថេរ នៅក្នុងឧបករណ៍ប្រមូលទិន្នន័យ ។ គឺឯកសារទិន្នន័យដំបូងនេះ/ម៉ាទ្រិចនៃជួរផ្តេក និងបញ្ឈរនេះហើយ ដែលអ្នកស្រាវជ្រាវអាចធ្វើការនៅមុនពេលប្រមូលទិន្នន័យ ។ ការរៀបចំនេះថែមទាំងមានធ្វើនៅក្នុងពេលប្រមូលទិន្នន័យបើសិនជាអ្នកណាម្នាក់អាចទទួលធ្វើការងារនេះនៅពេលអ្នកស្រាវជ្រាវកំពុងប្រមូលពតិមានដែលត្រូវការ ។ នៅពេលទិន្នន័យត្រូវបានប្រមូលកែសំរួលជំរះអស់ ហើយបញ្ចូលទិន្នន័យ ឬដាក់លេខកូដ អាចត្រូវបានគេបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យសំរាប់អ្នកមិនយល់ដែលត្រូវបានបង្កើតហើយ ។

ការសំរេចចិត្តយ៉ាងសំខាន់ នៅក្នុងការតំរៀបជាស្រេចលើមូលដ្ឋានទិន្នន័យបានត្រូវកំណត់នៅក្នុងកម្មវិធីកុំព្យូទ័រ (Computer software) ឬកម្មវិធីកុំព្យូទ័រដែលត្រូវប្រើ ពីព្រោះកម្មវិធីខុសគ្នាតំរូវឱ្យមានរបៀបរៀបចំខុសគ្នា (Fowler, 1993:124) ។ ឧទាហរណ៍ ការប្រើកម្មវិធី Microsoft Access សំរាប់ដាក់កូដទិន្នន័យ ធ្វើឱ្យអ្នកស្រាវជ្រាវនៅក្នុងដំណាក់កាលរៀបចំមូលដ្ឋានទិន្នន័យ អាចកំណត់វិធានដែលក្នុងនោះកុំព្យូទ័របដិសេធ លេខកូដមួយ នៅពេលគេបញ្ចូលទិន្នន័យមិនត្រឹមត្រូវ

ពីព្រោះវាមិនស្ថិតនៅក្នុងរង្វង់កំណត់នៃកូដរបស់សំណួរ ។ តែការប្រើកម្មវិធី SPSS ទាមទារឱ្យអ្នកស្រាវជ្រាវកំណត់អថេរពេលគឺថា គាត់ត្រូវបញ្ជាក់នៅក្នុងជួរបញ្ឈរនីមួយៗ នូវឈ្មោះនៃអថេរ (ឬលេខសំណួរ នៅក្នុងឧបករណ៍សំភាសន៍) តើកំរិតរង្វាស់របស់វាគឺអ្វី តើមានប៉ុន្មាន តួអក្សរដែលត្រូវចុះក្នុងជួរបញ្ឈរ តើតំលៃលេខកូដ ប៉ុន្មានសំរាប់ចំលើយមួយណា ។ល។

នៅក្នុងការរៀបចំប្រព័ន្ធទិន្នន័យនៅក្នុងកុំព្យូទ័រ អ្នកស្រាវជ្រាវត្រូវដឹងថា សំណុំទិន្នន័យមួយ (Data file) អាចទទួលយកបានឯកតានៃការវិភាគតែមួយទេ ។ បើគេប្រើឯកតានៃការវិភាគពីរ ឬបីក្នុងពេលជាមួយគ្នា មានន័យថា សំណុំទិន្នន័យពីរ ឬលើសពីពីរ គួរតែគេរៀបចំអោយរួចជាស្រេច ។ ដូច្នេះ បើការវិភាគត្រូវធ្វើនៅកំរិតបុគ្គល និងកំរិតគ្រួសារ គេត្រូវរៀបចំសំណុំទិន្នន័យអោយដូចគ្នានឹងឯកតានៃការវិភាគនេះដែរ ។

ជំពូក ៤

# ផ្នែកទី ៣

# ការអនុវត្តន៍នៅតាមមូលដ្ឋាន និង ការវិភាគទិន្នន័យ

## ជំហានទី ៣ : ការប្រមូល រៀបចំចំណាត់ថ្នាក់ និងរៀបចំចងក្រងពត៌មាន


ក្រមសីលធម៌នៅក្នុងការសិក្សាស្រាវជ្រាវ ........ ៧៧

ការស្វែងយល់អំពីអត្រានៃការឆ្លើយតប ........ ៧៨

បច្ចេកទេសសំភាសន៍ និងកត់ត្រា ........ ៧៩

ដំណើរការបញ្ចូល និងសង្ខេបទិន្នន័យ ........ ៨៣

រៀបចំទំរង់នៃរបាយការណ៍ ........ ៩៥

# ជំហានទី ៣ : ការប្រមូល រៀបចំចំណាត់ថ្នាក់ និងរៀបចំចងក្រងពត៌មាន

*ក្រមសីលធមិនៅក្នុងការស្រាវជ្រាវ.... បច្ចេកទេសសំភាសន៍ និងបច្ចេកទេសកត់ត្រា ........សង្ខេបទិន្នន័យ ........រៀបចំគំរោងរបាយការណ៍*

| ជំហានទី ៣ | |
|---|---|
| បច្ចេកទេស/ឧបករណ៍ប្រមូលទិន្នន័យ | ការបញ្ចូលទិន្នន័យ |
| | |
| | |
| | |

## ក្រមសីលធមិនៅក្នុងការស្រាវជ្រាវ

ការធ្វើការស្រាវជ្រាវផ្នែកសង្គម មានភ្ជាប់មកជាមួយនូវការគិតពិចារណាខាងក្រមសីលធមិដែរ ។ ដោយសារការងាររបស់យើងធ្វើជាមួយនឹងមនុស្ស ដូច្នេះគោលការណ៍ណែនាំត្រូវមានជាចាំបាច់នៅក្នុងអ្វីដែលយើងធ្វើ ពីព្រោះវាប្រាប់យើងពីអ្វីដែលសង្គម អាចទទួលយកបាន ឬមិនទទួលយកបាន នៅពេលយើងធ្វើការជាមួយនឹងអ្នកផ្តល់ចំលើយរបស់យើង ។ ចំណុចពីរនៃក្រមសីលធមិនៅក្នុងការស្រាវជ្រាវផ្នែកសង្គម គឺមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ភាពឯកជន និងការសំងាត់ ហើយការយល់ព្រមដោយមានការគិតគូរត្រឹមត្រូវ/ការចូលរួមដោយស្ម័គ្រចិត្ត ត្រូវបានរៀបរាប់ខ្លីៗខាងក្រោមនេះ (Burns, 2000:17-21; Babbie, 1998:38; Fowler, 1993:132-134) ។

១. ការមិនធ្វើឱ្យប៉ះពាល់ដល់ការសំងាត់/ភាពឯកជន ត្រូវបានចាត់ទុកថាជាវិធានទីមួយនៃផ្នែកក្រមសីលធមិ ។ អ្នកស្រាវជ្រាវផ្នែកសង្គម ត្រូវដឹងជានិច្ចថាគេអាចនឹងធ្វើឱ្យប៉ះពាល់ដោយអចេតនាដល់អ្នកឆ្លើយ និង/ឬសហគមន៍របស់គេ ។ បញ្ហានេះកើតមាននៅពេលដែលពត៌មានដែលអាចធ្វើឱ្យប៉ះពាល់ដល់អ្នកឆ្លើយ ហើយត្រូវបានគេទំលាយប្រាប់ទៅអ្នកដទៃជាពិសេសរឿងទាក់ទងនឹងការមាក់ងាយនៅក្នុងសង្គម (ឧទាហរណ៍ ការរំលោភផ្លូវភេទ ការដែលត្រូវបានគេយកទៅលក់) ។ នេះជាទំរង់ការខ្លះ ដើម្បីកាត់បន្ថយលទ្ធភាពនៃការរំលោភលើការសំងាត់ :

- អ្នកពាក់ព័ន្ធនៅក្នុងការស្រាវជ្រាវ ត្រូវតែសន្យាជាលាយលក្ខណ៍អក្សរថានឹងរក្សាការសំងាត់ចំពោះពត៌មានដែលបានទទួល ។
- កាត់បន្ថយឱ្យបានច្រើនបំផុតនូវចំលើយ និងអ្វីៗទាក់ទងដែលនាំឱ្យគេដឹងអត្តសញ្ញាណរបស់អ្នកនិយាយ ។
- ឧបករណ៍ ឬឯកសារសំភាសន៍ទាំងអស់ មិនត្រូវឱ្យអ្នកក្រៅពីសមាជិកក្រុមស្រាវជ្រាវដឹងទេ ។
- សំណុំបញ្ជីទិន្នន័យត្រូវស៊ីគ្នានឹងលេខសំគាល់ (ID Number) (លេខឧបករណ៍សំភាសន៍/កំរងសំណួរ)
- ទុកដាក់ឧបករណ៍សំភាសន៍ឱ្យបានត្រឹមត្រូវ នៅពេលលែងប្រើឧបករណ៍ចុះអង្កេត ។

២. ការចូលរួមដោយស្ម័គ្រចិត្ត និងការយល់ព្រមដោយមានការគិតគូរត្រឹមត្រូវ-ក៏ជាគោលការណ៍ក្រមសីលធមិសំខាន់មួយដែរចំពោះការស្រាវជ្រាវផ្នែកសង្គម ។ អ្នកឆ្លើយត្រូវយល់ពីលក្ខណៈ និងបំណងនៃការស្រាវជ្រាវ ហើយត្រូវផ្តល់ការយល់ព្រមរបស់គេ ចំពោះការចូលរួមដោយមិនមានការបង្ខិតបង្ខំឡើយ ។ អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ ច្រើនតែធ្វើតាមរបៀបនេះគឺ

ដោយឱ្យអ្នកចូលរួមចុះហត្ថលេខាយល់ព្រមលើឯកសារមិនផ្លូវការដែលមាននិយាយពីបំណងនៃការស្រាវជ្រាវ ទំរង់ការហានិភ័យ និងការរំខាន អត្ថប្រយោជន៍ និងសិទ្ធិដកខ្លួន ឬមិនបន្តការសំភាសន៍។ ការយល់ព្រមរបស់អ្នកឆ្លើយនៅពេលថតសំលេងក្នុងការសំភាសន៍ ក្នុងករណីចាំបាច់ គួរតែគេស្នើសុំការយល់ព្រម។

ទាក់ទងនឹងចំនុចខាងលើនេះដែរ វាជាទទួលខុសត្រូវរបស់អ្នកស្រាវជ្រាវ ចំពោះក្រុមអ្នកចុះសំភាសន៍របស់គាត់ បើមានក្រុមអ្នកចុះសំភាសន៍មានការចូលរួមពាក់ព័ន្ធ (Fowler, 1993:135)។ និយាយឱ្យចំទៅ គាត់ត្រូវធ្វើយ៉ាងណាឱ្យក្រុមអ្នកចុះសំភាសន៍របស់គាត់ទទួលបានពត៌មានពេញលេញ និងត្រឹមត្រូវសំរាប់ផ្តល់ ឱ្យទាក់ទងនឹងការស្រាវជ្រាវដើម្បីកុំឱ្យគេអាចកុហក ឬផ្តល់ពត៌មានដែលមិនពិត។ គាត់ត្រូវទទួលខុសត្រូវលើសុវត្ថិភាពរបស់អ្នកចុះសំភាសន៍ ពីព្រោះអ្នកចុះសំភាសន៍អាចនឹងត្រូវចុះទៅដល់តំបន់ដែលមានបទល្មើសច្រើន ឬអាចឆ្លងជំងឺឆ្លងបាន។ ក្រុមអ្នកចុះសំភាសន៍ ត្រូវតែទទួលបានពត៌មានទាក់ទងនឹងទីតាំងដែលគេត្រូវចុះទៅដើម្បីធានាសុវត្ថិភាពរបស់គេ។

បញ្ហាមួយទៀត ដែលទាក់ទងនឹងក្រមសីលធមិនៅក្នុងការស្រាវជ្រាវផ្នែកសង្គមផងដែរ គឺការលួចចំលងយកគំនិតគេ។ បើយោងទៅតាម Babbie (1998:A18) ការចំលងយកលទ្ធផលរបស់គេ (Plagiarism) គឺជា "ការលួចពាក្យ និង/ឬគំនិតរបស់អ្នកដទៃណាម្នាក់ - ទោះដោយចេតនា ឬអចេតនាក្តី - ដើម្បីយកមកធ្វើជាពាក្យ ឬគំនិតនោះរបស់អ្នក"។ អ្នកស្រាវជ្រាវផ្នែកសង្គមនេះ ថែមទាំងលើកឡើងនូវវិធានជាមូលដ្ឋានចំពោះការលួចចំលងគំនិតយោបល់របស់អ្នកឯទៀតដូចតទៅ :

- គេមិនអាចប្រើពាក្យដូចគ្នាបេះបិទរបស់អ្នកនិពន្ធមួយទៀត ដោយមិនប្រើសញ្ញាអញ្ញប្រកាស ហើយនិងប្រភពនោះទេ។ ការប្រាប់ពីប្រភពនៃពាក្យដកស្រង់ ធ្វើឱ្យអ្នកអានដឹងពីភាពដើមរបស់ពាក្យ ឬគំនិតនោះ។ ជាទូទៅ ការលួចស្រង់ពាក្យគេចាប់ពី ៨ពាក្យឡើងទៅ ដោយគ្មានការផ្តល់ប្រភពច្បាស់លាស់ គឺជាការរំលោភច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ។
- លើសពីនេះ គេមិនអាចកែប្រែ ឬរៀបឃ្លាឡើងវិញរបស់អ្នកដទៃ ហើយយកធ្វើជាស្នាដៃខ្លួនឯងបានទេ។
- ការលើកយកគំនិតរបស់អ្នកដទៃធ្វើជារបស់ខ្លួនក៏មិនបានដែរ បើទោះបីជាអ្នកប្រើពាក្យខុសគ្នាទាំងស្រុងសំរាប់គំនិតទាំងនោះក៏ដោយ។

ការលួចយកគំនិតរបស់អ្នកដទៃគឺជាការខុសច្បាប់ ហើយអាចនឹងរងការប្តឹងប្តល់។ អ្នកស្រាវជ្រាវផ្នែកសង្គមជាច្រើនដែលនៅថ្មីថ្មោង និងអ្នកដែលមានបទពិសោធន៍ច្រើនឆ្នាំហើយ ក៏អាចនឹងមានបញ្ហានេះដែរ ដោយគេគិតថា អ្នកអាន ឬអ្នកប្រើប្រាស់ផលិតផលចុងក្រោយរបស់គេនឹងមិនដឹងពីរឿងការយកពាក្យ ឬឃ្លាប្រយោគដែលមាននៅក្នុងការងាររបស់គេនោះ។ តាមពិតអ្នកនិពន្ធដើម (ពិសេសអ្នកស្រាវជ្រាវ) នៅក្នុងការសិក្សាទាំងនេះ ដែលគំនិត ពាក្យ និងប្រយោគរបស់គេត្រូវបានលួច អាចនឹងត្រូវបានរកឃើញព្រោះគាត់តាមដានហេតុការណ៍ និងការស្រាវជ្រាវថ្មីៗដែលទាក់ទងនឹងវិស័យរបស់គាត់ដែរ។ ហេតុនេះហើយមិនយូរមិនឆាប់អ្នកលួចពាក្យ ឬគំនិតរបស់គេ នឹងត្រូវបានបកអាក្រាត ព្រមទាំងត្រូវបាត់បង់មុខមាត់ និងការទទួលស្គាល់។

## ការស្វែងយល់អំពីអត្រានៃការឆ្លើយតប (Understanding response rate)

វិធានការជាមូលដ្ឋាននៅក្នុងការវាយតំលៃការងារប្រមូលទិន្នន័យ អត្រានៃការឆ្លើយយោងទៅរកចំនួនមនុស្សដែលត្រូវបានសំភាសន៍ (ឬឆ្លើយ) ចែកនឹងចំនួនមនុស្ស (ឬក្រុម) ដែលត្រូវបានកំណត់ជាសំណាក (Fowler, 1993:39)។ ភាគបែង (Denominator) រួមមានមនុស្សទាំងអស់ដែលនៅក្រោមការស្រាវជ្រាវ ដែលត្រូវបានជ្រើសរើសឡើងតែមិនឆ្លើយដោយហេតុផលផ្សេងៗ ដូចជាការមិនព្រមឆ្លើយ បញ្ហាផ្នែកភាសា ការមានជំងឺ ឬការមិនមានពេលទំនេរនៅឆ្លើយ។ ទស្សនៈនេះមាន

សារៈសំខាន់នៅក្នុងការស្រាវជ្រាវផ្នែកសង្គមពីព្រោះអត្រា នៃការឆ្លើយខ្ពស់ មានន័យថា ទិន្នន័យកាន់តែមានភាពដែលគេអាចជឿជាក់បានកាន់តែច្រើន ហើយការមិនឆ្លើយ អាចនាំឱ្យគេចំណាយកាន់តែច្រើនលើការប្រមូលទិន្នន័យ (Lewis-Beck et al, 2004:740) ។

អត្រានៃការឆ្លើយអាចពិនិត្យមើលនៅលំដាប់អ្នកឆ្លើយ (''ឯកតា'' មិនឆ្លើយ) ('Unit' non-response) ឬនៅលំដាប់ថ្នាក់សំណួរ (សំណួរ ''មិនមានចំលើយ'') ។ ឯកតាមិនឆ្លើយអាចមានដោយសារហេតុផលដែលនិយាយពីដើមមក-ការមិនព្រមឆ្លើយ បញ្ហាភាសា ។ល ។ ឧទាហរណ៍ ការមិនព្រមឆ្លើយមាននៅក្នុងករណីដែលឪពុកម្តាយ មិនអនុញ្ញាតិឱ្យមានការសំភាសន៍ជាមួយនឹងកូន (នៅពេលឯកតានៃការវិភាគគឺកូន) ដោយហេតុផលណាមួយ នៅពេលគេគិតថា ពួកគេទៅរកប្រាក់ចំណូលប្រសើរជាងចូលរួមធ្វើសំភាសន៍ ការអង្កេតនោះអាចបណ្តាលឱ្យគេបាត់បង់ការងារ ។ល ។ ការបង្វែរការបដិសេធនេះឱ្យទៅជាការយល់ព្រមបានក្លាយជាផ្នែកមួយនៅក្នុងគំរោងការរៀបចំ ការប្រមូលទិន្នន័យ ហើយអាចរួមមានយុទ្ធសាស្ត្រដូចខាងក្រោម ដើម្បីទទួលបានការសហការរបស់អ្នកឆ្លើយតប សំភាសន៍បន្តរយៈពេលប្រមូលទិន្នន័យ ដើម្បីមានពេលកសាងពីទំនាក់ទំនង ទំនុកចិត្តនៅក្នុងតំបន់ដែលចុះទៅស្រាវជ្រាវជ្រើសរើសអ្នកផ្សេងមកកំណត់ធ្វើជាសំណាក ធ្វើការណាត់ជួបជាមួយនឹងអ្នកឆ្លើយសំភាសន៍ មុនពេលកំណត់អ្នកដែលត្រូវចុះសំភាសន៍ ផ្តល់ការលើកទឹកចិត្តជាថវិកា ឬមិនមែនជាថវិកាដល់អ្នកឆ្លើយ ។ល ។ ទំលាប់ដែលគេច្រើនធ្វើម្យ៉ាងទៀត គឺរកមើលមនុស្សពេញវ័យម្នាក់ទៀតនៅក្នុងគ្រួសារដែលអាចជំនួសអ្នកឆ្លើយនោះបាន តែការធ្វើដូច្នេះអាចចោទជាបញ្ហាត្រង់ថា អ្នកជំនួសនោះមិនអាចឆ្លើយសំណួរខ្លះ ។

ចំពោះចំណុចស្តីអំពីការមិនមានចំលើយ គឺកើតមាននៅពេលដែលអ្នកឆ្លើយមិនអាចឆ្លើយ ឬមិនឆ្លើយសំណួរ ។ រឿងនេះកើតមានផងដែរ នៅពេលដែលសំណួរត្រូវរំលងបែរជាមិនត្រូវបានរំលងដោយអ្នកសួរ ។ ប៉ុន្តែបញ្ហានេះគេអាចដោះស្រាយបាន ។ គឺថាអ្នកសួរអាចចរចារជាមួយនឹងអ្នកឆ្លើយនៅពេលគេមិនព្រមឆ្លើយសំណួរមួយ ដោយស្ទាបស្ទង់មើលថា ហេតុអ្វីក៏គេមានការពិបាកនឹងឆ្លើយ ឬពន្យល់ពាក្យខ្លះ (ផ្អែកលើនិយមន័យដែលកំណត់ដោយ ឬជាមួយនឹងអ្នកស្រាវជ្រាវ) ដែលអាចមានន័យមិនច្បាស់ ។ ប៉ុន្តែគេគួរចាំថា ការមិនមានចំលើយអាចជាលទ្ធផលនៃការរៀបចំសំណួរមិនល្អ ភាពមិនច្បាស់របស់អ្នកសួរស្តីពីសំណួរដែលត្រូវរំលង ឬដោយសារថា សំណួរនោះទាក់ទងនឹងរឿងងាយប៉ះពាល់អារម្មណ៍ដែលទាមទារឱ្យអ្នកសួរមានវិធានការស្របគ្នាដើម្បីទទួលបានទិន្នន័យ ។

## បច្ចេកទេសសំភាសន៍ និងកត់ត្រា (Interviewing and Recording Techniques)

### ការជ្រើសរើស និងការបណ្តុះបណ្តាលអ្នកចុះសំភាសន៍

អ្នកចុះសំភាសន៍គឺជាអ្នកដែលទាក់ទងដោយផ្ទាល់របស់អ្នកស្រាវជ្រាវជាមួយនឹងអ្នកឆ្លើយ ជាពិសេសនៅពេលដែលការស្រាវជ្រាវនោះមានសំណាកធំទូលាយ ។ ការសិក្សាទាំងឡាយបានបង្ហាញថា ចរិកលក្ខណៈរបស់អ្នកចុះសំភាសន៍អាចមានផលប៉ះពាល់ដោយផ្ទាល់ លើដំណើរការប្រមូលទិន្នន័យ ដូច្នេះវាអាចនាំឱ្យទិន្នន័យលំអៀង ។ លក្ខណៈខ្លះៗរបស់អ្នកចុះសំភាសន៍បានល្អ (Fowler, 1993:109;Feuerstein, 1986:90-93) :

- ត្រូវចេះអាន និងសរសេរបានល្អ ។
- ចេះធ្វើការតាមកាលវេលាដែលអាចបត់បែនបាន ព្រោះថាការសំភាសន៍អាស្រ័យលើពេលវេលាដែលអ្នកឆ្លើយតបសំភាសន៍ទំនេរ ។

- ត្រូវតែមានភាពរហ័សរហួន ការទាមទារនេះ ច្រើនតែមិនរាប់បញ្ចូលអ្នកដែលមានពិការភាពរាងកាយ ពីព្រោះគេអាចនឹងត្រូវដើរឆ្ងាយដើម្បីទៅជួបអ្នកឆ្លើយតបសំភាសន៍ ។

ចំណុចពិចារណាផ្សេងទៀតដែលត្រូវបានលើកឡើងទាក់ទងនឹងអាយុ ភេទ ប្រវត្តិ និងឋានៈនៅក្នុងសហគមន៍ ។ល ។ ប៉ុន្តែបញ្ហាថា តើលក្ខណៈទាំងនេះមានការទាក់ទងយ៉ាងណានោះអាស្រ័យលើលក្ខណៈ ឬប្រភេទនៃការសិក្សាស្រាវជ្រាវ ។ ឧទាហរណ៍ ការសំភាសន៍ជាមួយនឹងស្ត្រីទាក់ទងនឹងសុខភាពបន្តពូជ មានស្ត្រីជាអ្នកចុះសួរសំភាសន៍អាចទទួលពត៌មានបានល្អជាងចំណែកឯការសំភាសន៍ជាមួយនឹងមនុស្សក្មេងៗ បើមានអ្នកចុះសំភាសន៍ជាមនុស្សក្មេងៗវាល្អជាជាងមនុស្សដែលមានភាពចាស់ទុំ ដែលមើលទៅប្រៀបដូចជាឪពុកម្តាយវា ហើយធ្វើឱ្យវាមិនចង់ផ្តល់ពត៌មាន ។

នៅពេលជ្រើសរើសបានមក អ្នកចុះសំភាសន៍ត្រូវតែទទួលបានការបង្រៀន ។ អ្វីដែលគេគួររៀនគឺមានដូចជា :

- ទំរង់ការនៃការទាក់ទងអ្នកឆ្លើយ និងនិយាយណែនាំដំបូងពីការស្រាវជ្រាវ ។
- ទំលាប់ធ្វើជាធម្មតា នៅក្នុងការតាក់តែងឧបករណ៍ប្រមូលទិន្នន័យទាក់ទងនឹងការប្រើពាក្យពេជន៍ និងការណែនាំពីការត្រូវរំលងដើម្បីឱ្យអ្នកចុះសួរអាចសួរសំណួរដែលមានភាពស្របគ្នាត្រឹមត្រូវ ។
- ទំរង់ការនៃការស្ទាបស្ទង់ចំលើយដែលឆ្លើយមិនគ្រប់គ្រាន់ តាមលក្ខណៈមិនបង្គាប់បញ្ជា ។
- ទំរង់ការនៃការកត់ត្រាចំលើយចំពោះសំណួរបើក និងសំណួរបិទ ។
- វិធាន និងគោលណែនាំទាក់ទងនឹងការប្រាស្រ័យគ្នាក្នុងការសំភាសន៍តាមលក្ខណៈមិនមានភាពលំអៀង ។

ទំរង់ការនៃការបណ្តុះបណ្តាលក៏ជាបញ្ហាមួយដែរ ។ វិធីសាស្ត្ររៀនសូត្រជាមូលដ្ឋានចំនួនប្រាំត្រូវមាន : ការប្រើឯកសារ ការធ្វើបទបង្ហាញលំហាត់ធ្វើតាមការរៀបចំមុន ការដើរតួ (ពិសេសការដើរតួសំភាសន៍) ការសង្កេតមើលការងារនៅនឹងមូលដ្ឋាន (Neuman, 2000:278; Fowler, 1993:113;) ។ ចំពោះឯកសារ សរសេរសៀវភៅក្បួនសំរាប់អ្នកចុះសំភាសន៍មានប្រយោជន៍ ពីព្រោះវាផ្តល់សេចក្តីរៀបរាប់ពេញលេញពីទំរង់ការនៃការសំភាសន៍ ដោយរួមទាំងនិយមន័យនៃពាក្យដែលត្រូវប្រើ រួមទាំងការប្រែឯកតាមូលដ្ឋាននៃរង្វាស់រង្វាល់ (Local units of measures) ឱ្យទៅជាឯកតារង្វាស់រង្វាល់ដែលគេចង់បាន ។ ការហាត់ធ្វើសំភាសន៍ (ដើរតួ) មានតំលៃ ពីព្រោះវាជួយអ្នកចុះសំភាសន៍ឱ្យស្គាល់សំណួរ និងលេខកូដរបស់វា (បិទ) លំនាំនៃទំរង់ត្រូវរំលងសំណួរ ហើយយល់ច្បាស់ពីអ្វីដែលសំណួរចង់បាន ។ ការឱ្យអ្នកចុះសំភាសន៍ចូលរួមនៅក្នុងការធ្វើតេស្តសាកល្បងជាមុន មានប្រយោជន៍ផងដែរ ពីព្រោះការធ្វើដូច្នេះផ្តល់ឱកាសឱ្យគេបានហាត់ធ្វើនៅក្នុងស្ថានភាពដែលគេនឹងជួបប្រទះនៅកន្លែងសំភាសន៍មែនទែន នៅក្នុងការស្រាវជ្រាវហើយធ្វើការត្រិះរិះជាមួយនឹងគ្រូបច្ចេកទេសទៅលើចំណុចខ្សោយនៃសំណួរ និងលើបញ្ហាដែលគេជួបប្រទះនៅក្នុងការសួរសំណួរ ។ រយៈពេលនៃការបង្រៀនអ្នកចុះសំភាសន៍ អាចមានពីមួយអាទិត្យ ទៅពីរអាទិត្យ ឬវែងជាងនេះ ដោយអាស្រ័យលើប្រភេទនៃការស្រាវជ្រាវ ។ ការអង្កេតផ្នែកសេដ្ឋកិច្ចសង្គម នៅថ្នាក់ជាតិកាលពីឆ្នាំ២០០៤ នៅក្នុងប្រទេសកម្ពុជា ត្រូវការការបង្រៀនរយៈពេលមួយខែ សំរាប់អ្នកចុះសំភាសន៍ ។

## អ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើនៅក្នុងការសំភាសន៍

ការសំភាសន៍សំរាប់ការស្រាវជ្រាវសង្គម ពិសេសការសំភាសន៍សំរាប់ការអង្កេត គឺជាការឆ្លើយឆ្លងគ្នាខ្លីៗ រវាងជនចំណែកពីរនាក់ ដោយមានបំណងច្បាស់លាស់គឺម្នាក់ចង់បានពត៌មានពីម្នាក់ទៀត (Neuman, 2000:274) ។ គេទទួលបានពត៌មានពីការសន្ទនាដែលមានការរៀបចំ ដែលក្នុងនោះអ្នកសំភាសន៍សួរសំណួរមានរៀបចំទុកជាមុន ហើយកត់ត្រាចំលើយដែលអ្នកឆ្លើយ

ផ្តល់ ។ តួនាទីរបស់អ្នកសួរអាចមានការពិបាក ពីព្រោះគេត្រូវធ្វើឱ្យអ្នកឆ្លើយស្រួលចិត្ត ហើយព្រមឆ្លើយប្រាប់ដោយនៅក្នុងពេលជាមួយគ្នានោះគេត្រូវរក្សាអព្យាក្រឹត្យភាព ។ លើសពីនេះទៀត គេត្រូវជជីករកពតិមានដែលមើលទៅមិនបានជាប្រយោជន៍អ្វីសំរាប់អ្នកឆ្លើយទេ ។ នៅក្នុងតួនាទីបែបនេះគេត្រូវកាត់បន្ថយការរអែងការភ័យខ្លាច និងការសង្ស័យដើម្បីឱ្យអ្នកឆ្លើយស្រួលចិត្តនៅក្នុងការផ្តល់ពតិមាន ។

ទោះបីជាការបង្រៀន និងការតាមការពិនិត្យមើលអាចផ្តល់តួនាទីសំខាន់នេះដល់អ្នកចុះសំភាសន៍ក្តី ប៉ុន្តែក៏នៅមានគោលការណ៍ណែនាំខ្លះ ដែលអ្នកស្រាវជ្រាវផ្នែកសង្គមត្រូវធ្វើតាមដើម្បីធានាប្រសិទ្ធភាពនៃការងារប្រមូលទិន្នន័យ ។ គោលការណ៍ណែនាំទាំងនេះមានដូចខាងក្រោមនេះ :

**អ្វីដែលត្រូវធ្វើ** | **អ្វីដែលមិនត្រូវធ្វើ**

*ចំណាយពេលវេលាទៅលើ :*

- បង្កើតក្រុមចុះសំភាសន៍
- កំណត់តួនាទី និងការទទួលខុសត្រូវ
- ស្វែងយល់ប្រធានបទ
- គ្រោងផែនការលើការសំភាសន៍
- ជ្រើសរើសកន្លែងសំរាប់ការសំភាសន៍

| | |
|---|---|
| ចូរគិតថា អ្នកគឺជាអ្នករៀនសូត្រ (សូមទុកឋានៈសមិទ្ធិផល និងបទពិសោធន៍មួយឡែកសិន) | កុំធ្វើឫកធំដាក់អ្នកភូមិ ។ កុំគិតថា អ្នកគ្មានអ្វីដែលត្រូវរៀនទៀតនោះទេ ។ សូមកុំរួញរានៅក្នុងការ សួរបញ្ជាក់ការសង្ស័យ និងចំងល់របស់អ្នក ។ |
| ត្រូវគិតពីអារម្មណ៍ (ខឹង ធុញទ្រាន់ ឈឺចាប់ សោមនស្ស ។ ល ។) របស់មនុស្ស ។ ត្រូវវាងវៃ-រកមើលចំណុចផ្តើម និងចំណុចបន្ត ។ | |
| ធ្វើតាមពិធីការ-ណែនាំខ្លួនឯងឱ្យគេស្គាល់ ប្រាប់ពីគោលបំណងដែលអ្នកចុះទៅ សួរគេថាតើ....បានទេ ។ល ។ | ត្រូវគោរពដល់គេ កុំមើលស្រាលគេ ។ |
| សំរួលការសំភាសន៍ | កុំនាំគ្នានិយាយច្រើននៅក្នុងពេលជាមួយគ្នា ព្រោះវាធ្វើឱ្យមានការច្រឡំ ។ |
| បង្កើតបរិយាកាសជឿទុកចិត្តនិងសប្បាយ ។ ត្រូវចាំថាគ្រប់គ្នាមានអ្វីត្រូវនិយាយ ។ ជំរុញឱ្យអ្នកស្ងាត់ស្ងៀមនិយាយ ពិសេសស្ត្រី ។ កុំនិយាយតែម្នាក់ឯង (ក្នុងករណីដែលអ្នកនិយាយតែម្នាក់ឯងបែបហ្នឹង ចូរនាំគាត់ដើរលេងបន្តិចដើម្បីឱ្យអ្នកឯទៀត អាចបន្តនិយាយដោយមិនមានការរំខាន) ។ | កុំនិយាយតែម្នាក់ឯង កុំបង្រៀនក្នុងពេលនេះ |

| | |
|---|---|
| ស្តាប់ដោយយចិត្តទុកដាក់ហើយជំរុញដល់ដំណើរផ្តល់ពត៌មានជាហូរហែ ។ | កុំរំខាន វាបណ្តាលឱ្យរំខានដល់លំហូរនៃការគិតរបស់អ្នកសំភាសន៍ និងធ្វើឱ្យបាត់បង់ការប្រមូលផ្តុំការគិត |
| បើកឱ្យមានការធ្វើតាមវិធីត្រីកោណ (ការសួរ ពិនិត្យឡើងវិញដើម្បីផ្ទៀងផ្ទាត់) ដោយអ្នកភូមិខ្លួនគេ ។ | កុំបកស្រាយពត៌មានខុស ។ |
| បញ្ចប់ការសំភាសន៍ `មិនល្អ´ ដោយមិនមានការអាក់អន់ ឬខឹងអ្វីចំពោះរឿងហ្នឹងទេ។ តែចូរខំគិតមើលថាមានអ្វីខ្លះដែលមិនស្រួល ។ | |
| រាប់មើលចំនួនកិច្ចសំភាសន៍ដែលបានធ្វើមក។ ដោយឡែកសំរាប់ការស្រាវជ្រាវបែបរិមាណ ការធ្វើដូច្នេះ ធ្វើឱ្យក្រុមអ្នកស្រាវជ្រាវដឹងថា តើគេកំពុងតែធ្វើត្រូវ ឬអត់ នៅក្នុងបំណងឈានទៅសំរេចលើទំហំសំណាកដែលត្រូវបានកំណត់មក។ | |
| កត់ឈ្មោះអ្នកឆ្លើយ ហើយអរគុណគេចំពោះពត៌មានដែលគេបានផ្តល់ ។ | |
| ពិនិត្យកែសំរួលកំរងសំណួរដែលត្រូវបានធ្វើហើយនៅកន្លែងចុះទៅស្រាវជ្រាវដើម្បីធានាបានភាពពេញលេញ និងភាពច្បាស់លាស់នៃចំលើយទៅនឹងសំណួរ។ ការធ្វើដូច្នេះធ្វើឱ្យអ្នកចុះសំភាសន៍អាចត្រឡប់ទៅរកអ្នកឆ្លើយវិញ នៅក្នុងករណីដែលចំលើយមានភាពមិនពេញលេញ ឬមិនច្បាស់។ | |

## គោលការណែនាំស្តីពីវិធីកត់ត្រាពត៌មាន

### ក. កត់ត្រាកិច្ចសំភាសន៍[១០]

ការកត់ត្រាសេចក្តីលំអិតនៃកិច្ចសំភាសន៍មានសារៈសំខាន់បំផុត។ នៅក្នុងការងារចុះមូលដ្ឋានភាគច្រើន ពត៌មានល្អៗជាច្រើនបាត់បង់ដោយការមិនបានកត់ត្រា។ ខាងក្រោមនេះគឺជាគោលណែនាំសំខាន់ៗនៅក្នុងការកត់ត្រា (Pretty et al, 1995:75) :

- សុំការអនុញ្ញាតិដើម្បីកត់ត្រាការពិភាក្សាពីអ្នកមានវត្តមាន។
- ប្រើកូនសៀវភៅ (មិនមែនផ្ទាំងក្រដាសធំទេ)។
- កត់លំអិតពីអ្វីដែលគេបាននិយាយ បើធ្វើបាន និងអ្វីដែលគេមិនបាននិយាយ អាចកាត់យល់បាន។ (ដូចជា ការអល់ឯក ឬតានតឹងនៅក្នុងខ្លួន ដែលសុទ្ធតែជារឿងសំខាន់ផងដែរ។)
- កត់លំអិតនូវអ្វីដែលសង្កេតឃើញ និងដំណើរការនៃការសំភាសន៍។
- កត់អ្នកណានិយាយអ្វី (ប្រុស/ស្រី ក្មេង/ចាស់ ក្រ/មាន)។

[១០] ផ្នែកនេះបន្ថែមចំណុចពិភាក្សាដែលបានមកពី Pretty et al, 195:75

- ធ្វើការផ្ទៀងផ្ទាត់ក្រោយការសំភាសន៍ (ក្នុងនោះសមាជិកក្រុមសំភាសន៍ប្រៀបធៀបកំណត់ហេតុរបស់គេ ជាមួយនឹងកំណត់ហេតុរបស់អ្នកផ្សេងទៀត) ។
- សរសេរចូលចំណាប់អារម្មណ៍ផ្ទាល់ខ្លួនទៅលើការសំភាសន៍ ។

## ៩. ការកត់ត្រានៅពេលចុះទៅ : មតិស្នើទូទៅ [១១]

មតិស្នើទូទៅខ្លះនៅពេលកត់ត្រាក្នុងពេលចុះទៅប្រមូលទិន្នន័យមានដូចតទៅ :

- កត់ត្រាឃ្លា និងពាក្យគន្លឹះ ពេលសំភាសន៍គេមិនត្រូវបញ្ឈប់អ្នកឆ្លើយ នៅពេលគេកំពុងតែនិយាយ ដើម្បីកត់ត្រាគ្រប់ពាក្យនោះទេ។ ការយកម៉ាស៊ីនថតសំលេងមកដាក់ថតធ្វើឱ្យមានអារម្មណ៍មិនធម្មតា ហើយប៉ះពាល់ដល់ដំណើរជាធម្មតានៃការសន្ទនា។ ផ្ទុយទៅវិញ នៅក្នុងពេលសន្ទនា គេអាចដកយកពាក្យ ឬឃ្លាគន្លឹះៗហើយកត់ចូល ។

- កត់លំដាប់នៃព្រឹត្តិការណ៍ សកម្មភាពដែលកើតឡើងនៅតាមមូលដ្ឋានច្រើនតែមានកំរិតហួសពីសមត្ថភាពគ្រប់គ្រងបានរបស់អ្នកស្រាវជ្រាវ ដូច្នេះមិនមានការរៀបរយទេ។ នៅក្នុងការកត់ត្រានៅទីនោះ គោលការណ៍ណែនាំមួយដែលល្អ គឺត្រូវយល់ពីលំដាប់នៃហេតុការណ៍ ។ នៅពេលអ្នកស្រាវជ្រាវសរសេរកំណត់សំគាល់ខ្លីៗរបស់គេ គេត្រូវប្រាប់ថាតើព្រឹត្តិការណ៍អ្វី ឬការសន្ទនាណាដែលបានកើតឡើងមុនព្រឹត្តិការណ៍ដែលត្រូវបានកត់ចូល ហើយមានអ្វីដែលបានចាប់ផ្តើមកើតឡើងបន្ទាប់ពីព្រឹត្តិការណ៍ដែលត្រូវបានកត់ចូលនោះ។ តាមរយៈការសន្ទនាដែលរកមើលលំដាប់នៃព្រឹត្តិការណ៍ដែលកើតឡើង អ្នកស្រាវជ្រាវអាចនឹកដល់ចំណុចលំអិត និងខ្លឹមសារនៃកិច្ចសន្ទនាវែងៗបាន។

- សរសេរសេចក្តីពេញលេញភ្លាម បន្ទាប់ពីចាកចេញពីកន្លែងសំភាសន៍។ ការភ្លេចមានឆាប់ណាស់។ កាលណាគេកម្រនឹងបានធ្វើការបកប្រែអក្សរកាត់របស់គេ (ដែលត្រូវបានសរសេរនៅឯនៅមូលដ្ឋាន) ពេលនោះការភ្លេចក៏រឹតតែមានច្រើនកាលនោះដែរ។ ពេលខ្លះគ្រាន់តែការសំរាកហូបបាយ ក៏ធ្វើឱ្យភ្លេចខ្លះដែរ ។

- សរសេរសេចក្តីរបស់អ្នក និងរបស់សមាជិកក្រុមរបស់អ្នក មុនពេលបង្ហាញទៅអ្នកឯទៀត ។ អ្វីដែលគេត្រូវធ្វើតាមគឺថាកុំនិយាយហើយគិតតែពីសរសេរចេញនូវពតិមានដែលបានមកពីការសំភាសន៍ រួចហើយទើបនិយាយជាក្រោយ។ ក្រៅពីការអាចភ្លេចពតិមានលំអិតសំខាន់ៗមុនពេលសរសេរចូល អ្នកស្រាវជ្រាវខ្លះអាចបំផ្លើសហេតុការណ៍ដោយអចេតនា។ ទោះបីជាអចេតនាក្តី ក៏ការពន្លើសនេះធ្វើឱ្យខូចដល់ទិន្នន័យដែលមានសារៈសំខាន់ ។

## ដំណើរការបញ្ចូល និងសង្ខេបទិន្នន័យ (Processing and summarizing the data)

ការវិភាគទិន្នន័យ ជាដំណើរការតំរៀបលំដាប់លំដោយ រចនាសម្ព័ន្ធ និងខ្លឹមសាររបស់ទិន្នន័យដែលត្រូវបានប្រមូលមក។ វាជាដំណើរការស្មុគស្មាញ ស្រពិចស្រពិល ស៊ីពេលច្រើន គួរចាប់អារម្មណ៍ និងប្រកបដោយភាពច្នៃប្រឌិត។ ដំណើរការនេះមិនមែនប្រព្រឹត្តទៅជាលក្ខណៈខ្សែបន្ទាត់ត្រង់នោះទេ។ ដូចដែលត្រូវបានគេកត់សំគាល់ពីដើមមកហើយ ផ្លូវជ្រើសរើសនៅក្នុងការវិភាគ និងលើកបង្ហាញទិន្នន័យគួរតែគេពិភាក្សា ហើយសំរេចតាំងពីដើមទីនៃការគ្រោងរៀបចំការស្រាវជ្រាវ។ បច្ចេកទេសនៅក្នុងការវិភាគទិន្នន័យគួរបំពេញបំណង ហើយស្របតាមប្រភេទទិន្នន័យដែលប្រមូលបាន។

[១១] ចំណុចពិភាក្សានេះត្រូវបានដកចេញពី Berg, 1989:73-74

ការវិភាគទិន្នន័យរួមមានដំណាក់កាលខុសៗគ្នា ។ ដំណាក់កាលសំខាន់គឺការរៀបចំ និងកាត់បន្ថយទិន្នន័យ (ពោលគឺការបញ្ចូលទិន្នន័យ) និងការបកស្រាយ (ពោលគឺរៀបរាប់លទ្ធផលរកឃើញ ធ្វើការភ្ជាប់ពីផ្នែកមួយទៅផ្នែកមួយ រកមើលបុព្វហេតុដើម បញ្ហាសំខាន់ៗហើយសរសេរសេចក្តីវិភាគ ទាញការសន្និដ្ឋាន ហើយចេញជាអនុសាសន៍) ។ ការស្រាវជ្រាវបែបបរិមាណ និងគុណភាព មានដំណើរការច្បាស់លាស់ដូចរៀបរាប់ខាងក្រោម :

## ការវិភាគទិន្នន័យបែបបរិមាណ

ការពិនិត្យមើលទិន្នន័យនៅក្នុងការស្រាវជ្រាវបែបបរិមាណ រួមមានដំណើរការជាចាំបាច់នៅក្នុងការរៀបចំសំរាប់ទុកដាក់ទិន្នន័យ ការកែតំរូវ ការបញ្ចូលទិន្នន័យ ឬការដាក់កូដទិន្នន័យមូលដ្ឋាន ការសំអាតទិន្នន័យ ការសង្ខេប ឬកាត់បន្ថយទិន្នន័យឱ្យទៅជាតារាង ឬទំរង់សង្ខេបទិន្នន័យផ្សេងទៀត (ក្រាហ្វិក តារាង) និងបកស្រាយលទ្ធផលរកឃើញ ។

### *ការរៀបចំចំពោះការទុកដាក់ទិន្នន័យ* ***(Preparing for data handling)***

នៅពេលដែលអ្នកចុះសួរបង្ហើយកំរងសំណួរ អ្នកស្រាវជ្រាវ (ឬសមាជិកក្រុមដែលមាននាទីជាអ្នកមើលខុសត្រូវលើការប្រមូលទិន្នន័យ) គួររាប់ដើម្បីកំណត់ថា បទសំភាសន៍គ្រប់ចំនួនត្រូវបានធ្វើហើយ ។ គេត្រូវពិនិត្យកំរងសំណួរនីមួយៗ ដើម្បីឱ្យប្រាកដថា វាមានលក្ខណៈពេញលេញហើយធ្វើតាមការណែនាំនៅក្នុងការវំលងសំណួរ ក្រោយពីមានការឆ្លើយតាមបែបណាមួយនោះ ។ ការពិនិត្យកំរងសំណួរឡើងវិញ មុនពេលចាកចេញពីមូលដ្ឋាន ធ្វើឱ្យអ្នកមើលការខុសត្រូវ ឬអ្នកស្រាវជ្រាវអាចត្រឡប់ទៅរកអ្នកឆ្លើយសំភាសន៍វិញ បើសិនជាមានកំហុស ឬភាពមិនស៊ីគ្នានៃចំលើយដែលត្រូវបានកត់ត្រាចូល ។

ការបូកសរុបពតិមានដែលអ្នកបានប្រមូលដោយវិធីណាមួយ និងពីប្រភពណាមួយត្រូវធ្វើក្រោយពីត្រឡប់មកពីមូលដ្ឋានវិញ ។ ជាដំបូង អ្នកស្រាវជ្រាវតំរៀបក្រដាសប្រមូលពតិមានដែលបានបំពេញហើយ (ឧទាហរណ៏ ឧបករណ៏អង្កេតដែលត្រូវបានបំពេញហើយការពិភាក្សារបស់ក្រុមគោលដៅ និងឧបករណ៏សំខាន់ៗស្តីពីអ្នកឆ្លើយ) ទៅតាមប្រភេទអ្នកឆ្លើយសំភាសន៏ ឬក្រុមគោលដៅ ហើយរាប់ឧបករណ៏ទាំងនេះ ។ គេអាចត្រូវផាត់ចោលការសំភាសន៏ខ្លះ បើក្រដាសសំភាសន៏នោះមិនត្រូវបានបំពេញបានត្រឹមត្រូវទេ ឬអ្នកឆ្លើយមិនមែនជាប្រភេទមនុស្សដែលអ្នកចង់សំភាសន៏ទេ ។ ឧទាហរណ៏ អ្នកចង់សំភាសន៏មនុស្សចំណាកស្រុកទៅរកការងារធ្វើនៅតំបន់ផ្សេង ប៉ុន្តែអ្នកដែលឆ្លើយនោះបែរជាម្តាយរបស់គេទៅវិញ ។ ការអង្កេតនេះមិនត្រូវរាប់បញ្ចូលទេហើយត្រូវបោះចោល បើសិនជាពតិមានសំខាន់ៗទាក់ទងនឹងបទពិសោធន៏របស់អ្នកធ្វើចំណាកស្រុកទៅធ្វើការនៅកន្លែងផ្សេងមិនមានទេនោះ ។ សរសេរចូលចំនួនបទសំភាសន៏សរុបត្រឹមត្រូវដែលបានធ្វើ រួចហើយស្រង់ចំនួនបទសំភាសន៏តាមកន្លែងឬប្រភេទមួយៗ ។ ការធ្វើបែបនេះរួមមានចំនួនក្រុមគោលដៅ និងចំនួនសរុបនៃអ្នកដែលចូលរួម ។ ការកត់ចំនួនស្ត្រីប៉ុន្មាននាក់ដែលបានចូលរួមក៏ជាការល្អដែរ ។

ជំហ៊ានបន្ទាប់គឺបង់លេខសំរាប់កំរងសំណួរអង្កេតទៅតាមលេខរៀង ។ ចំនួននេះធ្វើជាលេខសំគាល់លើ "មនុស្ស" ឬ "គ្រួសារ" ។ ការបង់លេខតគ្នាលើអ្នកឆ្លើយនៅក្នុងមួយភូមិៗអាចជួយសំរួលដល់ការងារនៅក្នុងការរកមើលកំរងសំណួរដែលត្រូវបានបំពេញហើយ បើសិនជាគេត្រូវការរកមើល ។ ដូច្នេះបើភូមិ *ក* មានអ្នកឆ្លើយចំនួន ២០នាក់ នោះអ្នកឆ្លើយទាំងអស់នៅក្នុងភូមិនេះមានលេខតគ្នា បន្ទាប់មកបង់លេខតទៅទៀតនៅក្នុងភូមិ *ខ* ។

### *ការកែសំរួលទិន្នន័យដែលនៅមិនទាន់កែច្នៃនៅឡើយ (Editing raw data)*

ជាការជៀសមិនផុត កំហុស ឬភាពមិនស៊ីគ្នានៅក្នុងការសរសេរចំលើយចូលតែងកើតមានឡើងនៅក្នុងពេលប្រមូលទិន្នន័យ ។ ដោយហេតុនេះ ការកែសំរួលទិន្នន័យមិនទាន់កែច្នៃ ក្លាយជាការងារបន្ទាប់ដែលគេគួរគិតបញ្ចូលទៅក្នុងពេលវេលាវិភាគទិន្នន័យ នៅពេលណាដែលគេរៀបចំផែនការលើការចុះអង្កេត ។ នៅក្នុងដំណាកកាលនេះអ្វីដែលគេត្រូវរកមើលគឺ :

- ពាក្យបំពេញដែលគេត្រូវសរសេរឱ្យពេញ
- ឯកតាវាស់វែងខុសៗគ្នាដែលគេត្រូវគិតឱ្យទៅតាមរង្វាស់កំណត់ ឬរង្វាស់រួម (ឧទាហរណ៍ ចំនួនឆ្នាំដែលបានរៀនសូត្រ គួរសរសេរចំនួនឆ្នាំពិតប្រាកដជាជាងប្រាប់កំរិតថ្នាក់ដែលគេរៀនដល់ ។ ចំនួនឆ្នាំដែលបានធ្វើការត្រូវមានជាចំនួនឆ្នាំជាក់ស្តែងជាជាង "ចាប់តាំងពីឆ្នាំ១៩៩៨")
- ការមិនបានឆ្លើយ ឬកន្លែងដែលមិនមានសរសេរអ្វីដែលគេត្រូវសរសេរថា "មិនដឹង" "មិនមានចំលើយ" "មិនមានការទាក់ទង" គឺជាកង្វល់ដែលគេត្រូវគិតគូរនៅក្នុងពេលធ្វើការសំអាតទិន្នន័យនៅនឹងមូលដ្ឋាន ។
- បញ្ហាក់ពីភាពមិនស៊ីគ្នានៅក្នុងទិន្នន័យ - ឧទាហរណ៍ គូសយកមនុស្សនៅក្នុងក្រុមដែលមានអាយុពី "១៥- ១៨ឆ្នាំ" សំរាប់អ្នកឆ្លើយដែលមានកំរិតសិក្សាដល់ "សញ្ញាប័ត្របណ្ឌិត" ។ ហេតុអ្វីក៏មានចំលើយទៅនឹងសំណួរមួយចំនួនត្រូវរំលង បើការណែនាំចំពោះសំណួរគឺត្រូវធ្វើបែបហ្នឹង ។

### *បញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធកុំព្យូទ័រ (Collapsing data onto the database)*

ចំណុចនេះ គ្រាន់តែចង់និយាយពីការបញ្ចូលទិន្នន័យរួមរបស់អ្នកទៅក្នុងកំរងសំណួរនៅក្នុងតារាងដោយកុំព្យូទ័រ (ពោលគឺធ្វើការបញ្ចូលទិន្នន័យ) ឬដោយដៃ ។ ការធ្វើដូច្នេះ ធ្វើឱ្យអ្នកស្រាវជ្រាវអាចផ្តុំទិន្នន័យទាំងអស់សំរាប់ធ្វើការបូកសរុបពតិមានជាភាគរយ និងស្ថិតិផ្សេងទៀត (ឧទាហរណ៍ ចំនួនមធ្យម មេគុណបញ្ជាក់ពីទំនាក់ទំនង ។ល ។) ។ នេះជាការងារធ្វើទៅត្រង់ៗក្នុងការចុះលេខកូដនៃចំលើយដែលបានមកទៅក្នុងតារាងដែលគេរៀបចំជាមុនស្រេច ហើយគេអាចកំណត់សំរាប់អ្នកចុះលេខកូដទិន្នន័យដែលមានជំនាញ បើសិនជាមានថវិកាកំណត់សំរាប់ការចំណាយនេះ ។

បើសំណួរបើកត្រូវបានប្រើនៅក្នុងឧបករណ៍ប្រមូលទិន្នន័យ (ឧទាហរណ៍ នៅលើចំណែកថ្នាក់ចំលើយផ្សេងទៀត) នោះជំហ៊ានជាក់ស្តែងត្រូវមាន (ក) ស្រង់បញ្ជីលើចំលើយទាំងអស់ (ខ) ផ្តុំចំលើយដែលដូចគ្នាជាក្រុមៗ ហើយបង្កើតចំណែកថ្នាក់នៃចំលើយថ្មី និង (គ) ដាក់លេខកូដ ។ ការដាក់លេខកូដឡើងវិញលើចំលើយ នៅពេលអ្នកឆ្លើយសំភាសន៍ផ្តល់ចំលើយរួម (a combination of answers) និងការកំណត់លេខកូដថ្មីមួយ ប្រហែលជាគេត្រូវធ្វើនៅពេលនេះ ។ នៅពេលគេកំណត់លេខកូដសំរាប់ចំលើយទៅនឹងសំណួរបើករួចហើយនោះ ការចុះទិន្នន័យទៅក្នុងទិន្នន័យមូលដ្ឋានអាចត្រូវបានបង្ហើយ ។

### *សំអាតទិន្នន័យ*[១២] *(Cleaning the data)*

ជានិច្ចជាកាល វាមានប្រយោជន៍ បើគេពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យដែលមានលេខកូដ ហើយតាមរយៈ ដំណើរការ "សំអាត" បើទោះបីជាទិន្នន័យត្រូវបានគេបញ្ចូលដោយប្រុងប្រយ័ត្នទៅក្នុងទិន្នន័យមូលដ្ឋានក្តី ។ ការសំអាតទិន្នន័យដែលមានលេខកូដ

---

[១២] ផ្នែកនេះបានមកពី Neuman, 2000:316-317 and Babbie, 1998:366.

ហើយអាចធ្វើបានពីររបៀប ។ *ការពិនិត្យលេខកូដដោយព្រាវ* (Wild code checking) រួមមានការពិនិត្យប្រភេទនៃអថេរទាំងអស់ រកមើលលេខកូដដែលមិនទំនងទៅរួច (impossible code) ។ ឧទាហរណ៍ ភេទរបស់អ្នកឆ្លើយអាចកំណត់លេខកូដថា ១ = ប្រុស ២ = ស្រី ដោយរកឃើញលេខកូដ "៣" ឬលេខដែលមិនស្ថិតនៅក្នុងរង្វង់នៃលេខកូដចំនួនពីរចំពោះចំលើយទាំងពីរនេះ បង្ហាញឱ្យឃើញថាមានកំហុស នៅក្នុងការបញ្ចូលលេខកូដ។ *ការពិនិត្យរកមើលភាពស៊ីគ្នា* គឺជាវិធីទីពីរដែលគេអាចសំអាតទិន្នន័យ ។ ឧទាហរណ៍ នៅពេលកំរងសំណួរសួររកចំនួនកូនដែលស្ត្រីមាន ស្ត្រីទាំងអស់ដែលឆ្លើយគួរត្រិះរិះលើចំនួនជាក់ច្បាស់ដែលគេនិយាយ ឬលេខកូដពិសេស (ឧទាហរណ៍ "មិនមានការទាក់ទង" បើសិនជាមិនដែលរៀបការ) ។ បើសិនជាអ្នកឆ្លើយម្នាក់ជាបុរសមានលេខកូដដែលបញ្ជាក់ថា មានកូនបីនាក់នោះ មានន័យថាមានកំហុសដែលគេគួរកែតំរូវ ។

ចំពោះវិធីទាំងពីរយ៉ាងនៃការពិនិត្យមើលទិន្នន័យឡើងវិញ ការចុះបែប "មើលដោយភ្នែក (eye-balling)" នៅក្នុងចន្លោះបញ្ឈរ[១៣]និមួយៗនៃតារាង គឺជាសកម្មភាពមួយសំរាប់ធានាភាពត្រឹមត្រូវនៃទិន្នន័យដែលចុះកូដហើយ ។ តាមផ្លូវម្យ៉ាងទៀតគេអាចបញ្ជាកុំព្យូទ័រឱ្យធ្វើតារាងប្រេកង់ងាយៗស្តីពីអថេរត្រូវបានគេជ្រើសឡើងដោយចៃដន្យ ។ នេះជាដំណើរការមួយដែលនាំឱ្យមានលេខកូដមិនត្រឹមត្រូវ ឬមិនសមស្របក្នុងទិន្នន័យមូលដ្ឋាន ។ ការពិនិត្យមើលទិន្នន័យដោយភ្ជាប់អថេរមួយទៅអថេរមួយទៀត (Cross-tabulation) ក៏ជារបៀបមួយទៀតដែលអ្នកស្រាវជ្រាវអាចប្រើ ។ នៅក្នុងឧទាហរណ៍ខាងលើ ស្តីពីចំនួនកូនដែលអ្នកឆ្លើយជាស្ត្រីទាំងអស់មាន នោះការភ្ជាប់ពីអថេរមួយទៅអថេរអំពីយេនឌ័រ ជាមួយនឹងចំនួនកូននឹងបង្ហាញដោយងាយថា ចំលើយត្រូវបានគេដាក់កូដឱ្យខុសសំរាប់អ្នកឆ្លើយជាបុរស ។ ដូចគ្នានេះដែរ បើគេធ្វើការបូកខ្វែងការសិក្សាអប់រំ និងមុខរបរនោះគេអាចមើលឃើញកំហុស បើសិនជាលទ្ធផលបង្ហាញឱ្យឃើញនូវលំនាំដែលមិនទំនងដូចជា មនុស្សម្នាក់បានត្រូវគេរាយការណ៍មកថា បានរៀនដល់តែត្រឹមថ្នាក់ទី៨ ទេ តែបែរជាមានគេនិយាយថា គាត់ជាវេជ្ជបណ្ឌិត ។

តំរូវការសំអាតទិន្នន័យមានធំធេងណាស់ ដោយសារកំហុសនៅក្នុងការបញ្ចូលទិន្នន័យទៅក្នុងទិន្នន័យមូលដ្ឋានអាចធ្វើឱ្យប៉ះពាល់ដល់ភាពអាចយកជាការបាននៃពតិមាន ហើយអាចនាំឱ្យមានលទ្ធផលខុស ។ ទោះបីថា នេះគឺជាដំណាក់កាលដែលគេកំណត់ឡើងមុនពេលការរៀបចំសេចក្តីបូកសរុបទិន្នន័យក្តី តែការសំអាតទិន្នន័យនៅតែមាននៅក្នុងពេលរៀបរៀងជាតារាង ឬដំណើរការរៀបចំសេចក្តីបូកសរុបទិន្នន័យ ដោយសារគេយល់ឃើញលទ្ធផលមិនទំនងនៅក្នុងពេលគេបញ្ចូលពតិមាន (ឧទាហរណ៍ ចំណូលដែលខ្ពស់ពេកសំរាប់មុខងារណាមួយ) ។

### ***ការបន្ថយទិន្នន័យ ឬ សង្ខេបទិន្នន័យ (Data reduction or summarizing the data)***

ការបូកសរុបទិន្នន័យគឺការបង្ហាញទិន្នន័យតាមរបៀបដែលធ្វើឱ្យគេងាយអាន និង/ឬបកស្រាយ ។ មានវិធីខ្លះៗ ដែលជួយក្នុងការកាត់បន្ថយពតិមានដើម្បីឱ្យអ្នកអានងាយយល់ដូចជា ៖

- តារាង
- ដ្យាក្រាម
- ក្រាហ្វិកបង្គោល
- ក្រាហ្វិកបន្ទាត់
- រូបភាព/ផែនទី

[១៣] គេនឹងចាំថាចន្លោះបញ្ឈរនិមួយៗនៅក្នុងតារាងតំណាងឱ្យសំណួរសំភាសន៍មួយ ឬអថេរនៃការសិក្សា

នៅក្នុងទំរង់នៃការបង្ហាញនេះ មានសំរង់ជាលេខខ្លះ (ឧទាហរណ៍ ចំនួនគិតជាមធ្យម របាយប្រេកង របាយ ភាគរយ ។ល ។) ដែលតំរូវឱ្យមានការអនុវត្តន៍តាមទំរង់ការពិតមួយ (ប្រអប់ទី៦) ។ ការនេះមានន័យថា ពិនិត្យមើលស៊ីជំរៅទៅលើប្រព័ន្ធទិន្នន័យក្នុងកុំព្យូទ័រដែលបញ្ចូលរួច ឬទិន្នន័យដែលបានបូកដោយដៃនៅលើផ្ទាំងក្រដាសធំ ។ ខាងក្រោមនេះគឺជាវិធីមួយចំនួនសំរាប់បន្ថយទិន្នន័យច្រើនឱ្យទៅជាទំរង់ដែលមានប្រយោជន៍ ។

***រៀបចំទិន្នន័យ (Organize data)***

មានវិធីច្រើនយ៉ាងនៅក្នុងការរៀបចំលទ្ធផលរកឃើញរបស់អ្នក ហើយវាអាស្រ័យលើប្រភេទនៃការសិក្សាស្រាវជ្រាវ ។វិធីដែលគេនិយមច្រើនជាងគេគឺមានដូចខាងក្រោមនេះ :

- តាមលំដាប់នៃទីកន្លែង នៅពេលប្រៀបធៀបស្ថានភាពនៅតាមសហគមន៍ ឬប្រព័ន្ធអេកូឡូស៊ីផ្សេងៗ ។
- លំដាប់លំដោយពេលវេលាសំរាប់វិភាគរឿងអ្វីមួយ ឬការផ្លាស់ប្តូរណាមួយ ។
- តាមប្រធានបទ ចំណែកថ្នាក់ ឬអត្ថន័យសំរាប់បញ្ហាទូទៅ ។
- តាមប្រភេទនៃបញ្ហា និងបុព្វហេតុនៃការពិបាកនៅក្នុងដំណើរការ
- តាមតួអង្គ ឬកត្តាសំខាន់ៗចំពោះការវិភាគជំលោះ ឬទំនាក់ទំនងនៃអំណាច ។

## ប្រអប់ទី ៦ : ការយល់ពីស្ថិតិដែលជាតួលេខសង្ខេបសំរាប់ទិន្នន័យ

**ស្ថិតិបែបរៀបរាប់** ច្រើនតែរៀបរាប់បរិមាណធំៗ និងស្ថានភាព ។ វាធ្វើឱ្យអ្នកស្រាវជ្រាវអាចសង្ខេបបរិមាណទិន្នន័យធំៗ ដោយប្រើរង្វាស់ដែលអ្នកសង្កេតងាយយល់ ។ ឧទាហរណ៍ បើអ្នកអានទៅដឹងថា អត្រានៃវេជ្ជបណ្ឌិត ធៀបជាមួយនឹងប្រជាជន គឺមាន ១:៥០.០០០ (មានវេជ្ជបណ្ឌិតម្នាក់សំរាប់ប្រជាជនប្រាំម៉ឺននាក់) អ្នកអាចមើលឃើញថា មានវេជ្ជបណ្ឌិតតិចពេក ហើយសំរាប់ប្រជាជនដ៏ច្រើននោះ ។ ស្ថិតិបែបរៀបរាប់មានបច្ចេកទេសបែបលេខ និងក្រាហ្វិកសំរាប់សង្ខេបទិន្នន័យ ។ ប្រភេទស្ថិតិសំខាន់ជាងគេដែលត្រូវបានគេប្រើគឺមធ្យមភាគ ភាគរយ និងរបាយចំនួនចំលើយ ។

១. ភាគរយ : មានន័យថាផ្នែកមួយនៃអ្វីមួយប្រៀបទៅនឹងដុំទាំងមូលរបស់វាដែលតាមធម្មតាគឺ ១០០% ។ដើម្បីគណនាចំនួនភាគរយ គេចែកចំនួនមនុស្ស ឬរបស់នៅក្នុងក្រុមមួយទៅនឹងចំនួនសរុបនៅក្នុងក្រុម នោះរួចហើយយកទៅគុណនឹង ១០០ ។ ឧទាហរណ៍ :

ចំនួនសរុបរបស់មនុស្សនៅក្នុងភូមិ = ៣០០ នាក់

ចំនួនសរុបនៃស្ត្រីនៅក្នុងភូមិ = ៦០ នាក់

ដូច្នេះចំនួនភាគរយនៃស្ត្រីនៅក្នុងភូមិមាន (៦០/៣០០) x ១០០ = ២០%

ពេលខ្លះភាគរយត្រូវបានផ្តល់ឱ្យ ហើយគេត្រូវការរកចំនួនមនុស្ស ឬរបស់តាមភាគរយនោះ ។ នៅក្នុងករណីបែបនេះគេចែកចំនួនភាគរយនឹងចំនួន ១០០ហើយគុណនឹងចំនួនសរុបនៃមនុស្ស ឬរបស់ដែលគេប្រាប់ ។ ឧទាហរណ៍ កសិករចំនួន៦០ភាគរយ នៅក្នុងចំណោមកសិករចំនួន ២០នាក់ កំពុងតែប្រើជីថ្មី ។ តើមានកសិករចំនួនប៉ុន្មាននាក់ដែលកំពុងប្រើជីថ្មី?

ភាគរយនៃកសិករដែលកំពុងតែប្រើជីថ្មី = ៦០/១០០

ចំនួនសរុបនៃកសិករដែលកំពុងតែប្រើជីថ្មី = (៦០/១០០) x ២០ = ១២

៣ ជំពូក

២. ចំនួនមធ្យមៈ ចំនួនមធ្យមនៃក្រុមចំនួនមួយចំនួនគឺជាផលបូកនៃចំនួនទាំងនោះ ចែកទៅនឹងចំនួនសុរបនៃចំនួនទាំងនោះ។ ដើម្បីគណនាចំនួនមធ្យម ចូរបូកចំនួនទាំងអស់ចូលគ្នា រួចហើយចែកទៅនឹងចំនួនសរុប។ ឧទាហរណ៍ ក្មេងចំនួន ១០នាក់ បានមកគ្លីនិកហើយអាយុរបស់វាមាន ៥ ៧ ៥ ៣ ៦ ៨ ៦ ៤ ៤ ២ ។ ដើម្បីរកចំនួមមធ្យម :

ចំនួនក្មេង = ១០

អាយុសរុបរបស់វា = ៥០ឆ្នាំ

អាយុរបស់វាគិតជាមធ្យម = ៥០/១០ = ៥ ឆ្នាំ

ចំនួនមធ្យមអាចជួយនៅក្នុងការប្រៀបធៀបក្រុមនៃចំនួនខុសគ្នា ដោយប្រើប្រាស់តែមួយចំនួនសំរាប់ក្រុមនីមួយៗ។ ចំណុចនេះមានសារៈសំខាន់ នៅពេលណាដែលមានបរិមាណច្រើននៃចំនួនត្រូវពិនិត្យ ។

៣. របាយចំនួនចំលើយ (Frequency of distributions)ៈ ភាពញឹកញាប់នៃអ្វីមួយដែលកើតឡើងមានន័យថា ចំនួនពេលវេលាដែលវាកើតឡើងដដែលៗតាមចន្លោះពេលជាក់លាក់។ បើអ្នកមានចំនួនច្រើន (A lot of numbers) នោះអ្នកអាចប្រើរបាយប្រេកង់ ដើម្បីចង់ដឹងថាតើវាកើតមានញឹកញាប់យ៉ាងណា។ នេះជាគោលការណែនាំខ្លះ :

- រៀបចំនួនរបស់អ្នកជាក្រុមៗដោយបញ្ចូលចំនួនទាំងអស់ពីចំនួនធំជាងគេរហូតដល់ចំនួនតូចជាងគេ ។
- ក្រុមទាំងអស់ត្រូវមានទស្សនៈទូលំទូលាយ (Width) ដូចៗគ្នាសំរាប់ជាប្រយោជន៍ប្រៀបធៀបការធ្វើដូច្នេះធ្វើឱ្យអ្នក អាចប្រៀបធៀបចំនួននៅក្នុងក្រុមផ្សេងៗ។
- ជៀសវាងការជាន់គ្នា - ចំនួនមួយសំរាប់តែក្រុមមួយតែប៉ុណ្ណោះ ។
- បន្ថែម ហើយពិនិត្យមើលលទ្ធផលរបស់អ្នក-ចំនួនសរុបគួរតែដូចនឹងចំនួនរង្វាស់ដែលអ្នកចាប់ផ្តើមជាមួយពីដំបូងមក។
- ប្រែក្លាយលទ្ធផលរបស់អ្នកឱ្យទៅជាតារាងប្រេកង់-ឥឡូវនេះអ្នកអាចកែប្រែតារាងឱ្យទៅជារបាយប្រេកង់ដោយមានចំណងជើងដែលរៀបរាប់ពីរង្វាស់ ។

*ប្រភពៈ Feuerstein, 1986:121-123*

ចំពោះគំរោងស្រាវជ្រាវតូចៗ វិធីល្អនៅក្នុងការរៀបចំទិន្នន័យគឺត្រូវប្រើសំណួរគន្លឹះ និងវិធីនៅក្នុងការឆ្លើយរបស់អ្នក។ ដើម្បីធ្វើដូច្នេះ ចូរប្រើគំរុយណែនាំចំហនៅក្នុងការសំភាសន៍ (Blank interview guide) ហើយសង្ខេបចំលើយទៅនឹងសំណួរនីមួយៗ ដោយបូកបញ្ចូលគ្នានូវទំហំនៃចំលើយទៅនឹងសំណួរ។ ចំពោះការសិក្សាស្រាវជ្រាវធំៗ ចូរពិនិត្យសំណួរស្រាវជ្រាវគន្លឹះរបស់អ្នក ដែលអ្នកចង់បានចំលើយ រួចហើយធ្វើបញ្ជីសំណួរ សំភាសន៍ និងឧបករណ៍ណាដែលមើលទៅអាចឆ្លើយទៅនឹងសំណួរគន្លឹះ។

ផលបូក ឬការរៀបប្រេកង់ គឺជាការគណនាមួយចង់ដឹងថា តើអ្នកឆ្លើយប៉ុន្មាននាក់ដែលសមល្មមសំរាប់បញ្ចូលទៅក្នុងចំណែកថ្នាក់ទិន្នន័យ ឬអថេរណាមួយ (ឧទាហរណ៍ ក្រុមអាយុ ចំណាត់ក្រុមទៅតាមកំរិតប្រាក់ចំណូល) (Fink and Kosecoff, 1985:78)។ ចំណុចនេះបង្ហាញថា គេត្រូវស្រង់ចំលើយទាំងអស់ដែលអ្នកស្រាវជ្រាវបាន/មិនបានកំណត់ជាមុន ហើយគេត្រូវបង្ហាញកំណត់សំគាល់ដើម្បីដឹងថា តើមានប៉ុន្មាននាក់ដែលផ្តល់ ចំលើយដូចគ្នា ឬខុសគ្នាទៅនឹងសំណួរ។ ការសិក្សាស្រាវជ្រាវរបស់ ADI ស្តីពី *ការបែងចែកដីធ្លីក្នុងទ្រង់ទ្រាយតូចនៅក្នុងប្រទេសកម្ពុជា : មេរៀនដែលដកស្រង់ចេញពីករណីសិក្សាចំនួនបី* សំណួរសំភាសន៍ដែលស៊ីគ្នានឹងសំណួរស្រាវជ្រាវត្រូវបានគេផ្តុំជាក្រុមមុន ហើយចំលើយទៅនឹងសំណួរសំភាសន៍ បន្ទាប់មកត្រូវបានគេ

គណនា និងសង្ខេប ឬបូកសរុប ។ ដូច្នេះ នៅលើបញ្ហាស្តីពីវិធីដែលអ្នកឆ្លើយចំនួន ៣១នាក់ នៅកំពង់ធំកំណត់កម្មសិទ្ធិរបស់គេនៅលើដីមួយដុំដែលគេបានទទួល ក្រុមអ្នកស្រាវជ្រាវពីដំបូងធ្វើតារាងការងារមួយ (ឧទាហរណ៍ទី១) ដែលស្រង់ចំលើយ ហើយគូស បើមានចំលើយប្រហាក់ប្រហែលគ្នារបស់គ្រួសារអ្នកឆ្លើយ គឺដូចមានបង្ហាញខាងក្រោមនេះ :

*ឧទាហរណ៍ទី១ :*

**សំណួរស្រាវជ្រាវ :** តើមានលក្ខខ័ណ្ឌចាំបាច់អ្វី និងវិធីសាស្ត្រអ្វីដែលគេប្រើដើម្បីផ្ទេរកម្មសិទ្ធិដីធ្លី?

**សំណួរក្នុងការសំភាសន៍ :** បើអ្នកមានសិទ្ធិពេញលេញលើដីដែលអ្នកបានទទួល តើជំហ៊ានអ្វីខ្លះដែលអ្នកត្រូវធ្វើតាមដើម្បីផ្ទេរកម្មសិទ្ធិ?

| ចំលើយ | កំណត់សំគាល់ផលបូកសរុប | ចំនួនសរុប | ភាគរយ |
|---|---|---|---|
| ខ្ញុំអត់ត្រូវបង់ទេ តែខ្ញុំមានបញ្ហាខ្លះដោយខ្ញុំមិនមានក្រដាសស្នាមសំរាប់បង្ហាញកម្មសិទ្ធិរបស់ខ្ញុំ ដូច្នេះនៅពេលដែលខ្ញុំមានបញ្ហា ខ្ញុំរត់ទៅរកមេឃុំ ចៅហ្វាយស្រុក និងចៅហ្វាយខេត្តឱ្យជួយ ដោះស្រាយបញ្ហា | I | ១ | ៣,២ |
| បងប្រុសខ្ញុំឱ្យខ្ញុំ | I | ១ | ៣,២ |
| បានបង់លុយថ្លៃដីហើយត្រូវការក្រដាស និងការធ្វើសាក្សីដោយប្រធានក្រុម ប្រធានភូមិ និងឃុំ | I | ១ | ៣,២ |
| បានសុំការអនុញ្ញាតិពីមេបញ្ជាការកងទ័ព | I | ១ | ៣,២ |
| មិនចាំបាច់មានឯកសារ | II | ២ | ៦,៥ |
| មិនមានការទាក់ទង | III | ៣ | ៩,៧ |
| រានយកដីដោយខ្លួនឯង ។ មិនមាននិតិវិធី | III | ៣ | ៩,៧ |
| ខ្ញុំអត់ត្រូវបង់អ្វីទេ | III | ៣ | ៩,៧ |
| ត្រូវជំរាបប្រធានភូមិមុនពេលលក់ | ~~IIII~~ I | ៦ | ១៩,៤ |
| មិនមានចំលើយ | ~~IIII~~ ~~IIII~~ | ១០ | ៣២,២ |
| សរុបៈ | | ៣១ | ១០០,០ |

### ***ចំពោះសំណួរមួយដែលមានចំលើយច្រើន (Dealing with Multiple Responses)***

មានករណីដែលអ្នកឆ្លើយតបផ្តល់ចំលើយច្រើនទៅនឹងសំណួរតែមួយ ហើយគេត្រូវគិតគូរទៅតាមហ្នឹង ។ ដោយប្រើឧទាហរណ៍ដូចខាងលើនេះ និងដោយសន្មត់ថា មានអ្នកឆ្លើយបីនាក់ដែលផ្តល់ចំលើយលើសពីមួយនោះ ចំលើយសរុបដែលគេរាប់ឃើញខុសពីចំនួនសរុបនៃករណី (ឬអ្នកឆ្លើយ) គឺមាន ៣៧ និង៣១ ។ ការគណនាភាគរយនៃតួលេខថ្មីនេះ អាចចោទឱ្យមានបញ្ហាដែលពិបាកដោះស្រាយនៅត្រង់ថា តើគេគួរដាក់លេខ ៣១ ឬលេខ ៣៧ យកធ្វើជាមូលដ្ឋានសំរាប់គណនារបាយភាគរយ (សូមមើលឧទាហរណ៍ទី២ ខាងក្រោមនេះ) ។ មិនមានវិធានកំណត់ច្បាស់លាស់ទេនៅក្នុងបញ្ហានេះ ឱ្យតែអ្នកស្រាវជ្រាវផ្តល់កំណត់សំគាល់នៅខាងក្រោមតារាង ឬនៅកន្លែងណាមួយនៅក្នុងសេចក្តីរៀបរាប់របស់តារាង ស្តីពីការដែលមានអ្នកឆ្លើយខ្លះដែល

ផ្តល់ចំលើយលើសពីមួយចំពោះសំណួរមួយ ។ ប៉ុន្តែតាមធម្មតា គេមិនបង្ហាញភាគរយទាំងពីរនេះនៅលើតារាងមួយទេ ដូច្នេះ អ្នកស្រាវជ្រាវត្រូវសំរេចថា តើត្រូវប្រើមួយណា ។ អ្នកស្រាវជ្រាវមួយចំនួនប្រើចំនួនភាគរយដោយផ្អែកលើចំនួន ចំលើយហើយ មិនផ្តល់តួលេខសរុបទេ ( ត្រូវបានបង្ហាញជាតួលេខដែលដាក់ស្នាមមិនច្បាស់ក្នុងតារាងខាងក្រោមនេះ) ប៉ុន្តែ ( ក) ចំណាំថា ចំនួន សរុបនៃករណី ( នោះគឺ N = ៣១) ក្រោយចំណងជើងនៃកូឡោនបញ្ឈរ ដែលបង្ហាញពីចំនួនដង ដែលគេរាប់ឃើញ និង ( ខ) បង្ហាញនៅបាតតារាងថា "ភាគរយសរុបលើសពី១០០ ដោយសារមានចំលើយច្រើនចំពោះសំណួរដដែល" ។ វាជាការល្អដែរដែល គេត្រូវដឹងថា អក្សរអិនធំ (N) ត្រូវបានគេប្រើញឹកញាប់ដើម្បីបង្ហាញទំហំនៃសំណាក ចំណែកឯអក្សរអិនតូច (n) បង្ហាញចំនួនដង ឬចំនួននៃចំលើយនៅលើប្រភេទចំលើយនីមួយៗ ។

*ឧទាហរណ៍ទី២ :*

**សំណួរស្រាវជ្រាវ :** តើមានលក្ខខ័ណ្ឌចាំបាច់អ្វីនិងវិធីសាស្រ្តអ្វីដែលគេប្រើដើម្បីផ្ទេរកម្មសិទ្ធិដីធ្លី?

**សំណួរក្នុងការសំភាសន៍ :** បើអ្នកមានសិទ្ធិពេញលេញលើដីដែលអ្នកបានទទួល តើជំហានអ្វីខ្លះដែលអ្នកត្រូវធ្វើតាម ដើម្បីផ្ទេរកម្មសិទ្ធិ?

| ចំលើយ | កំណត់សំគាល់ផលបូកសរុប | សរុប ផ្អែកលើចំនួនចំលើយ a/ | ភាគរយផ្អែកលើចំនួនករណី | ភាគរយ |
|---|---|---|---|---|
| ខ្ញុំអត់ត្រូវបង់ទេ តែខ្ញុំមានបញ្ហាខ្លះដោយខ្ញុំមិនមានក្រដាសស្នាម សំរាប់បង្ហាញកម្មសិទ្ធិរបស់ខ្ញុំ ដូច្នេះនៅពេលដែលខ្ញុំមានបញ្ហា ខ្ញុំរត់ទៅរកមេឃុំ ចៅហ្វាយស្រុក និងចៅហ្វាយខេត្តឱ្យជួយដោះស្រាយបញ្ហា | I | ១ | ៣,២ | ២,៧ |
| បងប្រុសខ្ញុំឱ្យខ្ញុំ | II | ២ | ៦,៥ | ៥,៤ |
| បានបង់លុយថ្លៃដី ហើយត្រូវការក្រដាសនិងសាក្សីដោយប្រធានក្រុម ប្រធានភូមិ និងមេឃុំ | II | ២ | ៦,៥ | ៥,៤ |
| បានសុំការអនុញ្ញាតិពីមេបញ្ជាការកងទ័ព | III | ៣ | ៩,៧ | ៨,១ |
| មិនចាំបាច់មានឯកសារ | III | ៣ | ៩,៧ | ៨,១ |
| មិនមានការទាក់ទង | III | ៣ | ៩,៧ | ៨,១ |
| បានយកដីដោយខ្លួនឯង -មិនមាននិតិវិធី | III | ៣ | ៩,៧ | ៨.១ |
| ខ្ញុំអត់ត្រូវបង់អ្វីទេ | III | ៤ | ១២,៩ | ១០.៨ |
| ត្រូវជំរាបប្រធានភូមិមុនពេលលក់ | ~~III~~ I | ៦ | ១៩,៤ | ១៦,២ |
| មិនមានចំលើយ | ~~IIII~~ ~~IIII~~ | ១០ | ៣២,២ | ២៧,០ |
| សរុបៈ | | ៣៧ | ១១៩,៤ | ១០០,០ |

a/ ចំនួនភាគរយសរុបលើសពី ១០០ ដោយសារមានចំលើយច្រើនចំពោះសំណួរដដែល ។

### *រៀបចំណាត់ក្រុម/ប្រមូលសរុបទិន្នន័យ (Classify and Group/Consolidate the Data)*

ដោយបានប្រមូលសរុបពត៌មានទាំងអស់ស្ដីពីសំណួរហើយ ជំហ៊ានបន្ទាប់គឺរៀបចំណាត់ក្រុមចំពោះពត៌មាន ជាចំណែកថ្នាក់ដែលមានន័យ ។ ទិន្នន័យបង្ហាញនៅក្នុងតារាងខាងលើនេះធ្វើឱ្យគេមានការពិបាកប្រើដោយសារ :

- មិនមានលំដាប់លំដោយចំលើយ
- ពិបាកយល់បាន
- ពិបាកភ្ជាប់ទៅនឹងពត៌មានដែលបានមកពីសំណួរសំភាសន៍ផ្សេងទៀត
- ពិបាកទាញចេញជាគំនិតយោបល់ (ដែលយល់ឃើញ)

ដូច្នេះ គេត្រូវធ្វើឱ្យវាកាន់តែមានភាពងាយយល់ ។ អ្នកស្រាវជ្រាវត្រូវពិនិត្យទិន្នន័យដោយប្រយ័ត្ន ហើយតាមធម្មតា ទំរង់បែបផែន ឬគំនិតដែលច្រើនកើតមាន ឬភាសាគឺគេអាចរកឃើញនៅក្នុងចំណោមចំលើយ ។ ទំរង់បែបផែននេះ គេអាចយកកំណត់ជាផ្នែក (Category) ដែលនៅជុំវិញនោះគេរាប់ចំលើយ ។ បន្ទាប់មកចំលើយត្រូវបានសង្ខេបជាភាគរយ ហើយមានលក្ខណៈរៀបរាប់ច្រើនពីគ្រួសារដែលត្រូវបានវិភាគ ។ តារាងខាងក្រោមនេះបញ្ជាក់បន្ថែមលើឧទាហរណ៍ទី១ ហើយបង្ហាញពីវិធីដែលតារាងនេះសំរួលឱ្យងាយយល់ និងសង្ខេប ។

| | N | % |
|---|---|---|
| **ជំរាប ឬប្រាប់មន្ត្រីម្នាក់ឱ្យចូលរួម**<br>(បានបង់លុយថ្លៃដី និងត្រូវការក្រដាសស្នាមពីប្រធានភូមិ ឬក្រុម ឬឃុំ ។ ខ្ញុំមិនចាំបាច់បង់លុយទេ តែខ្ញុំមានបញ្ហាពីព្រោះខ្ញុំមិនមានក្រដាសស្នាមសំរាប់បញ្ជាក់កម្មសិទ្ធិរបស់ខ្ញុំ ដូច្នេះនៅពេលខ្ញុំមានបញ្ហាខ្ញុំរត់ទៅរកមេឃុំ ចៅហ្វាស្រុក និងខេត្តឱ្យជួយដោះស្រាយបញ្ហា ។ ត្រូវជំរាបប្រធានភូមិមុនពេលលក់ ។ សុំការអនុញ្ញាតិពីមេបញ្ជាការកងទ័ព ។ | ៩ | ២៩ |
| **មិនបានប្រើនិតិវិធីអ្វីទេ**<br>[រានដីដោយខ្លួនឯង ដូច្នេះមិនមាននិតិវិធីទេ (៣) ។ បងប្រុសខ្ញុំឱ្យខ្ញុំ (១) ។ មិនចាំបាច់មានឯកសារ (២) មិនមានការទាក់ទង (៣)] | ៩ | ២៩ |
| **មិនចាំបាច់បង់លុយ** | ៣ | ៩.៩ |
| **មិនមានចំលើយ** | ១០ | ៣២.៣ |
| **សរុប** | ៣១ | ១០០ |

នៅក្នុងតារាងដែលត្រូវបានសំរួលឱ្យងាយនេះ មានចំណែកថ្នាក់ចំនួនតែបួនទេត្រូវបានប្រើហើយ ចំលើយទាំងអស់ដែលដូចគ្នាត្រូវបានបញ្ចូលគ្នា ។ ចំលើយទាំងអស់ដែលនិយាយដល់មន្ត្រី (មន្ត្រីយោធា ខេត្ត ស្រុក ឬឃុំ) ត្រូវបានផ្គុំគ្នា ហើយចំលើយដែលមិនបង្ហាញឱ្យឃើញនិតិវិធីត្រូវបានផ្គុំគ្នា (ឧទាហរណ៍ បងប្រុសខ្ញុំឱ្យខ្ញុំ) ។ ចំលើយដែលថា "មិនបាច់ត្រូវបង់លុយ" ត្រូវដាក់ដោយឡែក ពីព្រោះវាមិនមានការទាក់ទងនឹងសំណួរ ។ ជាទូទៅ លទ្ធផលរកឃើញដែលមានចំនួនប្រេកង់ច្រើនជាងគេបំផុត ត្រូវបានស្រង់មុន ហើយ "ចំលើយថាទេ" ត្រូវបានដាក់ក្រោយគេនៅក្នុងតារាង ។ តួលេខសង្ខេបបែបនេះ (គឺប្រេកង់) អាចត្រូវបានគេបង្ហាញដូចនៅក្នុងតារាងខាងលើជាតារាងបន្ទាត់ ឬតារាង Pie Chart, Histogram និងដ្យាក្រាមខ្សែបន្ទាត់ (រូបភាពទី៨) ។

**រូបទី ៨. គំរូនៃ Pie Chart**




ខាងលើនេះគឺជាឧទាហរណ៍នៃវិធីដែលគេបូកសរុបទិន្នន័យដើម្បីធ្វើឱ្យសេចក្តីសង្ខេបទិន្នន័យមានភាពកាន់តែច្បាស់លាស់ ។ ប៉ុន្តែគេត្រូវចាំថា រឿងដែលនៅពីក្រោយចំលើយដែលត្រូវបានគេរាយការណ៍មកសំខាន់ដូចគ្នានឹងចំនួន និងភាគរយដែរ ។ នៅក្នុងឧទាហរណ៍នេះ អ្នកស្រាវជ្រាវបានប្រាប់ក្រុមថា តាមពិតទៅគ្មាននរណាម្នាក់បានផ្តល់ប័ណ្ណកម្មសិទ្ធិដល់គេលើដីរបស់គេទេ ។ គ្មានអ្នកភូមិណាម្នាក់មានឯកសារផ្លូវច្បាប់ដែលបង្ហាញថា ដីនោះជារបស់គេទេ ។ ឯកសារតែមួយគត់ដែលមាន គឺផែនទីដែលប្រធានភូមិជាអ្នកទុក ។ បើគេចង់លក់ដីរបស់គេ គេត្រូវសុំការអនុញ្ញាតិពីប្រធានភូមិ ហើយប្រធានភូមិអាចកែប្រែផែនទី ។ នេះគឺជាពត៌មានដែលត្រូវពិចារណា និងសរសេរទុកដើម្បីឱ្យគេយល់សាច់រឿងបានច្បាស់ ។

### ការវិភាគទិន្នន័យបែបគុណភាព (Qualitative Data Analysis)

ការវិភាគទិន្នន័យបែបគុណភាព គឺជាការស្រាវជ្រាវមួយដើម្បីចេញជាសេចក្តីថ្លែងរួមអំពីទំនាក់ទំនងនានា នៅក្នុងចំណោមចំណែកផ្នាក់នៃទិន្នន័យ ។ ទំរង់ការនៃការវិភាគមានច្រើនជំហានគឺ រៀបចំទិន្នន័យ កំណត់ជាផ្នែក ការធ្វើតេស្តសម្មតិកម្ម (hypothesis) ផ្ទៀងផ្ទាត់ទៅនឹងទិន្នន័យ រកមើលសេចក្តីពន្យល់ផ្សេងទៀតចំពោះទិន្នន័យ ហើយសរសេររបាយការណ៍ ។ ដំណាក់កាលនីមួយៗនៃការវិភាគទិន្នន័យត្រូវមានការបង្រួមទិន្នន័យ ពីព្រោះទិន្នន័យ ច្រើនត្រូវបង្រួមឱ្យមានចំនួនដែលអាចក្តាប់បាន និងការបកស្រាយ ពីព្រោះអ្នកស្រាវជ្រាវត្រូវបញ្ជាក់អត្ថន័យ និងការយល់ឃើញចំពោះពាក្យសំដី និងទង្វើរបស់អ្នកចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវ ។

### *តំរៀប និងរៀបចំទិន្នន័យ[១៤] (Sorting and Organizing the Data)*

ការអានទិន្នន័យ ហើយអានទៀតធ្វើឱ្យអ្នកស្រាវជ្រាវស្គាល់ពីទិន្នន័យ ។ នៅក្នុងដំណើរការនេះ អ្នកស្រាវជ្រាវអាចស្រង់ទុកនៅលើក្រដាសនូវទិន្នន័យដែលមានធ្វើការកែសំរួលតិចតួចបើចាំបាច់ ហើយ "សំអាត" ជាទូទៅ ។ ដោយសារអ្នកស្រាវជ្រាវត្រូវធ្វើការកត់ចំណាំច្រើននៅក្នុងការប្រមូលទិន្នន័យ អ្នកស្រាវជ្រាវត្រូវរៀបចំទុកដាក់ឯកសាររបស់គាត់ក្នុងប្រអប់ផ្សេងៗ ឬក្នុងឯកសារក្នុងកុំព្យូទ័ររបស់គាត់ទៅតាមប្រព័ន្ធលំដាប់លេខរៀងត្រឹមត្រូវ ។ ការរៀបចំក្រដាសសំណេរដែលបានពីការចុះមូលដ្ឋាន ធ្វើទៅតាមលំដាប់លេខរៀង ឬតាមប្រធានបទដែលធ្វើឱ្យអ្នកស្រាវជ្រាវងាយរកវាឃើញនៅពេលត្រូវការពិនិត្យមើលទិន្នន័យ ។ អ្វីដែលសំខាន់បំផុត ចំពោះការងារនេះគឺការពិនិត្យមើលឡើងវិញលើសំណួរស្រាវជ្រាវ ពីព្រោះវាអាចកំណត់ថា តើអ្នកស្រាវជ្រាវអាចធ្វើបានល្អប៉ុនណាចំពោះសំណួរទាំងនេះ និងថាតើទំហំ ឬអត្ថន័យថ្មីៗអ្វីខ្លះដែលអ្នកស្រាវជ្រាវបានស្វែងយល់ ឬបន្ថែមលើសំណួរ ។

[១៤] ផ្នែកនេះបន្ថែមលើការពិភាក្សាស្តីពីការវិភាគលើទិន្នន័យរបស់ Marshall and Rossman, 1989:114-116 and Mason, 1996:107-108, 131.

សកម្មភាពដែលមានប្រយោជន៍នៅក្នុងការតំរៀប និងរៀបចំទិន្នន័យបែបគុណភាពគឺការរៀបចំដ្យាក្រាម និងតារាង ។ គេអាចប្រើដ្យាក្រាម និងតារាងបែបនេះដើម្បីកត់ត្រា ឬបង្ហាញទិន្នន័យពីព្រោះវាងាយអាន ។ តារាង (Flow chart) បង្ហាញលំដាប់តគ្នានៃអ្វីដែលកើតមាន ឬម៉ាទ្រិចនៃទំនាក់ទំនងរវាងសមាសភាគផ្សេងៗនៃបញ្ហាមួយដែលកំពុងត្រូវបានវិភាគ ។ ផ្ទុយទៅវិញ ដ្យាក្រាមអាចពន្យល់បង្ហាញពីទំរង់ ឬលំដាប់តគ្នានៃអំពើដែលមានទៅវិញទៅមក នៅក្នុងចំណោមសមាសភាគនៃបញ្ហាសំរាប់ការសិក្សាស្រាវជ្រាវ ។

### ***កំណត់ចំណែកថ្នាក់ ផ្នែកសំខាន់ៗ និងនិន្នាការ[១៥] (Generating Categories, themes and patterns)***

ការកំណត់ប្រធានបទលេចធ្លោ គំនិតដែលច្រើនមាន ឬភាសា និងបែបផែននៃជំនឿដែលផ្សាភ្ជាប់មនុស្សទៅនឹងបរិយាកាសកំណត់ជុំវិញ គឺជាដំណាក់កាលពិបាកជាងគេនៃការវិភាគទិន្នន័យ ហើយជាដំណាក់កាលមួយដែលអាចបញ្ចូលគ្នានូវការងារទាំងមូល ។ តាមរយៈការដេញដោលលើទិន្នន័យ និងការឆ្លុះបញ្ចាំងលើក្របខ័ណ្ឌដែលអាចយកធ្វើជាមូលដ្ឋាននៃការស្រាវជ្រាវរបស់អ្នកបាន អ្នកស្រាវជ្រាវអាចចាប់យកគំនិត និងទិន្នន័យនៅក្នុងការងារស្រាវជ្រាវរបស់គេ ។

ដំណើរការនៃការរៀបចំចំណែកថ្នាក់ទិន្នន័យមានការកត់សំគាល់ លើភាពមិនប្រក្រតីនៃបរិយាកាសជុំវិញ ឬមនុស្សដែលត្រូវបានគេជ្រើសរើសសំរាប់ការសិក្សាស្រាវជ្រាវ ។ នៅពេលមានចំណែកថ្នាក់នៃប្រធានបទ ហើយអ្នកស្រាវជ្រាវរកមើលចំណែកថ្នាក់ដែលមានលក្ខណៈស៊ីគ្នាច្បាស់លាស់ដោយខ្លួនឯងតែខុសគ្នាពីមួយទៅមួយ ។ វិធីមួយទៀតនៅក្នុងការកំណត់ចំណែកថ្នាក់ប្រធានបទ (ឬអត្ថន័យ) និងទំរង់បែបផែនគឺការវិភាគ ដែលក្នុងនោះ ការងារកំណត់ចំណាត់ថ្នាក់ប្រសព្វគ្នាខ្លះ ដើម្បីបានការយល់ដឹងថ្មី ។ ដោយតាមធម្មតាត្រូវបានបង្ហាញជាទំរង់ម៉ាទ្រិច ការកំណត់ចំណាត់ថ្នាក់បែបប្រសព្វគ្នា (cross-classification) នេះនាំឱ្យគេឃើញមានភាពខុសគ្នានៅក្នុងទិន្នន័យដែលត្រូវបានគេវិភាគហើយ ។ ការនេះនាំឱ្យគេគិតទៅដល់ផ្នែកដែលក្នុងនោះទិន្នន័យត្រូវគេរកមិនឃើញ ។

### ***ការវិភាគលើខ្លឹមសារ[១៦] (Content analysis)***

ការវិភាគលើខ្លឹមសារគឺជាពាក្យដែលគេប្រើដើម្បីវិភាគលើរបាយការណ៍បែបរៀបរាប់ទាក់ទងនឹងនិន្នាការ ប្រធានបទ ឬព្រឹត្តិការណ៍ ។ គេអាចប្រើការវិភាគលើខ្លឹមសារដើម្បីសង្ខេបពត៌មានរៀបរាប់ ឬរៀបចំទំរង់នៃពត៌មានបែបគុណភាពឡើងវិញ ។ គេប្រើវាផងដែរដើម្បីកំណត់ចំណែកថ្នាក់នៃតារាងបែបបរិមាណ ។ ដូច្នេះបើសិនជាមនុស្សចំនួន ១០០នាក់ ត្រូវបានគេសួរពីអត្ថប្រយោជន៍នៃការប្រើអណ្តូងស្នប់ ពត៌មាននេះអាចត្រូវបានគេសង្ខេបដោយប្រើការវិភាគលើខ្លឹមសារ ការកំណត់លេខកូដការរៀបជាតារាងនៅក្នុងលក្ខណៈដូចខាងក្រោមនេះ ៖

**ជំហ៊ានទី១ :** អានចំលើយ ហើយសរសេរចំលើយនីមួយៗ ។

**ជំហ៊ានទី២ :** រើសចំលើយដែលមានច្រើនជាងគេ ហើយបញ្ជាក់ដោយខ្លីៗលើចំលើយ ។ ផ្តុំចំលើយសំខាន់នីមួយៗ ជាចំណែកថ្នាក់មួយ ។ ឧទាហរណ៍ "អណ្តូងស្នប់ស្រួលប្រើច្រើន ។ សូម្បីតែកូនពៅរបស់ខ្ញុំ ក៏ខ្ញុំអាចប្រើវាឱ្យទៅដងទឹកបានដែរ ។ ទឹកស្អាតជានិច្ច ហើយអណ្តូងនោះមិនដែលខូចទេ ។"

---

[១៥] Ibid, 114

[១៦] ផ្នែកនេះបានមកពីNarayan, 1996:131-132 ។ គេគួរកត់សំគាល់ថា ការវិភាគលើខ្លឹមសារមានភាពស្មុគស្មាញជាងវិធីដែលគេរៀបរាប់វានៅក្នុងសៀវភៅនេះ ។ បើចង់ដឹងបន្ថែមនៅត្រង់ផ្នែកនេះ ចូរអានក្នុង Berg, 1989 and Mason, 1996 ។

កំណត់ជាផ្នែកៈ ១. ងាយស្រួលប្រើ
២. ក្មេងអាចប្រើបាន ។
៣. ទឹកស្អាត
៤. ជាប្រភពអាចពឹងអាស្រ័យបាន-មិនខូច ។

**ជំហានទី៣ :** ពិនិត្យចំណែកថ្នាក់នីមួយៗដើម្បីបញ្ជាក់ថា វាមិនដូចគ្នាហើយអ្នកកំណត់កូដយល់ច្បាស់អំពី ថាតើចំលើយមួយណាត្រូវចូលទៅក្នុងចំណែកថ្នាក់ណា ។

**ជំហានទី៤ :** បំពេញទំរង់ការនៃការកំណត់កូដ ។

**ជំហានទី៥ :** រៀបជាតារាងលើប្រេកង់សំរាប់ចំលើយមួយៗ ។

### *ការធ្វើតេស្តលើសម្មតិកម្មដែលមានការប្រែប្រួល*[១៧] *(Testing evolving hypothesis)*

នៅពេលកំណត់ចំណែកថ្នាក់ និងទំរង់បែបផែនរួចហើយ អ្នកស្រាវជ្រាវចាប់ផ្តើមដំណើរការនៃការវាយតំលៃលើភាពអាចឱ្យគេជឿបាននៃសម្មតិកម្មថ្មីៗទាំងនេះ ហើយធ្វើតេស្តវាផ្ទៀងផ្ទាត់នឹងទិន្នន័យ ។ ការងារនេះត្រូវមានការរកមើលក្នុងទិន្នន័យចោទជាសួរដេញដោលលើសម្មតិកម្ម ហើយរកមើលករណីអវិជ្ជមាននៃទំរង់បែបផែនហើយបញ្ចូលវាទៅក្នុងគំនិតធំៗបើចាំបាច់ ។ ផ្នែកមួយនៃដំណាក់កាលនេះ គឺវាយតំលៃទិន្នន័យដើម្បីរកមើលភាពគ្រប់គ្រាន់របស់វាផ្អែកពតិមាន ភាពអាចឱ្យគេជឿបាន ភាពមានប្រយោជន៍ និងត្រូវនឹងប្រធានបទ ។ ក្រៅពីនេះ អ្នកស្រាវជ្រាវត្រូវកំណត់ថា តើទិន្នន័យមានប្រយោជន៍ ឬអត់នៅក្នុងការបំភ្លឺលើសំណួរដែលគេកំពុងតែស្វែងយល់ ឬថាតើវាទាក់ទងនឹងរឿងដែលកំពុងលាតត្រដាងអំពីស្ថានភាពសង្គម ដែលកំពុងត្រូវបានស្រាវជ្រាវដែរឬទេ ។

### *រកមើលសេចក្តីពន្យល់ផ្សេងៗ*[១៨] *(Searching for alternative explanations)*

នៅពេលបានជាចំណែកថ្នាក់ និងទំរង់បែបផែនហើយ អ្នកស្រាវជ្រាវត្រូវស្វែងយល់លើភាពត្រឹមត្រូវនៃទំរង់បែបផែនដែលលេចឡើងនោះ ។ អ្នកស្រាវជ្រាវត្រូវរកមើលសេចក្តីពន្យល់ដ៏សមស្របផ្សេងទៀត ចំពោះទិន្នន័យទាំងនេះ និងការភ្ជាប់គ្នានៃទិន្នន័យទាំងនោះ ។ សេចក្តីពន្យល់ម្យ៉ាងទៀតតែងតែមានជានិច្ច ។ អ្នកស្រាវជ្រាវត្រូវតែរកមើលវា ហើយរៀបរាប់វា បន្ទាប់មកសំដែងឱ្យឃើញថា សេចក្តីពន្យល់នោះពិតជាមានហេតុផលត្រឹមត្រូវជាងគេមែន ។

### *ការសរសេររបាយការណ៍*[១៩] *(Writing Reports)*

ការសរសេរអំពីទិន្នន័យបែបគុណភាពមិនអាចចែកដាច់ចេញពីដំណើរការវិភាគបានទេ ។ តាមពិតទៅ វាមានសារៈសំខាន់បំផុតដល់ដំណើរការនោះ ពីព្រោះនៅក្នុងការជ្រើសរើសពាក្យដើម្បីសង្ខេប និងធ្វើការឆ្លុះបញ្ចាំងលើភាពស្មុគស្មាញនៃទិន្នន័យ អ្នកស្រាវជ្រាវត្រូវធ្វើការបកស្រាយកំណត់រូបរាងទំរង់ និងអត្ថន័យនៃទិន្នន័យដែលមិនទាន់ធ្វើការកែច្នៃ (Raw data) ដ៏សន្ធឹក

---

[១៧] ផ្អែកនេះដកស្រង់ចេញពី Marshall and Rossman, 1989:118

[១៨] Ibid, p. 119

[១៩] សេចក្តីពិភាក្សានេះត្រូវបានដកស្រង់ចេញពី Marshall and Rossman, 1989:119

សន្ទាប់នោះ ។ មានរបៀបច្រើនយ៉ាងនៅក្នុងការសរសេររបាយការណ៍ ហើយវិធីសរសេររបាយការណ៍ ៥ យ៉ាងត្រូវបានលើកស្នើឡើង[២០] ។ ទីមួយគឺប្រវត្តិជីវិតបែបរៀបរាប់ ។ នៅត្រង់នេះសេចក្តីរៀបរាប់ពីជីវិតរបស់មនុស្សម្នាក់ ត្រូវបានលើកបង្ហាញអមដោយចំណុចវិភាគពីសារៈសំខាន់ផ្នែកសង្គមនៃជីវិតនោះ ។ ទីពីរ គឺការបង្ហាញពីទិន្នន័យដែលត្រូវបានប្រមូលមកឆ្លងតាមការសំភាសន៏លំអិត និងការសង្កេតរបស់អ្នកចូលរួម ដែលក្នុងនោះទស្សនៈយល់ឃើញរបស់អ្នកចូលរួមត្រូវបានលើកបង្ហាញ ហើយទស្សនៈរបស់គេ អំពីការបង្កើតបានជាទំរង់នៃរបាយការណ៍ ។ ទីបី ការអនុវត្តន៏ទាក់ទងនឹងទ្រឹស្តី ។ ទិន្នន័យបែបរៀបរាប់ត្រូវបានសង្ខេប ហើយភ្ជាប់ជាមួយនឹងទ្រឹស្តីទូទៅ ។ វិធីទីបួនគឺការចង់កសាងទ្រឹស្តីដោយទាញចេញពីទិន្នន័យដែលប្រមូលបានពីស្ថាប័នច្រើនប្រភេទ និងនៅក្រោមលក្ខ័ណ្ឌផ្សេងៗនៃការស្រាវជ្រាវ ។

### *រឿងខ្លីៗ (Anecdotes)*

ពេលខ្លះរឿងខ្លីៗសំខាន់ៗ និងសំរង់ពាក្យសំដីខ្លី អាចសង្ខេបបានលើអត្ថន័យនៃអ្វីដែលគេបាននិយាយ ឬសន្និដ្ឋាន (Narayan, 1996:132) ។ ដោយត្រូវបានប្រើតាមបរិបទ វាអាចជាឧបករណ៏វិភាគដ៏មានប្រសិទ្ធភាព (Narayan) ។ ជាទូទៅ វិធីសាស្រ្តស្ថិតនៅក្នុងរង្វង់នៃការវិភាគលើសេចក្តីរៀបរាប់ដែលចង់សំដៅ លើកន្សោមនៃវិធានដែលប្រើប្រាស់អត្ថបទផ្សេងៗ ដែលមានលក្ខណៈដូចជាទំរង់សាច់រឿង (Lewis-Beck et al, 2004:705) ។ នៅក្នុងរបាយការណ៏វាយតំលៃពីការអភិវឌ្ឍផ្នែកសង្គម និងរបាយការណ៏ជំរឿនខ្លីៗ នេះអាចធ្វើជាសេចក្តីពន្យល់បំភ្លឺ ឬការអនុវត្តជាក់ស្តែងលើទំរង់បែបផែនដែលត្រូវបានគេសង្កេត ឬការអនុវត្តជាក់ស្តែងលើសេចក្តីដកស្រង់នៃដំណើរជឿនលឿនទៅមុខ ឬអ្វីដែលកើតឡើងហើយកំពុងត្រូវបានគេវិភាគ ។

## រៀបចំទំរង់នៃរបាយការណ៏ (Preparing the Outline of the Report)

ទោះបីជានៅពេលដែលអ្នកស្រាវជ្រាវកំពុងតែបញ្ចូលទិន្នន័យក្តី ការត្រិះរិះថា តើរបាយការណ៏ស្រាវជ្រាវមើលទៅមានលក្ខណៈយ៉ាងដូចម្តេច និងរបៀបដែលគេសរសេររបាយការណ៏ ត្រូវតែអ្នកស្រាវជ្រាវយកចិត្តទុកដាក់ជាងគេ ពីព្រោះវាជួយធ្វើឱ្យគេចងចាំវិធីលើកបង្ហាញទិន្នន័យសង្ខេបឱ្យបានល្អ ។ ការមានគ្រោងរបាយការណ៏នៅជិតដៃធ្វើឱ្យអ្នកស្រាវជ្រាវអាចសរសេរចំណាប់អារម្មណ៏ ឬការគិតគូរដំបូងរបស់គាត់ទៅលើទំរង់បែបផែនដែលកំពុងត្រូវបានសង្កេតទាក់ទងនឹងទិន្នន័យនៅក្នុងផ្នែកសមស្របនៃទំរង់របាយការណ៏ ។

របាយការណ៏គឺជា*សេចក្តីរៀបរាប់សង្ខេបនូវព្រឹត្តិការណ៏* ឬបទពិសោធន៏ដែលត្រូវបានគេរៀបចំដើម្បីផ្តល់ដល់អ្នកប្រើប្រាស់នូវ *សេចក្តីសន្និដ្ឋាន ឬពត៌មានជាគន្លឹះ* ដើម្បីជួយគេឱ្យប្រើប្រាស់ពត៌មានបានត្រឹមត្រូវឬ/និងក្នុងការសំរេចចិត្តឱ្យបានល្អ ។ នៅក្នុងការស្រាវជ្រាវរបាយការណ៏ត្រូវបានសរសេរដើម្បីប្រាប់ច្បាស់នូវលទ្ធផលរកឃើញ និងវិធីសាស្រ្តនៃការស្រាវជ្រាវ (Neuman, 2000:466) ។ ផ្នែកសំខាន់នៃរបាយការណ៏ ជាធម្មតារួមមានសេចក្តីផ្តើម តួសេចក្តី និងសេចក្តីសន្និដ្ឋាន (និងអនុសាសន៏) ។

ការត្រៀមរៀបចំសរសេររបាយការណ៏មានច្រើនជំហ៊ាន ជំហ៊ានដំបូងៗគឺការគិតគូរលើសំណួរគន្លឹះដូចខាងក្រោមនេះ ៖

១. តើអ្នកណាជាអ្នកអាន?
២. តើគេត្រូវការពត៌មានអ្វី?
៣. តើពត៌មានដែលគេត្រូវការនោះមានតាមទំរង់កំណត់ដែរឬទេ?

[២០] Talor, S.J. and R. Bogdan, 1984, Introduction to Qualitative Research: The Search for Meanings as cited in Marshall and Rossman, 1989:119

៤. តើគេដឹងអ្វីខ្លះហើយ?
៥. តើអ្នកអាននឹងយករបាយការណ៍ទៅធ្វើអ្វី?
៦. តើនៅពេលណាដែលអ្នកអានត្រូវការរបាយការណ៍?

នៅពេលដែលចំលើយសំរាប់សំណួរខាងលើនេះត្រូវបានរៀបចំហើយ គេត្រូវធ្វើសេចក្តីព្រាងលើគ្រោងរបាយការណ៍។ គ្រោងគឺគ្រាន់តែជាឧបករណ៍សំរាប់ជួយអ្នកស្រាវជ្រាវនៅក្នុងការរៀបចំគំនិតរបស់គេនៅលើក្រដាស។ បើនិយាយឱ្យចំគឺវាជួយ (ក) តំរៀបគំនិតយោបល់តាមលំដាប់ (ពោលគឺអ្វីដែលត្រូវនិយាយដំបូងទី២ និងទី៣) (ខ) ផ្តុំនូវគំនិតដែលទាក់ទងគ្នា និង(គ) ចែកដាច់ពីគ្នានូវគំនិតដែលមានលក្ខណៈទូទៅ ឬមានកំរិតខ្ពស់ ដកគំនិតចេញពីគំនិតជាក់លាក់ផ្សេងៗ ហើយគំនិតជាក់លាក់នោះត្រូវចេញពីគំនិតដ៏លំអិតឯទៀត (Neuman, 2000:466) ។ គ្រោងដំបូងមានលក្ខណៈជាពង្រាងដែលគេអាចនឹងកែ និងពង្រីកបន្ថែមនៅពេលគេបន្តពិនិត្យទិន្នន័យ។ គេត្រូវចាំថា គ្រោងគឺគ្រាន់តែជាគំរុយណែនាំសំរាប់អ្នកស្រាវជ្រាវតែប៉ុណ្ណោះ។ អ្នកស្រាវជ្រាវអាចធ្វើការកែសំរួលទំរង់នោះខ្លះ នៅពេលដែលគាត់សរសេរ ហើយក៏នឹកឃើញដល់គំនិតថ្មីៗដែលមានភាពច្បាស់ជាង។

*គ្រោងអាចមានលក្ខណៈដូចតារាងទី៦ :*

**តារាងទី៦ : ទំរង់នៃរបាយការណ៍**

| | |
|---|---|
| I. ចំណងជើងធំដំបូង សារៈសំខាន់ជាងគេលំដាប់ទី ១ | |
| ក. ចំណងជើងបន្ទាប់នៃចំណងជើង I | សារៈសំខាន់ជាងគេលំដាប់ទី២ |
| ១. ចំណងជើងបន្ទាប់នៃចំណងជើង ក | សារៈសំខាន់ជាងគេលំដាប់ទី៣ |
| ក. ចំណងជើងបន្ទាប់នៃ ១ | សារៈសំខាន់ជាងគេលំដាប់ទី៤ |
| ខ. ចំណងជើងបន្ទាប់នៃ ១ | " |
| ១ ចំណងជើងបន្ទាប់នៃ ខ | សារៈសំខាន់ជាងគេលំដាប់ទី៥ |
| ២ ចំណងជើងបន្ទាប់នៃ ខ | " |
| (ក) ចំណងជើងបន្ទាប់នៃ (២) | សារៈសំខាន់ជាងគេលំដាប់ទី៦ |
| (ខ) ចំណងជើងបន្ទាប់នៃ (២) | " |
| ១. ចំណងជើងបន្ទាប់នៃ (ខ) | សារៈសំខាន់ជាងគេលំដាប់ទី៧ |
| ២. ចំណងជើងបន្ទាប់នៃ (ខ) | " |
| ២. ចំណងជើងបន្ទាប់នៃចំណងជើង ក | សារៈសំខាន់ជាងគេលំដាប់ទី៣ |
| ខ. ចំណងជើងបន្ទាប់នៃចំណងជើង I | សារៈសំខាន់ជាងគេលំដាប់ទី២ |
| II. ចំណងជើងធំទី ២ ។ល។ | សារៈសំខាន់ជាងគេលំដាប់ទី ១ |

ដកស្រង់ពី Neuman, 2000:466

ដោយលើកឧទាហរណ៍ជាក់ស្តែង ទំរង់ដូចខាងលើនេះ និងដំណាក់កាលផ្សេងៗនៃការស្រាវជ្រាវ គេអាចឃើញនៅក្នុងគំរោងខាងក្រោមនេះនៃរបាយការណ៍ស្តីពីការសិក្សា CCC- ADI ទៅលើការប្រើប្រាស់ថ្នាំញៀន :

| **ផ្នែកជាក់ស្តែងនៃរបាយការណ៍ (Actual parts of the report)** | **ដំណាក់កាលរៀបចំការស្រាវជ្រាវ និងអនុវត្ត (Research design and implementation phases)** | **ទំរង់របាយការណ៍ (Outline level)** |
|---|---|---|
| I. សេចក្តីថ្លែងពីបញ្ហា | សេចក្តីថ្លែងពីបញ្ហា/ប្រធានបទស្រាវជ្រាវ | មានសារៈសំខាន់មួយ ក្នុងចំណោមសារៈសំខាន់ឯទៀត |
| II. គោលបំណងនៃការស្រាវជ្រាវ | គោលបំណងស្រាវជ្រាវរួម | មានសារៈសំខាន់មួយ ក្នុងចំណោមសារៈសំខានឯទៀត |
| III. សំណួរគន្លឹះ | សំណួរស្រាវជ្រាវនីមួយៗនិងសេចក្តីត្រូវការពតិមាន | មានសារៈសំខាន់មួយ ក្នុងចំណោមសារៈសំខានឯទៀត |
| IV. វិធីសាស្ត្រស្រាវជ្រាវ | វិធីសាស្ត្រស្រាវជ្រាវត្រូវបានកំណត់ | មានសារៈសំខាន់មួយ ក្នុងចំណោមសារៈសំខានឯទៀត |
| V. លទ្ធផលរកឃើញនិងការវិភាគ | ទិន្នន័យត្រូវបានប្រមូល និងសង្ខេប | មានសារៈសំខាន់មួយ ក្នុងចំណោមសារៈសំខានឯទៀត |
| ក. និន្នាការនៅក្នុងការប្រើថ្នាំញៀន | ចំលើយចំពោះសំណួរស្រាវជ្រាវនីមួយៗស្តីពីគោលបំណងស្រាវជ្រាវ ១ | មានសារៈសំខាន់ក្នុងកំរិតទី ២ |
| ១. ស្ថានភាពនៃការប្រើថ្នាំញៀន | | មានសារៈសំខាន់ក្នុងកំរិតទី ៣ |
| ២. អាកប្បកិរិយានៃអ្នកញៀន | | មានសារៈសំខាន់ក្នុងកំរិតទី ៣ |
| ខ. ហេតុនិងផលវិបាកនៃការប្រើថ្នាំ | ចំលើយចំពោះសំណួរស្រាវជ្រាវនីមួយៗស្តីពីគោលបំណងស្រាវជ្រាវ ២ | មានសារៈសំខាន់ក្នុងកំរិតទី ២ |
| ១. ហេតុផលនៃការប្រើថ្នាំ | | មានសារៈសំខាន់ក្នុងកំរិតទី ៣ |
| ២. ផលនៃការប្រើថ្នាំលើអ្នកប្រើ | | មានសារៈសំខាន់ក្នុងកំរិតទី ៣ |
| គ. ផលដែលមានទៅលើជីវិតគ្រួសារ | ចំលើយចំពោះសំណួរស្រាវជ្រាវនីមួយៗស្តីពីគោលបំណងស្រាវជ្រាវ ៣ | មានសារៈសំខាន់ក្នុងកំរិតទី ២ |
| ឃ. ផលដែលមានលើជីវិតសហគមន៍ | ចំលើយចំពោះសំណួរស្រាវជ្រាវនីមួយៗស្តីពីគោលបំណងស្រាវជ្រាវ ៤ | មានសារៈសំខាន់ក្នុងកំរិតទី ២ |
| VI. សេចក្តីសន្និដ្ឋាន | សេចក្តីថ្លែងចុងក្រោយទាក់ទងនឹងគោលបំណងនិងសំណួរស្រាវជ្រាវ | មានសារៈសំខាន់ជាងគេមួយ |
| VII. បញ្ហាពាក់ព័ន្ធ (Implications) | ភាពមានប្រយោជន៍នៃការស្រាវជ្រាវ/អត្ថន័យនៃអ្វីដែលជាលទ្ធផលរកឃើញទាក់ទងនឹងការធ្វើគោលនយោបាយនិងការប្រតិបត្តិលើការអភិវឌ្ឍន៍។ | មានសារៈសំខាន់ជាងគេមួយ |
| ក. បញ្ហាគោលនយោបាយ | | មានសារៈសំខាន់ក្នុងកំរិតទី ២ |
| ខ. បញ្ហាអប់រំ និងបន្សាបថ្នាំ | | មានសារៈសំខាន់ក្នុងកំរិតទី ២ |
| គ. បញ្ហាអភិវឌ្ឍន៍សហគមន៍ | | មានសារៈសំខាន់ក្នុងកំរិតទី ២ |

# ជំហានទី ៤ ពិពណ៌នានូវលទ្ធផលរកឃើញរបស់អ្នក ហើយភ្ជាប់រវាងផ្នែកផ្សេងៗ

កំណត់រកលំនាំ/និន្នាការ និងផ្នែកសំខាន់ៗ ........................................................ ១០១

ភ្ជាប់ទំនាក់ទំនងរវាងការសង្កេត និងលំនាំផ្សេងៗទៀតដែលបានដឹង ........................ ១០៦

# ជំហានទី៤ : ពិពណ៌នានូវលទ្ធផលរកឃើញរបស់អ្នក ហើយភ្ជាប់រវាងផ្នែកផ្សេងៗ

*ស្វែងយល់ទំរង់បែបផែន/និន្នាការ/ផ្នែកសំខាន់ៗ: ភ្ជាប់លំនាំទៅនឹងនិន្នាការដែលត្រូវបានសង្កេត (ចំណុចសំខាន់) ផ្តើមចេញពីសំណួរគន្លឹះ មួយទៅសំណួរគន្លឹះមួយទៀត... ឆ្លុះបញ្ចាំងលើលំនាំដែលបានសង្កេត (ចំណុចសំខាន់) ដើម្បីរកមើលការពន្យល់ .....ពន្យល់/បកស្រាយលំនាំដែលបានសង្កេតឃើញ....*

| ជំហានទី ៤ |
|---|
| កំណត់ចំណុចសំខាន់/ចំណុចវិភាគ |
| |
| |
| |

| ចំណុចសំខាន់ | ការភ្ជាប់ទៅនឹងសេចក្តីសង្កេតដទៃទៀត<br>ភាពដូចគ្នា/ភាពខុសគ្នាទៅនឹងស្ថានភាពដទៃទៀត |
|---|---|
| លើកបង្ហាញចំណុចសំខាន់ៗ ឬពត៌មានដែលលេចធ្លោនៅក្នុងសេចក្តីសង្ខេបទិន្នន័យ (តារាង) ហើយទាក់ទងនឹងគោលបំណងស្រាវជ្រាវ ឬសំណួរស្រាវជ្រាវគន្លឹះ ។ | • តើចំណុចសំខាន់មានការទាក់ទងយ៉ាងដូចម្តេច ទៅនឹងការសង្កេតដទៃទៀ?<br>• តើមានឧទាហរណ៍អ្វីខ្លះស្តីពីស្ថានភាពដូចគ្នា ឬមិនដូចគ្នាដែលអ្នកអាចប្រៀបធៀបជាមួយនឹងលទ្ធផលរកឃើញ?<br>• តើឯកសារអ្វីដែលអ្នកអាចលើកឡើងដើម្បីបញ្ជាក់ទៅលើលទ្ធផលរកឃើញ ឬការសង្កេតឃើញ? |

## កំណត់រកលំនាំ/និន្នាការ និងផ្នែកសំខាន់ៗ (Discerning Patterns/Trends and Themes)

ការស្វែងយល់លំនាំបែបផែន ឬនិន្នាការ និងប្រធានបទនៅក្នុងទិន្នន័យមានន័យថា ដកយកចំណុចសំខាន់ៗពីលទ្ធផលរកឃើញ និងការរៀបរាប់វា ។ នេះគឺជាដំណាក់កាលនៃការវិភាគទិន្នន័យ នៅពេលដែលអ្នកស្រាវជ្រាវពិនិត្យទិន្នន័យដែលបានសង្ខេបហើយដើម្បីរកមើលភាពប្រក្រតី/មិនប្រក្រតីខ្លះ និងប្រធានបទដែលច្រើនមាន ព្រមទាំងដើម្បី "អាន" ន័យដែលភាពប្រក្រតី/មិនប្រក្រតី និងប្រធានបទទាំងនោះបង្ហាញឡើងទាក់ទងនឹងគោលបំណងស្រាវជ្រាវ ព្រមទាំងសំណួរស្រាវជ្រាវជាគន្លឹះ ។ ការទាញចេញនូវចំណុចសំខាន់ៗគឺចង់និយាយពីការស្វែងយល់លើលទ្ធផលនៃការសិក្សាស្រាវជ្រាវ និងទិដ្ឋភាពលំអិតលើទំរង់បែបផែនដែលត្រូវបានសង្កេត ហើយទំរង់បែបផែននេះ ច្រើនតែត្រូវបានកំណត់រូបរាង និងលើកកំពស់ដោយចំណេះដឹងផ្ទាល់ខ្លួនរបស់អ្នកស្រាវជ្រាវ ការពិនិត្យឯកសារសិក្សាមុនៗ ឬបទពិសោធន៍ស្តីពីការសិក្សាស្រាវជ្រាវ ។ អ្នកស្រាវជ្រាវវាយតំលៃទិន្នន័យនៅក្នុងបរិបទនៃរបៀបទាំងអស់នេះ ពន្យល់បំភ្លឺគំនិតឬទស្សនះខ្លះ ដែលទាក់ទងនឹងបញ្ហាដែលកំពុងត្រូវបានពិនិត្យ (ឧទាហរណ៍ ការចូលរួមនៅក្នុងការសំរេចចិត្ត ការដឹកនាំបែបផ្តាច់ការ/បែបប្រជាធិបតេយ្យ ។ល។)

ទំរង់បែបផែន និងនិន្នាការនៅក្នុងទិន្នន័យដែលគេអាចកំណត់តាមរយៈ :

- ប្រេកង់ ឬចំនួនដងនៃរឿងអ្វីមួយកើតឡើង ឬចំលើយមួយត្រូវបានផ្តល់ ។ ចូរចំណាំថា អាចមានការខុសគ្នារវាងប្រេកង់ និងអ្វីដែលគេចង់រាយការណ៍ប្រាប់ ។

- ទំហំដែលកំណត់លំដាប់ និងវិសាលភាពនៃបាតុភូតដែលគេបានសង្កេតឃើញ (ឧទាហរណ៍ ការអាចទទួលបានដីធ្លី អត្រានៃការប្រើថ្នាំពេទ្យនជាដើម ។)
- រចនាសម្ព័ន្ធដែលពន្យល់បង្ហាញប្រព័ន្ធមួយ និងផ្នែកផ្សំរបស់វា ដែលបញ្ជាក់ពីការរៀបចំ និងទំនាក់ទំនងនៅក្នុងរង្វង់នៃបាតុភូតដែលត្រូវបានគេសង្កេត ។
- ដំណើរការដែលរៀបរាប់លំដាប់ ឬភាពខ្វះលំដាប់រៀបរយនៅក្នុងចំណោមសមាសភាគរបស់រចនាសម្ព័ន្ធ ។
- បុព្វហេតុ និងផលវិបាក ។

ប៉ុន្តែ ទិន្នន័យសង្ខេបដែលបានមកពីការសិក្សាអង្កេត ឬឧបករណ៍ប្រមូលទិន្នន័យដែលមានរៀបចំជារចនាសម្ព័ន្ធប្រហាក់ប្រហែលនោះ តាមធម្មតាមិនត្រូវបានគេរ៉ាយរ៉ាប់តាមលំដាប់នៃគំនូសដូចមាននៅក្នុងតារាងទេ ។ ដោយទាញយកចំណុចសំខាន់ៗ ហើយរៀបរាប់វាគឺជាផ្នែកពិភាក្សានៃរបាយការណ៍នេះ ហើយមានបំណងទាញការយកចិត្តទុកដាក់របស់អ្នកអានទៅរកចំណុចសំខាន់នៃសេចក្តីសង្ខេបប្អូលទ្ធផលរកឃើញ ដែលលេចធ្លោទាក់ទងនឹងសំណួរនិង/ឬទិសដៅស្រាវជ្រាវ ។ វិធីធម្មតាគឺរៀបរាប់និន្នាការដែលគេអាចសង្កេតឃើញសំរាប់ក្រុមទាំងអស់ និងវិធីចំពោះចំណែកថ្នាក់ទិន្នន័យ ឬអនុក្រុមសំណាក (Sample sub-group) (ឧទាហរណ៍ ចំណែកថ្នាក់ជាមួយនឹងចំលើយដែលមានច្រើនជាងគេ/តិចជាងគេ) ។ ភាពខុសគ្នារវាង និងក្នុងចំណោមអនុក្រុម ក៏គួរតែគេកត់សំគាល់ដែរនៅត្រង់នេះ ។

ដោយទាញចេញពីការសិក្សារបស់ CCC-ADI ស្តីពី *ការបែងចែកដីធ្លីក្នុងទ្រង់ទ្រាយតូចនៅក្នុងប្រទេសកម្ពុជា : មេរៀនពីករណីសិក្សាចំនួនបី* និងដោយប្រើប្រែកង់ធ្វើជាមធ្យោបាយក្នុងការទាញយកចំណុចសំខាន់នេះ ចំលើយចំពោះសំណួរសំភាសន៍ជាបន្តបន្ទាប់ត្រូវបានបង្ហាញនៅក្នុងរូបទី១០ ដែលបន្ទាប់មកទៀតចំណុចសំខាន់ត្រូវបានគេរៀបរាប់[២១] ។ ឧទាហរណ៍នេះថែមទាំងពន្យល់បំភ្លឺពីរបៀបដែលចំណុចសំខាន់ៗត្រូវបានគេភ្ជាប់គ្នា ។

**រូបទី ៩ : ឧទាហរណ៍នៃការទាញចេញនូវចំណុចសំខាន់ៗ**

**សំណួរស្រាវជ្រាវ :** តើមានលក្ខណៈវិនិច្ឆ័យដំណើរការ និងយន្តការសំរេចចិត្តណាខ្លះដែលត្រូវបានគេប្រើដើម្បីជ្រើសរើស ផ្ទៀងផ្ទាត់ និងយល់ព្រមលើ អ្នកមានសិទ្ធិទទួលកម្មសិទ្ធិដីធ្លី?

**សំណួរសំភាសន៍ :** ពតិមានទាក់ទងនឹងដីដែលគេបានទទួល (ក): តើអ្នកបានចូលរួមនៅក្នុងគំរោងបែងចែកដីធ្លីយ៉ាងដូចម្តេច?

| ចំលើយ | N | ភាគរយ |
|---|---|---|
| មិនបានចូលរួម | ១៨ | ៥៨,១ |
| បានចូលរួមប្រជុំ | ៧ | ២២,៥ |
| បានតវ៉ាហើយបានជួបនឹងទាហ៊ានដទៃទៀត បាននិយាយជាមួយនឹងមេបញ្ជាការ | ៣ | ៩,៧ |
| ហើយបានទៅភ្នំពេញដើម្បីបានជួបនឹងមន្ត្រីនានា ធ្វើការជាមួយនឹងគណៈកម្មាធិការដើម្បីវាស់វែងដី | ១ | ៣,២ |
| មិនមានចំលើយ | ២ | ៦,៥ |
| សរុប | ៣១ | ១០០ |

[២១] ដោយត្រូវបានកែសំរួលសំរាប់សៀវភៅនេះ ឧទាហរណ៍នេះគឺជាឯកសារសំរាប់ចែកឱ្យនៅក្នុងសិក្ខាសាលា/វគ្គសិក្សាថ្នាក់ខ្ពស់ជាបន្ត បន្ទាប់របស់ ADI ស្តីពីការស្រាវជ្រាវជាមូលដ្ឋាននៅចន្លោះពីខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០០១ (ភ្នំពេញ) ដែលនៅពេលនោះសិក្ខាកាមបានចូលរួមដាក់ស្តែងនៅក្នុងការធ្វើរបាយការណ៍ស្រាវជ្រាវដែលត្រូវបានបោះពុម្ពឡើងជាមួយនឹងចំណងជើងដដែល ។

**ចំណុចសំខាន់ :** នៅក្នុងចំណោមអ្នកឆ្លើយដែលត្រូវបានសំភាសន៍ជាមួយ ជាងពាក់កណ្តាល (៥៨,១ ភាគរយ) មិនបានចូលរួមនៅក្នុងគំរោងបែងចែកដីធ្លីទេ។

**ការបកស្រាយ :**

*សេចក្តីពន្យល់ដែលគេអាចនឹងផ្តល់*

- ការផ្សព្វផ្សាយពតិមានមិនបានគ្រប់គ្រាន់
- អ្នកឆ្លើយមិនមានវត្តមាននៅពេលគេធ្វើយុទ្ធនាការផ្តល់ពតិមាន
- នៅដាច់ឆ្ងាយពីសហគមន៍
- មិនបំពេញបានតាមលក្ខណៈវិនិច្ឆ័យ
- មិនមានការខ្នះខ្នែងសុំការចូលរួមរបស់ប្រជាជននៅក្នុងគំរោងបែងចែកដីធ្លីទេ

ការពន្យល់ដែលគួរឱ្យគេជឿជាងគេ (ដោយរួមជាមួយនឹងលទ្ធផលរកឃើញពីការពិភាក្សាជាមួយក្រុមគោលដៅ)

មិនមានការផ្សព្វផ្សាយពតិមានឱ្យបានគ្រប់គ្រាន់ ឬមិនមានការខិតខំសុំការចូលរួមរបស់ប្រជាជនទេ។ ទិន្នន័យដែលបានប្រមូលពីការពិភាក្សាជាមួយនឹងក្រុមគោលដៅនោះបង្ហាញថា ពិតមែនតែមានការប្រជុំ តែគេមិនមានឃើញការនិយាយពីយុទ្ធនាការផ្តល់ពតិមានទេ។



**សំណួរស្រាវជ្រាវ :** តើមានលក្ខណៈវិនិច្ឆ័យដំណើរការ និង យន្តការសំរេចចិត្តអ្វីខ្លះដែលត្រូវបានគេប្រើដើម្បី ជ្រើសរើស ផ្ទៀងផ្ទាត់ និងអនុម័តយល់ព្រមផ្តល់ឱ្យអ្នកមានសិទ្ធិដីដែរឬ?

**សំណួរសំភាសន៍ :** ពតិមានទាក់ទងនឹងដីដែលបានទទួល (ខ)ៈតើអ្នកបានបំពេញតាមគោលការណ៍កំណត់អ្វីខ្លះ?

| ចំលើយ | N | ភាគរយ |
|---|---|---|
| ទាហ៊ាន (ភាគច្រើនពិការ) ហើយនិងការយល់ព្រមរបស់មេបញ្ជាការ | ១៨ | ៥៨,១ |
| មនុស្សចាស់ | ២ | ៦,៥ |
| មិនមានលក្ខណៈវិនិច្ឆ័យ | ១ | ៣,២ |
| ខ្ញុំស្គាល់អ្នកដែលបែងចែកដីធ្លី | ១ | ៣,២ |
| មិនមានចំលើយ | ៩ | ២៩,០ |
| សរុប | ៣១ | ១០០,០ |

**ចំណុចសំខាន់ :** ទាហ៊ានដែលរួមមាន ៥៨,១ភាគរយនៃអ្នកឆ្លើយ មានសិទ្ធិជាអ្នកទទួលនៅក្នុងគំរោងបែងចែកដីធ្លីដែលត្រូវបានធ្វើនៅក្នុងឆ្នាំ១៩៩៦ ។

**ការបកស្រាយ :**

*សេចក្តីពន្យល់ដែលគេអាចមាន :*

- អ្នកឆ្លើយតបសំភាសន៍ ដឹងពីមន្ត្រីដែលពាក់ព័ន្ធនៅក្នុងគំរោង ។
- អ្នកឆ្លើយសំភាសន៍គឺជាជនពិការ ឬមានរបួស ។

***ការពន្យល់ដែលធ្វើអោយគេជឿបំផុត (រួមជាមួយនិងលទ្ធផលរកឃើញពីការពិភាក្សាក្រុមគោលដៅ)***

ដោយផ្អែកលើលទ្ធផលរកឃើញពីការពិភាក្សាក្រុមគោលដៅ យើងដឹងថាលក្ខណៈវិនិច្ឆ័យតែមួយគត់សំរាប់ជ្រើសរើសអ្នកទទួលគឺពិការភាព ។ ការសង្កេតឃើញនេះ រួមជាមួយនឹងការដែលថា ទាហានទាំងនេះនៅក្នុងកងពលទាំងមូលបានមកតាំងនៅកន្លែងនោះ ធ្វើឱ្យពួកគេគឺជាមនុស្សភាគច្រើនជាអ្នកទទួល ។

***សំណួរស្រាវជ្រាវ :*** តើមានលក្ខខ័ណ្ឌ និងហេតុផលអ្វីសំរាប់ដំណើរការគំរោងបែងចែកដីធ្លីនៅតាមតំបន់ណាមួយ?

***សំណួរសំភាសន៍ :*** ពតិមានទាក់ទងនឹងដីដែលបានទទួល (គ)ៈ តើដីប្រភេទណាដែលអ្នកបានទទួល (ដីលំនៅដ្ឋាន ដីចំការ ឬដីស្រែ?) ។ តើដីដែលបានចែកឱ្យនោះអាចយកទៅប្រកបរបរកសិកម្មបានទេ?

ចំលើយ (ដូចមានសង្ខេបនៅក្នុងតារាងដែលមានអថេរច្រើន*)

| ប្រភេទដី | ទំហំ | ចំនួនអ្នកឆ្លើយ | អាចដាំដំណាំបាន (ទេ/ចាស់/បាទ) | ការប្រើប្រាស់ដី | ភាគរយនៃដីដែលប្រើ |
|---|---|---|---|---|---|
| | ១០ គុណ ១០ម | ១ | ទេ | - | - |
| | ២០ គុណ ៨០ ម | ៣ | ចាស់/បាទ | ដាំស្រូវ ឈើហូបផ្លែ បន្លែ ដំណាំ | ៥០ ៧០ ១០០ |
| | ២០ គុណ ១០០ ម | ១ | ចាស់/បាទ | ស្រូវ ឈើហូបផ្លែ | ១០០ |
| | ២២,៥ គុណ ៨០ ម | ២ | ចាស់/បាទ | ឈើហូបផ្លែ បន្លែ ដំណាំ | ៥០ ១០០ |
| | ២៥ គុណ ៧០ ម | ១ | ចាស់/បាទ | បន្លែ ដំណាំ | ១០០ |
| | ២៥ គុណ ៨០ ម | ១៤ | ចាស់/បាទ | ដាំស្រូវ ឈើហូបផ្លែ បន្លែ ដំណាំ | ១០០ |
| | ២៥ គុណ ១០០ ម | ១ | ចាស់/បាទ | ដំណាំ | - |
| | ២៨ គុណ ៨០ ម | ១ | ចាស់/បាទ | ស្រូវ | ១០០ |
| | ៣០ គុណ ៨០ ម | ១ | ចាស់/បាទ | ស្រូវ | ១០០ |
| | ៣០ គុណ ៩០ ម | ១ | ចាស់/បាទ | ឈើហូបផ្លែ ដំណាំ | ១០០ |
| | ៥០ គុណ ៥០ ម | ១ | ចាស់/បាទ | ឈើហូបផ្លែ | ១០០ |
| | ៥០ គុណ ១០០ ម | ១ | ចាស់/បាទ | ឈើហូបផ្លែ | ៦០ |
| | ១៥០ គុណ ១០០ម | ១ | ចាស់/បាទ | ស្រូវ | - |
| | គ្មានពតិមាន | ២ | - | - | - |
| ដីស្រែ | ០,៧៥ ហត | ១ | ចាស់/បាទ | ស្រូវ | ១០០ |
| | ១ ហត | ១ | ចាស់/បាទ | មិនប្រើដោយសារនៅចំងាយ៣០គម | |

* ចង់យោងទៅរកការមានអថេរលើសពីមួយ

**ចំណុចសំខាន់ :** ក្នុងដីដែលត្រូវបានបែងចែកឱ្យទាំងអស់មាន ៩៤ភាគរយ ត្រូវបានគេប្រាប់មកថា ជាដីលំនៅដ្ឋាន ហើយទំហំដែលច្រើនមានជាងគេគឺ ២៥ គុណ ៨០ម ។ ជាការគួរឱ្យកត់សំគាល់ដែរ ក្នុងចំណោមអ្នកដែលបានទទួលដីលំនៅដ្ឋាន ស្ទើរតែទាំងអស់គ្នាប្រើប្រាស់ដីដើម្បីដាំស្រូវ ឈើហូបផ្លែ បន្លែ និងដំណាំផ្សេងទៀត ។ ការប្រើប្រាស់ដីមានកំរិតខ្ពស់ដោយភាគច្រើនបានលើកឡើងថា ប្រើអស់ ១០០% ហើយមានតែ ១២%ទេ ដែលនិយាយថាប្រើតិចជាង៧០%នៃដី ។

**ការបកស្រាយ :**

*សេចក្តីពន្យល់ដែលគេអាចនឹងផ្តល់*

- ហេតុផលចំពោះទំហំដូចគ្នា/ខុសគ្នានៃដីៈ (ក) ភាគច្រើនមានទំហំដីប្រហាក់ប្រហែលគ្នា ពីព្រោះគេជាអ្នកវាស់ខ្លួនគេ។ (ខ) អ្នកខ្លះមានដីធំជាងអ្នកផ្សេង ពីព្រោះគេមានលទ្ធភាពរានដីបានច្រើន។
- ហេតុផលចំពោះការប្រើប្រាស់ដី : (ក) ចំពោះជនពិការ មិនមានប្រភពចំណូលនៅនឹងមូលដ្ឋាន ។(ខ) មិនមានលុយទិញស្បៀង

*សេចក្តីពន្យល់ដែលគេអាចជឿបានច្រើនជាងគេ* ដូចខាងលើដែរ ។

*សំណួរស្រាវជ្រាវ :* តើកត្តាឬតួអង្គអ្វីខ្លះដែលនាំឱ្យមានជោគជ័យ បញ្ហានិង/ឬបរាជ័យ?

*សំណួរសំភាសន៍ :* ពតិមានទាក់ទងនឹងដីដែលបានទទួល (ឃ): តើអ្នកអាចជ្រើសរើសដីដែលអ្នកបានទទួលដែរឬទេ? បើមិនអាចទេ តើហេតុអ្វី?

| ចំលើយ | N | *ភាគរយ* |
|---|---|---|
| តើអាចជ្រើសរើសដីដែលបានទទួលទេ? | | |
| អាច | ២៦ | ៨៤,0 |
| មិនអាច | ៥ | ១៦,0 |
| បើមិនអាច តើហេតុអ្វី? | | |
| មិនអាចបំពេញបានតាមលក្ខណៈវិនិច្ឆ័យ | ១ | ២០ |
| មិនមានលក្ខណៈវិនិច្ឆ័យឬវិធានច្បាស់លាស់ | ១ | ២០ |
| ខ្ញុំមកយឺតពេល | ១ | ២០ |
| មិនមានចំលើយ | ២ | ៤០ |
| សរុប | ៥ | ១០០ |

**ចំណុចសំខាន់ :** អ្នកឆ្លើយចំនួន ៨៤ ភាគរយ អាចជ្រើសរើសដីដែលគេមានឥឡូវនេះ ។

**ការបកស្រាយ :**

*ការពន្យល់ដែលគេអាចនឹងផ្តល់*

- ការខិតខំរួមគ្នាដើម្បីជ្រៀកដីចែកគ្នាតទៅទៀតនៅក្នុងចំណោមពួកគេ។

*សេចក្តីពន្យល់ដែលគេអាចនឹងជឿច្រើនជាងគេ* ដូចសេចក្តីពន្យល់ខាងលើ ។

*សំណួរស្រាវជ្រាវ :* តើកត្តា/តួអង្គអ្វីខ្លះដែលរួមចំណែកឱ្យមានជោគជ័យ បញ្ហា និង/ឬ ការបរាជ័យ?

*សំណួរសំភាសន៍ :* ពតិមានទាក់ទងនឹងដីដែលបានទទួល(ង): តើដីដែលអ្នកបានទទួលជួយលើកកំពស់ការីតជីវភាពរស់នៅរបស់អ្នកយ៉ាងដូចម្តេច?

| ចំលើយ * | N | ភាគរយ |
|---|---|---|
| មិនមានចំលើយ (បណ្តាលមកពីខ្វះ ឬបាត់តាមការបកស្រាយ ខ្លះសរសេរដោយដៃ) | ១៥ | ៤៨,៤ |
| ធ្វើបាន តែតិចពេក មិនគ្រប់ទេ | ១០ | ៣២,៣ |
| កន្លែងរស់នៅ | ១ | ៣,២ |
| ចំណូលបានមកពីលក់ទៅឱ្យអ្នកដទៃទៅនៅតំបន់ក្បែរខាង | ១ | ៣,២ |
| មិនទាន់បានគ្រាន់បើនៅឡើយទេ | ៤ | ១២,៩ |
| សរុប | ៣១ | ១០០,០ |

* គេគួរកត់សំគាល់ថា ស្ទើរតែពាក់កណ្តាលនៃចំលើយត្រូវបានចាត់ចូលជាចំណាត់ថ្នាក់ "មិនមានចំលើយ" ដោយសារកំហុសរបស់អ្នកស្រាវជ្រាវ (ពោលគឺខ្វះការបកស្រាយ)។ ចំលើយដែលនៅសល់បង្ហាញតាមបែបអ្វីម្យ៉ាងថា ការទទួលបានដីជួយកែលំអរជីវភាពរស់នៅរបស់គេបានខ្លះ។ ដូច្នេះ ចំណុចសំខាន់ទទួលស្គាល់ថាមានចំណុចខ្សោយនេះ។

**ចំណុចសំខាន់ :** នៅក្នុងចំណោមអ្នកឆ្លើយដែលត្រូវបានសំភាសន៍មាន ៣៨,៧ភាគរយ បង្ហាញពីការបានប្រសើរឡើងនៃជីវភាពរស់នៅរបស់គេ ពីព្រោះគេអាចផលិតស្បៀងបានតិចតួច (៣២,២%) គេអាចរកចំណូលបានពីការលក់ (៣,២%) ហើយគេអាចរកកន្លែងរស់នៅបាន (៣,២%)។

**ការបកស្រាយ :**

*សេចក្តីពន្យល់ដែលគេអាចនឹងផ្តល់ :*

- ដូចគេអាចដឹងតាមរយៈលទ្ធផលរកឃើញមុនៗស្តីពីប្រភេទដីដែលគេបានទទួល និងស្តីពីការប្រើប្រាស់ដី គ្រួសារប្រើដីលំនៅដ្ឋានដែលគេបានទទួលដើម្បីដាំដំណាំផ្សេងៗដែលអាចជួយរួមចំណែកបានមួយកំរិតដល់ប្រាក់ចំណូល និងសន្តិសុខស្បៀង ។
- តាមរយៈលទ្ធផលរកឃើញស្តីពីប្រភេទដីដែលបានទទួល និងការប្រើប្រាស់ដី ការទទួលបានដីលំនៅដ្ឋាន បានបង្កើតឱ្យមានស្ថេរភាពមួយកំរិតនៅក្នុងជីវិតរបស់គេ ។

*សេចក្តីពន្យល់ដែលងាយអោយគេជឿជាងគេ* ដូចគ្នានឹងការពន្យល់ដែលគេអាចនឹងផ្តល់

## ភ្ជាប់ទំនាក់ទំនងរវាងការសង្កេត និងលំនាំផ្សេងៗទៀតដែលបានដឹង (Making connections between the observations and other known patterns)

នៅក្នុងដំណើរការនៃការស្វែងយល់ និងផ្តោតទៅលើទំរង់បែបផែនទិន្នន័យគឺមានការអធិប្បាយទៅលើរឿងទាំងនេះ ឬដំណើរការបកស្រាយ។ តើលទ្ធផលរកឃើញមានការទាក់ទងគ្នាទៅវិញទៅមក ដោយប្រើព័តមានដែលបានមកពីការងារប្រមូលទិន្នន័យទាំងអស់ (ឧទាហរណ៍ ការអង្កេត ការពិភាក្សាក្រុមគោលដៅ ការសំភាសន៍ជាមួយនឹងអ្នកឆ្លើយសំភាសន៍សំខាន់ៗ) - គួរត្រូវបានគេកំណត់ច្បាស់ដើម្បីអាចបរិយាយវិធីដែលការសង្កេតឃើញបញ្ជាក់លើភាពត្រឹមត្រូវ/ផ្ទុយគ្នា និងធ្វើឱ្យមានភាពស៊ីគ្នា និងអត្ថន័យនៅក្នុងសេចក្តីសង្កេតឃើញ/ចំណុចសំខាន់ៗដូចម្តេច។ ការភ្ជាប់ទំនាក់ទំនងទាំងនេះ បើកផ្លូវឱ្យគេរកមើលទំរង់បែបផែន/និន្នាការថ្មីៗ ឬដែលមានកំរិតថ្នាក់ខ្ពស់ព្រមជាមួយនឹងបញ្ហាជាមូលដ្ឋានដែលគេត្រូវរកមើល។ ជាករណី

ដែលអ្នកស្រាវជ្រាវបានបង្កើតសម្មតិកម្មជាច្រើននៅក្នុងការសិក្សាស្រាវជ្រាវ ដំណាក់កាលនេះនៅក្នុងការសិក្សាស្រាវជ្រាវ គឺជាពេលដែលគេត្រូវវាយរ៉ាប់ពីវិធីដែលលទ្ធផលរកឃើញរួមចំណែកនៅក្នុងការបញ្ជាក់ ឬបដិសេធសម្មតិកម្មដែលមាននិយាយមកទាំងនេះ ។ ការកំណត់ទំនាក់ទំនងរវាងសេចក្ដីសង្កេតឃើញគួរតែឈរនៅលើមូលដ្ឋានបែបទស្សនៈ ហើយផ្អែកលើលក្ខណៈទូទៅនៃសំណួរស្រាវជ្រាវ និងក្របខ័ណ្ឌទ្រឹស្ដីដែលជាមូលដ្ឋាននៃការសិក្សាស្រាវជ្រាវ ។ ការកំណត់ឱ្យមានទំនាក់ទំនងគ្នាទាំងនេះអាចជួយពង្រឹងហេតុផល ឬសេចក្ដីថ្លែងទូទៅដែលគេលើកឡើងស្ដីអំពីលទ្ធផលរកឃើញទាក់ទងនឹងសំណួរស្រាវជ្រាវ និងសំរាប់សេចក្ដីសន្និដ្ឋានរួមរបស់ការសិក្សា ។

ការកំណត់ទំនាក់ទំនងគ្នារវាងចំណុចសំខាន់ៗ ឬទំរង់បែបផែន/និន្នាការ និងប្រធានបទក៏ជាឱកាសមួយដែរ នៅពេលដែលបទពិសោធន៍ ឬទ្រឹស្ដីដែលនៅក្រៅវង្វង់នៃការសិក្សាអាចត្រូវបានគេដាក់បញ្ចូលឱ្យមានការទាក់ទងនឹងលទ្ធផលរកឃើញ ដែលធ្វើឱ្យឃើញមានរូបភាពធំ ។ បទពិសោធន៍ និងទ្រឹស្ដីទាំងនេះអាចចេញមកពីចំណេះដឹងផ្ទាល់ខ្លួនរបស់អ្នកស្រាវជ្រាវ ឬពីឯកសារសិក្សាមុនៗដែលគាត់ដឹងច្បាស់ ។ ចំណុចភ្ជាប់ទាំងនេះជាមួយនឹងបទដ្ឋាន ឬទំរង់បែបផែនដទៃទៀត ដែលគេដឹងមានសារៈប្រយោជន៍ ពីព្រោះវាអាចស្ដែងឱ្យឃើញលក្ខណៈដូចគ្នា ឬខុសគ្នានៃសំណាកនៃប្រជាជនរួមទាំងអស់ ឬប្រជាជនណាផ្សេងទៀត ឬស្ដែងឱ្យឃើញរបៀបដែលលទ្ធផលរកឃើញពន្យល់បំភ្លឺពីទស្សនៈយល់ឃើញស្ដីពីការប្រតិបត្តិ និងទ្រឹស្ដីស្ដីពីការអភិវឌ្ឍនិង/ឬចំណេះដឹងផ្នែកវិទ្យាសាស្ត្រផ្សេងទៀត ។ ឧទាហរណ៍ បើអ្នកស្រាវជ្រាវរៀបរាប់ទំហំដីរបស់អ្នកឆ្លើយនៅក្នុងចំនួនកំណត់ណាមួយនោះ គាត់អាចវាស់មើលទំហំដីគិតជាមធ្យមរបស់គ្រួសារនៅតាមជនបទនៅក្នុងប្រទេសកម្ពុជា ។ អ្នកស្រាវជ្រាវដែលស្វែងយល់ពីដំណើរការជាលក្ខណៈចូលរួមនៃគំរោងអភិវឌ្ឍ អាចប្រៀបធៀបលទ្ធផលរកឃើញរបស់គេទៅនឹងរង្វាស់ដែលគេដឹង ឬទស្សនៈបែបទ្រឹស្ដីស្ដីពីការចូលរួម ហើយធ្វើសេចក្ដីថ្លែងស្ដីពីរបៀបដែលប្រធានបទនៃការសិក្សាស្រាវជ្រាវរបស់គាត់ជួនគ្នាជាមួយ ឬមិនបានដល់កំរិតបទដ្ឋានកំណត់ស្ដីពីការចូលរួម ។

ហួសពីការរៀបរាប់ពីទំរង់បែបផែនតាមរយៈការប្រៀបធៀប និងភ្ជាប់លទ្ធផលរកឃើញពីមួយទៅមួយ ការពន្យល់គួរគេធ្វើផងដែរ ទាក់ទងនឹង "មូលហេតុ" នៃការសង្កេត ឬហេតុផលនៃនិន្នាការ និងទំរង់បែបផែនដែលបានសង្កេត ។ ជំហ៊ានទី៥ នៅផ្នែកបន្ទាប់នេះផ្ដល់គោលការណ៍ណែនាំអំពីរបៀបដែលអាចសំរេចបានលើចំណុចនេះ ។

ផ្នែកទី ៣

## ជំហ៊ានទី ៥ កំណត់រកបុព្វហេតុឬសគល់ បញ្ហាគន្លឹះ និង សរសេរការវិភាគរបស់អ្នក


ស្វែងយល់ពីទំនាក់ទំនងនៅក្នុងលំនាំដែលត្រូវបានសង្កេតឃើញ ........ ១១១

ការភ្ជាប់ទំនាក់ទំនងគ្នា/ភាពខុសគ្នា និងបុព្វហេតុនៃការសង្កេតឃើញ ........ ១១៦

ឧបករណ៍ និងបច្ចេកទេសដើម្បីធ្វើការភ្ជាប់ទំនាក់ទំនងផ្សេងៗ ........ ១១៨

ការទាញចេញនូវបញ្ហាជាប់ពាក់ព័ន្ធ ........ ១២៤

# ជំហានទី ៥: កំណត់រកបុព្វហេតុឬសគល់ បញ្ហាគន្លឹះ និងសរសេរការវិភាគរបស់អ្នក




## ស្វែងយល់ពីទំនាក់ទំនងនៅក្នុងលំនាំដែលត្រូវបានសង្កេតឃើញ (Understanding Relationships in Observed Patterns)

ការស្វែងយល់ទំនាក់ទំនង ឬការជាប់ទាក់ទងគ្នារវាងការអង្កេត គឺជាបញ្ហាប្រឈមមួយសំខាន់នៅក្នុងការវិភាគទិន្នន័យ ។ ពីព្រោះថានៅមានផ្នែក និងលំនាំ អ្នកស្រាវជ្រាវត្រូវតែភ្ជាប់ការគិតយ៉ាងសកម្មដែលប្រឈមនឹង លំនាំដែលលេចឡើងជាក់ស្តែង (Marshall and Rossman 1989:119) ។ អ្នកស្រាវជ្រាវត្រូវរកមើលការ រៀបរាប់ដែលអាចជឿជាក់បានក្រៅពីអ្វីដែលទិន្នន័យផ្តល់អោយ ។ ជំរើសនៃការពន្យល់ផ្សេងៗទៀតមាន**ជានិច្ច** អ្នកស្រាវជ្រាវត្រូវស្វែងរកមើលកំណត់សំគាល់ និងការរៀបរាប់របស់គេយ៉ាងដូចម្តេចដែលជាបង្ហាញថា ការពន្យល់ទៅហើយនោះ ពិតជាគួរអោយជឿជាក់បាន ។

ជាទូទៅ អ្នកស្រាវជ្រាវត្រឡប់ទៅមើលសំណួរស្រាវជ្រាវដែលគាត់បានឆ្លើយមិនច្បាស់នៅក្នុងចំលើយ នៅក្នុងការពិនិត្យពីរបៀបសង្កេតរបស់គាត់មានការទាក់ទងគ្នា ។ ដោយរំលឹកឡើងវិញនូវតារាងទី២ ដែលក្នុងនោះ សេចក្តីរៀបរាប់ពីការវិភាគត្រូវបានលើកឡើងសំរាប់ប្រភេទសំណួរដោយឡែកៗ ការស្វែងយល់ទៅលើទំនាក់ទំនង នៃការសង្កេតអាចត្រូវបានគេធ្វើតាមរយៈវិធីមួយ ឬវិធីច្រើនដែលបានរៀបចំដូចខាងក្រោមនេះ (Mason, 1996:137) ។

១. ***ប្រៀបធៀប:*** គេអាចធ្វើការប្រៀបធៀបក្រុមមនុស្សក្នុងសង្គម បាតុភូតសង្គម ដំណើរការសង្គម ទីតាំងសង្គម អត្ថន័យផ្នែកសង្គម ។ល។ និង ។ល។ ទាំងនេះជារឿយៗមានបំណងទាញបាននូវលក្ខណៈដូចគ្នា និង/ឬ លក្ខណៈខុសគ្នានៃក្រុមមនុស្ស បាតុភូតចំនួនពីរ ឬច្រើន ។ល។ ដើម្បីអោយគេកំណត់ពីភាពទូទៅនៃការសង្កេតស្តីពីឯកត្តានៃការវិភាគ ។ បើអ្នកស្រាវជ្រាវ

ចង់ធ្វើការប្រៀបធៀប ឬចង់អោយវិធីនេះមានសារៈសំខាន់ចាំបាច់ នៅក្នុងចំលើយតបនឹងសំណួរស្រាវជ្រាវនោះ គាត់ត្រូវដឹងអោយច្បាស់ថា ការនេះនឹងត្រូវបានគេធ្វើហើយ ត្រូវមានបញ្ចូលនូវសំណួរដែលជាប់ការទាក់ទងនៅក្នុងឧបករណ៍ប្រមូលទិន្នន័យរបស់គាត់ (ដូច្នេះ គេត្រូវប្រមើលមើលជាមុនថា តើវិធីសាស្ត្រវិភាគមួយណាដែលត្រូវយកមកប្រើនៅក្នុងការរៀបចំសំណួរ ទិសដៅ និងឧបករណ៍ប្រមូលទិន្នន័យសំរាប់ការស្រាវជ្រាវ) ។

គេអាចធ្វើការប្រៀបធៀបលើអ្វីដែលងាយៗដូចជា ការរៀបរាប់ប្រភេទការងាររបស់ជនចំណាកស្រុក ដោយអាស្រ័យលើស្ថានភាពរបស់គេជាអ្នកធ្វើចំណាកស្រុក សំរាប់រយៈពេលវែងឬរយៈពេលខ្លី ។ ដូចជា ករណី លទ្ធផលដែលរកឃើញរបស់ការស្រាវជ្រាវដែលធ្វើដោយអង្គការ CCC-ADI កាលពីឆ្នាំ២០០៣ស្តីពី *ការចេញទៅប្រកបការងារនៅប្រទេសថៃ និងតំបន់ព្រំដែនកម្ពុជា-ថៃ* ។ ក្នុងនោះអ្នកស្រាវជ្រាវស្វែងយល់ពីទំនាក់ទំនងទាំង នេះនៅពេលដែលគេពិនិត្យសំណួរស្រាវជ្រាវរបស់គេថា តើការធ្វើចំណាកស្រុកទៅធ្វើការបានក្លាយទៅជាយុទ្ធសាស្ត្រចិញ្ចឹមជីវភាពជាអចិន្ត្រៃយ៍សំរាប់ក្រុមគ្រួសាររបស់អ្នកចាកចេញទៅដែរឬទេ? (សូមមើលឧទាហរណ៍ ទី ១ នៅក្នុងរូបទី ១០) ។

នៅក្នុងឧទាហរណ៍ដែលលើកឡើងខាងលើនេះអំពីការសិក្សាស្រាវជ្រាវរបស់អង្គការ CCC-ADI ស្តីពីការបែងចែកដីធ្លីនៅក្នុងទ្រង់ទ្រាយតូច ការប្រៀបធៀបលើលក្ខណៈសម្បត្តិខ្លះៗនៃគំរោងបែងចែកដីធ្លីទាំងបី ធ្វើអោយគេងាយយល់លើលក្ខណៈដូចគ្នានិងខុសគ្នារបស់វា និងបានកំណត់សមាសភាគដែលជួយកំណត់រូបរាងនៃជោគជ័យ/បរាជ័យរបស់គំរោង (ឧទាហរណ៍ទី ២ រូបទី ១០) ។ *ដែលទាញបានពីការប្រៀបធៀបនេះ* ថែមទាំងធ្វើអោយអ្នកស្រាវជ្រាវអាចពង្រឹងមូលដ្ឋានសំរាប់ឆ្លើយទៅនឹងសំណួរស្រាវជ្រាវស្តីពី ថាតើការស្រាវជ្រាវគួរមានមតិស្នើឡើងយ៉ាងដូចម្តេច? ដើម្បីធ្វើអោយដីសម្បទានសង្គមនៅក្នុងប្រទេសកម្ពុជា ដែលជាបញ្ហាត្រូវ*បានពិភាក្សាគ្នានៅក្នុង ឆ្នាំ* ២០០១ អាចសំរេចបានជោគជ័យខ្លះ ។

### រូបទី ១០. ឧទាហរណ៍នៃការវិភាគតាមបែបប្រៀបធៀបទៅលើសេចក្តីសង្កេតឃើញ

**ឧទាហរណ៍ ១.** ប្រភេទនៃការងាររបស់អ្នកធ្វើចំណាកស្រុករយៈពេលខ្លី និងរយៈពេលវែង ខែ តុលា ឆ្នាំ ២០០៣
(ប្រភព : អ្នកធ្វើចំណាកស្រុកទៅប្រទេសថៃ និងព្រំដែនកម្ពុជា-ថៃ ២០០៣ :៨)

| ប្រភេទការងារ | ជនចំណាកស្រុក រយៈពេលវែង | ជនចំណាកស្រុក រយៈពេលខ្លី | សរុប (N= 119) |
|---|---|---|---|
| កម្មករសំណង់ | ៣៤ | ២ | ៣៦ |
| កម្មករផ្នែកដឹកជញ្ជូន | ១៦ | ៣ | ១៩ |
| អ្នកធ្វើការនៅតាមផ្ទះ | ១២ | ២ | ១៤ |
| អ្នករត់តុ | ៩ | ២ | ១១ |
| អ្នកលក់ដូរបន្តិចបន្តួច | ៩ | ១ | ១០ |
| អ្នកដាំអំពៅ | ៤ | ៩ | ១៣ |
| អ្នកស្ទូងស្រូវ | ៤ | ៨ | ១២ |
| អ្នករានដី | ៣ | ២៨ | ៣១ |
| អ្នកច្រូតស្រូវ | ៣ | ៩ | ១២ |
| ។ល។ | | | |

**ឧទាហរណ៍ទី ២.** លក្ខណៈនៃភាពជោគជ័យ/បរាជ័យនៅក្នុងគំរោងបែងចែកដីធ្លីចំនួនបី

*( **ប្រភពៈ** ការបែងចែកដីធ្លីទ្រង់ទ្រាយតូចនៅក្នុងប្រទេសកម្ពុជា : មេរៀនពីករណីសិក្សាចំនួនបី ២០០១:៧)*

| លក្ខណៈ | បាត់ដំបង | | កំពង់ធំ | សៀមរាប |
|---|---|---|---|---|
| | តាគត់ | ទំនប់តាគួន | (ត្រពាំងចំបក់) | (គោកត្រើល) |
| ការពាក់ព័ន្ធរបស់មន្ត្រីរដ្ឋាភិបាល (អ្នកទទួលផលទទួលបាន/បាត់បង់ដីធ្លី) | ✓ | ✓ | ✓ | ✓ |
| ការផ្សព្វផ្សាយពត៌មានអំពីការបែងចែកដីធ្លី | - | - | - | ✓ |
| ជាមួយនឹងគោលការណ៍ណែនាំ/យន្តការនៅក្នុងការបែងចែកដីធ្លី | - | ✓ | ✓ | ✓ |
| ដំណើរការបែងចែកដីធ្លីឈរលើការចូលរួមរបស់ប្រជាជន | - | ✓ | - | ✓ |
| ទំហំដីដែលត្រូវបានបែងចែក (សំរាប់តែដីលំនៅដ្ឋានទេ) | | | | |
| តិចជាង ១ ហត | ៦៩% | | ១០០% | ៩៤% |
| ធំជាង ឬស្មើ ១ ហត | ៣១% | | | ៦% |
| ប្រភេទដីដែលត្រូវបានបែងចែក | | | | |
| ដីលំនៅដ្ឋាន | ✓ | ✓ | ✓ | ✓ |
| ដីស្រែ | ២២% | | - | ✓ - |
| ដីចំការ | - | - | - | - |
| ភស្តុតាងបញ្ជាក់កម្មសិទ្ធិ (ប័ណ្ណសំគាល់ដី ឬ បណ្ណ័កម្មសិទ្ធិដែលត្រូវបានចេញ អោយ) | - | - | - | ✓ |
| ការទទួលបានជំនួយពីអង្គការមិនមែនរដ្ឋាភិបាល | ✓ | ✓ | - | ✓ |
| ផលប៉ះពាល់ដែលមានទៅលើជីវភាពរស់នៅរបស់អ្នកទទួលផល | - | - | ✓ | ✓ |
| បញ្ហា | | | | |
| ការចាប់យកដី/រឹបអូស/រំលោភដីធ្លី | ✓ | ✓ | ✓ | ✓ |
| ការទាមទារកម្មសិទ្ធិរបស់អ្នកក្រៅ/អ្នកដែលមិនមែនជាអ្នកទទួលផល | - | - | ✓ | ✓ |
| កង្វះភាពច្បាស់លាស់ស្តីពីការិយាល័យ/អ្នកដែលទទួលខុសត្រូវចំពោះបញ្ហាដីធ្លី | ✓ | ✓ | ✓ | ✓ |
| ការខ្វះ ឬមិនមានរចនាសម្ព័ន្ធ | ✓ | ✓ | ✓ | - |
| **ទស្សនៈរួមរបស់អ្នកទទួលផល** | (-)) | (-) | (-) | (+) |

## ២. *ការរៀបចំ និង ពិនិត្យមើលនិន្នាការ* ( *Developing and tracing)*

ការវិភាគប្រភេទនេះគឺចង់តាមដាន និងរកមើលមូលហេតុនៃការកើតមានឡើង និងការរីកធំនៃបាតុភូតផ្នែកសង្គម ដំណើរការផ្នែកសង្គម ការផ្លាស់ប្តូរសង្គម ។ល។ ដោយវាមានសារៈប្រយោជន៍ពិសេសនៅពេលដែលអ្នកស្រាវជ្រាវកំណត់ ឬធ្វើតារាងស្តីពីនិន្នាការនៃបញ្ហាសង្គម ការនេះត្រូវមានការលាតត្រដាងពីលទ្ធផលរកឃើញដូចជាលំដាប់ ប្រវត្តិនៃព្រឹត្តិការណ៍ នៅក្នុងការអភិវឌ្ឍន៍សមស្របនឹងបញ្ហាមួយដែលគេងាយធ្វើការសង្កេត ។ ការនេះសន្មតថាទិន្នន័យ ដែលប្រមូលបានមក អនុញ្ញាតិអោយគេធ្វើការតាមដានដំណាក់កាលអភិវឌ្ឍរបស់បញ្ហាហើយទាំងអស់នេះត្រូវបាន រៀបចំ ឬប្រមូលពតិមានក្នុងទំរង់មួយដែលធ្វើអោយអ្នកស្រាវជ្រាវអាចរួមបញ្ចូលគ្នានូវទិន្នន័យរបស់ពួកគាត់តាមរបៀបបែបពន្យល់ ។

ការសិក្សាស្រាវជ្រាវរបស់ ADI ដែលពន្យល់បង្ហាញវិធីនេះគឺជាការសិក្សាស្រាវជ្រាវទៅលើ *ការប្រើប្រាស់ថ្នាំញៀនគឺជាបញ្ហាសង្គម* (២០០៤) ។ នៅត្រង់នេះ អ្នកស្រាវជ្រាវស្វែងយល់ពីអត្រាប្រើថ្នាំញៀននៅក្នុងអំឡុងពេល ៥ ឆ្នាំ ដោយរៀបតារាងស្តីពីលទ្ធផលរកឃើញដើម្បីពិនិត្យមើលថា តើនិន្នាការមានការកើនឡើង ថយចុះ ឬមិនមានការប្រែប្រួល (រូបទី ១១) ។

**រូបទី១១: ឧទាហរណ៍នៃការវិភាគដោយចងក្រងនិងតាមដានន្លូវការសង្កេត** (Example of analysis by developing and tracing observations)

**ឧទាហរណ៍:** ឆ្នាំដែលអ្នកឆ្លើយ ឬកូនរបស់គាត់ចាប់ផ្តើមប្រើថ្នាំញៀន ខែ កុម្ភៈ ឆ្នាំ ២០០៤

| ឆ្នាំ | អ្នកញៀនថ្នាំ (N = 30) | គ្រួសារអ្នកញៀនថ្នាំ (N = 33) |
|---|---|---|
| មុន ១៩៩៨ | ២ | ០ |
| ១៩៩៨-២០០០ | ៦ | ៧ |
| ២០០១ - ២០០២ | ៩ | ១៣ |
| ២០០៣ - ២០០៤ | ១៣ | ១៥ |

## ៣. *ការពិពណ៌នា*

ការបង្កើតទំនាក់ទំនងរវាងអថេរ (Variables) ដោយរៀបរាប់រួមបញ្ចូលនូវទំនាក់ទំនងជាគំរូ តាមបែបនៃការពន្យល់ទៅលើអ្វីដែលកំពុងកើតមាននៅកន្លែងណាមួយ ឬយន្តការនៃដំណើរការមួយចំនួនផ្នែកសង្គម ។ Mason (1996:137) កត់សំគាល់ថា "ការពន្យល់បែបរៀបរាប់គឺជាពាក្យដែលមានភាពមិនច្បាស់ និងស្មើថា ដើម្បីអោយមានប្រយោជន៍ អ្នកស្រាវជ្រាវគួរប្រើលក្ខណៈវិនិច្ឆ័យខ្លះ ដែលនៅជុំវិញនោះ គេផ្អែកលើការរៀបរាប់ខាងលើ ។

ការសិក្សាស្រាវជ្រាវមួយរបស់ CCC-ADI នៅក្នុងឆ្នាំ ២០០៤ ដែលពន្យល់បង្ហាញវិធីនេះ គឺការសិក្សាស្រាវជ្រាវស្តីពី *ការឆ្លើយតបរបស់ជនជាតិដើមភាគតិចទៅនឹងការធ្លាក់ចុះនៃធនធានធម្មជាតិ* ។ ដោយប្រើការស្រាវជ្រាវនេះ

ដើម្បីស្វែងយល់ ពីវិធីនេះ ការសិក្សាស្រាវជ្រាវបានប្រើប្រាស់ការរៀបរាប់ ដោយផ្តោតលើទំនាក់ទំនងមួយចំនួនដើម្បីកំណត់ពីការធ្លាក់ចុះនៃធនធានធម្មជាតិនៅក្នុងភូមិពីរនៅខេត្តក្រចេះ ហើយការធ្លាក់ចុះធនធានធម្មជាតិរបៀបនេះមានផលប៉ះពាល់ទៅដល់អ្នកប្រើប្រាស់ ។ ការសំភាសន៍ជាមួយក្រុមមនុស្សសំខាន់ៗជាមួយមនុស្សសំខាន់ៗ អ្នកស្រាវជ្រាវផ្ទៀងផ្ទាត់ព័ត៌មានពីពន្ធផ្នែកធនធានធម្មជាតិ នឹងស្វែងយល់ពីភាពគ្រប់គ្រាន់នៃ ធនធានទាំងនោះតាមរយៈការអង្កេតតាមផ្ទះ ។ រង្វាស់នៃភាពគ្រប់គ្រាន់រួមមានការវិភាគ លើគ្រួសារ បំរែបំរួលយុទ្ធសាស្ត្រផ្សេងៗរបស់គ្រួសារក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត និងការចូលរួមរបស់គេនៅក្នុងទីផ្សារ ។ នៅក្នុងការរៀបរាប់ទិន្នន័យបែបបរិមាណ និងគុណភាពអ្នកស្រាវជ្រាវកំណត់និន្នាការធ្លាក់ចុះនៃគុណភាពធនធាននៃគ្រួសារ ដោយផ្អែកលើភាពគ្រប់គ្រាន់នៃធនធានរបស់គេ រួមទាំងការធ្លាក់ចុះធនធានធម្មជាតិទាំងនេះ ទើបនាំអោយមានកំនើននៃភាព ក្រីក្រដល់ភូមិទាំងពីរ ។

### ៩. **ការព្យាករណ៍** (Predicting)

ការព្យាករណ៍ផ្អែកលើគោលការណ៍ថា បើគេអាចសង្កេតអ្វីដែលបានកើតឡើងនៅក្រោមលក្ខខ័ណ្ឌណាមួយនៅកន្លែងមួយពិតប្រាកដ អ្នកស្រាវជ្រាវអាចប្រមើលមើលអ្វីដែលកើតមានឡើងនៅពេលអនាគតក្រោមលក្ខខ័ណ្ឌ ដូចគ្នានេះ ឬក្នុងករណីដែលមានលក្ខខ័ណ្ឌផ្សេងតាមរបៀបមួយដែលគេដឹង (Mason, 1996:137) ។ ការប្រើវិធីបែបនេះ “ចំពោះការពន្យល់បែបរៀបរាប់នេះដូចជាមិនច្បាស់ពីទំនាក់ទំនង” និងស្នើឡើងថាអាចមានផលប្រយោជន៍ គឺទាមទារអោយអ្នកស្រាវជ្រាវយល់ច្បាស់ពីលក្ខណៈវិនិច្ឆ័យចំពោះការព្យាករណ៍ដែលគាត់កំពុងប្រើ ហើយគួរប្រើលក្ខណៈវិនិច្ឆ័យខ្លះជុំវិញអ្វីដែលបានរៀបរាប់ផ្អែកលើដំណើការស្រាវជ្រាវ ។ នៅក្នុងការវិភាគបែបនេះអ្នកស្រាវជ្រាវច្រើនតែដាក់សម្មតិកម្ម (hypothesis) (នៅក្នុងការស្រាវជ្រាវបែបបរិមាណ) ឬគំនិត យោបល់ (នៅក្នុងការស្រាវជ្រាវបែបគុណភាព) ស្វែងរកមើលនិងរៀបចំពតិមានចាំបាច់ដើម្បីកំណត់ភាពអាចនឹង កើតមានឬមិនកើតមាននៃបញ្ហា ហេតុការណ៍ បាតុភូត ។ល។ នៅក្នុងទិដ្ឋភាពផ្សេងមួយទៀតនៅក្រោមលក្ខខ័ណ្ឌ ដូចគ្នាឬខុសគ្នាបន្តិចបន្តួច ។

ការសិក្សាស្រាវជ្រាវចំនួនពីររបស់ CCC-ADI ដែលមានធ្វើការព្យាករណ៍ខ្លះៗ គឺការសិក្សាស្រាវជ្រាវស្តីពី *ការចេញទៅប្រកបការងារនៅប្រទេសថៃ និងតំបន់ព្រំដែនកម្ពុជា-ថៃ និងអំពើហឹង្សាក្នុងគ្រួសារនៅក្នុង តំបន់តាំងទីលំនៅថ្មីដែលមានកំនើនប្រជាពលរដ្ឋយ៉ាងឆាប់រហ័ស* ។ ទោះបីជាមិនមានចោទជាសំណួរស្រាវជ្រាវ ជាមួយនឹងការព្យាករណ៍យកធ្វើជាចំណុចផ្តោតសំខាន់នៃការសិក្សាក្តី តែកត្តាទាំងពីរដែលត្រូវបានកំណត់មាន ទាក់ទងនឹងការមានជានិច្ចនូវបញ្ហាពីរ ហើយដូច្នេះ វានឹងមានកើតឡើងជាបន្តនូវរឿងរ៉ាវ (Incidence) ក្នុងស្ថានភាពដែលមានលក្ខខ័ណ្ឌទាំងនេះ ។ ចំពោះការធ្វើចំណាកស្រុកទៅប្រកបការងារ លក្ខខ័ណ្ឌទាំងនេះរួមមានផងដែរ នូវភាពបន្ទាន់នៃសេដ្ឋកិច្ចទីផ្សារ ការផ្លាស់ទីកន្លែងនៃកម្មករ/អ្នកធ្វើការខ្មែរការបើកចំហព្រំដែនកម្ពុជា-ថៃ ។ ចំណែកឯអំពើហឹង្សានៅក្នុងគ្រួសារធ្វើអោយគេចាប់អារម្មណ៍លើលក្ខណៈបុគ្គល ដូចជាកំរិតវប្បធម៌របស់ប្តី ការធ្លាប់ធ្វើជាទាហ៊ានឬប៉ូលីស អាកប្បកិរិយាបែបត្រួតត្រារបស់ប្តី ការចូលរួមរបស់ប្រពន្ធនៅក្នុងការសំរេចចិត្ត ។ល ។

ការស្រាវជ្រាវស្តីពីការអនុវត្តក៏ផ្តល់ជាគំរូល្អមួយផងដែរស្តីពីវិធីសាស្ត្របែបពន្យល់/បែបវិភាគ បើទោះបីជាមានលក្ខណៈបែបគុណភាពច្រើនជាងក្តី ។ វាយ៉ាងដូច្នេះ ពីព្រោះអ្វីដែលមាននៅជាប់នឹងការសិក្សាស្រាវជ្រាវផ្ទាល់បែបនេះ គឺមានសំណួរស្រាវជ្រាវដែលសួររកលក្ខខ័ណ្ឌអាចឆ្លើយបានតាមការនិយាយ និងអនុវត្តនៅកន្លែងផ្សេងបាន ។

## ការភ្ជាប់ទំនាក់ទំនងគ្នា ចំណុចខុសគ្នា និង បុព្វហេតុរវាងការសង្កេតឃើញ (Association, Differences and Causality between Observations)

នៅក្នុងលំនាំខាងលើនៃការភ្ជាប់ទំនាក់ទំនងរវាងការសង្កេត/អថេរចំនួនពីរឬលើសពីពីរ ទំនាក់ទំនងអាចត្រូវបានគេកំណត់លក្ខណៈថាជាទំនាក់ទំនងបែប :

(ក) ការទំនាក់ទំនងដោយផ្ទាល់ ឬមិនផ្ទាល់ដែលឆ្លុះបញ្ចាំងអោយឃើញពីទិសវិជ្ជមាន ឬអវិជ្ជមាន និង
(ខ) ផ្នែកហេតុផល ឬហេតុ និងឥទ្ធិពល

ការសង្កេតត្រូវបានគេនិយាយថា មានជាប់ជាមួយគ្នានៅពេលដែលការផ្លាស់ប្តូរវិជ្ជមាន/អវិជ្ជមាននៅក្នុង **X** មានមកជាមួយនូវការផ្លាស់ប្តូរវិជ្ជមាន/អវិជ្ជមាននៅក្នុង **Y** ។ ដោយលើកយកការសិក្សាស្រាវជ្រាវខាងលើ ស្តីពីអំពើហឹង្សាក្នុងគ្រួសារធ្វើជាឧទាហរណ៍ លំនាំដែលត្រូវបានសង្កេតឃើញរបស់អ្នកស្រាវជ្រាវគឺថា បញ្ហាងាយនឹងកើតឡើង បើប្តីបញ្ចេញអកប្បកិរិយាត្រួតត្រានៅពេលប្រពន្ធមិនសូវមានលទ្ធភាពចូលរួមនៅក្នុងការសំរេចចិត្តនៅក្នុងគ្រួសារ ។ល ។ មានការកត់សំគាល់ថាអំពើហឹង្សានៅក្នុងគ្រួសារ (**Y**) អាចកើតឡើងនៅពេលដែលបុគ្គលបញ្ចេញអត្តចរិកបែបណាមួយ (**X**) ។ ដូច្នេះ ស្ថានភាពជាក់ស្តែងបង្ហាញអោយឃើញពីធាតុសំខាន់មួយ ដែលបានកើតឡើង **Y** ក៏អាស្រ័យលើ **X** ដែរ ។

ទោះបីមានទំនាក់ទំនងបែបនេះក្តី គេគួរនិយាយថា **X** មិនមែនចេះតែបណ្តាលអោយមាន **Y** នោះទេ ។ លក្ខណៈរបស់បុគ្គលអាចកំណត់រូបរាងបានមួយចំណែកលើការកើតមាននៃអំពើហឹង្សាតែគេត្រូវតែកំណត់អោយច្បាស់ថា ទាំងនេះគឺពិតជាមានមកជាមួយគ្នា (ជាធម្មតា) ។ អ្នកស្រាវជ្រាវបែបបរិមាណប្រើការធ្វើតេស្តបែបស្ថិតិ ដើម្បីបញ្ជាក់បង្ហាញពីទំនាក់ទំនង ឬការមានទំនាក់ទំនងគ្នាបែបនេះ... ។ វិធីសាស្ត្រទូទៅ រួមគឺវិធី Chi-square test of independence, ការជាប់ទាក់ទងគ្នា (correlation), regression[២២] ។ នៅក្នុងតេស្តទាំងនេះ គេពិនិត្យលើទំហំ និងការទំនាក់ទំនង ។ នៅក្នុងឧទាហរណ៍ដែលកំពុង បានគេ ឬពិភាក្សាទិសដែលធ្វើអោយគេនឹក ឃើញដល់លទ្ធផលរកឃើញមួយគឺមានភាពវិជ្ជមាននៅត្រង់ថា បើកាលណាអាកប្បកិរិយារបស់ប្តីមានលក្ខណៈត្រួតត្រាខ្លាំងកាលណា អំពើហឹង្សានៅក្នុងគ្រួសារកើតមានកាលនោះ ។ ម្យ៉ាងវិញទៀតមានរឿងបញ្ច្រាសមួយរវាងការចូលរួមរបស់ប្រពន្ធនៅក្នុងការសំរេចចិត្ត និងអំពើហឹង្សាក្នុងគ្រួសារ នៅពេលដែលប្រពន្ធចូលរួមតិចនៅក្នុងការសំរេចចិត្ត បញ្ហាអំពើហឹង្សាក្នុងគ្រួសារងាយនឹងកើតឡើង ។

កំរិតលំដាប់មួយទៀតដែលការសិក្សាស្រាវជ្រាវអាចស្វែងយល់បាន គឺនៅត្រង់បុគ្គលអ្នកឆ្លើយសំភាសន៍នៅក្នុងភូមិមួយដែលបានសិក្សា ទៅប្រៀបធៀបនឹងចំលើយរបស់បុគ្គលដែលមកពីភូមិមួយទៀត គឺតាមរបៀបនេះ គេវាយតំលៃភាពខុសគ្នារវាងក្រុមផ្តល់ចំលើយនៅក្នុងភូមិទាំងពីរនេះបាន ។ នៅក្នុងករណីនេះ សំណួរស្រាវជ្រាវ/សម្មតិកម្មអាចពិនិត្យថា តើភូមិទាំងពីរខុសគ្នា ឬស្តែងអោយឃើញនូវលំនាំទូទៅដូចគ្នា ដែលត្រូវបានគេកត់សំគាល់អំពីលក្ខណៈបុគ្គល និងការកើតឡើងនៃបញ្ហានោះ ។ ការស្វែងយល់ពីភាពខុសគ្នាបែបនេះ និង សារៈសំខាន់នៃភាពខុសគ្នារវាងអ្នកឆ្លើយសំភាសន៍ទាំងពីរក្រុមនេះក៏អាចត្រូវបានគេធ្វើតេស្តបែបស្ថិតិទៅ ដូចជា t-test, Chi-square test, ការវិភាគលើ Variance/ឬបច្ចេកទេសស្មុគ្រស្មាញដែលមានកំរិតលំអៀងច្រើនយ៉ាង (multivariate techniques) សំរាប់តេស្តមើលទំនាក់ទំនងរវាងអថេរនានា ។

[២២] ឧបសម្ព័ន្ធ៦ ផ្តល់នូវបញ្ជីឯកសារសំរាប់អានទៅលើប្រធានបទនោះ

ដោយយោងទៅលើការពិភាក្សាពីមុនស្តីពីមូលហេតុ និងរបៀបដែលលក្ខណៈនៃបុគ្គលអ្នកឆ្លើយមិនមែនសុទ្ធតែបណ្តាលអោយមានអំពើហឹង្សាទេនោះ ការអះអាងគាំទ្រខាងផ្លូវហេតុផល ឬទំនាក់ទំនងគ្នានៃហេតុនិងផលទាមទារអោយមានលក្ខណៈវិនិច្ឆ័យចំនួនបី (Babbie, 1998:73-74; Vogt, 1993:31) ៖

(ក) - ហេតុកើតមុនផល ឬថា **X** (ពោលគឺ លក្ខណៈរបស់បុគ្គល ឬអថេរឯករាជ្យ) មានមុន **Y** (ពោលគឺអំពើហឹង្សានៅក្នុងគ្រួសារឬអថេរមិនឯករាជ្យ) ពីព្រោះវាគ្មានហេតុផលទេដែលគេអះអាងថា លក្ខខ័ណ្ឌមួយដែលបានកើតឡើងបន្ទាប់ពីបាតុភូតមួយ ឬបញ្ហាមួយ គឺជាហេតុដែលបណ្តាលអោយមានបាតុភូត ឬបញ្ហានោះ ។

(ខ) - អថេរទាំងពីរ ឬការសង្កេតឃើញត្រូវបានគេកំណត់ថាមានការពឹងអាស្រ័យគ្នាឬមានមកជាមួយគ្នា (ពោលគឺ មានការទាក់ទងគ្នាទៅវិញទៅមកតាមភាពជាក់ស្តែង) ទៅវិញទៅមក ។

(គ) - ទំនាក់ទំនងអាស្រ័យគ្នាទៅវិញទៅមករវាង **X** និង **Y** មិនអាចអោយគេពន្យល់តាមរយៈកត្តាទីបីណាមួយ ឬអថេរដែលបណ្តាលអោយមាន **X** និង **Y** នោះទេ ។ លក្ខណៈវិនិច្ឆ័យនេះមានន័យថាអ្នកស្រាវជ្រាវត្រូវដឹងអោយច្បាស់ថាមិនមានការពន្យល់ណាផ្សេងទៀតដែលបញ្ជាក់ដល់ការរួមចំណែកអោយកើត **Y** ឡើងនោះទេ ។ ដូច្នេះនៅលើឧទាហរណ៍ដែលស្តីពីអំពើហឹង្សាក្នុងគ្រួសារដែលជាផលនៃលក្ខណៈបុគ្គល អ្នកស្រាវជ្រាវមិនគួរសន្និដ្ឋានជាមុនលើការដែលថាមានកត្តាផ្សេងទៀតដែលមានជាប់មកជាមួយនឹងបញ្ហា ដូចជាកត្តាដែលការសិក្សាស្រាវជ្រាវបានរកឃើញ ហើយដែលស្ថិតនៅក្នុងរង្វង់នៃបញ្ហាបរិយាកាសច្បាប់ និងសង្គម-វប្បធម៌ ។

ទំនាក់ទំនងខាងបុព្វហេតុអាចមានភាពងាយ ឬមានច្រើន (Vogt, 1993:31) ។ ទំនាក់ទំនងជាបុព្វហេតុ ដែលមានភាពងាយធ្វើអោយគេដឹងថា រាល់ពេលដែលហេតុការណ៍ដំបូង (បុព្វហេតុ) កើតឡើង ហេតុការណ៍ទីពីរ (ផល) ក៏កើតមានដែរ ។ ការមានបុព្វហេតុច្រើនជាករណីដែលមានច្រើននៅក្នុងរឿងទាក់ទងនឹងសង្គម និងអាកប្បកិរិយា ហើយវាបញ្ជាក់ថាបុព្វហេតុច្រើនអាចធ្វើអោយមានផលដូចគ្នាតែមួយ ។ បុព្វហេតុច្រើនអាចមានលក្ខណៈបែបហ្នឹងហើយមិនមានមួយណាដែលសុទ្ធតែនាំអោយមានផលតែមួយដូចគ្នានោះទេ តែបើមានរួមគ្នាច្រើនអាចបណ្តាលដែរ ។ ដូចមាននៅក្នុងឧទាហរណ៍ស្តីពីអំពើហឹង្សាក្នុងគ្រួសារលក្ខណៈខ្លះរបស់បុគ្គលដែលត្រូវបានគេលើកឡើង (នោះគឺកិរិតវប្បធម៌របស់ប្តី ប្រវត្តិប្តីធ្លាប់ធ្វើជាទាហ៊ាន ឬនគរបាល អាកប្បកិរិយាបែបត្រួតត្រារបស់ប្តីការចូលរួមរបស់ប្រពន្ធនៅក្នុងការសំរេចចិត្ត ។ល។) មិនមានទិសកំណត់ដូចគ្នា (និងទំហំផង) ដែលទាក់ទងនឹង បញ្ហាទេ ។ ការធ្វើតេស្តបែបស្ថិតិលើទិន្នន័យ (Statistical test) (ឧទាហរណ៍ការវិភាគលើកត្តាប្រែប្រួលច្រើន និងទំនាក់ទំនង ដែលមានទៅវិញទៅមក ដូចជាការវិភាគលើកត្តា និងជម្រេរសេស៊ីន ដែលមានច្រើនសណ្ឋាន (Multiple regression) ធ្វើអោយអ្នកស្រាវជ្រាវអាចពិនិត្យទំហំនៃទំនាក់ទំនងដែលគេកំណត់តាមសម្មតិកម្មព្រមទាំងអាចកំណត់ការរួមគ្នានៃចរិកលក្ខណៈដែលនាំអោយកើតមានបញ្ហា ។

ការរកមូលហេតុ ឬសគល់នៃលំនាំខ្លះនៅក្នុងទិន្នន័យ និងការរកមើលបញ្ហាគន្លឹះពីលទ្ធផលរកឃើញ អាចជាដំណើរការមានភាពស្មុគស្មាញ ។ ទោះបីមានបញ្ហាប្រឈមនិងកិរិតនៃភាពស្មុគស្មាញដែលអ្នកស្រាវជ្រាវត្រូវប្រឈមជាមួយក្តី តែជំហាននេះអាចជាលំហាត់ដែលមានលក្ខណៈធ្វើអោយគេចាប់អារម្មណ៍ខ្លាំង ពីព្រោះគេវេញចូលគ្នានូវទិន្នន័យទាំងឡាយ ហើយបញ្ចេញអោយឃើញនូវការទាក់ទងគ្នារវាងទំរង់បែបផែននានាដែលមាន ។

## ឧបករណ៍ និងបច្ចេកទេសដើម្បីធ្វើការភ្ជាប់ទំនាក់ទំនងផ្សេងៗ (Tools and Techniques to Drawing out Relationships)

ជាបន្ថែមលើឧបករណ៍ផ្នែកស្ថិតិដែលអ្នកស្រាវជ្រាវមានបទពិសោធន៍ប្រើនៅក្នុងការស្វែងរកការពន្យល់ និងនៅក្នុងការបង្កើត ឬបង្ហាញអោយគេឃើញនូវទំនាក់ទំនងនៃលំនាំដែលគេបានសង្កេតពីទិន្នន័យ នៅមានឧបករណ៍ និងបច្ចេកទេសផ្សេងទៀតដូចជាតារាង (Chart) និងដ្យាក្រាម ។ ទាំងអស់នេះសុទ្ធតែ ត្រូវបានស្គាល់ហើយចំពោះអ្នកដែលធ្លាប់ជួបប្រទះ ឬស៊ាំនឹងវិធីសាស្ត្រនៃការរៀនសូត្រ និងសកម្មភាពបែបចូលរួម (PLA)[២៣] ឬការវាយតំលៃឆាប់រហ័សដោយមានការចូលរួម (PRA) ដូចដែលគេចេះមក ហើយប្រើជាញឹកញាប់ ។ តែគេគួរនិយាយថា ឧបករណ៍ទាំងនេះ មួយចំនួនត្រូវបានគេស្គាល់ច្រើនជាងឧបករណ៍ពីដើមរបស់វានៅក្នុងវិទ្យាសាស្ត្រអនុវត្ត និងវិទ្យាសាស្ត្រសង្គម ។ តារាងឆាត និងដ្យាក្រាមត្រូវមាននៅក្នុងការវិភាគទិន្នន័យ ពីព្រោះវាធ្វើអោយអ្នកស្រាវជ្រាវអាចតំរៀប និងចាត់ចំណាត់ថ្នាក់លើទិន្នន័យដើម្បីស្វែងយល់ថាអ្វីត្រូវនៅជាមួយនឹងអ្វី និងពិចារណាមើលថាតើ ទិន្នន័យដោយឡែកៗអាចត្រូវបានគេភ្ជាប់គ្នាយ៉ាងដូចម្តេចសមទៅតាមវិធីដែលគេមិនស្គាល់ពីមុនមក (Wolcott, 1990:62) ។ ឧបករណ៍ និងបច្ចេកទេសទាំងនេះខ្លះត្រូវបានរៀបរាប់ និងបញ្ជាក់ដោយសង្ខេប ដូចខាងក្រោមនេះ :

### ដ្យាក្រាមវែន

ដ្យាក្រាមវែនពីដើមត្រូវបានគេប្រើនៅក្នុងគណិតវិទ្យា ហើយយកឈ្មោះតាមអ្នកតក្កវិទ្យាជាជនជាតិអង់គ្លេស ។ ដ្យាក្រាមនេះបង្ហាញទិន្នន័យដែលប្រើរង្វង់ដើម្បីរៀបរាប់ពត៌មាន និងទំនាក់ទំនងរបស់វា ។ គេប្រើវា ច្រើននៅក្នុង (PRA) ដើម្បីសិក្សាពីទំនាក់ទំនងស្ថាប័នហើយមានបំណងផ្តល់ការយល់ដឹង និងធ្វើអោយមានការ វិភាគលើរចនាសម្ព័ន្ធនៃសិទ្ធិអំណាចដំណើរការធ្វើការសំរេចចិត្ត ។ល ។ (Kumar, 2002:234-235) ។ ដោយត្រូវបានប្រើនៅក្នុង PRA ផងដែរទំហំនៃរង្វង់ និងប្រវែងពីមួយទៅមួយមានអត្ថន័យ គឺថារង្វង់កាន់តែធំបុគ្គល ឬស្ថាប័នកាន់តែមានសារៈសំខាន់ច្រើន ។ ចំងាយរវាងរង្វង់មួយទៅរង្វង់មួយបង្ហាញពីកំរិតនៃឥទ្ធិពល ឬការទាក់ទងរវាងស្ថាប័ន ឬបុគ្គល ។ រង្វង់ដែលកាត់គ្នាបង្ហាញនូវអន្តរកម្ម ហើយទំហំនៃការមានត្រួតគ្នាបង្ហាញពីកំរិតលំដាប់នៃអន្តរកម្ម (Kumar, 234) ។

ដ្យាក្រាមវែនមានប្រយោជន៍ផងដែរសំរាប់អ្នកស្រាវជ្រាវ នៅពេលគេស្វែងយល់ទៅក្នុងទំនាក់ទំនងរវាងលំនាំ/និន្នាការដែលត្រូវបានគេសង្កេតឃើញនៅក្នុងទិន្នន័យរបស់គេ ។ តាមរយៈនេះ អ្នកស្រាវជ្រាវកាន់តែពិនិត្យបានល្អលើទំនាក់ទំនង (ឬកង្វះទំនាក់ទំនង) ដូចជាអ្នកធ្វើការងារអភិវឌ្ឍន៍ ជាពិសេសស្តីពីកំរិតនៃការយល់ដឹងលើ ការសំរបសំរួលនិង/ឬការត្រួតគ្នានៅក្នុងមុខងារដែលកំពុងត្រូវបានបំពេញ ។ នៅក្នុងការសិក្សាស្រាវជ្រាវរបស់ CCC-ADI ស្តីពី*បទពិសោធន៍របស់ក្រុមប្រឹក្សាឃុំសង្កាត់ នៅក្នុងការលើកកំពស់អភិបាលកិច្ចមូលដ្ឋានដែលមានលក្ខណៈចូលរួម* ការរកមើលទំនាក់ទំនងនៅក្នុងចំណោមតួអង្គនៅក្នុងការអភិវឌ្ឍន៍អាចត្រូវបានគេបង្ហាញនៅក្នុងរូប ១២ ដែលក្នុងនោះការមាន/មិនមានវត្តមាននៃអន្តរកម្ម ឬការសហការគ្នារវាងអង្គការមិនមែនរដ្ឋាភិបាល និងក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបានគេតាមដានមើល ។

---

[២៣] ឥឡូវនេះគេបកស្រាយកាន់តែច្រើនថាជាសកម្មភាពនិងការឆ្លុះបញ្ចាំងតាមលក្ខណៈចូលរួម (Chambers, 2002:x) ហើយប្រើអក្សរកាត់ ដូចពាក្យដើមរបស់វា ។

**រូបទី ១២. ស្វែងយល់ពីទំនាក់ទំនងរវាងអង្គការមិនមែនរដ្ឋាភិបាល និងក្រុមប្រឹក្សាឃុំតាមរយៈដ្យាក្រាមស្ថាប័ន**




**ការវិភាគលើបណ្តាញសង្គម** (Social Network Analysis)

ការវិភាគលើបណ្តាញ គឺជាការសិក្សាចំរុះវិស័យទៅលើទំនាក់ទំនងផ្នែកសង្គម ហើយមានឫសគល់នៅក្នុងវិទ្យាសាស្ត្រដែលសិក្សាពីមនុស្ស សង្គមវិទ្យា ចិត្តវិទ្យា និងគណិតវិទ្យាបែបអនុវត្ត (Lewis-Beck et al, 2004:719)។ វាត្រូវបានគេពេញនិយមប្រើជាឧបករណ៍មួយរបស់ PRA ផងដែរទស្សនៈជាសារវ័ន្តរបស់វា គឺថាបណ្តាញផ្នែកសង្គម ជាគំរិតមូលដ្ឋានដែលមានតួអង្គផ្នែកសង្គមមួយចំនួន និងចំណងជាទំនាក់ទំនងមួយចំនួន ដែលផ្សារភ្ជាប់ជាគូៗនៃតួអង្គទាំងនេះ។ ចំណុចសន្មតដំបូងមួយរបស់វា គឺជាតួអង្គផ្នែកសង្គមមានការពឹងផ្អែកគ្នាទៅវិញទៅមក នឹងចំណងទាក់ទងនៅក្នុងចំណោមតួអង្គទាំងនោះ មានផលវិបាកសំខាន់ៗសំរាប់តួអង្គនីមួយៗផ្នែកសង្គម និងសំរាប់ក្រុមធំផ្នែកសង្គមដែលមាននៅក្នុងនោះ។ សមាជិករបស់បណ្តាញអាចជាក្រុមឬអង្គការ និងមនុស្ស។ គោលដៅនៃការចូលរួមនៅក្នុងបណ្តាញនៃការវិភាគគឺដើម្បីពិនិត្យមើលរចនាសម្ព័ន្ធរបស់បណ្តាញ តាមរយៈទស្សនៈដូចជា ដង់ស៊ីតេ ភាពនៅកណ្តាល (Centrality) កិត្យានុភាព ភាពមានទៅមានមក និងតួនាទី (Lewis-Beck et al, 719)។ ការប្រើវានៅក្នុងការឆ្លុះបញ្ចាំង និងការវិភាគជាលក្ខណៈចូលរួមជាមួយនឹងការតាក់តែងពីដើមមក ព្រោះថារបៀបនៃការវិភាគនេះពិនិត្យលើចរិកលក្ខណៈ និងគុណភាពនៃការទំនាក់ទំនង មុខងារនៃទំនាក់ទំនង និងភាពញឹកញាប់នៃការទាក់ទង។ល។ (Kumar, 2002:211 )។ ដោយត្រូវបានលាតត្រដាងជាទំរង់រូបភាពមួយ ដ្យាក្រាមបណ្តាញផ្តល់រូបភាពរួមស៊ីជំរៅ និងភាពសំបូរបែបនៃចំណងទាក់ទង ដែលកំពុងមាននៅក្នុងចំណោមតួអង្គផ្នែកសង្គមដែលកំពុងត្រូវបានសិក្សាស្រាវជ្រាវ។

ដ្យាក្រាមបណ្ដាញដូចគ្នាខ្លះជាមួយនឹងដ្យាក្រាមវែន (Kumar, 211) ។ តែវាខុសគ្នាត្រង់ថា *ដ្យាក្រាមវែនមានសារៈសំខាន់ និងភាពជិតស្និទ្ធនៃស្ថាប័នជាមួយនឹងមនុស្ស* ។ ចំណែកដ្យាក្រាមបណ្ដាញទាក់ទងច្រើននឹងការរៀបរាប់ និងការវិភាគលើធម្មជាតិ គុណភាព ភាពចំរុះ ហេតុផល និងចំនួនប្រេកង់នៃការទាក់ទងរបស់ប្រធានបទជាមួយនឹងអ្នកខាងក្រៅ (រូបទី១៣) ។ ជាលក្ខណៈដោយឡែកមួយនៃគោលបំណងរបស់ផ្នែកនេះក្នុងការ កំណត់ឧបករណ៍សំរាប់ស្វែងរកការពន្យល់ និងទាញបាននូវទំនាក់ទំនងស្ដីពីលំនាំដែលគេបានសង្កេតឃើញពីទិន្នន័យ ដ្យាក្រាមបណ្ដាញមានប្រយោជន៏ទាក់ទងសំរាប់អ្នកស្រាវជ្រាវ ដោយគាត់ចង់យល់ពីតួអង្គផ្នែកអភិវឌ្ឍន៏ក្នុងក្រុមណាមួយជាមួយនឹងពិភពខាងក្រៅ ដោយគាត់អាចមានវិធានការណាមួយ ដើម្បីពង្រឹងការទាក់ទងរបស់តួអង្គអភិវឌ្ឍន៏ ពង្រឹងបណ្ដាញ និងសម្ព័ន្ធភាពជាយុទ្ធសាស្ត្រទាំងនោះ ។

**រូបទី ១៣. ឧទាហរណ៏នៃដ្យាក្រាមបណ្ដាញ**




*ប្រភព*: Kumar, 2002:212.

**ដ្យាក្រាមស្ដីពីការវិភាគលើជីវភាពរស់នៅ** (Livelihood Analysis Diagrams)

ដោយប្រើបច្ចេកទេសនិងឧបករណ៍កំណត់មួយចំនួនដែលជាឧបករណ៏ដែលគេប្រើជាទូទៅនៅក្នុង PRA/PLA ដ្យាក្រាមស្ដីពីការវិភាគលើជីវភាពរស់នៅ ក្នុងការវិភាគទិន្នន័យត្រូវបានគេគិតថាមានសារៈប្រយោជន៏ នៅពេលដែលអ្នកស្រាវជ្រាវពិនិត្យទិន្នន័យ ឬស្វែងយល់និន្នាការដែលទាក់ទង នឹងប្រាក់ចំណូលចំណាយលើស្បៀង ការដោះស្រាយវិបត្តិមុខរបរ បញ្ហាទាក់ទង នឹងការងារការចិញ្ចឹមសត្វ ផលិតកម្មកសិកម្ម ។ល ។ (Kuma, 2002: 289-290) ។ ដ្យាក្រាមទាំងនេះ

ត្រូវបានគេប្រើដើម្បីជួយបកស្រាយពីអាកប្បកិរិយា ការសំរេចចិត្តនិងយុទសាស្ត្រដោះស្រាយរបស់គ្រួសារដែលមានលក្ខណៈស្ថានភាពផ្នែកសេដ្ឋកិច្ចសង្គមកិច្ចខុស១គ្នា (Theis and Grady,1991: 108) ។ ជាញឹកញាប់ គេប្រើផ្សំជាមួយឧបករណ៍ផ្សេងទៀតដូចជាតារាង Pie Chart តារាងលំហូរតារាងពេលវេលា ដ្យាក្រាមតាមរដូវកាល ឧបករណ៍កត្តា/តួអង្គដែលជួយ និងតួអង្គ/កត្តាដែលរាំងស្ទះ ។ល ។ ដើម្បីកំណត់បាននិន្នាការ និងភាពទាក់ទងគ្នាទៅវិញទៅមកនៃសមាសភាគទាំងឡាយនៅក្នុងរង្វង់នៃលំនាំ ឬ និន្នាការនៅក្នុងទិន្នន័យ ។

**ការវិភាគតាមឧបករណ៍** SWOT

ការវិភាគ SWOT ជាទូទៅត្រូវបានគេប្រើធ្វើជាឧបករណ៍សំរាប់ធ្វើការជាមួយនឹងក្រុមនានា ដើម្បីឆ្លុះបញ្ចាំង/វិភាគបញ្ហាឬព្រឹត្តិការណ៍ និងដើម្បីកំណត់ជំរើសយុទ្ធសាស្ត្រសំរាប់សហគមន៍ អង្គការឬបុគ្គល នៅពេលណាមួយ (IIRR, 1996:68) ។ អ្នកស្រាវជ្រាវអាចប្រើឧបករណ៍ដើម្បីពន្យល់បន្ថែម ឬបញ្ជាក់ទៅលើការសង្កេត ឃើញរបស់គេអំពីទិន្នន័យរបស់គេ ពីព្រោះការនេះបង្កលក្ខណៈល្អសំរាប់ការវាយតំលៃដោយប្រុងប្រយ័ត្នទៅលើលទ្ធផលរកឃើញ និងធ្វើការសន្និដ្ឋាន ដោយមានការគិតគូរច្បាស់លាស់ព្រមទាំងផ្តល់នូវអនុសាសន៍ ។ រូបទី ១៤ បង្ហាញម៉ាទ្រិច SWOT ធម្មតា ។

**រូបទី១៤. ម៉ាទ្រិចស្តីពីចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និង ឧបសគ**

| | **ចំណុចខ្លាំង**<br>លក្ខណៈវិជ្ជមាន និងអត្ថប្រយោជន៍នៃបញ្ហា ស្ថានភាព ឬបច្ចេកទេស | **ចំណុចខ្សោយ**<br>លក្ខណៈអវិជ្ជមាន និងគុណវិបត្តិ បញ្ហា ស្ថានភាព ឬបច្ចេកទេស |
|---|---|---|
| **ឱកាស**<br>កត្តាស្ថានភាពដែលអាចផ្តល់ប្រយោជន៍ លើកកំពស់ឬកែលំអរបញ្ហាស្ថានភាព ឬ បច្ចេកទេស ។ | S-O Analysis<br>តើគេអាចប្រើចំណុចខ្លាំងយ៉ាងដូចម្តេច ដើម្បីទាញយកប្រយោជន៍ពីឱកាសនៃការអភិវឌ្ឍន៍? | W-O Analysis<br>តើគេអាចបំបាត់ចំណុចខ្សោយយ៉ាងដូចម្តេចដើម្បីទាញយកប្រយោជន៍ពីឱកាសក្នុងការអភិវឌ្ឍន៍? |
| **ឧបសគ្គ**<br>កត្តា ឬស្ថានភាពរាំងដល់បញ្ហា ស្ថានភាព ឬបច្ចេកទេស ។ | S-T Analysis<br>តើគេអាចប្រើចំណុចខ្លាំងបានយ៉ាងដូចម្តេច? ដើម្បីទប់ នឹង ការគំរាមកំហែងដែលធ្វើអោយរាំងស្ទះដល់ការសំរេចបានជោគជ័យលើទិសដៅ និងការចាប់យកឱកាស? | W-T Analysis<br>តើគេអាចជំនះចំណុចខ្សោយបានយ៉ាងដូចម្តេច? ដើម្បីទប់ស្កាត់ នឹងការគំរាមកំហែងដែលរាំងដល់ការសំរេចជោគជ័យលើទិសដៅ និងការឈោងទៅចាប់យកឱកាស? |

*ប្រភព ៖ IIRR, 1996, Recording and Using Indigenous Knowledge: A Manual, p. 69*

ផ្នែកទី ៣

## ហេតុនិងផល/ដ្យាក្រាមសំបុកពីងពាង (Cause and Effect/Web Diagrams)

ដោយត្រូវបានគេស្គាល់ផងដែរថាជាដ្យាក្រាមឆ្អឹងត្រី ឬដ្យាក្រាមអ៊ីស៊ីកាវ៉ា ដ្យាក្រាមហេតុនិងផលផ្តោតទៅលើកត្តាផ្នែកហេតុផលនៃបាតុភូត សកម្មភាព ឬបញ្ហាមួយ និងផលដែលមានមកជាប់ជាមួយគ្នានោះ (Kumar, 2002:188) ។ ទាំងនេះគឺជាការបង្ហាញអោយឃើញនូវហេតុផល និងការទំនាក់ទំនងគ្នាទៅវិញទៅមករបស់វា ដែលជួយអោយគេយល់បានស៊ីជំរៅលើប្រធានបទណាមួយ ហើយផ្តល់ជាក្របខ័ណ្ឌសំរាប់ធ្វើការវិភាគសំរាប់ការរៀបចំអនុសាសន៍ និងសំរាប់សកម្មភាពតាមប្រធានបទនៃការសិក្សាស្រាវជ្រាវ (រូបទី ១៥) ។ ការរៀបចំដ្យាក្រាមបែបនេះមានផលប្រយោជន៍ជាពិសេសសំរាប់អ្នកស្រាវជ្រាវ ពីព្រោះវាធ្វើអោយគេអាចឆ្លុះបញ្ចាំងលើគ្រប់ ហេតុទាំងអស់ដែលអាចមានចំពោះបញ្ហា ឬបាតុភូតមួយជាពិសេសនៅពេលដែលការធ្វើតេស្តបែបស្ថិតិត្រូវបានគេពិចារណាធ្វើ គេអាចចាំបានថា ការលើកឡើងនូវមតិអំពីហេតុដែលនាំអោយមានអ្វីមួយកើតឡើង (Causality) រវាងការសង្កេត ទាមទារការបំពេញបានតាមលក្ខណៈវិនិច្ឆ័យមួយចំនួន ។ ការបកស្រាយបង្ហាញលទ្ធផលរកឃើញ នៅក្នុងដ្យាក្រាមបែបនេះ អាចជួយអ្នកស្រាវជ្រាវនៅក្នុងការរាវរកមើលបុព្វហេតុនិងផលស្របទៅតាមលក្ខណៈវិនិច្ឆ័យនោះហើយ ពិនិត្យការទាក់ទងទៅវិញទៅមកដែលអាចមានរវាងហេតុនិង/ឬផល ។

## ការវិភាគលើកត្តា/តួអង្គដែលជួយ និងកត្តា/តួអង្គដែលរាំងស្ទះ (Force-field Analysis)

ការវិភាគលើកំលាំងនៅនឹងកន្លែង គឺជាបច្ចេកទេសដែលគេប្រើដើម្បីកំណត់ និងវិភាគកំលាំង (ឬកត្តា) ដែលគេអាចមើលឃើញហើយដែលមានផលប៉ះពាល់ នឹងស្ថានភាពនៃបញ្ហាដើម្បីនាំមកនូវការប្រែប្រួលវិជ្ជមាន (រូបទី ១៦) (Kumar, 2002:270) ។ ដោយត្រូវបានប្រើនៅក្នុងបរិបទមួយចំនួន វាអាចជាឧបករណ៍របស់អ្នកស្រាវជ្រាវនៅពេលដែលពួកគាត់ថ្លឹងថ្លែងទិដ្ឋភាពវិជ្ជមាន និងអវិជ្ជមាននៃការសង្កេតឃើញរបស់គាត់ដើម្បីធ្វើការសន្និដ្ឋានអំពីលំនាំ/និន្នាការ ហើយផ្តល់អនុសាសន៍ដែលមានការទាក់ទង ពិសេសប្រសិនបើការសិក្សាស្រាវជ្រាវនោះមានការទាក់ទង នឹងការផ្លាស់ប្តូរផ្នែកសង្គម ។ ពេលវេលាតិចតួចក្នុងការចង្អុលបង្ហាញពីដែនកំលាំងដែលបានពិពណ៌នា តែសំរាប់កំលាំងនីមួយៗមិនចាំបាច់មានកំលាំងទប់ទេ ។ កំលាំងដែលប៉ះពាល់លើស្ថានភាព បញ្ហាត្រូវបានគេកំណត់ទំងន់ អោយស្របទៅតាមផល របស់វាទៅលើស្ថានភាពនៃបញ្ហាតាមដែលគេយល់ឃើញ ។ ដូច្នេះវាធ្វើអោយមានភាពងាយស្រួលក្នុងការដៅអោយចំកំលាំងដែលគេត្រូវពង្រឹងថែមទៀតនិងដៅអោយចំកំលាំងដែលគេត្រូវធ្វើអោយខ្សោយ (Kumar,2000:270) ។ ឧបករណ៍នេះក៏ត្រូវបានប្រើប្រាស់ដោយអ្នក ស្រាវជ្រាវដែលធ្វើតាមវិធី បែបចូលរួមនៅពេលគេធ្វើការវិភាគបញ្ហា និងកំណត់ដំណោះស្រាយ ។ នៅក្នុងចំណោមកំហិតព្រំដែនដែលត្រូវបានគេលើកឡើង គឺមានការសន្មតថា ស្ថានភាពនៃបញ្ហាណាមួយអាចត្រូវបានចាត់ទុកថា កំពុងតែស្ថិតនៅក្នុងសភាពមានលំនឹង ហើយវាជាការងាយស្រួលក្នុងការពន្យល់ភាពស៊ាំញ៉ាំនៃបញ្ហា ។

## រូបទី ១៥. ឧទាហរណ៏នៃផ្សាក្រាមស្តីពីហេតុនិងផលនៃការធ្វើចំណាកស្រុកតាមរដូវ




*ប្រភព:* ទទួលបានពី Kumar, 2002:193; ទិន្នន័យបានពីលទ្ធផលរកឃើញ ដែលបង្ហាញដោយអង្គការCCC-ADI's ការសិក្សាស្រាវជ្រាវខ្នាតតូច ជំហ៊ានទាំង ១០ ក្នុងការវិភាគ , 2000: 107-111.

## រូបទី១៦. ការលាតត្រដាងនៃឧបករណ៏វិភាគ (Force-Field)




*ប្រភព:* umar, 2002:271.

## ការទាញយកនូវបញ្ហាដែលជាប់ពាក់ព័ន្ធ (Drawing out Implications)

ការបកស្រាយលទ្ធផលរកឃើញរួមមាន ការទាញបាននូវភាពជាប់ពាក់ព័ន្ធនៃបញ្ហានៅក្នុងសំណាកសិក្សាស្រាវជ្រាវ (ឬឯកត្តានៃការវិភាគ) និង/ឬសង្គមទាំងមូលដែលមានសំណាកនៅក្នុងនោះ ។ បញ្ហាពាក់ព័ន្ធទាំងនេះ (Implication) ត្រូវបានទាញចេញពីលំនាំដែលគេបានវិភាគនៅក្នុងទិន្នន័យ និងអត្ថន័យនៅក្នុងលទ្ធផលរកឃើញ (ក) សំណាក ឬប្រធានបទនៃការសិក្សា តួអង្គ/បញ្ហាដែលទាក់ទងនឹងក្រុម ឬប្រការដែលកំពុងត្រូវបានវិភាគ ដូចជា អង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន ។ល ។ និងបញ្ហា/ប្រជាជនទូទៅ ដែលសំណាកតំណាងអោយ (ខ) ចំណេះដឹងដែលការសិក្សាស្រាវជ្រាវនឹងជួយរួមចំណែក ។ ការរកមើលបញ្ហាពាក់ព័ន្ធនៃលទ្ធផលរកឃើញ ត្រូវមានការឆ្លុះបញ្ចាំងលើអ្វីដែលបានលើកឡើង ហើយគេអាចដកស្រង់បានដោយការចោទជាសំណួរទាំងនេះ :

- តើលទ្ធផលរកឃើញដែលទាក់ទងនឹងសំណួរស្រាវជ្រាវមានសារៈសំខាន់បែបណាខ្លះដល់សំណាកនៅក្នុងការសិក្សាស្រាវជ្រាវនោះ? តើសកម្មភាពជាក់ស្តែង និងការរៀបចំគោលនយោបាយអ្វីខ្លះដែលលទ្ធផលរកឃើញបានដាក់ស្នើឡើង?
- តើលទ្ធផលរកឃើញមានន័យយ៉ាងដូចម្តេច សំរាប់ចំណេះដឹងដែលមានហើយឬសំរាប់ការកសាង ចំណេះដឹងថ្មី? តើបញ្ហាឬចំណេះដឹងអ្វីខ្លះដែលលទ្ធផលរកឃើញចង្អុលទៅរកហើយដែលអ្នកស្រាវជ្រាវ គួរស្វែងយល់បន្ថែមទៀត?

ដូច្នេះការសិក្សាស្រាវជ្រាវអាចមានការអនុវត្តតាមទ្រឹស្តី និងតាមភាពជាក់ស្តែង ។ បញ្ហាដែលជាប់ពាក់ព័ន្ធ ជាក់ស្តែងពិចារណាក៏វិតដែលលទ្ធផលរកឃើញមានឥទ្ធិពលលើគោលនយោបាយផ្នែកសង្គម កម្មវិធីដែលកំពុងមានជាបន្ត ឬមតិសាធារណៈទាក់ទងនឹងបញ្ហាសាធារណៈ (Shah, 1972:51) ។ ការលើកឡើងបញ្ហាពាក់ព័ន្ធ ជាក់ស្តែងទាំងនេះត្រូវមានការវិភាគលើលទ្ធភាពរបស់វាសំរាប់ការអនុវត្តន៍ ពីព្រោះថាការចង្អុលបង្ហាញវាមិនគ្រប់គ្រាន់ទេ ។ ការវិភាគទាំងនេះស្វែងយល់ពីលក្ខខ័ណ្ឌ ឬកត្តា (ឧទាហរណ៍ ធនធានដែលត្រូវការ ទស្សនៈឬគុណតំលៃ ដែលមានជាទូទៅ ។ល ។ សំរាប់គាក់តែងគោលនយោបាយថ្មីជាដើម) ដែលធ្វើអោយអ្នកអានអាចជំរុញមតិស្នើឡើងបាន ។ វាត្រូវធ្វើយ៉ាងដូច្នេះនៅពេលខ្លះដែលមានប្រយោជន៍ បើគេបញ្ចូលមតិស្នើឡើងជាក់ស្តែង ឬជំរើសផ្សេងៗទៀតនៃលទ្ធផលរកឃើញដែលជាប់ទាក់ទិន និងជាចំលើយតប ។ ដូច្នេះ ភាពជាប់ពាក់ព័ន្ធទាំងនោះគឺ **មិនមែនជា**អនុសាសន៏ដែលអ្នកស្រាវជ្រាវបង្កើតទេ ប៉ុន្តែវាជួយត្រួសត្រាយដល់ការផ្តល់អនុសាសន៏ទាំងនេះ ។

បញ្ហាជាប់ពាក់ព័ន្ធនឹងទ្រឹស្តី (Theoritical Implication)ទាក់ទងនឹងការកសាងទ្រឹស្តី ពោលគឺ ការទាក់ទងទាំងនេះពិចារណា លើចំណេះដឹងដែលបានពីការស្រាវជ្រាវ ការពង្រីកទស្សនៈយល់ឃើញទៅលើក្រុម/អនុក្រុមមនុស្សក្នុងសង្គម (ឧទាហរណ៍ ស្រ្តី កុមារ និងក្រុមមនុស្សដទៃទៀតដែលងាយរងគ្រោះ) បញ្ហា (ការចូលរួម ភាពក្រីក្រ) បាតុភូត (ការធ្វើចំណាកស្រុកដើម្បីប្រកបការងារការប្រើថ្នាំញៀន) ។ល ។ ឆ្លងតាមរយៈភស្តុតាងវិជ្ជមាន និងអវិជ្ជមានដែលការសិក្សាស្រាវជ្រាវបានរកឃើញ ។ នៅត្រង់នេះការពិនិត្យឯកសារដែលបានសិក្សាមុនៗមានសារៈប្រយោជន៏ ពីព្រោះអត្ថន័យដែលទាញបានពីលទ្ធផលរកឃើញមានការទាក់ទងនឹងអ្វីដែលគេដឹងហើយឬមិនដឹងនាំអោយគេគិតគូររកជំរើសថ្មីនៅក្នុងការគិតគូរពីប្រធានបទនៃការសិក្សាស្រាវជ្រាវ ។ ការបង្ហាញបញ្ហាជាប់ពាក់ព័ន្ធ (Implication) តាមទ្រឹស្តីកត់សំគាល់ ដំណើរការស្រាវជ្រាវទាំងមូល ហើយថ្លឹងថ្លែងចំណុចខ្វះខាតរបស់វា ។ ការនេះមានតំលៃសំរាប់អ្នកស្រាវជ្រាវផ្សេងទៀត នៅពេលគេគ្រោងរៀបចំការស៊ើបអង្កេត ដែលអាចនាំទៅដល់ (ក) ចំលើយច្បាស់លាស់ដល់សំណួរស្រាវជ្រាវឬ (ខ) វិធានការណ៏

ដែលជំនះលើកំហិតព្រំដែនផ្នែកវិធីសាស្ត្រដែលធ្វើដោយការសិក្សាស្រាវជ្រាវ ។ ពិតណាស់ថា វាមានប្រយោជន៏បើគេលើកបង្ហាញជាផ្នែកមួយនៃភាពពាក់ព័ន្ធជាទ្រឹស្តីនូវទស្សនៈរបស់គេស្តីពីវិធីដែលលទ្ធផលរកឃើញរបស់ការស្រាវជ្រាវអាចត្រូវបានពង្រឹងនៅពេលអនាគត ដោយប្រភេទណាមួយនៃការស្រាវជ្រាវថែមទៀត ។

បញ្ហាជាប់ពាក់ព័ន្ធទាំងនេះ អាចត្រូវបានលើកឡើងនៅពេលណាក៏បាននៅក្នុងការពិភាក្សាលើលទ្ធផលរកឃើញនៅពេលដែលមានលំនាំអ្វីមួយលេចធ្លោឡើងក្នុងពេលធ្វើការភ្ជាប់ទំនាក់ទំនងនៃការសង្កេត ។ ជាពិសេស វាពិតជាកើតមានដោយសារនៅក្នុងដំណើរការនៃការពិភាក្សាលទ្ធផលរកឃើញ ការគិតគូររបស់អ្នកស្រាវជ្រាវ មានទាក់ទងទៅនឹងសំណួរស្រាវជ្រាវ និងគិតទៅដល់ចំលើយដែលត្រូវយកទៅបង្ហាញ ដើម្បីឱ្យមានភាពខុសប្លែកគ្នា (តាមរយៈគោលនយោបាយការផ្លាស់ប្តូរក្នុងកម្មវិធី ។ល។) បញ្ហាដែលកំពុងវិភាគ ។ តែរឿងនេះមិនសូវកើតមានទេ ចំពោះបញ្ហាពាក់ព័ន្ធនឹងទ្រឹស្តី ដោយសារគេច្រើនតែយកមកបញ្ជាក់នៅក្នុងសេចក្តីសន្និដ្ឋានរបស់អ្នកស្រាវជ្រាវ ពីព្រោះភាពជាប់ពាក់ព័ន្ធផ្នែកទ្រឹស្តីតំរូវអោយមានការឆ្លុះបញ្ចាំងលើភស្តុតាង/លទ្ធផលរកឃើញសំខាន់ៗជារួម (ដោយរួមទាំងដំណើរការស្រាវជ្រាវផង) និងការទាញភ្ជាប់ទៅនឹងក៏រិតទស្សនៈដែលមានលក្ខណៈជាអរូបីយ ដើម្បីអោយមានភាពប្រហាក់ប្រហែលគ្នា និងអាចចូលទៅក្នុងក្របខ័ណ្ឌទ្រឹស្តី ។

## រូបទី ១៧. ឧទាហរណ៍នៃវិធីទាញយកនូវបញ្ហាដែលពាក់ព័ន្ធ (Example of how to draw out implications)

សំណួរស្រាវជ្រាវ : តើកត្តា/តួអង្គអ្វីដែលបានរួមចំណែកអោយមានជោគជ័យ បញ្ហានិង/ឬបរាជ័យនៃគំរោងបែងចែកដីធ្លី?a/

| ចំណុចសំខាន់ៗ | លក្ខណៈដូចគ្នា/មិនដូចគ្នាទៅនឹងស្ថានភាពធម្មតា | ទាមទារ ការពន្យល់ (បាទ/ចាស៎ ឬទេ) | តើការពន្យល់មានអ្វីខ្លះ? | បញ្ហាដែលពាក់ព័ន្ធសំរាប់គំរោងបែងចែកដីនៅពេលអនាគត |
|---|---|---|---|---|
| ១. អ្នកទទួលផលពីគំរោងបែងចែកដីធ្លីនៅសៀមរាប រួមមានមនុស្សពិការ មេម៉ាយ ជនមាតុភូមិនិវត្តន៍ និងប្រជាជនក្រីក្រអ្នកគ្មានដី ។ | - វិស័យដែលមិនមានប្រយោជន៍នេះគឺគោលដៅនៃគំរោងអភិវឌ្ឍសហគមន៍នៅក្នុងប្រទេសកម្ពុជា និងកន្លែងដទៃ ។ | ទេ | - | - |
| ២.គំនិតផ្តួចផ្តើម និងការជួយរបស់អង្គការមិនមែនរដ្ឋាភិបាលច្រើន ដោយរួមមានការជួយពេញលេញរបស់អង្គការ CONCERN នៅក្នុងចំណោមអ្នកទទួលផលនៅក្នុងគំរោងបែងចែកដីធ្លីឃើញថាគឺ ជាកត្តារួមចំណែកដល់ជោគជ័យនៃគំរោងបែងចែកដីធ្លីនៅសៀមរាប ។ | - ស្ថានភាពនេះមិនខុសគ្នានឹងស្ថានភាពនៅកោះគរ នៅខេត្តកណ្តាល ដែលនៅទីនោះនារីអ្នកទទួលផលពីគំរោងផ្តល់ទីជំរក Hagar ត្រូវបានគេផ្តល់ឱ្យដីភូមិមួយចំណែក ។ | បាទ/ចាស៎ | វត្តមានរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងតំបន់ផ្តល់ជាប្រយោជន៍ដល់អ្នកទទួលផលតាមរបៀបច្រើនយ៉ាង: អង្គការកម្មវិធីស្បៀងអាហារពិភពលោកកសាងផ្លូវល្អដល់សហគមន៍ អង្គការ AGRISUD ផ្តល់ជំនាញបច្ចេកទេសកសិកម្ម ផ្តល់សំភារៈ (ដូចជាគ្រាប់ពូជ) និងអ្នក បច្ចេកទេសក្នុងស្រុក ។ អង្គការ CONCERN ជួយឱ្យមានការបែងចែកដីធ្លី ជួយគេឱ្យទទួលបានប័ណ្ណកម្មសិទ្ធិលើដីផ្តល់សំភារៈសាងសង់ផ្ទះ ធ្វើប្រឡាយស្រោចស្រប់ ។ល ។ | - អង្គការមិនមែនរដ្ឋាភិបាល អាចដើរតួជាអ្នកជំរុញធ្វើអោយគំរោងបែងចែកដីធ្លីមានប្រសិទ្ធិភាព ។<br>- ទោះបីជាអង្គការមិនមែនរដ្ឋាភិបាល អាចរួមចំណែកបានខ្លាំងក្លាដល់ជោគជ័យរបស់កម្មវិធីក៏ដោយ តែអាចនាំឱ្យអ្នកទទួលផលមានចិត្តចាំតែពឹងពាក់គេ ។ |
| ៣. ជោគជ័យនៅក្នុងគំរោងបែងចែកដីធ្លីអាចបានមកពីស្មារតីម្ចាស់ការទទួលខុសត្រូវរបស់ប្រជាជននៅក្នុងដំណើរការនៃការបែងចែកដីធ្លី ។ | - បទពិសោធន៍នៅក្នុងការអភិវឌ្ឍមូលដ្ឋានចង្អុលឱ្យគេឃើញនូវដំណើរការបែបផែនមួយនៅពេលដែលប្រជាជនចូលរួមយ៉ាងសកម្មនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃសកម្មភាព សិទ្ធិ កាន់កាប់ដីធ្លីមានភាពខ្លាំង (Burkey, 1993:63) | បាទ/ចាស៎ | - អ្នកទទួលផលស្ទើរតែទាំងអស់អាចជ្រើសរើសដីរបស់គេ (៩១%) ហើយទាំងអស់គ្នាបានចូលរួមនៅក្នុងដំណើរការបែងចែកដីធ្លី ។ ក្រៅពីនេះ មាន ៧៨%ដែលរីករាយនឹងគំរោងបែងចែកដីធ្លី ។ | - គំរោងបែងចែកដីធ្លីអាចកាន់តែមានប្រសិទ្ធិភាពច្រើន បើប្រជាជនចូលរួមនៅក្នុងដំណើរការទាំងមូល ។<br>- ការប្រើប្រាស់ដីសំរាប់ធានាជីវភាពគ្រួសារ និងស្ថេរភាពគ្រួសារអាចធានាបាននូវទៅមុខ |

a/ នេះជាឧទាហរណ៍មាននៅក្នុងឯកសារនៃវគ្គជាន់ខ្ពស់របស់ ADI/សិក្ខាសាលាដែលបានរៀបចំជាបន្តបន្ទាប់ ពីខែ កក្កដា ដល់ ខែ កញ្ញា ឆ្នាំ ២០០១ (ភ្នំពេញ) ។ នៅពេលនោះនាសិក្ខាកាមចូលរួមធ្វើដោយផ្ទាល់នៅក្នុងការងារស្រាវជ្រាវស្តីពី *ការបែងចែកដីធ្លីក្នុងប្រព័ន្ធក្រោយជម្លោះនៅកម្ពុជា: មេរៀនពីករណីសិក្សាចំនួនបី* ហើយត្រូវបានបោះពុម្ពនៅក្រោមចំណងជើងដូចគ្នានោះ ។

## ជំហ៊ានទី ៦: ការរៀបចំសេចក្តីសន្និដ្ឋាន

ទាញយកសេចក្តីសន្និដ្ឋានពីលទ្ធផលរកឃើញ ........ ១២៩
រៀបចំសេចក្តីសន្និដ្ឋានរបស់ការស្រាវជ្រាវទាំងមូល ........ ១៣១

# ជំហ៊ានទី៦ : ការរៀបចំសេចក្តីសន្និដ្ឋាន

*ទាញការសន្និដ្ឋានពីលទ្ធផលរកឃើញរបស់ការស្រាវជ្រាវ.... រៀបចំសេចក្តីសង្ខេបនៃលទ្ធផលរកឃើញ... បំផុសគំនិតគ្នាទាញការសន្និដ្ឋាន....... ទាញការសន្និដ្ឋានពីលទ្ធផលរកឃើញនៃការស្រាវជ្រាវ......*

| ជំហ៊ានទី ៦ |
| --- |
| កំណត់ចំណុចសំខាន់/ចំណុចវិភាគ |
| |
| |
| |

| រៀបចំសេចក្តីសន្និដ្ឋាន |
| --- |
| *ដោយផ្អែកលើទំនាក់ទំនងដែលត្រូវបានកំណត់ហើយដែលត្រូវបានសង្កេតឃើញរវាងចំណុច/លំនាំសំខាន់ៗនៅក្នុងលទ្ធផលរកឃើញ តើគេអាចធ្វើសេចក្តីប្រកាសរួមយ៉ាងដូចម្តេចទៅនឹងសំណួរស្រាវជ្រាវ?* |

## ទាញយកសេចក្តីសន្និដ្ឋានពីលទ្ធផលរកឃើញ (Deriving conclusions from Research Findings)

ការទាញសេចក្តីសន្និដ្ឋានពីលទ្ធផលរកឃើញក្នុងការស្រាវជ្រាវមានន័យថា ធ្វើការប្រកាសរួមនៃសេចក្តីបញ្ជាក់ដែលមានការទាក់ទងគ្នារវាងលំនាំ ឬអថេរ/ធាតុពីរ ឬច្រើនដែលកំពុងតែត្រូវបានវិភាគ។ ដូចដែលបានកត់សំគាល់ពីមុនមក សេចក្តីបញ្ជាក់របស់អ្នកស្រាវជ្រាវអាចជាវិជ្ជមាន ឬអវិជ្ជមាន។ អថេរបានគេនិយាយថា មានការទាក់ទងគ្នាជាវិជ្ជមាន នៅពេលដែលកំណើនក្នុងលទ្ធផលមួយ នាំឱ្យមានកំនើនក្នុងលទ្ធផលមួយទៀត។ ដេ ាយរំលឹកឡើងវិញពីឧទាហរណ៏នៃការសិក្សាស្រាវជ្រាវនៅឆ្នាំ ២00៤ របស់ CCC-ADI ស្តីពីអំពើហិង្សាក្នុងគ្រួសារ ការចូលរួមបែបវិជ្ជមាននេះ ត្រូវបានបង្ហាញដោយការរកឃើញបញ្ហាងាយនឹងកើតមាន នៅពេលដែលប្តីបញ្ចេញអាកប្បកិរិយាបែបត្រួតត្រា។ តែទំនាក់ទំនងផ្ទុយពីនេះមាននៅពេលកំនើននៅក្នុងអថេរមួយនាំឱ្យមានអត្រាថយចុះនៃអថេរទីពីរ។ គេឃើញមានចំណុចនេះនៅក្នុងការសិក្សាដដែលនោះ ដែលបញ្ហាត្រូវបានគេសង្កេតឃើញថាមិនងាយនឹងកើតមាននៅពេលប្រពន្ធអាចចូលរួមបានច្រើននៅក្នុងការសំរេចចិត្តនៅក្នុងគ្រួសារ។

ការវិភាគបន្ទាប់មកទៀតលើទិន្នន័យតាមរយៈការប្រៀបធៀបការតាមដានមើល ឬការកំណត់ហេតុ និងផលនៅក្នុងចំណោមអថេរនានា ធ្វើឱ្យអ្នកស្រាវជ្រាវអាចកសាងលំនាំមួយចំនួនដែលនាំទៅរកសេចក្តីសន្និដ្ឋានមួយចំនួន។ នៅក្នុងការសិក្សានេះ ស្តីពីអំពើហិង្សាក្នុងគ្រួសារ សេចក្តីសន្និដ្ឋានគូសបញ្ជាក់ថា "ទន្ទឹមនឹងកត្តាបុគ្គល ដែលបានធ្វើឱ្យស្ត្រីងាយរងគ្រោះនឹងអំពើហិង្សា កត្តាវប្បធម៌ និងសង្គម និងស្ថាប័នសង្គម ក៏មានចំណែកសំខាន់ នៅក្នុងការធ្វើឱ្យកើតមានអំពើហិង្សាជាបន្តបន្ទាប់ដែរ"។ សេចក្តីបញ្ជាក់ចុងក្រោយនេះ ក៏ត្រូវបានពិនិត្យមើល ដោយក្រុមអ្នកស្រាវជ្រាវផងដែរ។

គេមិនឈប់ត្រឹមនេះ ហើយក៏មិនទាញការសន្និដ្ឋានដោយផ្អែកតែលើការសង្កេតតែមួយមុខទេ ។ នៅក្នុងដំណើរការនេះ គេត្រូវការមើលធាតុសំខាន់ៗ និងរកសេចក្តីបញ្ជាក់ទាំងឡាយណាដែលនាំអោយបង្កើតបានជាធាតុសំខាន់ៗនោះឡើង ធ្វើការភ្ជាប់ទំនាក់ទំនងបន្ថែមទៀត និង "អាន" លំនាំ/និន្នាការដែលមានលេចចេញមក ។ ទោះជាយ៉ាងណាក្តី គេត្រូវយកចិត្តទុកដាក់ក្នុងការធ្វើសេចក្តីសន្និដ្ឋានដោយយោងតាមអ្វីដែលមានភាពជាក់លាក់ ។ នៅពេលណាចាំបាច់ អ្នកស្រាវជ្រាវគួរបញ្ជាក់ពីទំនាក់ទំនងនៃលក្ខខ័ណ្ឌ ឬស្ថានភាពជាក់ស្តែងពីមូលដ្ឋានទៅនឹងអថេររបស់គាត់ដែលបានកំណត់ ហើយពន្យល់អំពីស្ថានភាពជាក់ស្តែងថាតើវាអាចជួយកំណត់ឡើងវិញទៅលើនិន្នាការដែលបានសង្កេតឃើញបែបណាខ្លះ ។ ការពិនិត្យឯកសារសិក្សាមុនៗ ឬទស្សនៈខាងទ្រឹស្តីដែលពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវ ក៏មានសារៈសំខាន់ ពីព្រោះវាអាចពង្រឹងនូវការលើកឡើងនៅក្នុងផ្នែកការសន្និដ្ឋាន ។

នៅក្នុងការធ្វើសន្និដ្ឋានអំពីលទ្ធផលរកឃើញ អ្នកស្រាវជ្រាវគួរកុំលើកឡើងជាលក្ខណៈទូទៅពេក ពីព្រោះលទ្ធផលរកឃើញខ្លះអាចពិតចំពោះតែមនុស្សមួយក្រុមណាមួយដែលគេបានសិក្សា ពិសេសបើការសិក្សានោះ មានធ្វើតែតាមតំបន់កំណត់ច្បាស់លាស់ ហើយដែលមិនតំណាងអោយមនុស្សទូទៅដែលទាក់ទងនឹងបញ្ហាស្រាវជ្រាវ នោះ ។ ដូចគ្នានេះដែរអ្នកស្រាវជ្រាវគួរជៀសវាងការពន្យល់ជ្រុល ឬបណ្តែតបណ្តោយតាមលំនាំដែលគាត់សង្កេត ពីព្រោះគាត់អាចនឹងលើកឡើងដោយអចេតនានូវបញ្ហាដែលមិនមានការបញ្ជាក់ដោយទិន្នន័យ ឬមិនត្រូវបានគេលើកឡើងនៅក្នុងការសិក្សាស្រាវជ្រាវ ។ ធ្វើការជាមួយនឹងសមាជិកក្រុមស្រាវជ្រាវ (ឬគិតគូរជាមួយនឹងសហការី) ដើម្បីឈានដល់ការធ្វើការសន្និដ្ឋាន គឺមានប្រយោជន៍ជានិច្ច ពីព្រោះគេអាចមើលឃើញវិធីផ្សេងខុសៗគ្នានៅក្នុងការពិនិត្យមើលលំនាំតែមួយដដែល និងចំណុចខ្លះដែលអ្នកស្រាវជ្រាវម្នាក់អាចមើលមិនឃើញ ។

ជាសង្ខេបមក ប្រការដែលគួរធ្វើ និងមិនគួរធ្វើនៅក្នុងការធ្វើសេចក្តីសន្និដ្ឋានពីលទ្ធផលរកឃើញនៅក្នុងការស្រាវជ្រាវគឺៈ

| **អ្វីដែលគួរធ្វើ** | **អ្វីដែលមិនគួរធ្វើ** |
|---|---|
| ពិនិត្យធាតុសំខាន់ៗ ឬអថេរមួយចំនួន មុននឹងធ្វើការសន្និដ្ឋាន ។ ការសង្កេតតែមួយមិនអាចឱ្យគេធ្វើការសន្និដ្ឋានបានទេ ។<br>កុំធ្វើការអះអាងដោយលក្ខណៈទូទៅពេក ជាពិសេសបើការសិក្សាស្រាវជ្រាវមានធ្វើតែតំបន់ជាក់លាក់ណាមួយ ។<br>ប្រៀបធៀបនិន្នាការដែលជាធាតុសំខាន់នៃការសន្និដ្ឋានជាមួយនឹងឯកសារ ឬចំណេះដឹងស្តីពីបញ្ហាដែលកំពុងតែត្រូវបានពិនិត្យ ។ | កុំឃើញតែសេចក្តីបញ្ជាក់ហើយជឿភ្លាមនោះ-ចូរធ្វើការឆ្លុះបញ្ចាំងលើកត្តាដទៃទៀតដែលអាចជួយដល់ការកំណត់លំនាំ/និន្នាការដែលត្រូវបានសង្កេតនោះ ។<br>មិនត្រូវការពន្យល់ច្រើនពេកទេ ព្រោះការពន្យល់ច្រើនពេកអាចនាំឱ្យកើតមានចំងល់អំពី កង្វះទិន្នន័យ ឬពត៌មានផ្សេងទៀត ដែលមិនបានធ្វើអង្កេតសោះ ។ |

## ការរៀបចំសេចក្ដីសន្និដ្ឋាននៃការស្រាវជ្រាវទាំងមូល
(Arriving at the Research Study’s Conclusions)

សេចក្ដីសន្និដ្ឋានរបស់អ្នកស្រាវជ្រាវ ជាទូទៅគឺជាសេចក្ដីបូកសរុបនិងជាសេចក្ដីបញ្ជាក់ចុងក្រោយរបស់ គាត់អំពីភាពស៊ីគ្នា (ឬកង្វះភាពស៊ីគ្នា) នៃលទ្ធផលរកឃើញរបស់គាត់ជាមួយនឹង (ក) ទំនាក់ទំនងតាមសម្មតិកម្ម ដែលមានបង្ហាញនៅក្នុងសំណួរស្រាវជ្រាវរបស់គាត់ ឬ (ខ) ជាមួយនឹងអ្វីដែលគាត់មានបំណងធ្វើដូចដែលបានបញ្ជាក់នៅក្នុងគោលបំណងស្រាវជ្រាវរបស់គាត់ ។ តាមពិតទៅសេចក្ដីសន្និដ្ឋានពិនិត្យមើលឡើងវិញដោយខ្លីនូវអ្វី ដែលការសិក្សាស្រាវជ្រាវប៉ងធ្វើអ្វីដែលត្រូវបានរៀនសូត្រ និងបញ្ហាថ្មីអ្វីខ្លះដែលត្រូវបានលើកឡើង (Wolcot, 1990:56) ។

សេចក្ដីសន្និដ្ឋាននៃការសិក្សាស្រាវជ្រាវតាមធម្មតាចាប់ផ្ដើមដោយសេចក្ដីសង្ខេបនៃលទ្ធផលរកឃើញ ។ ការបង្ហាញសេចក្ដីសង្ខេប ធ្វើឱ្យអ្នកស្រាវជ្រាវពិនិត្យអ្វីដែលត្រូវបានធ្វើទាក់ទងនឹងសេចក្ដីបញ្ជាក់ពីបញ្ហា/សំណួរស្រាវជ្រាវ និងគោលបំណងនៃការសិក្សាស្រាវជ្រាវ ។ វាថែមទាំងផ្ដល់ឱកាសឱ្យគេអាចគិតប្រមាណជាមុនទៅលើប្រតិកម្ម ដោយចង្អុលបង្ហាញនូវចំណុចខ្វះខាតរបស់ការសិក្សាស្រាវជ្រាវ និងវិធីសាស្ត្រអាចត្រូវបានកែលំអបាននៅពេលក្រោយ ។ តែមិនមែនគ្រប់គ្នារៀបចំសេចក្ដីសង្ខេបទេ តែបើគេចាប់យកតាមវិធីនេះ វាជាការ មានប្រយោជន៍ បើគេសរសេរសេចក្ដីសង្ខេបខ្លីៗនៅក្នុងរបាយការណ៍ស្រាវជ្រាវទាំងមូល (ពោលគឺតាមរយៈសេចក្ដីសង្ខេបតាមផ្នែក) ពីព្រោះការនេះជួយឱ្យគេអាចឈ្វេងយល់បាន តាមរយៈសេចក្ដីដែលគេពិភាក្សាតាមផ្នែកនិមួយៗនិងដើម្បីធ្វើឱ្យអ្នកស្រាវជ្រាវ និងអ្នកអានអាចផ្ដោតការយកចិត្តទុកដាក់ ។ សេចក្ដីសង្ខេបខ្លីៗទាំងនេះ ថែមទាំងសំរាលបន្ទុកលើការរៀបចំសេចក្ដីសង្ខេបជារួមនៃលទ្ធផលរកឃើញ ។

ដូចគ្នានឹងការផ្ដល់ការសន្និដ្ឋានពីលទ្ធផលរកឃើញនៃការស្រាវជ្រាវរបស់គេដែរ ការសំរេចចេញសេចក្ដីបញ្ជាក់នៅចុងបញ្ចប់នៃការសិក្សាស្រាវជ្រាវ ជាពិសេសទាក់ទងនឹងអ្វីដែលត្រូវបានរៀនសូត្រមកគឺមានបំណងឱ្យក្រុមអ្នកស្រាវជ្រាវអាចធ្វើការរួមគ្នានៅក្នុងការចេញសេចក្ដីអះអាងរួមគ្នាអំពីចំលើយចំពោះសំណួរ និងគោលបំណងស្រាវជ្រាវ និងអំពីវិធីដែលគេអាចធ្វើឱ្យអ្នកអានយកចិត្តទុកដាក់គិតមកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ និងអាចបោះជំហានទៅមុខទៀត ។ ក្រុមអាចជ្រើសរើសក្នុងការសង្ខេបពីរ ឬបីកឋាខ័ណ្ឌក្នុងចំលើយនៃការស្រាវជ្រាវទៅនឹងសំណួរស្រាវជ្រាវនៅក្នុងបរិបទ នៃព្រំដែនកំណត់នៃការសិក្សាស្រាវជ្រាវ និងដើម្បីបញ្ជាក់ជាថ្មី នូវទស្សនៈយល់ឃើញជាទ្រឹស្ដីដែលការសិក្សាជំរុញ និង វិធីដែលលទ្ធផលរកឃើញបញ្ជាក់ ឬបដិសេធរបៀបជាធម្មតាមកនៃការប្រមើលមើលទៅបញ្ហានៃការសិក្សាស្រាវជ្រាវ ឬផ្ដល់វិធីថ្មីៗនៅក្នុងការគិតគូរពីរឿងហ្នឹង ។

គ្រោះថ្នាក់មួយដែលគេគួរជៀសវាងគឺ ការវាយតំលៃជាលក្ខណៈទូទៅក្នុងក្រុមធំទៅលើប្រជាពលរដ្ឋទូទៅ នៅពេលដែលសំណាកមានកំរិតកំណត់ ហើយនិងមិនតំណាងឱ្យទិដ្ឋភាពរួម ។ ជំនួសឱ្យការស្នើឡើងក្នុងផ្ដល់អនុសាសន៍សំរាប់ចំលងតាមការសិក្សាស្រាវជ្រាវបែបនេះម្ដងទៀត ត្រូវផ្ទៀងផ្ទាត់មើលភាពអាចយកទៅអនុវត្តបាន ក្នុងលក្ខខ័ណ្ឌប្រហាក់ប្រហែលគ្នា ឬខុសគ្នាបន្តិចបន្តួច ។ គេគួរជៀសវាងការប្រាប់ ឬបញ្ហាដែលមិនត្រូវបញ្ជាក់ដោយទិន្នន័យ ឬដែលមិនបានលើកយកមកដោះស្រាយដោយអ្នកស្រាវជ្រាវ ។ ការនេះអាចកើតមាននៅពេលអ្នកស្រាវជ្រាវបណ្ដែតបណ្ដោយទៅតាមការនឹកឃើញដែលចង់ឱ្យមានទីបញ្ចប់មួយ ធ្វើឱ្យមានការភ្ញាក់ផ្អើលដែលមិនជាការចាំបាច់ ។ សេចក្ដីសន្និដ្ឋានរបស់ការសិក្សាស្រាវជ្រាវ គឺជាការព្យាយាមថ្លែងនូវការបិទចុងក្រោយ និងខណៈនោះផ្ដល់លទ្ធភាពដល់អ្នកមានមតិ ឬតំលៃរបស់អ្នកស្រាវជ្រាវអាចឈានដល់ការបកស្រាយ ។ គេគួររក្សាឱ្យមានភាពបើកទូលាយសំរាប់ការបកស្រាយដទៃទៀតទៅលើសេចក្ដីសន្និដ្ឋាន ។

# ជំហានទី ៧ : ការរៀបចំអនុសាសន៍

ការកំណត់រកអនុសាសន៍ .......... ១៣៥
រៀបចំកំណត់បញ្ហាដែលពាក់ព័ន្ធ .......... ១៣៧

# ជំហានទី៧ : ការរៀបចំអនុសាសន៍

*"អានឡើងវិញ" នូវការវិភាគលើលទ្ធផលរកឃើញ....ចែកឱ្យដាច់ពីគ្នារវាងចំលើយចំពោះផលប៉ះពាល់នៅកំរិតមីក្រូ និងមូលហេតុនៅកំរិតម៉ាក្រូ....សរសេរដំណោះស្រាយដែលបានកំណត់ឱ្យទៅជាអនុសាសន៍..*

| ជំហានទី ៧ |
|---|
| កំណត់ចំណុចសំខាន់/ចំណុចវិភាគ |
| |
| |
| |

| បង្កើតអនុសាសន៍ |
|---|
| ជាមួយនឹងការសន្និដ្ឋាន តើអ្នកអានត្រូវធ្វើយ៉ាងដូចម្តេចទៀត? |

## ការកំណត់រកអនុសាសន៍ (Deriving the Recommendations)

ជាធម្មតា អនុសាសន៍ភាគច្រើនទាញបានពីសេចក្តីសន្និដ្ឋាន ដែលឆ្លើយទៅនឹងសំណួរថា "យ៉ាងម៉េចទៅ?" ជាពិសេសបើការសិក្សាផ្តោតលើការប្រតិបត្តិការនៃការអភិវឌ្ឍសង្គម ឬសកម្មភាពសង្គម ។ ប៉ុន្តែមិនមែនជាលក្ខខ័ណ្ឌទាមទារទេ ដូច្នេះអ្នកស្រាវជ្រាវអាចមានជំរើសងាយៗមកបញ្ជាក់ក្នុងការសិក្សានេះក៏បានដែរ ជាជាងដាក់ចេញនូវដំណោះស្រាយ ឬគោលការណ៍ណែនាំស្តីពីរបៀបឆ្លើយតបទៅនឹងបញ្ហាដែលបានរកឃើញនៅក្នុងការសិក្សា ។ ការសំរេចចិត្តក្នុងការអ្នកប្រើប្រាស់ ភាពជាប់ពាក់ព័ន្ធទៅលើប្រភេទ និងគោលបំណងនៃការសិក្សារបស់អ្នកប្រើប្រាស់/អ្នកស្តាប់ និងរបៀបប្រើ ឬការចោទសួររបស់អ្នកស្រាវជ្រាវ (ឧទាហរណ៍ ការតស៊ូមតិ ទីប្រឹក្សាពិគ្រោះយោបល់ រួមចំណែកការសង្កេត ផ្តល់យោបល់) (Wolcott, 1990:58) ។

អនុសាសន៍ គឺជាលទ្ធផលដែលកើតចេញមកពីការវិភាគរបស់អ្នកស្រាវជ្រាវ ហើយអ្នកប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវ ច្រើនតែទន្ទឹងរង់ចាំចំលើយពីអ្នកស្រាវជ្រាវ ។ អ្នកទន្ទឹងរង់ចាំលទ្ធផល រមែងតែងតែមិនបានទទួលអ្វីដែលរំពឹងទុកនោះទេ ដូច្នេះគេអាចពិនិត្យទៅតាមប្រការណាមួយ ឬប្រការច្រើនរួមគ្នាដូចខាងក្រោមនេះ (Wolcot, 1990:59-60) :

- ចង្អុលបង្ហាញនូវអ្វីដែលគាត់មិនយល់ ឬហាក់ដូចជាការកំណត់មិនច្បាស់ វាអាចធ្វើឱ្យយើងបង្ហាញនូវភាពមិនច្បាស់លាស់ក្នុងបញ្ហាដែលកំពុងវិភាគ ។
- កំណត់រកមតិផ្ទុយ (Paradox) ឬលើកឡើងនូវករណីនៅពេលដែលគេធ្វើតាមវិធីនៃសំណាករបស់ការសិក្សាស្រាវជ្រាវនាំឱ្យមានផលខុសគ្នា ឬពេលខ្លះផ្ទុយគ្នាទៅនឹងអ្វីដែលគេបានប៉ងចង់បានមក ។
- កំណត់រកមើលជំរើសផ្សេងជំនួសឱ្យការប្រតិបត្តិបច្ចុប្បន្ន (ឬដំណោះស្រាយទៅលើបញ្ហាចំពោះមុខ) ដែលទទួលខុសត្រូវសកម្មភាព ឬអ្នកដែលរងការប៉ះពាល់ដោយទង្វើនោះ នៅពេលពិនិត្យលើផលវិបាកវាជាជំរើសមួយ ។ តាមជំនាញនៃការវិភាគរបស់អ្នកសាវជ្រាវមិនមែនគ្រាន់តែជាប្រភពធនធានសំរាប់អ្នកអានប៉ុណ្ណោះទេ ថែមទាំងអាចជាគំរូសំរាប់គេនៅក្នុងការធ្វើការអង្កេតស្វែងយល់ដោយខ្លួនគេផង ។

ប្រហែលជាជំហ៊ានមួយសំខាន់ក្នុងការកំណត់រកអនុសាសន៍គឺ ជាដំបូងគេត្រូវវិលត្រឡប់ទៅរកមើលផ្នែកផ្សេងៗនៃរបាយការណ៍ដែលបានការពិភាក្សានូវលទ្ធផលរកឃើញ ព្រោះថាផ្នែកនីមួយៗអាចបង្ហាញពីបញ្ហាជាប់ពាក់ព័ន្ធទៅនឹងនិន្នាការដែលលេចឡើង។ ដូចបានកត់សំគាល់ពីមុនមក បញ្ហាជាប់ពាក់ព័ន្ធតែងតែផ្សាភ្ជាប់ជាមួយសំណូមពរ និងមានជំរើសសំរាប់ដោះស្រាយបញ្ហាដែលលើកឡើងដោយអ្នកស្រាវជ្រាវ។ ដោយបានកត់សំគាល់បញ្ហាជាប់ពាក់ព័ន្ធទាំងនេះ អ្នកស្រាវជ្រាវអាចពិនិត្យមើលថាតើបញ្ហាពាក់ព័ន្ធទាំងនេះត្រូវដាក់តាមក្រុម និងចាត់ជាចំណាត់ក្រុមដែលមានអត្ថន័យខុសៗគ្នា ដើម្បីធ្វើជាអនុសាសន៍មួយ ឬច្រើនចំណុច។ វាមានប្រយោជន៍ផងដែរ គេគួរតែត្រឡប់ទៅមើលការវិភាគបែបដ្យាក្រាម (ឧទាហរណ៍ដូចជាដ្យាក្រាមស្តីពីហេតុនិងផល) ដើម្បីទាញបាននូវដំណោះស្រាយដែលមានលក្ខណៈទាក់ទង និងស្ថានភាព/បញ្ហាដែលកំពុងលើកឡើង។ អត្ថប្រយោជន៍ក្នុងការអង្គុយជាមួយនឹងក្រុមអ្នកស្រាវជ្រាវ និងអ្នកពាក់ព័ន្ធដទៃទៀតជាប្រការសំខាន់ណាស់ពីព្រោះថាវាអាចនាំមក នូវគំនិតប្លែកៗទាក់ទងទៅនឹងការបង្កើតអនុសាសន៍ ។

ចំណុចសំខាន់ដែលត្រូវពិចារណាមួយចំពោះការផ្តល់អនុសាសន៍ គឺទាក់ទងនឹងលំដាប់ថ្នាក់នៃលទ្ធភាពនៃការឆ្លើយតប។ បើនិយាយឱ្យចំគឺ អ្នកស្រាវជ្រាវគួរចែកឱ្យដាច់ស្រឡះពីគ្នារវាងចំលើយទៅនឹងបញ្ហាដែលជាលក្ខណៈមីក្រូ ដែលចេញមកពីបុព្វហេតុម៉ាក្រូ (ឧទាហរណ៍ ការផ្លាស់ទីលំនៅគ្រួសារដោយសារគំរោងមួយរបស់រដ្ឋាភិបាលដូចជា ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការហូរចូលនៅក្នុងតំបន់ទំនាបទៅកាន់ខេត្តរតនៈគីរី ដោយសារធ្លាក់ចុះនៃព្រៃឈើសម្បទាន ការចាប់ផ្តើមធ្វើចំការបែបឧស្សាហកម្ម គំរោងវារីអគ្គិសនីនៅក្បែរនោះដែលត្រូវជំលៀសចេញ និងអាចប៉ះពាល់ដល់សហគមន៍ជនជាតិ[២៨]) និងដំណោះស្រាយនៅលំដាប់ថ្នាក់ម៉ាក្រូដោយសារបុព្វហេតុដូចគ្នានេះ។ ដូច្នេះអនុសាសន៍អាចខុសគ្នាសំរាប់គ្រួសារក្រុមងាយរងគ្រោះ សហគមន៍ដែលទទួលរងនូវការប៉ះពាល់ និងសំរាប់អាជ្ញាធរថ្នាក់ខេត្តនិងជាតិ ឬរួមទាំងពីរតែម្តង (ឧទាហរណ៍ការតស៊ូមតិ)។ ឱកាសនេះហើយគេយល់ថាការយកដ្យាក្រាមហេតុ និងផលមកប្រើប្រាស់អាចមានប្រយោជន៍ ដើម្បីឱ្យអ្នកស្រាវជ្រាវ អាចកំណត់រកនូវអនុសាសន៍ដែលមានភាពប្រាកដនិយម។

គោលការណ៍ណែនាំផ្សេងទៀតនៅក្នុងការរៀបចំអនុសាសន៍ ជាពិសេសបើការសិក្សាផ្តោតលើការងារ អភិវឌ្ឍន៍សង្គម ឬសកម្មភាពសង្គម គឺមានដូចខាងក្រោមនេះ :

- រៀបចំដំណោះស្រាយដែលទាក់ទងនឹងតួអង្គជាក់ស្តែង និងតួអង្គនៅពេលអនាគត (ឧទាហរណ៍ អង្គការមិនមែនរដ្ឋាភិបាល មន្ត្រីអាជ្ញាធរមូលដ្ឋាន សហគមន៍ និងគ្រួសារដែលទទួលរងនូវការប៉ះពាល់) ដោយចាំទុកនូវអាណត្តិខុសគ្នារបស់គេ ហើយនិងឧបសគ្គរួមទាំងចំលើយដែលអាចមាននៅតាមលំដាប់ថ្នាក់ផ្សេងៗនៃអង្គការទាំងនេះ។
- ពិនិត្យឡើងវិញលើទិន្នន័យមិនទាន់ច្នៃ (Raw data) ហើយរកសេចក្តីស្នើយោបល់ពីអ្នកដែលបានសំភាសន៍ ឬដំណោះស្រាយដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រដោះស្រាយបញ្ហាដែលមានស្រាប់។
- ពិនិត្យឡើងវិញនូវដំណោះស្រាយតាមវិស័យដែលមាន (កសិកម្ម ឥណទាន) និងវិធីធ្វើការកែលំអរ។
- រៀបចំដំណោះស្រាយច្រើនយ៉ាងតែមានភាពស៊ីគ្នាសំរាប់រយៈពេលខ្លី និងពេលវែង-ឧទាហរណ៍ ការលើកកំពស់ការយល់ដឹង/ការតស៊ូមតិ ការរៀបចំសហគមន៍ ការបណ្តុះបណ្តាលជំនាញ និងសកម្មភាពកសាងសមត្ថភាពដទៃទៀត ការកសាងបណ្តាញការងារឥណទានខ្នាតតូច។ល។

[២៨] ចំពោះចំណុចលំអិតស្តីពីបញ្ហានេះ សូមមើល John P. McAndrew, 2000, “Field Study Report – Indigenous Adaptation to a Rapidly Changing Economy: The Experience of Two Tampuan Villages in Northeast Cambodia” Bulletin of Concerned Asian Scholars, 32(4):39-52.

- ពិចារណាលើដំណោះស្រាយដែលអាចពិនិត្យដោះស្រាយលើវិស័យទាក់ទង ដូចជាបរិស្ថានលក្ខខ័ណ្ឌផ្នែក សង្គម វប្បធម៌ និងស្ថាប័ន បរិបទផ្នែកច្បាប់-នយោបាយ និងស្ថានភាពជាក់ស្តែងផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ កាលៈទេសៈទាក់ទងនឹងបច្ចេកទេស និងហេដ្ឋារចនាសម្ព័ន្ធ។
- ស្វែងយល់លើជំរើសផ្សេង/ដំណោះស្រាយប្លែកគេដែលអាចដោះស្រាយលើសេចក្តីត្រូវការពិសេស របស់ស្ត្រី ឬអ្នកក្រីក្រខ្លាំង ។

## រៀបចំកំណត់រកបញ្ហាជាប់ពាក់ព័ន្ធ (Working with Implications)

ក្នុងករណីសមស្រប បញ្ហាជាប់ពាក់ព័ន្ធអាចចាត់ទុកថាជាអនុសាសន៍ដែរ ។ ការកំណត់រកបញ្ហាជាប់ពាក់ព័ន្ធ គឺដូចគ្នានឹងការផ្តល់អនុសាសន៍ តែធ្វើឱ្យអ្នកស្រាវជ្រាវស្ថិតនៅឆ្ងាយ និងមានលក្ខណៈសញ្ជប់សញ្ជឹងគិត (Wolcott, 1990:60) ។ បើអ្នកស្រាវជ្រាវកំណត់រកបញ្ហាជាប់ពាក់ព័ន្ធសំរាប់មនុស្សពិសេសៗ (ដូចជា ភ្នាក់ងារអភិវឌ្ឍន៍ អ្នកគ្រប់គ្រងរដ្ឋបាល អ្នកធ្វើគោលនយោបាយ អ្នកស្រាវជ្រាវដទៃទៀត) នោះរបៀបប្រយោលដែលគាត់ធ្វើគឺ គាត់កំណត់រកបញ្ហាពាក់ព័ន្ធដោយលើកជាសំណួរជាជាងផ្តល់ចំលើយទៅវិញ ។

ការកំណត់រកបញ្ហាជាប់ពាក់ព័ន្ធដើម្បីធ្វើការសន្និដ្ឋានទៅលើការសិក្សាស្រាវជ្រាវ គឺផ្តល់លទ្ធភាពឱ្យអ្នកស្រាវជ្រាវធ្វើការឆ្លុះបញ្ចាំងលើលទ្ធផលរកឃើញ និងប្រើប្រាស់ពត៌មានដែលទាក់ទងនឹងចំណុចទំនាក់ទំនង សំខាន់ៗដែលលេចឡើងដោយបញ្ហានៃការសិក្សាស្រាវជ្រាវ ។ ដូចដែលមានលើកឡើងខាងលើមកដល់ត្រឹមនេះ គឺជាពេលដែលអ្នកស្រាវជ្រាវអាចដកខ្លួនឱ្យស្ថិតនៅឆ្ងាយពីបញ្ហា ឬស្ថានភាពដែលកំពុងត្រូវបានពិនិត្យ និងការភ្ជាប់ទំនាក់ទំនងនៅក្នុងលទ្ធផលរកឃើញដោយដាក់ជាសំណួរ ឬបញ្ហាចំពោះមុខដែលត្រូវប្រឈម ហើយពិនិត្យមើលថាតើបញ្ហាប្រឈមទាំងនេះ អាចមានផលវិជ្ជមាន ឬអវិជ្ជមានទៅលើតួអង្គ/អ្នកពាក់ព័ន្ធផ្សេងៗ ព្រមទាំងបរិយាកាសផ្នែកច្បាប់ នយោបាយ សេដ្ឋកិច្ច និងវប្បធម៌សង្គមអាចប៉ះពាល់ដល់ស្ថានការណ៍បែបណា ។ ក្រៅពីនេះ ក៏ត្រូវដាក់ខ្លួនឱ្យនៅឆ្ងាយពីផលវិបាកនៃសកម្មភាពផ្សេងៗដែលគេអាចយកទៅធ្វើ និងពិនិត្យមើលលើស្ថានការណ៍អនាគត ដោយផ្អែកទៅតាមនិន្នាការដែលបានវិភាគឃើញ ។ ដូច្នេះគេអាចនិយាយដល់ផ្នែកទ្រឹស្តី និងលក្ខណៈជាក់ស្តែងយោងតាមលទ្ធផលរកឃើញ តែត្រូវមតិខ្លះដែលបង្កប់អត្ថន័យគឺ ត្រូវឱ្យអ្នកអានគិត ពិចារណាពីអ្វីដែលអាចនាំឱ្យគេធ្វើអ្វីប្លែកៗ ពោលគឺឱ្យគិតទៅដល់សម្ថភាពណាដែលអាចយកទៅអនុវត្តន៏បាន ឬអាចជជែកគ្នាទាក់ទងទៅនឹងទស្សនៈផ្សេងៗ ដែលការស្រាវជ្រាវបានលើកឡើង ។

ជំពូក ៣

# ផ្នែកទី ៤

# សរសេរ និង ផ្សព្វផ្សាយរបាយការណ៍

## ជំហានទី ៨ :  ការសរសេររបាយការណ៍


ពិនិត្យមើលឡើងវិញ  និងកែសំរួលទំរង់របាយការណ៍ ...................................... ១៤១

សរសេររបាយការណ៍  និងផ្នែកសំខាន់ខ្លះៗ .................................................... ១៤១

បញ្ជីត្រួតពិនិត្យសំរាប់កែលំអររបាយការណ៍ពង្រាង .......................................... ១៤៦

# ជំហ៊ានទី ៨ៈ សរសេររបាយការណ៍

*ពិនិត្យមើលឡើងវិញ និងកែសំរួលទំរង់នៃរបាយការណ៏.......សរសេររបាយការណ៏ និងផ្នែកសំខាន់ខ្លះៗ.... បញ្ជីត្រួតពិនិត្យសំរាប់កែលំអរពង្រាងរបាយការណ៏.....*

| ជំហ៊ានទី ៨ |
|---|
| សរសេររបាយការណ៏ |
| |
| |

## ពិនិត្យមើលឡើងវិញ និងកែសំរួលទំរង់របាយការណ៏
## (Reviewing and Modifying the Outline of the Report)

ដូចដែលបានរៀបរាប់នៅក្នុងជំហ៊ានទីបីនៃឯកសារនេះ ណែនាំពីការរៀបចំការសរសេររបាយការណ៏ ចាប់ផ្ដើមពីដំណាក់កាលបញ្ចូលទិន្នន័យនៃការស្រាវជ្រាវ ។ ការងារនេះសំរេចបានដោយមានពង្រាងការរៀបចំគំរោងមួយដែលអ្នកស្រាវជ្រាវដទៃទៀតនៅពេលខ្លះចាត់ទុកថាជាការពង្រីកទំរង់របាយការណ៏នៃមាតិការ ។ គេអាចចាំបានថា ការពង្រាងរបស់គំរោងអាចមិនមានលក្ខណៈពេញលេញពីដំបូងមក និងអាចគ្រាន់តែចាប់យកផ្នែកធំៗ ដែលមាននៅក្នុងការគ្រោងរៀបចំការស្រាវជ្រាវ ។

ដំណើរការត្រួតពិនិត្យឡើងវិញ និងកែតំរូវរបាយការណ៏ គឺជាដំណើរការដែលត្រូវធ្វើជាបន្តរហូត ពីព្រោះការបញ្ចូលទិន្នន័យ និងការរៀបចំនៃការសង្ខេបទិន្នន័យបន្ត និងគំនិតសំរាប់លើកបង្ហាញ និងពិភាក្សាលទ្ធផលរកឃើញក៏មានរូបរាងឡើង ។ ចំណងជើងអាចកំណត់ជាបណ្ដោះអាសន្ននៅក្នុងគ្រោងអាចលុបចោលបាន ឬសរសេរកែឡើងវិញនៅពេលផ្នែកនីមួយៗ ដែលត្រូវបានគេកំណត់កាន់តែច្បាស់ ពិសេសនៅពេលគេសរសេររបាយការណ៏តែម្ដង ។ ការសង្កេតអំពីទិន្នន័យនៅក្នុងដំណើរការរៀបចំការបូកសរុប ឬអត្ថន័យថ្មីៗនៅក្នុងការស្រាវជ្រាវក៏អាចមានន័យផងដែរ បន្ថែមចំណងជើងតូចៗ ឬផ្នែកតូចៗ ហើយកែតំរូវលំដាប់របស់វា ។

គំរោងប្រៀបបាននឹងគ្រោងឆ្អឹងរបស់របាយការណ៏ ដែលត្រូវបានប្រែក្លាយទៅជារបាយការណ៏ ដោយអ្នកស្រាវជ្រាវបំពេញផ្នែកផ្សេងៗរបស់វានៅក្នុងពេលសរសេរ ។ វាជាការមានប្រយោជន៏ដែលគេត្រូវចាំថាក្នុងនាមជាឧបករណ៏សំរាប់រៀបចំ គំនិតយោបល់ អាចត្រូវបានគេកែតំរូវដើម្បីធ្វើឱ្យឯកសារចុងក្រោយកាន់តែមានប្រសិទ្ធភាព ពីព្រោះអ្នកស្រាវជ្រាវធានាធ្វើយ៉ាងណាឱ្យមានការរៀបចំល្អ តាមលំដាប់លំដោយត្រឹមត្រូវ និងជួយដល់អ្នកអាននៅក្នុងការតាមដានលទ្ធផលរកឃើញដែលអ្នកស្រាវជ្រាវរាយការណ៏ ។

## សរសេររបាយការណ៏ និងផ្នែកសំខាន់ខ្លះៗ
## (Writing Reports and Some Components Parts)

ការសរសេររបាយការណ៏ គឺជាដំណាក់កាលពិបាកជាងគេនៃដំណើរការស្រាវជ្រាវ ពីព្រោះនេះជាពេលដែលអ្នកស្រាវជ្រាវត្រូវផ្គុំគ្នានូវការគ្រោងរៀបចំការស្រាវជ្រាវ លទ្ធផលរកឃើញ និងឯកសារដែលមានការទាក់ទងឱ្យទៅជាឯកសារមួយដែលមានគ្រប់លក្ខណៈ ។ ទាក់ទងនឹងចំណុចនេះ គោលការណ៏ណែនាំរួមដែលបានជំរុញឡើងសំរាប់អ្នកដែលរៀបចំរបាយការណ៏ស្រាវជ្រាវគឺៈ

- របាយការណ៍គឺជាការខិតខំមួយនៅក្នុងការរៀបរាប់ពីដំណើរការ និងបទពិសោធន៍ក្នុងការស្រាវជ្រាវទាំងមូល ។
- គោលបំណងរបស់របាយការណ៍ គឺ**មិនមែនជា**ការទាក់ទងជាមួយនឹងខ្លួនឯងទេ តែជាការទាក់ទងជាមួយនឹងមនុស្សច្រើនដែលជាអ្នកអាន ។
- ចំណុចសំខាន់នៃរបាយការណ៍ គួរប្រាប់ពីអ្វីដែលកើតឡើងពិតប្រាកដ នៅក្នុងដំណើរការស្រាវជ្រាវទាំងមូលមិនមែនអ្វីដែលយើងសង្ឃឹមថា នឹងកើតឡើងនៅក្នុងដំណាក់ការនីមួយៗនោះទេ ។
- សរសេរពីការបរាជ័យ និងកំហិតព្រំដែននៃការស្រាវជ្រាវ ។ បើអាចធ្វើបានចូរបញ្ចូលមតិរបស់អ្នកស្តីពីហេតុផលដែលនាំទៅដល់ការបរាជ័យ ឬកំហិតព្រំដែននៅក្នុងការសិក្សាស្រាវជ្រាវ ។
- វាមានភាពងាយស្រួលច្រើនក្នុងការប្តូរគំរោងរបាយការណ៍ជាងការប្តូរពង្រាងរបាយការណ៍ទាំងមូល ។ ដូច្នេះវាមានប្រសិទ្ធភាព បើគេរៀបចំទំរង់របាយការណ៍បានគ្រប់គ្រាន់ រួចហើយធ្វើបន្តដោយរៀបចំពង្រាងរបាយការណ៍ដែលមានលក្ខណៈលំអិត ។
- រៀបចំ និងបែងចែករបាយការណ៍ជាជំពូក ផ្នែកនិងផ្នែកតូចៗបន្តទៀត ដោយមានចំណងជើងត្រឹមត្រូវ ។

**តារាងទី៧. ខ្លឹមសាររួមនៃរបាយការណ៍ស្រាវជ្រាវ និងការស្រាវជ្រាវស្តីពីការប្រើថ្នាំញៀនរបស់ CCC-ADI**

| ខ្លឹមសាររួមនៃរបាយការណ៍ | ផ្នែកនៃរបាយការណ៍ស្រាវជ្រាវរបស់ CCC-ADI ស្តីពីការប្រើថ្នាំញៀន | ដំណាក់ការក្នុងការគ្រោងរៀបចំរបាយការណ៍ និងអនុវត្តន៍ |
|---|---|---|
| ទំព័រចំណងជើង | | |
| អារម្ភកថា | | |
| សេចក្តីសង្ខេប/ខ្លឹមសារសង្ខេប | | |
| មាតិកា | | |
| សេចក្តីផ្តើម | I. ការពិពណ៌នាអំពីបញ្ហា<br>II. ទិសដៅនៃការស្រាវជ្រាវ<br>III. សំណួរគន្លឹះ | ពិពណ៌នាពីបញ្ហា/ប្រធានបទស្រាវជ្រាវ<br>ទិសដៅនៃការស្រាវជ្រាវ<br>សំណួរស្រាវជ្រាវជាក់លាក់ និងពត៌មានដែលត្រូវការ |
| វិធីសាស្ត្រ (ការគ្រោងរៀបចំការស្រាវជ្រាវ និងការប្រមូលទិន្នន័យ ការបញ្ចូល និងវិភាគទិន្នន័យ) | IV. វិធីសាស្ត្រស្រាវជ្រាវ | វិធីសាស្ត្រស្រាវជ្រាវដែលត្រូវបានកំណត់ |
| លទ្ធផលរកឃើញ | V. លទ្ធផលរកឃើញនិងការវិភាគ<br>ក. និន្នាការនៅក្នុងការប្រើប្រាស់ថ្នាំញៀន<br>១. លក្ខណៈទូទៅនៃអ្នកប្រើថ្នាំញៀន<br>២. អាកប្បកិរិយានៃអ្នកប្រើថ្នាំញៀន<br>ខ. បុព្វហេតុនិងផលវិបាកនៃការប្រើថ្នាំញៀន<br>១. ហេតុផលនៃការប្រើថ្នាំញៀន<br>២. ឥទ្ធិពលនៃការប្រើថ្នាំលើអ្នកប្រើប្រាស់ | ទិន្នន័យដែលត្រូវបានប្រមូលនិងសង្ខេប<br>ចំលើយចំពោះសំណួរស្រាវជ្រាវមួយៗ ស្តីពីទិសដៅស្រាវជ្រាវទី១<br><br>ចំលើយចំពោះសំណួរស្រាវជ្រាវមួយៗ ស្តីពីទិសដៅស្រាវជ្រាវទី២ |

| | | |
|---|---|---|
| | គ. ឥទ្ធិពលដែលមានទៅលើជីវិតគ្រួសារ<br><br>ឃ. ផលដែលប៉ះពាល់ទៅលើការរស់នៅសហគមន៍ | ចំលើយចំពោះសំណួរស្រាវជ្រាវមួយៗ ស្តីពីទិសដៅស្រាវជ្រាវទី៣<br>ចំលើយចំពោះសំណួរស្រាវជ្រាវមួយៗ ស្តីពីទិសដៅស្រាវជ្រាវទី ៤ |
| សេចក្តីសង្ខេប អនុសាសន៍/បញ្ហាជាប់ពាក់ព័ន្ធ | VI. សេចក្តីសន្និដ្ឋាន<br><br>VII. ភាពជាប់ពាក់ព័ន្ធ<br>ក. បញ្ហាគោលនយោបាយ<br>ខ. បញ្ហាអប់រំនិងការស្តារឡើងវិញ<br>គ. បញ្ហាអភិវឌ្ឍសហគមន៍ | សេចក្តីបញ្ចាក់ចុងក្រោយទាក់ទងនឹងសំណួរ និងទិសដៅស្រាវជ្រាវ<br>ប្រយោជន៍ទាក់ទងនៃការស្រាវជ្រាវ/អ្វីដែលលទ្ធផលរកឃើញមានន័យទាក់ទងនឹងការធ្វើគោលនយោបាយ និងការប្រតិបត្តិនៅក្នុងការអភិវឌ្ឍន៍។ |
| សេចក្តីបន្ថែម/ឧបសម្ព័ន្ធ | | |
| ឯកសារយោង | | |

## សរសេររបាយការណ៍

ដោយបានឆ្លងកាត់ជំហ៊ានសំខាន់ៗនៃដំណើរការស្រាវជ្រាវ និងបានសរសេរចូលទៅក្នុងគំរោងប្លង់របស់គាត់នូវផ្នែកសំខាន់ៗនៃរបាយការណ៍ អាចនឹងមានធ្វើការកែប្រែ (និងបង្កើតថ្មី) នូវផ្នែកផ្សេងៗជាបណ្តើរៗ អ្នកស្រាវជ្រាវត្រូវផ្គុំផ្នែកផ្សេងៗទាំងនេះឱ្យទៅជាផ្នែកទាំងមូលមួយ (តារាងទី៧)។ នៅពេលគេធ្វើដូច្នេះរួចហើយ គេត្រូវពិនិត្យមើលឡើងវិញពីគោលបំណងនៃការសិក្សាស្រាវជ្រាវ ពីព្រោះលក្ខណៈនៃការធ្វើរបាយការណ៍ ដោយរួមទាំងរបៀបរបប និងភាសារបស់វាមានភាពស៊ីគ្នានៅក្នុងឯកសារទាំងមូល និងត្រូវគិតទៅដល់អ្នកអានរបាយការណ៍ផង។ ដូច្នេះ គេក៏ត្រូវបែងចែកឱ្យដាច់ស្រឡះពីគ្នារវាង ការពិត មតិ និងពាក្យចចាមអារាម នៅពេលសរសេររបាយការណ៍ស្រាវជ្រាវ ពីព្រោះបញ្ហានេះមានសារៈសំខាន់ណាស់នៅក្នុងការធ្វើឱ្យគេមាន ឬមិនមានជំនឿមកលើឯកសារស្រាវជ្រាវរបស់ខ្លួន។ ភាពខុសគ្នារវាងចំណុចទាំងបីនេះគឺមានដូចខាងក្រោមនេះ (Pretty et al, 1995:193) :

- ការពិត - ពតិមានដែលគេយល់ដូចគ្នាជាទូទៅ ដែលមានភស្តុតាងបញ្ជាក់ដោយងាយៗ។
- មតិ - ទស្សនៈយល់ឃើញរបស់មនុស្សម្នាក់ ឬមនុស្សមួយក្រុមទៅលើប្រធានបទ ឬស្ថានភាពមួយ។
- ពាក្យចចាមអារាម - ពតិមានដែលគ្មានមូលដ្ឋានពីប្រភពដែលគេមិនស្គាល់។

ក្រៅពីការគិត អ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើនៅពេលរៀបចំពង្រាងដំបូង និងពង្រាងបន្តបន្ទាប់មក របាយការណ៍គេត្រូវដឹងថា គ្មានវិធីណាមួយដែលកំណត់ឱ្យប្រាកដថា ជាវិធីដែលត្រូវក្នុងការនិយាយពីអ្វីមួយនោះទេ។ វិធីម្យ៉ាងនៃការនិយាយអាចថាត្រឹមត្រូវ តែមិនជាទីចាប់អារម្មណ៍ទេ។ វិធីម្យ៉ាងទៀត អាចជាទីចាប់អារម្មណ៍តែមិនចំ ឬពិតទេ (Berg, 1989:158)។ មធ្យោបាយដែលអាចទទួលយកបាននិងព្យាយាមបន្ទាប់ពី ៣ ឬ ៤ ឬច្រើនជាងនេះ ប៉ុន្តែអាចមិនពិតថា ជាវិធីល្អតែម្យ៉ាងនៅក្នុងការរៀបចំពាក្យនោះទេ។

## ការរៀបចំកថាខ័ណ្ឌ (Developing the Paragraphs)

បញ្ហាដែលច្រើនមានញឹកញាប់គួរសមរបស់អ្នកនិពន្ធទាំងអស់គឺបញ្ហានៃការចាប់ផ្តើម (Becker, 1986 ដូចដែលមានលើកឡើងនៅក្នុង Berg, 1989:158)។ ការនឹករកមើលគំនិតយោបល់ ឬពាក្យនៅលើកដំបូង និងឃ្លាបន្តបន្ទាប់មកសំរាប់កឋាខ័ណ្ឌនីមួយៗដែលត្រូវសរសេរគឺជាការពិបាក។ បច្ចេកទេសមួយដែលមានប្រយោជន៍ ថាតើយកតាមវិធីទូលាយ (Deductive) ឬវិធីជាក់លាក់ (Inductive) សំរាប់ការបង្ហាញពត៌មាន។ វិធីទូលាយផ្តើមចេញពីការអះអាងទូទៅឆ្ពោះទៅរកភាពជាក់លាក់ រីឯវិធីជាក់លាក់វិញផ្តើមចេញពីពត៌មានច្បាស់លាស់ទៅរកគំនិតទូទៅ ក្នុងការលើកបង្ហាញពត៌មាន។ កឋាខ័ណ្ឌនៅក្នុងការសិក្សារបស់ CCC-ADI ស្តីពី*ការយល់បញ្ហានៃការប្រើប្រាស់ថ្នាំញៀនថាជាបញ្ហាសង្គមមួយ* បង្ហាញឱ្យឃើញពីវិធីសាស្ត្រការពិតរួម ដូចមានបង្ហាញខាងក្រោមនេះ៖

"**.....ការប្រើថ្នាំញៀនប៉ះពាល់លើទំនាក់ទំនងរវាងមនុស្សយ៉ាងពិតប្រាកដ។** ជាងពាក់កណ្តាលនៃអ្នកប្រើថ្នាំញៀនដែលបានសំភាសន៏និយាយថា ផលវិបាកនៃការប្រើថ្នាំញៀនធ្វើឱ្យមានរការឈ្លោះប្រកែកជាមួយឳពុកម្តាយ និងសមាជិកដទៃទៀតនៃគ្រួសាររបស់គេ។ មានមនុស្សជាច្រើនបានរត់ចេញពីផ្ទះសម្បែងយ៉ាងហោចណាស់ ក៏មួយរយៈពេលខ្លីដែរ មានមិត្តភក្តិតិច មានបញ្ហាជាមួយនឹងអ្នកដទៃទៀតនៅក្នុងភូមិ អាជ្ញាធរមូលដ្ឋាន និងប៉ូលីស។ មានអ្នកខ្លះឆ្លើយថា គេមានមិត្តច្រើននៅក្នុងចំណោមអ្នកប្រើថ្នាំញៀនដូចគ្នា។ គ្រួសាររបស់អ្នកមិនប្រើថ្នាំញៀនបានកត់សំគាល់ឃើញថា ពួកគេបានបែងចែកការទំនាក់ទំនងជាមួយក្មេងដែលប្រើថ្នាំញៀន...."។

ដូចដែលបានកត់សំគាល់នៅក្នុងពាក្យដកស្រង់សំដីខាងលើ ប្រយោគទីមួយគឺជាខ្លឹមសារទូលាយ ហើយបន្ទាប់មកមានពត៌មានលំអិតច្បាស់លាស់សំរាប់បញ្ជាក់ការលើកឡើងដែលមានលក្ខណៈទូលាយនោះ។ កឋាខ័ណ្ឌដដែលនេះ គេអាចយកតាមវិធីជាក់លាក់/លំអិតឆ្ពោះមកកាន់ភាពទូលាយវិញបានដែរ (Deductive) ដែលគេអាចរៀបចំឃ្លាប្រយោគឡើងវិញ ដូចខាងក្រោមនេះស្រាប់៖

".....ជាងពាក់កណ្តាលនៃអ្នកប្រើថ្នាំញៀនដែលបានសំភាសន៏បាននិយាយថា ផលវិបាកនៃការប្រើថ្នាំញៀន គឺបង្កឱ្យមានការឈ្លោះប្រកែកច្រើនជាមួយនឹងឳពុកម្តាយ និងសមាជិកគ្រួសារដទៃទៀត។ មានមនុស្សច្រើនបានចាកចោលផ្ទះ យ៉ាងហោចណាស់ក៏មួយរយៈពេលខ្លីដែរ មានមិត្តកាន់តែតិច និងមានបញ្ហាជាមួយអ្នកភូមិ អាជ្ញាធរមូលដ្ឋាន និងប៉ូលីស។ មានខ្លះនិយាយថា គេមានមិត្តកាន់តែច្រើននៅក្នុងចំណោមអ្នកប្រើថ្នាំញៀនដូចគ្នា។ គ្រួសាររបស់អ្នកប្រើថ្នាំញៀនបានកត់សំគាល់ឃើញដូចគ្នានេះដែរ ក្នុងទំនាក់ទំនងរបស់កូនគាត់ដែលប្រើថ្នាំញៀន។ **ពិតណាស់ ការប្រើប្រាស់ថ្នាំញៀនប៉ះពាល់ទៅលើទំនាក់ទំនងរវាងមនុស្សម្នាក់ទៅម្នាក់ទៀត.....**"។

អ្នកដែលដឹងប្រយោគសំខាន់ (topic sentence) ប្រហែលយល់ថា ការនេះមិនមានអ្វីប្លែកទេ ពីព្រោះប្រយោគសំខាន់គឺជាសេចក្តីបញ្ជាក់ដែលបង្ហាញតាមលក្ខណៈទូទៅថា តើគំនិត ឬប្រយោគអ្វីដែលអាចភ្ជាប់ ទំនាក់ទំនងគ្នាក្នុងកឋាខ័ណ្ឌ (OWL, 1995-2004)។ គោលការណ៍ណែនាំភាគច្រើនចំពោះការសរសេរសង្កត់ធ្ងន់ លើសារៈសំខាន់នៃចំណុចសំខាន់ហើយកត់ចំណាំថា ចំណុចសំខាន់នេះអាចស្ថិតនៅត្រង់កន្លែងណាក៏បានដែរ នៅក្នុងកឋាខ័ណ្ឌនៅខាងដើម (នៅពេលដែលវិធីសាស្ត្រ Deductive ត្រូវបានប្រើ) នៅកណ្តាល ឬជាប្រយោគចុងក្រោយ (នៅពេលដែលវិធី Inductive ត្រូវបានប្រើ) (WUWC, 1994)។ មិនថាវិធីទូលាយ ឬវិធីសំរាយទេ ចំណុចសំខាន់គឺថា កឋាខ័ណ្ឌត្រូវផ្តោតតែលើគំនិតតែមួយ តាមរយៈសេចក្តីលំអិតដែលត្រូវបានលើកបង្ហាញឡើងដើម្បីបញ្ជាក់ ឬពន្យល់ទៅលើប្រយោគសំខាន់ ។

## បញ្ចូលទិន្នន័យសង្ខេបនៅក្នុងរបាយការណ៍ (Locating Data Summaries within the Report)

សេចក្ដីលំអិតនៅក្នុងកឋាខ័ណ្ឌ (ឬបណ្ដាប្រយោគដែលមានបន្ទាប់ពីប្រយោគសំខាន់) ជាពិសេសខ្លឹមសារនៅក្នុងការពិភាក្សាលើលទ្ធផលរកឃើញ ច្រើនតែបង្ហាញពីទិន្នន័យទាក់ទងទៅនឹងចំណុចសំខាន់ៗដែលអ្នកស្រាវជ្រាវបានរៀបចំឡើងដូចដែលគេបានសង្ខេបនៅក្នុងតារាងក្រាហ្វិក និងវិធីផ្សេងទៀតសំរាប់ដាក់បង្ហាញ។ តារាង និងក្រាហ្វិកទាំងនេះមានសារៈសំខាន់នៅក្នុងរបាយការណ៍ ពីព្រោះវាងាយធ្វើឱ្យអ្នកអានឆាប់ចាប់អារម្មណ៍ដោយគេមើលឃើញការពិត និងទំនាក់ទំនងជារូបភាពតាមលក្ខណៈផ្សេង (Wolcott 1990: 64)។ ទាំងអស់នេះធ្វើឱ្យអ្នកស្រាវជ្រាវនឹកគិតទៅដល់ទំរង់ផ្សេងៗទៀត សំរាប់ពិពណ៌នាទិន្នន័យ និងសំរាប់ការលាតត្រដាងបន្ថែមឱ្យកាន់តែងាយយល់ ជៀសវាងការមានតែពាក្យពេជន៏សុទ្ធសាធពេញនៅលើទំព័រនីមួយៗ (Wolcott, 64)។ តែការយោងនូវប្រភពឯកសារទាំងនេះ គួរតែសរសេរនៅក្នុងរង្វង់កឋាខ័ណ្ឌ ឬអត្ថបទរបស់របាយការណ៍ ដើម្បីគូសបញ្ជាក់អ្វីដែលបានលើកឡើងមកជាអំណះអំណាង។ ការសង្ខេបទិន្នន័យក៏ត្រូវតែធ្វើដែរ តែឱ្យមានគោលបំណងច្បាស់លាស់ពោលគឺមិនមែនបន្ថែម ដើម្បីពង្រីកទំហំរបាយការណ៍ឱ្យកាន់តែច្រើន ឬអួតអាងប្រាប់គេនោះទេ (Wolcott, 1990:66)។

តារាង/ដ្យាក្រាម អាចយកមកប្រើនៅក្នុងផ្ទៃរឿងនៃរបាយការណ៍ ឬដាក់នៅក្នុងឧបសម្ព័ន្ធក៏បានដែរ។ ក្នុងករណីដែលមានតារាងច្រើន ហើយអាចធ្វើឱ្យមានការច្រឡំនៅក្នុងផ្ទៃរឿងនោះ គេគួរបន្ថែមឯកសារទាំងនោះនៅខាងចុង ទោះបីជាបានគេលើកមកនិយាយនៅក្នុងការពិភាក្សាលើលទ្ធផលរកឃើញក្ដី។ ដោយហេតុនេះ វាគួរតែត្រូវបានគេបង្ហាញជាលំដាប់លេខរៀងត្រឹមត្រូវតាមការពិភាក្សានៅក្នុងរបាយការណ៍។ ក្រៅពីនេះគេត្រូវ កំណត់ឈ្មោះវាឱ្យបានគ្រប់គ្រាន់ ដែលមិនចាំបាច់ឱ្យគេត្រឡប់ទៅមើលនៅក្នុងអត្ថបទទេ (Wolcott, 1990:65)។ សេចក្ដីសង្ខេបទិន្នន័យ គួរតែមានភាពច្បាស់លាស់ដោយខ្លួនឯង ដោយមិនបាច់ឱ្យគេតាមបញ្ជាក់នៅក្នុងអត្ថបទទាំងមូលទេ។

## សរសេរសេចក្ដីសង្ខេបរួម (Writingg Executive Summary)

របាយការណ៍ស្រាវជ្រាវច្រើនចាប់ផ្ដើមដោយមានសេចក្ដីសង្ខេបមួយ ឬខ្លឹមសារសង្ខេប។ បន្ទាប់មកខ្លឹមសារសង្ខេបច្រើនតែមានចំនួនពី ៥០-២០០ពាក្យ (Berg, 1989:146) គេប្រើនៅក្នុងអត្ថបទទស្សនាវដ្ដីវិទ្យាសាស្ត្រ និងមានពត៌មានស្ដីពីបញ្ហា/ប្រធានបទស្រាវជ្រាវ លក្ខណៈសំខាន់ៗនៃវិធីសាស្ត្ររបស់ការសិក្សាស្រាវជ្រាវ និងលទ្ធផលរកឃើញជាមូលដ្ឋាន។ម្យ៉ាងវិញទៀត សេចក្ដីសង្ខេបដែលមានបួន ឬប្រាំទំព័រត្រូវបានគេហៅថា សេចក្ដីសង្ខេបរួម ហើយនិងមានសេចក្ដីលំអិតជាងការមូលន័យសង្ខេប (Abstract)។ តាមធម្មតាអ្នកស្រាវជ្រាវ រៀបចំការសង្ខេបសំរាប់របាយការណ៍ ដែលត្រូវបានសរសេរសំដៅឱ្យអ្នកឯកទេសខាងការអភិវឌ្ឍសង្គម និងអ្នកធ្វើគោលនយោបាយអាន។ បន្ថែមទៅលើផ្នែកសេចក្ដីដែលតាមធម្មតាបានឆ្លុះបញ្ចាំងនៅក្នុងសេចក្ដីសង្ខេប ដែលវែងទាំងនេះរួមមានបញ្ហាជាប់ពាក់ព័ន្ធនៃការស្រាវជ្រាវ និង/ឬអនុសាសន៏សំខាន់ៗនៅក្នុងរបាយការណ៍។ សេចក្ដីសង្ខេបទាំងនេះច្រើនមានលក្ខណៈពេញលេញដោយខ្លួនឯង ហើយពេលខ្លះត្រូវបានគេចែកចាយដោយមិនមានរបាយការណ៍ទាំងមូលទេ នៅក្នុងចំណោមអ្នកដែលមានការពាក់ព័ន្ធនៅក្នុងបញ្ហារបស់ការស្រាវជ្រាវនោះ។

សេចក្ដីសង្ខេបរួម (និងមូលន័យសង្ខេប) មានមុខងារច្រើន។ ចំពោះអ្នកអានដែលមានការចាប់អារម្មណ៍តិចបង្ហាញថាតើក្នុងរបាយការណ៍មានអ្វីខ្លះ?។ សំរាប់អ្នកអានដទៃទៀតដែលរកមើលពត៌មានជាក់ច្បាស់ វាជួយឱ្យអ្នកអានកំណត់ថា តើរបាយការណ៍ពេញលេញមានពត៌មានដែលសំខាន់ដែរទេ (Neuman, 2000:472) អ្នកអានប្រើសេចក្ដីសង្ខេបដើម្បីចំរាញ់រកមើលពត៌មាន និងកំណត់ថាតើគួរអានរបាយការណ៍ទាំងមូលដែរឬទេ។ ចំពោះអ្នកអានដែលយកចិត្តទុកដាក់ខ្លាំង សេចក្ដីសង្ខេបបង្ហាញនូវរូបភាពយ៉ាងឆាប់នៃរបាយការណ៍ដែលធ្វើឱ្យគេអានទៅងាយយល់ហើយបានលឿន ។

### រៀបចំឧបសម្ព័ន្ធ (Preparing Appendices)

ឧបសម្ព័ន្ធ គឺជាឯកសារជំនួយដែលគេបន្ថែមនៅខាងចុងរបាយការណ៍ ហើយត្រូវតែមានន័យច្បាស់លាស់ (Wolcott, 1990:79)។ ដោយពេលខ្លះត្រូវបានគេហៅថា ជាឯកសារបន្ថែម សេចក្តីបន្ថែម ដែលទាំងនេះអាចរួមមាន តារាង ផែនទី ដ្យាក្រាម ដែលមានសារៈសំខាន់ចាំបាច់សំរាប់អត្ថបទ ជាការបន្ថែមលើឯកសារដទៃទៀតដែលអ្នកស្រាវជ្រាវចង់ផ្សព្វផ្សាយ។ បើសិនជាឯកសារបន្ថែមទាំងនេះមានច្រើនទំព័រពេក ហើយត្រូវបានគេរៀបចំដោយឡែក១ពីគ្នាជាញឹកញាប់គេហៅវាថា ឯកសារបន្ថែម។

ឧបសម្ព័ន្ធផ្តល់ដល់អ្នកអាននូវពត៌មានលំអិត ស្តីពីចំណុចដែលត្រូវបានរៀបរាប់នៅក្នុងផ្ទៃរឿង ហើយធ្វើ ឱ្យគេមើលឃើញប្រវត្តិករណីជាបន្ថែមលើន័យ នៅក្នុងអត្ថបទរបាយការណ៍ដោយមិនធ្វើឱ្យរំខានដល់ការរៀបរាប់នៅក្នុងរបាយការណ៍។ ឯកសារធម្មតាខ្លះដាក់ភ្ជាប់នៅក្នុងឧបសម្ព័ន្ធគឺ ការគ្រោងរៀបចំសំណាក វិធីប្រមូលទិន្នន័យនិងការវាស់វែង ផែនទី និងតារាងជាដើម។

### បញ្ជីត្រួតពិនិត្យសំរាប់កែលំអរពង្រាងរបាយការណ៍ (Checklist for Improving Draft Reports)

នៅពេលអ្នកស្រាវជ្រាវបានបង្ហើយពង្រាងរបាយការណ៍របស់គាត់ហើយ គេត្រូវការចាំបាច់ពិនិត្យឯកសារទាំងមូលឡើងវិញ។ គាត់ត្រូវរកមើលចំណុចជាច្រើន ដើម្បីបញ្ជាក់ឱ្យច្បាស់ថាគាត់បានសរសេរអ្វី១សព្វយ៉ាង ហើយបានបង្ហាញរបាយការណ៍តាមលក្ខណៈស៊ីគ្នាត្រឹមត្រូវ។ ខាងក្រោមនេះគឺជាបញ្ជីផ្ទៀងផ្ទាត់ដែលគាត់អាចប្រើនៅក្នុងការពិនិត្យពង្រាងរបាយការណ៍ដែលត្រូវបានបំពេញហើយ :

#### សេចក្តីផ្តើម

- តើរបាយការណ៍បញ្ជាក់ចំណងជើង ឈ្មោះអ្នកនិពន្ធនិងថ្ងៃខែដែរឬទេ?
- តើរបាយការណ៍បញ្ជាក់ពីប្រវត្តិ/សាវតានៃបញ្ហាស្រាវជ្រាវដែរឬទេ?

#### ប្រមូលពត៌មាន

- រកមើលពត៌មានដែលបាត់ហើយដាក់បំពេញវា ។
- បញ្ជាក់ប្រភពពត៌មាននៅក្នុងអត្ថបទ ឬដាក់វានៅក្នុងឧបសម្ព័ន្ធ។

#### រៀបចំពត៌មាន

- តើរបាយការណ៍មានបញ្ជាក់ផ្នែក១ និងចំណងជើងច្បាស់ទេ?
- តើផ្នែក១ត្រូវបានផ្តុំជុំវិញចំណុចសំខាន់តាមលំដាប់លំដោយពេលវេលា ឬចំណងជើងត្រឹមត្រូវទេ?

#### វិភាគពត៌មាន

- តើពត៌មានត្រូវសង្ខេបនៅជុំវិញចំនុចសំខាន់១ និងបញ្ហាដែរឬទេ?
- តើពត៌មានត្រូវបានផ្តុំ និងរៀបជាលំដាប់ពីសំខាន់បំផុតទៅមិនសូវសំខាន់ឬទេ?
- តើមានពត៌មានដែលអ្នកអានដឹង ហើយអាចលុបចោលបានដែរឬទេ?
- តើមានពត៌មានដែលអ្នកអានមិនដឹង ហើយត្រូវការយល់ដែរឬទេ?

- តើសេចក្តីសន្និដ្ឋានផ្អែកលើពត៌មានសំខាន់ៗជាការពិត និងមិនផ្អែកលើមតិយោបល់ផ្ទាល់ខ្លួនមែនទេ?

## រាយការណ៍ពត៌មាន

- តើរបាយការណ៍ឆ្លើយទៅនឹងសំណួរគន្លឹះ ឬគោលបំណងដែរឬទេ?
- តើរបាយការណ៍បញ្ជាក់លទ្ធផលរកឃើញបានត្រឹមត្រូវ និងច្បាស់លាស់ដែរឬទេ?
- តើរបាយការណ៍មានរឿងផ្ទាល់ខ្លួនមួយចំនួនដែលពន្យល់បង្ហាញចំណុចសំខាន់ៗដែលគេបានសង្កេតឃើញនៅក្នុងលទ្ធផលរកឃើញដែរឬទេ?
- តើរបាយការណ៍បញ្ជាក់ពីភាពជាប់ពាក់ព័ន្ធនៃលទ្ធផលរកឃើញ ឬអ្វីដែលត្រូវបានគេធ្វើអនុសាសន៍ទៅលើសំរាប់រយៈពេលខ្លី និងវែងដែរឬទេ?
- តើរបាយការណ៍មាននិយាយពីប្រភពដែលគួរឱ្យទុកចិត្តបាននៃពត៌មានសំខាន់ៗដែរឬទេ?

## សរសេរបានច្បាស់

- តើគំនិតសំខាន់ៗមានផុសចេញច្បាស់ក្នុងរបាយការណ៍ដែរឬទេ? តើវាងាយស្វែងរកដែរឬទេ?
- តើប្រយោគស្រួលអានដែរឬទេ? តើវាវែងពេកឬ?
- តើប្រយោគនីមួយៗមានប្រធាន កិរិយាស័ព្ទ និងនាមដែរឬទេ?
- តើរបៀប និងការប្រើប្រាស់ភាសាសមស្របដែរឬទេ?
- តើរបាយការណ៍ជៀសវាងការប្រើភាសាសាមញ្ញ ឬពាក្យបច្ចេកទេសដែរឬទេ?
- តើគំនិតយោបល់ត្រូវបានគេស្តែងចេញតាមលក្ខណៈដែលប្រកបដោយតុល្យភាពដែរឬទេ? (មិនអវិជ្ជមានពេក ឬមិនវិជ្ជមានពេក?)

## សរសេរកថាខ័ណ្ឌល្អ

- តើកឋាខ័ណ្ឌនីមួយៗមានលក្ខណៈពេញលេញអត្ថន័យដោយខ្លួនវាឬទេ?
- តើកឋាខ័ណ្ឌនីមួយៗចាប់ផ្តើមដោយចំណុចសំខាន់ដែលពន្យល់ពីកឋាខ័ណ្ឌដែរឬទេ?
- តើកឋាខ័ណ្ឌនីមួយៗមានតែពត៌មានដែលទាក់ទង នឹងប្រធានបទដែរឬទេ?
- តើរបាយការណ៍ប្រើឧទាហរណ៍ ឬពាក្យដកស្រង់ដែលជួយអោយអ្នកអានយល់ដែរឬទេ?
- តើកឋាខ័ណ្ឌនៅក្នុងផ្នែកនីមួយៗមានភ្ជាប់គ្នា ហើយទាក់ទងនឹងចំណងជើងរបស់ផ្នែកដែរឬទេ?

## សេចក្តីសង្ខេប សេចក្តីសន្និដ្ឋាន និងអនុសាសន៍

- តើពត៌មានត្រូវបានសង្ខេបឱ្យខ្លីបំផុត ដោយមិនមានបាត់បង់ន័យរបស់វាដែរឬទេ?
- តើសេចក្តីសន្និដ្ឋានខ្លី ហើយច្បាស់លាស់ដែរឬទេ?
- តើសេចក្តីសន្និដ្ឋាននិយាយយោងត្រឡប់ទៅរកគោលបំណងរបស់របាយការណ៍ដែរឬទេ?
- តើសេចក្តីសង្ខេប និងសេចក្តីសន្និដ្ឋានបញ្ជាក់ឡើងវិញនូវចំណុចសំខាន់ពីរបាយការណ៍ដែរឬទេ?
- តើសេចក្តីសន្និដ្ឋាន និងអនុសាសន៍ផ្អែកលើការពិតដែរឬទេ?

- តើអនុសាសន៍លើកឡើងពីសកម្មភាពមួយច្បាស់លាស់ដែលត្រូវធ្វើដែរឬទេ?
- តើអនុសាសន៍ត្រូវបានគេលើកឡើងដោយត្រង់ និងសមស្របដែរឬទេ?

### ប្លង់ និង របនាសម្ព័ន្ធ

- បើមានខ្នាតគំរូចាំបាច់សំរាប់សរសេររបាយការណ៍ តើខ្នាតគំរូនោះត្រូវបានប្រើដែរឬទេ?
- តើចំណងជើងមានដាក់លេខ សរសេរអក្សរធំ ឬមានគូសបន្ទាត់ពីក្រោមដូចគ្នាដែរឬទេ?
- តើបញ្ជីនៃអក្សរកាត់ និងអត្ថន័យរបស់វាមានសរសេរចូលដែរឬទេ?
- តើមានឧបសម្ព័ន្ធទេ ហើយតើរបាយការណ៍មាននិយាយយោងទៅរកឧបសម្ព័ន្ធនោះដែរឬទេ?
- តើរបាយការណ៍មានប្រើរូបភាព តារាង ឬក្រាហ្វិក ជាជំនួយក្នុងការសង្ខេបដែរឬទេ?
- តើក្រាហ្វិក តារាង និងឧទាហរណ៍ពន្យល់មានដាក់ចំណងជើង បង់លេខយោងនៅក្នុងរបាយការណ៍ដែរឬទេនៅក្នុងរបាយការណ៍?

### ការកែគំរូវចុងក្រោយ និងបញ្ជីត្រួតពិនិត្យចុងក្រោយ

- រៀបចំបញ្ជីនៃអក្សរកាត់ និងឈ្មោះកាត់ ។
- រកមើលពាក្យបាត់ដោយសារការវាយអក្សរលឿនពេក ។
- ប្រយោគមិនអាចចាប់ផ្តើមជាមួយនឹងពាក្យថា "និង" ឬ "ពីព្រោះ" ទេ បើសិនជាប្រយោគនេះមិនមានលក្ខណៈជាប្រយោគពេញលេញដែលមានប្រធាន កិរិយាស័ព្ទ និងនាមទេ។
- ប្រយោគមិនអាចចាប់ផ្តើមដោយលេខបានទេ។ ចូរសរសេរលេខនោះជាអក្សរវិញ។
- កុំទុកចន្លោះពីមុខសញ្ញាសួរ ឬក្បៀស។
- ពិនិត្យមើលអក្ខរាវិរុទ្ធ។
- សូមអានមើលពាក្យដែលកុំព្យូទ័រមិនកែបាន (ដូចជាពាក្យថា (Fun និង Fund) ។ ពាក្យទាំងពីរនេះ គឺត្រូវទាំងពីរ ប៉ុន្តែយើងចង់សរសេរពាក្យ Fund មិនមែនពាក្យ Fun នេះទេ ។
- ពេលខ្លះពាក្យខ្មែរត្រូវបានសរសេរខុសគ្នានៅក្នុងរបាយការណ៍តែមួយ (ឧទាហរណ៍ ពាក្យ Kampong Speu និង Kompong Speu) ។ ចូរកំណត់យកមួយណាឱ្យប្រាកដ។
- ក្រដាសត្រូវមានបង់លេខ ហើយការបង់លេខលើចំណងជើងនៃផ្នែកនីមួយៗ ក៏ត្រូវតែមានលក្ខណៈប្រាកដច្បាស់លាស់ដែរ ។
- សូមផ្ទៀងផ្ទាត់មើលកុំឱ្យមានធ្លាក់ឃ្លា/បន្ទាត់មិនសមស្រប ។
- ពិនិត្យមើលថាមិនមានប្រើកម្មសិទ្ធិបុរសទី១ ដូចជា "ខ្ញុំ" ឬ "យើង"

# ជំហានទី ៩: ឆ្លុះបញ្ចាំងលើលទ្ធផលរកឃើញជាមួយអ្នកពាក់ព័ន្ធ

ជំហាន ៩

# ជំហានទី៩ : ឆ្លុះបញ្ចាំងលើលទ្ធផលរកឃើញជាមួយអ្នកពាក់ព័ន្ធ

*ធ្វើឱ្យលទ្ធផលរកឃើញមានសុពលភាព និង ឱ្យគេដឹងឮលទ្ធផលរកឃើញ.... ដំណើរការជាលក្ខណៈចូលរួមនៅក្នុងការបង្ហាញបញ្ហាសំខាន់ៗនៅក្នុងលទ្ធផលរកឃើញ.....បញ្ចូលយោបល់ថ្មីៗទៅក្នុងរបាយការណ៍ចុងក្រោយ...។*

ជាញឹកញាប់នៅក្នុងពេលថ្មីៗកន្លងទៅនេះ អ្នកស្រាវជ្រាវបានធ្វើការសិក្សាស្រាវជ្រាវរបស់គេ សរសេរ និងបោះពុម្ពរបាយការណ៍របស់គេដោយមិនត្រឡប់ទៅសួរអ្នកផ្តល់បទសំភាសន៍ ដែលធ្វើឱ្យគេមិនដឹងឮអ្វីទាំងអស់ទៅលើពីអ្វីដែលបានកើតឡើងក្រោយពីអ្នកស្រាវជ្រាវបានប្រមូលទិន្នន័យរួច។ ការឱ្យតំលៃកាន់តែច្រើនចំពោះឱកាសការចូលរួម និងលទ្ធភាពទទួលបានពត៌មាន បានកែប្រែរបៀបរបបដែលលើកឡើងខាងដើមនេះ ដូច្នេះធ្វើឱ្យអ្នកស្រាវជ្រាវបែរទៅពិនិត្យផ្ទៀងផ្ទាត់លទ្ធផលរកឃើញរបស់គេជាមួយនឹងអ្នកដែលខ្លួនបានស្រាវជ្រាវជាមួយ ពោលគឺផ្តល់បទសំភាសន៍។

ការឆ្លុះបញ្ចាំងលើលទ្ធផលស្រាវជ្រាវជាមួយនឹងអ្នកពាក់ព័ន្ធផ្សេងៗ ជាពិសេសនៅលំដាប់សហគមន៍ គឺជាវិធីយ៉ាងសំខាន់មួយសំរាប់បញ្ជាក់ថា ការស្រាវជ្រាវពិតជាបកស្រាយ និងស្វែងរកពត៌មានគ្រប់គ្រាន់នូវបញ្ហា ឬស្ថានភាពដែលបានសិក្សាស្រាវជ្រាវ។ វាជាឱកាសមួយផងដែរសំរាប់ឱ្យអ្នកស្រាវជ្រាវបំភ្លឺចំណុចជាកង្វល់ដែលគាត់ក្តាប់មិនច្បាស់ (ឧទាហរណ៏ ភាពមិនស៊ីគ្នា ឬផ្ទុយគ្នានៅក្នុងលទ្ធផលរកឃើញរបស់គាត់) ក្រៅពីការទទួលប្រយោជន៍ពីការផ្តល់យោបល់ពីអ្នកដែលត្រូវបានស្រាវជ្រាវជាមួយ។ ដូចដែលមានលើកឡើងមកខាងលើនេះស្រាប់ ហេតុផលសំខាន់ជាងនេះទៀតគឺការធ្វើដូច្នេះ ដើម្បីផ្តល់លទ្ធភាពក្នុងការបានទទួលដឹងឮលទ្ធផលរកឃើញ នៅក្នុងចំណោមអ្នកផ្តល់ពត៌មានសំខាន់ៗដែលមិនមានពេល និងថវិកា ដើម្បីតាមរកមើលលទ្ធផលនៃសកម្មភាពប្រមូលទិន្នន័យរបស់អ្នកស្រាវជ្រាវនោះ។ ក្រៅពីការដឹងឮពីលទ្ធផលរកឃើញ និងពិនិត្យមើលលើភាពពិតរបស់វា ព្រមទាំងគ្របដណ្តប់ពត៌មានទូលំទូលាយជាទីគាប់ចិត្ត (ដោយរួមទាំងសេចក្តីសន្និដ្ឋាន និងអនុសាសន៍) ការធ្វើឱ្យដឹងឮនេះ ក៏ផ្តល់ការបើកច្រកដល់អ្នកប្រើប្រាស់លទ្ធផលនៃការស្រាវជ្រាវឯទៀត យកលទ្ធផលទៅអនុវត្តជាក់ស្តែង។

អ្នកចូលរួមនៅក្នុងការធ្វើការឆ្លុះបញ្ចាំងបែបនេះអាចថា អ្នកយកលទ្ធផលស្រាវជ្រាវទៅប្រើផ្ទាល់ ឬភ្លាមៗ ប្រើដោយផ្ទាល់ និង/ឬអ្នកប្រើក្នុងពេលចំពោះមុខនៃការស្រាវជ្រាវ។ ជាញឹកញាប់ អ្នកអានឯកសារស្រាវជ្រាវរបស់អ្នកស្រាវជ្រាវអាចមានតំណាងនៃសំណាកគំរូរបស់គាត់ (ឧទាហរណ៏ គ្រួសារដែលមានសមាជិកប្រើប្រាស់ថ្នាំញៀន អ្នករងនឹងអំពើហឹង្សានៅក្នុងគ្រួសារ អាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់ពត៌មានសំខាន់ៗនៅក្នុងភូមិអ្នកដទៃទៀតនៅក្នុងភូមិ ដែលមិនរងនូវការប៉ះពាល់ដោយបញ្ហា ។ល។) និងអ្នកដែលមានធនធានដែលអាចធ្វើឱ្យគេមានការផ្លាស់ប្តូរគួរឱ្យកត់សំគាល់ចំពោះអ្នកដែលប៉ះពាល់ដោយបញ្ហាណាមួយ (ឧទាហរណ៏ បុគ្គលិកចុះធ្វើការនៅតាមមូលដ្ឋានរបស់អង្គការមិនមែនរដ្ឋាភិបាល អ្នកគ្រប់គ្រងផ្នែកអភិវឌ្ឍន៍ អ្នករៀបចំគោលនយោបាយ ។ល។)។ ពីព្រោះអ្នកចូលរួមទាំងពីរក្រុមនេះមានលក្ខណៈខុសគ្នានៅត្រង់ចំណាប់អារម្មណ៏ សេចក្តីត្រូវការផ្នែកពត៌មាន ការមានពេលវេលា ភាសា និងកំរិតវប្បធម៌របស់គេ ដូច្នេះនៃការបង្ហាញត្រូវបានកែសំរួលស្របទៅតាមស្ថានភាពដែរ (Narayan, 1996:134)។ ឧទាហរណ៏ សមាជិកសហគមន៍ប្រហែលចង់ឮលទ្ធផលរកឃើញតាមការបកស្រាយផ្ទាល់មាត់ជាមួយនឹងរបស់លើកបង្ហាញរូបភាពខ្លះៗ។ តែអ្នកដែលស្ថិតនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកធ្វើគោលនយោបាយប្រហែលចង់បានសេចក្តីសង្ខេបរួមសំរាប់បង្ហាញទាំងមូលមុននឹងចូលរួមការប្រជុំផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ។

ដំណើរការនៃការបកស្រាយលទ្ធផលរកឃើញ និងការផ្តល់យោបល់ គឺមានសារៈសំខាន់ណាស់ដល់ការឆ្លុះបញ្ចាំងបែបនេះ ។ ការប្រជុំនេះអាចធ្វើពាក់កណ្តាលថ្ងៃ ទៅមួយថ្ងៃពេញអាស្រ័យលើអ្នកចូលរួមហើយ ក៏គួរតែគេគ្រោងរៀបចំធ្វើយ៉ាងណាឱ្យអ្នកដែលមិនសូវបាននិយាយ មានឱកាសនិយាយផង ។ បើអ្នកចូលរួមមានពេល គេថាការប្រជុំពិភាក្សាជាក្រុមតូចៗដើម្បីគេអាចបញ្ចេញកង្វល់/ទស្សនៈរបស់គេស្តីពីលទ្ធផលរកឃើញ ។ អ្នកស្រាវជ្រាវអាចអញ្ជើញអ្នកចូលរួមនៅក្នុងពេលពិភាក្សាជាក្រុមនេះនិយាយពីអ្វីដែលគេយល់ថា អ្វីខ្លះដែលអាចដោះស្រាយ និងជំរើសផ្សេងទៀត ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ ។

ដោយបានចំណាយពេលដើម្បីធ្វើការឆ្លុះបញ្ចាំងលើលទ្ធផលរកឃើញ ជាមួយនឹងអ្នកស្រាវជ្រាវ អាចបង្កើយរបាយការណ៍របស់ខ្លួនបាន ។ ឯកសារចុងក្រោយគួរតែឆ្លុះបញ្ចាំងទៅលើការផ្តល់យោបល់ដែលទទួលបាន អាចជួយកែសំរួលនៃទិន្នន័យ ឬការបកស្រាយទិន្នន័យតាមការយល់ឃើញថ្មីៗ ឬអនុសាសន៍បន្ថែម ។ លើសពីនេះទៀត អ្នកស្រាវជ្រាវត្រូវធ្វើយ៉ាងណាឱ្យឯកសារចុងក្រោយរបស់ខ្លួន ត្រូវបានកែសំរួលបកប្រែជាភាសាជាតិ ហើយត្រូវបានផ្សព្វផ្សាយទៅឱ្យអ្នកដែលនឹងយកលទ្ធផលទៅប្រើប្រាស់ជាចុងក្រោយ ។

# ជំហានទី ១០: ផ្សព្វផ្សាយលទ្ធផលរកឃើញ

# ជំហ៊ានទី ១០: ផ្សព្វផ្សាយលទ្ធផលរកឃើញ

*ការបោះពុម្ពផ្សាយរបាយការណ៍: ការបែងចែកឱ្យតាមបណ្ណាល័យ .... ការប្រជុំផ្សព្វផ្សាយ ....ការប្រកាសតាមវេបសាយ ..... ការឧទ្ទេសនាមរបាយការណ៍តាមវេទិកាផ្សេងៗ..... ។*

ជំហ៊ានចុងក្រោយនៅក្នុងការធ្វើការសិក្សាស្រាវជ្រាវខ្នាតតូច គឺផ្សព្វផ្សាយលទ្ធផលរកឃើញ។ ពិតមែនតែវាស្រដៀងគ្នានឹងការឆ្លុះបញ្ចាំងដែលអ្នកស្រាវជ្រាវទើបតែធ្វើនៅជំហ៊ានទី៩ក្តី តែជំហ៊ាននេះគឺស្តីពីការធ្វើឱ្យលទ្ធផលរកឃើញ/របាយការណ៍ស្រាវជ្រាវ/បានដល់មនុស្សទូទៅ/ដោយមាន ឬគ្មានការសំរបសំរួល ឬវត្តមាននៃអ្នកស្រាវជ្រាវ។ ការផ្សព្វផ្សាយរបាយការណ៍ស្រាវជ្រាវបំរើគោលបំណងច្រើន គឺដើម្បីគាំទ្រដំណោះស្រាយដែលលើក ឡើង ឬបង្ហាញពីវិធីផ្សេងចំពោះការវិភាគបញ្ហាសង្គម ដើម្បីបង្ហាញពីនិតិវិធីថ្មីៗដែលអ្នកស្រាវជ្រាវបានប្រើ និងធ្វើឱ្យមានការយល់ដឹងលើបញ្ហាដែលមានសារៈសំខាន់ ។ល។ ការស្រាវជ្រាវផ្នែកសង្គមមានបំណងរកមើលចំលើយចំពោះបញ្ហាផ្សេងៗ ហើយនៅក្នុងន័យនេះ ទើបធ្វើឱ្យការផ្សព្វផ្សាយឯកសារស្រាវជ្រាវពិតជាមានសារៈសំខាន់។ ការសំរេចចិត្តថា តើអ្នកណាគួរទទួលរបាយការណ៍ស្រាវជ្រាវ ជាទូទៅត្រូវបានកំណត់តាំងពីដើមទីនៃការសិក្សាស្រាវជ្រាវ ជាពិសេសនៅក្នុងដំណាក់កាលនៃការរៀបចំប្លង់នៃការស្រាវជ្រាវមកម្ល៉េះ។

មានវេទិកាច្រើនដែលគេអាចផ្សព្វផ្សាយរបាយការណ៍ស្រាវជ្រាវដល់សាធារណៈជនបានដូចជា:

- ការបោះពុម្ពផ្សាយតាមលក្ខណៈផ្សេងៗ : ផ្សាយជារបាយការណដោយឡែក ឬជាអត្ថបទមួយនៅក្នុងទស្សនាវដ្តីវិទ្យាសាស្រ្ត ផ្សាយតាមវេបសាយរបស់អ្នកស្រាវជ្រាវ ឬវេបសាយរបស់អង្គការដទៃចំលងដាក់ក្នុងស៊ីឌីដែលជាការមានសារៈសំខាន់ ជាពិសេសសំរាប់ការសិក្សាស្រាវជ្រាវបែបគុណភាពដែលចងក្រងនូវកង្វល់ ឬបញ្ហាសំខាន់ៗ។

- ធ្វើបទបង្ហាញនៅក្នុងការប្រជុំបច្ចេកទេសនៅក្នុងប្រទេសនៅក្នុងតំបន់និងក្រៅតំបន់។ នៅក្នុងប្រទេសកម្ពុជា ការប្រជុំបែបនេះ ខ្លះរួមមានសមាជស្រាវជ្រាវផ្នែកវប្បធម៌សង្គមប្រចាំឆ្នាំនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ការប្រជុំប្រចាំឆ្នាំរបស់ដៃគូរបស់ CCC-ADI ដែលរួមមានសិក្ខាសាលាបង្ហាលទ្ធផលស្រាវជ្រាវ ការពិភាក្សាតុមូលស្តីពីបញ្ហា ការប្រជុំផ្សេងៗនៃក្រុមការងាររបស់អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នរដ្ឋាភិបាលស្តីពីបញ្ហាអភិវឌ្ឍផ្សេងៗ និងការប្រជុំក្រៅផ្លូវការដូចជានាទីតុកាហ្វេរបស់ VBNK។

- ការប្រជុំធ្វើផែនការជាមួយនឹងម្ចាស់ជំនួយ និង/ឬអង្គការនានា/អង្គការមិនមែនរដ្ឋាភិបាល ដែលទទួលបានការគាំទ្រពីម្ចាស់ជំនួយដូចគ្នា（ពោលគឺការប្រជុំនៃដៃគូរបស់ម្ចាស់ជំនួយ）។

- ការចែកចាយរបាយការណ៍ស្រាវជ្រាវដល់អង្គការ ដែលធ្វើការទាក់ទងនឹងបញ្ហាស្រាវជ្រាវ ឬអង្គការឯទៀត ដែលអ្នកស្រាវជ្រាវតែងតែមកទំនាក់ទំនងរកឯកសារសំរាប់ការស្រាវជ្រាវរបស់ពួកគេ។

ជាមួយនឹងការបង្ហើយជំហ៊ានចុងក្រោយនេះ អ្នកស្រាវជ្រាវ ឬក្រុមអ្នកស្រាវជ្រាវប្រហែលចង់ចាប់ផ្តើមគិតពីការស្រាវជ្រាវមួយរឿងទៀត ដោយសារទទួលបានមេរៀនច្រើន និងមានភាពចាស់ទុំក្នុងការស្រាវជ្រាវកន្លងមក នឹងនាំឱ្យបានទទួលជោគជ័យសំរាប់ការស្រាវជ្រាវលើកក្រោយៗទៀត។

# ឯកសារពិគ្រោះ

# ឯកសារពិគ្រោះ

Agresti, Alan and Barbara Finlay. 1986. Statistical Methods for the Social Sciences. Englewood Cliffs, NJ: Prentice Hall, Inc.

Babbie, Earl. 1998. *The Practice of Social Research.* Eighth Edition. Belmont, CA: Wadsworth Publishing Company.

Berg, Bruce L. 1989. *Qualitative Research Methods for the Social Sciences.* Boston: Allyn and Bacon.

Brown, L. David and Rajesh Tandon. 1983. "Ideology and Political Economy in Inquiry: Action Research and Participatory Research" *The Journal of Applied Behavioural Science.* Volume 19, No. 3, JAI Press, Inc.

Burkey, Stan. 1993. *People First: A Guide to Self-Reliant Participatory Rural Development*. London: Zed Books.

Burns, Robert B. 2000. *Introduction to Research Methods*. London: Sage Publications.

CARERE. 1999. *Training Manual: Project Monitoring and Evaluation*. Phnom Penh: UNDP-CARERE.

Catalla, Rebecca F. 1993. *Programme Evaluation*. Unpublished paper written in partial fulfilment of graduate course requirements in Agricultural Education and Studies 524, Fall 1993, Iowa State University.

Chambers, Robert. 2002. *Participatory Workshops: A Sourcebook of 21 Sets of Ideas and Activities.* London: Earthscan Publications Ltd.

Cooperation Committee for Cambodia (CCC). 2000. *Conducting A Small Research Study: Ten Steps to Analysis.* Phnom Penh: Analyzing Development Issues Project, December 2000.

Dale, Reidar. 2003. "The Logical Framework: An Easy Escape, A Straitjacket, or a Useful Planning Tool?" *Development in Practice*, volume 13, number 1, February 2003.

Feuerstein, Marie-Thérèse. 1986. *Partners in Evaluation: Evaluating Development and Community Programmes with Participants*. New York: McMillan Publishers.

Fink, Arlene and Jacqueline Kosecoff. 1985. *How to Conduct Surveys: A Step-by-Step Guide.* Beverly Hills, CA: Sage Publications.

Fowler, Floyd Jr. J. 1993. *Survey Research Methods.* $2^{nd}$ ed. Newbury Park, CA: Sage Publications.

Gajanayake, Stanley and Jaya Gajanayake. 1993. *Community Empowerment: A Participatory Training Manual on Community Project Development*. New York: PACT Publications.

Hudelson, Patricia M. 1996. *Qualitative Research for Health Programmes*. Geneva: World Health Organisation.

International Institute of Rural Reconstruction (IIRR). 1996. *Recording and Using Indigenous Knowledge: A Manual*. Silang (Cavite), Philippines: IIRR.

Johnson, Allan G. 1995. *The Blackwell Dictionary of Sociology: A User's Guide to the Sociological Language*. Oxford: Blackwell Publishers Ltd.

Kumar, Krishna (ed). 1993. *Rapid Appraisal Methods.* Washington, DC: The International Bank for Reconstruction and Development/ The World Bank.

Kumar, Somesh. 2002. *Methods for Community Participation: A Complete Guide for Practitioners.* London: Intermediate Technology Development Group (ITDG) Publishing.

Lewis-Beck, Michael S., Alan Bryman, and Tim Futing Liao (eds). 2004. *The Sage Encyclopedia of Social Science Research Methods, Volumes 1-3.* Thousand Oaks, CA: Sage Publications.

Lofland, John and Lyn H. Lofland. 1984. A*nalysing Social Settings: A Guide to Qualitative Observation and Analysis.* Belmont, CA: Wadsworth Publishing Company.

Marshall, Catherine and Gretchen B. Rossman. 1989. *Designing Qualitative Research.* Newbury Park, CA: Sage Publications.

Mason, Jennifer. 1996. *Qualitative Researching.* London: Sage Publications.

McAndrew, John P. 2000. "Field Study Report – Indigenous Adaptation to a Rapidly Changing Economy: The Experience of Two Tampuan Villages in Northeast Cambodia" *Bulletin of Concerned Asian Scholars,* 32(4): 39-52

McDermott, Robert J. and Paul D. Sarvela. 1999. *Health Education Evaluation and Measurement: A Practitioner's Perspective.* WCB/ McGraw Hill Companies, Inc.

*Narayan, Deepa. 1996.* Toward Participatory Research. *World Bank Technical Paper Number 307. Washington D.C.: The World Bank*

Neuman, W. Lawrence. 2000. *Social Research Methods: Qualitative and Quantitative Approaches,* Fourth edition. Needham Heights, MA: Allyn and Bacon.

Online Writing Lab (OWL). 1995-2004. *The Paragraph.*

http://owl.english.purdue.edu/handouts/print/general/gl_pgrph2.html

Patton, Michael Q. 1987. *Utilization-Focused Evaluation.* Newbury Park, CA: Sage Publications.

Pretty, Jules N, Irene Guijt, Ian Scoones, and John Thompson. 1995. A Trainer's Guide for Participatory Learning and Action. London: International Institute for Environment and Development (IIED).

Shah, Vimal. 1972. *Reporting Research.* Papers on Survey Research Methodology. New York: Agricultural Development Council (A/D/C).

Sproull, Natalie L. 2002. *Handbook of Research Methods: A Guide for Practitioners and Students in the Social Sciences.* London: The Scarecrow Press, Inc.

*Theis, Joachim and Heather M. Grady. 1991.* Participatory Rapid Appraisal for Community Development. *London: International Institute for Environment and Development (IIED).*

*Vogt, W. Paul. 1993.* Dictionary of Statistics and Methodology: A Non-technical Guide for the Social Sciences. *Newbury Park, CA: Sage Publications.*

*Washburn University Writing Centre (WUWC). 1994.* Building Paragraphs.

*http://www.washburn.edu/services/zzcwwctr/paragraphs.txt*

*Wolcott, Harry F. 1990.* Writing Up Qualitative Research. *Newbury Park, CA: Sage Publications.*

Yin, Robert K. 1994. *Case Study Research: Design and Methods.* Applied Social Research Methods Series, Volume 5. Thousand Oaks, CA: Sage Publications.

# ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធ ១: ការសិក្សាស្រាវជ្រាវរបស់ក្រុម ADI ........ ១៦៣

ឧបសម្ព័ន្ធ ២: សន្ទានុក្រម ........ ១៦៤

ឧបសម្ព័ន្ធ ៣: ទំហំ ឬជ្រុងនៃការវិភាគ ........ ១៦៧

ឧបសម្ព័ន្ធ ៤: វិធីសាស្ត្រមួយចំនួនអំពីការរៀនសូត្រ និងធ្វើសកម្មភាពតាមការចូលរួម ..... ១៦៩

ឧបសម្ព័ន្ធ ៥: ការជ្រើសរើសសំណាកតាមវិធីបែងចែកជាស្រទាប់ពីរដំណាក់កាល ........ ១៧១

ឧបសម្ព័ន្ធ ៦: បញ្ជីឯកសារដែលត្រូវបានជ្រើសរើសសំរាប់ការអានជាបន្តទៀត ........ ១៧៤

ឧបសម្ព័ន្ធ ៧: សំណួរដែលគេតែងតែសួរញឹកញាប់ ........ ១៧៥

## ឧបសម្ព័ន្ធ ១

# ឯកសារស្រាវជ្រាវរបស់គំរោងអេឌីអាយ

**(របាយការណ៍ទាំងនេះ អាចរកបាននៅគេហទំព័រ** www.ccc-cambodia.org)

១. ការវិវត្តន៍ទៅកាន់វ័យចាស់ជរារបស់ពលរដ្ឋ នៅក្នុងអតីតមូលដ្ឋានដ៏រឹងមាំមួយរបស់ខ្មែរក្រហម: ការស្រាវជ្រាវនៅក្នុងសង្កាត់ពីរ នៅក្នុងទីក្រុងប៉ៃលិន: ខែ វិច្ឆិកា ២០០៦

២. ការប្រឈមមុខ ក្នុងការរស់នៅរបស់ជនពិការ នៅតំបន់ជនបទ ក្នុងប្រទេសកម្ពុជា: ការសិក្សាស្រាវជ្រាវអំពីជនពិការដែលមានបញ្ហាបំលាស់ទីនៅក្នុងបរិបទសង្គម ស្រុកព្រៃវែង ខេត្តព្រៃវែង: ខែមីនា ២០០៦

៣. ឥទ្ធិពលនៃឧស្សាហកម្មកាត់ដេរ ទៅលើជីវភាពរស់នៅ នៅតំបន់ជនបទ: បទពិសោធន៍ដែលទទួលបាន ពីកម្មករកាត់ដេរ និងគ្រួសារនៅជនបទ ក្នុងខេត្តព្រៃវែង: ខែ ឧសភា ២០០៥

៤. អំពើហិង្សាក្នុងគ្រួសារនៅក្នុងតំបន់តាំងទីលំនៅថ្មីជាយដែន នៅប៉ោយប៉ែតដែលមានកំណើនមនុស្សយ៉ាង ឆាប់រហ័ស: ការស្រាវជ្រាវនៅក្នុងភូមិពីរ ក្នុងឃុំប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ: ខែឧសភា ២០០៥

៥. ការលើកកំពស់ ជនជាតិដើមភាគតិច ក្នុងការអោយពួកគេទទួលបាននូវការប្រើប្រាស់ធនធានធម្មជាតិ នៅភូមិភាគឦសាន្តនៃប្រទេសកម្ពុជា: ខែធ្នូ ២០០៤

៦. ការឆ្លើយតបរបស់ជនជាតិដើមភាគតិច ទៅនឹងការថយចុះនៃធនធានធម្មជាតិ: ការសិក្សាស្រាវជ្រាវនៅក្នុងភូមិពីររបស់ជនជាតិស្ទៀង នៅស្រុកស្នួល ខេត្តក្រចេះ: ខែធ្នូ ២០០៤

៧. ការប្រើប្រាស់គ្រឿងញៀនជាបញ្ហាសង្គម: ទស្សនះរបស់ប្រជាជននៅក្នុងភូមិបី នៅជាយក្រុងបាត់ដំបង: ខែមេសា ២០០៤

៨. បទពិសោធន៍របស់ក្រុមប្រឹក្សាឃុំ ក្នុងការលើកកំពស់ការចូលរួមអភិបាលកិច្ចមូលដ្ឋាន: ការសិក្សាពីឃុំ ចំនួន៥: ខែមីនា ឆ្នាំ២០០៤

៩. ការចេញទៅប្រកបការងារនៅប្រទេសថៃ និងព្រំដែនកម្ពុជា-ថៃ និទ្ទាការនាពេលបច្ចុប្បន្ន នៅភូមិចំនួន៤ ក្នុងខេត្តបាត់ដំបង: ខែធ្នូ ២០០៣

១០. ផលប៉ះពាល់នៃឧស្សាហកម្មទេសចរណ៍ មកលើជីវភាពរស់នៅរបស់ប្រជាជន នៅខេត្តសៀមរាប តំបន់ឧទ្យានអង្គរ: ខែធ្នូ ២០០២

១១. ការសិក្សាខ្នាតតូច ស្តីពីការបែងចែកដីធ្លី នៅប្រទេសកម្ពុជា: ចំនុចសំខាន់ៗដែលទទួលបានពីករណី សិក្សាចំនួន៣: ខែវិច្ឆិកា ២០០១

# ឧបសម្ព័ន្ធ ២

# សទ្ទានុក្រម

| លក្ខណៈ (Attribute) | គឺជាធាតុសំខាន់ ឬ គុណភាពអ្វីមួយ ។ |
|---|---|
| សំណួរបិទ (Closed question) | គឺជាសំនួរដែលមានចំលើយច្បាស់លាស់សំរាប់អ្នកឆ្លើយ ។ |
| ការកំណត់កូដ (Coding) | ដំណើរការដែលក្នុងនោះទិន្នន័យដុលឬនៅត្រូវបានគេធ្វើឱ្យប្រែក្លាយឱ្យទៅជាទំរង់ដែលមានលក្ខណៈស្តង់ដាសំរាប់វិភាគនិងរៀបចំតាមកុំព្យូទ័រ (Babbie, 1998:G1) |
| ទំនាក់ទំនងទៅវិញ ទៅមក (Correlation) | កំរិតនៃចំនួនពីរឬច្រើនមានការទាក់ទងគ្នា ដែលមាននៅក្នុងការស្រាវជ្រាវបែប បរិមាណត្រូវបានគេគណនារកសន្ទស្សន៍មួយ ដែលគេហៅថា មេគុណបង្ហាញទំនាក់ទំនងគ្នា (Correlation coefficient) ។ |
| តារាងបូកសរុបទិន្នន័យ (Dummy Table) | គឺជាតារាងទទេដែលត្រូវបានបង្កើតឡើងមុនពេលទិន្នន័យត្រូវបានគេប្រមូល ហើយដែលគេដាក់ទិន្នន័យចូលនៅពេលប្រមូលបានមក (Vogt, 1993:75) ។ |
| ចំនួនចំលើយ (Frequency) | គឺចំនួនដងដែលហេតុការណ៍ប្រភេទណាមួយកើតឡើងឬចំនួនបុគ្គលឬគ្រួសារនៅក្នុងក្រុមណាមួយ (ឧទាហរណ៍ ចំនួនគ្រួសារដែលមានការពាក់ពន្ធ័ការប្រើថ្នាំពៀនត្រូវបានផ្តុំជាក្រុមទៅតាមភូមិដែលត្រូវបានយកមកសិក្សា ។) |
| របាយនៃចំនួនចំលើយ (Frequency of distribution) | គឺជាវិធីនៅក្នុងការបង្ហាញទិន្នន័យដែលរៀបរាប់នូវចំនួនករណីដែលមានធាតុជាច្រើននៅក្នុងអថេរមួយ ។ (ឧទាហរណ៍ តើមានមនុស្សប៉ុន្មាននាក់នៅក្រោមអាយុ ១៨ ឆ្នាំ ដែលមិនចូលសាលាត្រឹមត្រូវ បានរៀនត្រឹមថ្នាក់ទាបនៅក្នុងបឋមសិក្សា បានរៀនដល់ថ្នាក់ខ្ពស់ក្នុងបឋមសិក្សា មធ្យមសិក្សាបឋមភូមិ ។ល ។) |
| សំណួរគោល (Guide questions) | គឺជាបណ្តុំនៃសំណួរដែលត្រូវបានប្រើជាញ្ញឹកញាប់សំរាប់បច្ចេកទេសសំភាសន៍បែប គុណភាពដូចជាការពិភាក្សាជាក្រុមតូច និងការសំភាសន៍ជាមួយបុគ្គលសំខាន់ៗ ។ |
| បញ្ជីសំណួរសំរាប់សំភាសន៍ផ្ទាល់ (Interview Schedule) | បញ្ជីនៃសំណួរ និងប្រឡោះសំរាប់សរសេរចំលើយរបស់អ្នកសំភាសន៍ ប្រើប្រាស់ក្នុងពេលសំភាសន៍ (Vogt, 1993:116) ។ |
| ការសំភាសន៍ជាមួយនឹងបុគ្គលសំខាន់ៗ (key informant interviews) | គឺជាការសំភាសន៍បែបគុណភាពជាមួយនឹងក្រុមបុគ្គលដែលត្រូវបានជ្រើសរើសដែលអាចផ្តល់ពត៌មាន យោបល់ដែលគេត្រូវការ ទាក់ទងនឹងបញ្ហាណាមួយ ។ |

| | |
|---|---|
| មធ្យមភាគ (Mean) | គឺចំនួនមធ្យមដែលគេគណនាដោយបូកសរុបតំលៃនៃសេចក្តីសង្កេតជាច្រើនរួចចែកនឹងចំនួន នៃសេចក្តីសង្កេតរួម ។ |
| សំណួរបើក (Open-ended questions) | គឺសំណួរដែលក្នុងនោះប្រភេទ/បែបផែននៃចំលើយត្រូវបានផ្តល់ដោយអ្នកឆ្លើយជាជាងដោយអ្នកស្រាវជ្រាវ ឬអ្នកសំភាសន៍ ។ សំណួរបែបនេះត្រូវបានគេស្គាល់តាមបែបម្យ៉ាងទៀតថា ជាសំណួរគុណភាព ឬសំណួរដែលមានលក្ខណៈចំហរ (Lewis-Beck et al, 2004:768) ។ |
| ភាគរយ (Percentage) | មានន័យថាផ្នែកមួយនៃអ្វីមួយទាក់ទងនឹងចំនួនឬទំហំទាំងមូលដែលតាមធម្មតាគេគិតជាភាគរយ ។ ដើម្បីគណនាភាគរយ គេចែកចំនួនវត្ថុ ឬមនុស្ស នៅក្នុងក្រុមដោយចំនួនសរុបនៅក្នុងក្រុមនោះហើយគុណនឹង ១០០(Feurstein, 1986:122) ។ |
| បញ្ជីសំនួរ (Questionnaire) | ជាបណ្តុំនៃសំណួរ សំរាប់យកទៅសួរអ្នកផ្តល់ចំលើយដោយផ្ទាល់ ហើយគេក៏អាចផ្ញើរបញ្ជីសំណួរដើម្បីអោយអ្នកឆ្លើយអាចសរសេរចំលើយរបស់គេទៅតាមសំណួរនិមួយៗ (Vogt, 1993:184) ។ |
| ភាពឆ្លុះបញ្ចាំង (Reflexivity) | សំដៅលើភាពប៉ិនប្រសព្វរបស់អ្នកស្រាវជ្រាវ ដើម្បីឆ្លុះបញ្ចាំងទៅលើតួនាទីរបស់ពួកគេនៅក្នុងដំណើរការស្រាវជ្រាវ ជាពិសេស ដើម្បីកំណត់មើលពីគំរិតនៃភាពលំអៀងនៅក្នុងការស្រាវជ្រាវ ព្រោះគេជាអ្នកមានតួនាទីសំខាន់ ក្នុងដំណើរការស្រាវជ្រាវ ។ |
| ភាពអាចទុកចិត្តបាន (Reliability) | គឺស្តីពីភាពស៊ីគ្នា ភាពអាចពឹងផ្អែកបាន ភាពត្រឹមត្រូវនៃឧបករណ៍ប្រមូលទិន្នន័យដែលមានន័យថាសំណួរនៅក្នុងឧបករណ៍ប្រមូលទិន្នន័យតែមួយផ្តល់នូវចំលើយស៊ីគ្នានិង/ឬមានភាពស៊ីគ្នា នៅពេលគេសួរទៅអ្នកឆ្លើយផ្សេងទៀត ហើយផ្តល់ភស្តុតាងដែលអាចយកជាការបាន អំពីបញ្ហាដែលកំពុងតែស្រាវជ្រាវ ។ |
| សំណាក (Sample) | កម្មវត្ថុមួយក្រុមដែលត្រូវបានជ្រើសរើសចេញពីក្រុមធំមួយដោយរំពឹងថា ការសិក្សាទៅលើក្រុមតូចដែលជ្រើសរើសនេះ (គេហៅថា សំណាក) នឹងបង្ហាញអ្វីៗដែលមានសារៈសំខាន់ ឬតំណាងអោយក្រុមធំដែរ (គេហៅថា ប្រជាជន) (Vogt, 1993:200) ។ |
| ក្របខ័ណ្ឌនៃសំណាក (Sampling Frame) | ជាបញ្ជីនៃវត្ថុ ឬមនុស្ស ដែលជាគោលសំខាន់សំរាប់យកមកធ្វើការជ្រើសរើស សំណាក (Babbie, 1998:G6) ។ |

| | |
|---|---|
| វិធីចំរុះនៃការស្រាវជ្រាវ (Triangulation) | ចង់សំដៅលើ "ការប្រើវិធីលើសពីមួយនៅក្នុងការអង្កេតលើសំណួរស្រាវជ្រាវមួយ ដើម្បីបង្កើនទំនុកចិត្តលើលទ្ធផលរកឃើញ (Lewis-Beck et al, 2004:1142) ។ វិធីនេះមានច្រើនប្រភេទគឺ *វិធីចំរុះសំរាប់ផ្ទៀងផ្ទាត់ទិន្នន័យ* ដែលក្នុងនោះគេធ្វើការវាស់វែងតាមច្រើនបែបចំពោះបញ្ហា ឬហេតុការណ៍តែមួយ ដើម្បីឱ្យអ្នកស្រាវជ្រាវអាចពិនិត្យទិដ្ឋភាពផ្សេងៗរបស់វា ។ ប្រភេទមួយទៀតគឺ *វិធីចំរុះសំរាប់អ្នកអង្កេត* គឺសំដៅលើការប្រើប្រាស់អ្នកស្រាវជ្រាវលើសពីម្នាក់នៅក្នុងការប្រមូលនិងបកស្រាយទិន្នន័យ ។ ដោយឡែក *វិធីចំរុះតាមលក្ខណៈទ្រឹស្តី* ឬគេហៅថា ការប្រើប្រាស់មូលដ្ឋានទ្រឹស្តីច្រើន ដើម្បីយកមកបកស្រាយទិន្នន័យ ។ នៅមានប្រភេទមួយទៀតគឺ វិធីចំរុះតាមលក្ខណៈវិធីសាស្ត្រ គឺការយកវិធីជាច្រើនមកផ្សំដើម្បីប្រើប្រាស់ (ឧទាហរណ៍ ឧបករណ៍បែបបរិមាណ និងបែបគុណភាព) សំរាប់ប្រមូលទិន្នន័យ ។ |
| ឯកតានៃការវិភាគ (Unit of analysis) | ជាអ្វីឬនរណាដែលត្រូវបានស្រាវជ្រាវ (Babbie, 1998:G7) ។ នៅក្នុងការសិក្សាស្រាវជ្រាវ ផ្នែកសង្គម ឯកតានៃការវិភាគភាគច្រើនដែលគេប្រើគឺ បុគ្គល ឬគ្រួសារ ។ |
| សុពលភាព (Validity) | មានទំនាក់ទំនងគ្នាយ៉ាងខ្លាំងទៅនឹងភាពអាចទុកចិត្តបាន(Reliability)ព្រោះវាមានន័យថាជាការមាននូវឧបករណ៍ប្រមូលទិន្នន័យមួយ សំរាប់យកមកវាស់វែងទៅលើអ្វី ដែលគេមានបំណងចង់វាស់ ។ វាតំណាងអោយ ភាពសមស្រប មានខ្លឹមសារ និងសារៈប្រយោជន៍នៃការគិតពិចារណាដែលបានមកពីទិន្នន័យដែលប្រមូល ។ |
| អថេរ (Variables) | គឺជាសំណុំនៃធាតុជាច្រើន ។ ឧ. ភេទគឺជាអថេរមួយដែលបង្ហាញនូវ លក្ខណៈធាតុពីរ គឺ ស្ត្រី និងបុរស (Babbie, 1998: 141) |

# ឧបសម្ព័ន្ធ ៣

# ទំហំ ឬជ្រុងនៃការវិភាគ
**(Dimensions of Analysis)**

### កំរិតនិងទំហំនៃការវិភាគ

| កំរិត/ឯកតានៃការវិភាគ | ជ្រុងនៃការវិភាគ | | | | | |
|---|---|---|---|---|---|---|
| | សង្គម-វប្បធម៌ | ច្បាប់ -នយោបាយ | សេដ្ឋកិច្ច-ហិរញ្ញវត្ថុ | បច្ចេកវិទ្យា | ហេដ្ឋារចនាសម្ព័ន្ធ | បរិស្ថានរូបវ័ន្ត |
| **កំរិតម៉ាក្រូ** | | | | | | |
| កំរិតម៉ាក្រូឆ្លងកាត់ប្រទេស/តំបន់ | | | | | | |
| កំរិតម៉ាក្រូ (តាមប្រទេសនីមួយៗ) | | | | | | |
| **កំរិតមីក្រូ** | | | | | | |
| បុគ្គល | | | | | | |
| គ្រួសារ | | | | | | |
| ឃុំ/សង្កាត់ | | | | | | |
| អង្គការ/សមាគមន៍/ក្រុម | | | | | | |
| សកម្មភាពសង្គម/ការប្រតិបត្តិ ។ល ។ | | | | | | |

៧/. កំរិតមីតាគឺ: **មេសូ** ត្រូវបានគេប្រើសំរាប់វិភាគទៅលើបញ្ហា/កម្មវិធី ។ល។ កំរិតមេសូ ជាចម្លាត ផ្តោតលើបញ្ហានានាដែលនៅចន្លោះ កំរិតម៉ាក្រូ និង មីក្រូ ដូចជាលក្ខណៈ ឬធាតុទាំងឡាយណា ដែលមានផលប៉ះពាល់មកលើបញ្ហាមីក្រូ និងម៉ាក្រូ ។

ផ្នែកចំនួនប្រាំមួយដែលត្រូវបានបង្ហាញនៅក្នុងតារាងខាងលើនេះ តំណាងឱ្យសមាសភាគសំខាន់ៗចំនួន៦ គឺ បរិស្ថានរូបវ័ន្ត លក្ខខ័ណ្ឌផ្នែកសង្គមវប្បធម៌ បរិបទផ្នែកនយោបាយនិងច្បាប់ ស្ថានភាពជាក់ស្តែងផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថានភាពបច្ចេកវិទ្យា និងលក្ខខ័ណ្ឌនៃហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ។ ទាំងអស់នេះត្រូវបានរៀបរាប់ ដូចខាងក្រោមនេះ :

**បរិស្ថានរូបវ័ន្ត** (Physical environment) សំដៅលើប្រព័ន្ធអេកូឡូស៊ីដែលមានការទាក់ទងនឹងធនធានធម្មជាតិ ដែលមានសំរាប់មនុស្ស ។ វារួមមានប្រព័ន្ធកសិកម្ម ព្រៃតាមសហគមន៍ ឬតំបន់នេសាទ ។ វាគ្របដណ្តប់ផងដែរ លើធនធានដូចជាព្រៃឈើរុក្ខជាតិ ធនធានរ៉ែ រួមទាំងអាកាសធាតុ និងគ្រោះថ្នាក់ធម្មជាតិដូចជាគ្រោះរាំងស្ងួត និងទឹកជំនន់ ។ ការប្តូរទំរង់នៃការប្រើប្រាស់ដីធ្លីពីការធ្វើចំការតូចៗទៅរកការដាំជាចំការធំ (បែបឧស្សាហកម្ម) ឬការប្រើសំរាប់គោលបំណងឧស្សាហកម្ម និងការប្រែប្រួលដីធ្លីក្នុងស្ថានភាពពីជនបទទៅជាទីក្រុង ក៏ស្ថិតនៅក្នុងសមាសភាគនេះដែរ តែគេត្រូវពិនិត្យនៅក្នុងបរិបទនៃទំនាក់ទំនងទៅនឹងផ្នែកជនបទ/កសិកម្ម ។

**លក្ខខ័ណ្ឌផ្នែកសង្គមវប្បធម៌** (Socio-cultural conditions) រួមមានមនុស្សប្រភេទផ្សេងៗដែលមានលក្ខណៈសេចក្តីត្រូវការ និងចំណាប់អារម្មណ៍ខុសៗគ្នា និងមានទំនាក់ទំនងរវាងគ្នានិងគ្នា ដែលក្នុងនោះអំណាច និងជំលោះគ្នាគឺជាបញ្ហាដែលកើតមានជាធម្មតា ។ វារួមមានផងដែរនូវអង្គការសហគមន៍ និងអង្គការសាសនាជាមួយនឹងសកម្មភាព គុណតំលៃ បទដ្ឋានវប្បធម៌ និងប្រពៃណីរបស់គេ ។

**បរិបទនយោបាយ-ច្បាប់** (Political-legal context) ចង់សំដៅលើស្ថាប័នថ្នាក់ជាតិ មន្ទីរនានារបស់រដ្ឋាភិបាល ក្រសួងច្បាប់និងនយោបាយទាំងអស់ដែលមានឥទ្ធិពលទៅលើស្ថានភាព ។

ស្ថានភាពជាក់ស្តែងផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (Economic-financial realities) រួមមានយុទ្ធសាស្ត្រនៅក្នុងការប្រកបជីវភាពរស់នៅដែលប្រជាជនប្រើប្រាស់ដើម្បីចិញ្ចឹមគ្រួសាររបស់គេ ។ វារួមមានផ្សារនៅក្នុងមូលដ្ឋាន ឈ្មួញកណ្តាល និងតំលៃនៅទីផ្សារអន្តរជាតិ ។ លទ្ធភាពទទួលបានចំណេះដឹង និងពតិមានទាក់ទងនឹងការផ្គត់ផ្គង់ និងតំរូវការទីផ្សារគឺមានសារៈសំខាន់ណាស់ ។ រាល់ឱកាស បញ្ហា និងយុទ្ធសាស្ត្រដោះស្រាយទាំងអស់ ក៏ស្ថិតនៅក្នុងផ្នែកនេះដែរ ។ ភាពពិតជាក់ស្តែងដទៃទៀតដែលប៉ះពាល់ទៅលើមនុស្សនៅក្នុងមូលដ្ឋានដូចជា ការមានឥណទាន និងសោហ៊ុយនៃឥណទាន អត្រាប្តូរប្រាក់ ប្រាក់ឈ្នួល និងតំលៃក៏ត្រូវបញ្ចូលក្នុងផ្នែកនេះផងដែរ ។

**និន្នាការបច្ចេកវិទ្យា** (Technological trends) រួមមាន ឧបករណ៍ និងវិធីដែលមនុស្សយកមកប្រើប្រាស់ ។ ការផ្លាស់ប្តូរទាក់ទងនឹងផលប៉ះពាល់នៃបច្ចេកទេសចាស់ និងថ្មីគឺជាវិស័យដែលគេត្រូវពិនិត្យនៅក្នុងផ្នែកនេះ ។

ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ (Existing Infrastructure) សំដៅទៅលើផ្លូវថ្នល់ ស្ពាន ប្រឡាយ អគ្គីសនី បណ្តាញទូរស័ព្ទ ។ល ។

# ឧបសម្ព័ន្ធ ៤

# វិធីសាស្រ្តមួយចំនួនអំពី ការរៀនសូត្រ និងធ្វើសកម្មភាពតាមការចូលរួម (PLA)

- *ប្រភពបន្ទាប់បន្សំ* មានដូចជាឯកសារ របាយការណ៍ ផែនទី រូបថតពីលើអាកាស រូបភាពពីផ្កាយរណប អត្ថបទ និងសៀវភៅ ។
- *សំភាសន៍ពាក់កណ្តាលផ្លូវការ:* ការសំភាសន៏បែបនេះត្រូវបានគេចាត់ទុកជាវិធីស្នូលនៃការវាយតំលៃជនបទឆាប់រហ័ស (RRA) ។ វិធីនេះអាចតំរូវមានជាសំណួរគោលឬសំនួរផ្ទាល់មាត់ ប៉ុន្តែវាជាសំណួរបើក និងអនុលោមទៅតាមពតិមាន ដែលលេចចេញពីអ្នកផ្តល់បទសំភាសន៏ ។
- *អ្នកផ្តល់ពតិមានសំខាន់ៗ:* សាកសួរពតិមានពីអ្នកជំនាញ ជួនកាលតាមរយៈការធ្វើផែនទីសង្គម ដោយមានការចូលរួម ។
- *ប្រភេទក្រុមផ្សេងៗ* (ក្រុមធម្មតា អ្នកជំនាញ ឬក្រុមគោលដៅ ក្រុមដែលរៀបចំទុកបានត្រឹមត្រូវ សហគមន៏ ឬឃុំ/សង្កាត់ជិតខាង)ៈ ការសំភាសន៏ក្រុម គឺជាផ្នែកមួយនៃវិធីសាស្រ្តជាច្រើនទៀត ។
- *ការគូរផែនទីដោយមានការចូលរួម:* ប្រជាជនប្រើឧបករណ៏សំរាប់គូរគឺ គូរលើដី កំរាលឥដ្ឋ ឬក្រដាស ដើម្បីបង្ហាញធនធាន/ស្ថានភាពសង្គម ប្រជាសាស្រ្ត សុខភាព ធនធានធម្មជាតិ (ដី ដើមឈើ ព្រៃឈើ ធនធាន ទឹក ។ល។) សេវាកម្ម និងឱកាស ឬផែនទីកសិដ្ឋាន ឬបង្កើតជាម៉ូដែល៣ជ្រុងនៃដីស្រែរបស់គេ ។
- *ការដើរកាត់ទទឹងភូមិ:* ដើរជាមួយ ឬដើរដោយប្រជាជនមូលដ្ឋានឆ្លងកាត់តំបន់មួយដោយធ្វើការ សង្កេត សួរ ស្តាប់ពិភាក្សា កំណត់តំបន់ផ្សេងៗ ការប្រើប្រាស់ដីផ្សេងៗ ស្ថានភាពជីជាតិដី បន្លែ ដំណាំហូបផ្លែ ការចិញ្ចឹមសត្វ បច្ចេកវិទ្យាក្នុងស្រុក និងនាំចូល ។ល ។ ស្វែងរកបញ្ហា ដំណោះស្រាយ និងឱកាស និងធ្វើផែនទី និងដ្យាក្រាមបង្ហាញតំបន់ធនធានដែលមាន និងលទ្ធផលរកឃើញ ។ រីឯប្រភេទទូទៅនៃការ ដើរកាត់ទទឹងភូមិរួមមាននៅតាមទីចំណោទទីនៅជុំវិញ ។
- *ការវិភាគតាមពេលវេលា និន្នាការ និងការប្រែប្រួល:* ប្រវត្តិព្រឹត្តិការណ៏ ស្រង់នូវព្រឹត្តិការណ៏សំខាន់ៗនៅក្នុងភូមិដោយមានកាលបរិច្ឆេទប្រហាក់ប្រហែល ប្រវត្តិអតីតកាលរបស់មនុស្សទាក់ទងនឹងអ្វីដែលនៅជុំវិញ ខ្លួនមានការប្រែប្រួលនោះ ប្រវត្តិអេកូឡូស៊ី ការផ្លាស់ប្តូរការប្រើប្រាស់ដី និងដំណាំ ការផ្លាស់ប្តូរនូវប្រពៃណី និងការប្រតិបត្តិការប្រែប្រួលចំនួនប្រជាជន ចំណាកស្រុក ការប្រើប្រាស់ថាមពល ការអប់រំសុខភាព ឥណទាន និងបុព្វហេតុនៃការប្រែប្រួល ជាធម្មតាត្រូវបានគេធ្វើដោយមានការចូលរួម និងមានការប៉ាន់ស្មានទៅលើស្ថានការណ៏ខ្លះៗ ។
- *ប្រវត្តិ និងជីវប្រវត្តិជាតិពន្ធ:* ប្រវត្តិដែលនៅចងចាំតៗគ្នា និងប្រវត្តិរបស់មូលដ្ឋាន (ឧទាហរណ៏ ដំណាំ សត្វពាហនៈ ដើមឈើ កត្តាចង្រៃ និងស្មៅ)
- *ប្រតិទិនរដូវកាល:* តាមរដូវ ឬតាមខែ ដោយបង្ហាញពីការប្រែប្រួលក្នុងរដូវដូចជា ថ្ងៃ និងរបាយទឹកភ្លៀងបរិមាណទឹកភ្លៀង សំណើមដី ដំណាំ កំលាំងពលកម្មផ្នែកកសិកម្ម កំលាំងពលកម្មផ្នែកមិនមែនកសិកម្ម របបអាហារ ការហូបចុកប្រភេទជំងឺ តំលៃ ចំណីសត្វ ការប្រើប្រាស់ថាមពល ចំណាកស្រុក ប្រាក់ចំណូល ការចំណាយ ការជំពាក់បំណុល ។ល ។

- *វិភាគការប្រើប្រាស់ពេលប្រចាំថ្ងៃ:* បង្ហាញពីសកម្មភាពនៃចំនួនពេលវេលា ការិតនៃការងារមិនសូវសំខាន់ ជួនកាលបង្ហាញពីការប្រែប្រួលតាមរដូវ ។
- *វិភាគការចិញ្ចឹមជីវិត:* គឺវិភាគលើ ស្ថេរភាព វិបត្តិ និងដំណោះស្រាយ ប្រាក់ចំណូល ការចំណាយ ឥណទាន និងបំណុល សកម្មភាពចំរុះ ដោយគិតតាមខែ ឬរដូវ ។
- *ដ្យាក្រាមទំនាក់ទំនងដោយមានការចូលរួម:* សំដៅលើទំនាក់ទំនង លំហូរ ការទាក់ទង និងហេតុផល ។
- *ដ្យាក្រាមស្ថាបន័ ឬវ៉ែនដ្យាក្រាម:* វិធីនេះកំណត់ពីបុគ្គល និងស្ថាបន័មានសារៈសំខាន់នៅក្នុងសហគមន៍ និងសំរាប់សហគមន៍ ឬនៅក្នុងអង្គការ និងទំនាក់ទំនងរបស់វា ។
- *ចំណាត់ថ្នាក់ទ្រព្យធន និងសុខុមាលភាព:* កំណត់ចំណាត់ថ្នាក់ជាក្រុម ឬគ្រួសារផ្អែកទៅលើសុខមាលភាព ឬទ្រព្យសម្បត្តិ ដោយរាប់ទាំងអ្នកដែលក្រីក្របំផុត ឬមានការលំបាកបំផុត ដែលឱ្យមានការកំណត់រកឃើញនូវសូចនករសំខាន់នៃសុខមាលភាព ។
- *វិភាគទៅលើភាពខុសគ្នា:* ជាពិសេសទៅលើយេនឌ័រ ក្រុមសង្គម ព្រទ្យសម្បត្តិ/ភាពក្រីក្រ មុខរបរ និង អាយុ។ កំណត់រកភាពខុសគ្នារវាងក្រុមចំពោះបញ្ហា និងការចូលចិត្តរបស់គេ។ វិធីនេះរួមទាំងប្រៀបធៀប ពីភាពផ្ទុយគ្នាដោយសួរក្រុមមួយថា ហេតុអ្វីបានជាមួយនេះមានភាពខុសគ្នា ឬក៏ធ្វើអ្វីៗប្លែកពីគេ ហើយ ធ្វើរបៀបនេះរវាងក្រុមមួយទៅក្រុមមួយទៀវិញទៅមក។
- *ម៉ាទ្រិចពិន្ទុ និងរៀបតាមលំដាប់ថ្នាក់:* ជាពិសេស ប្រើម៉ាទ្រិច និងគ្រាប់ពូជ ដើម្បីប្រៀបធៀប តាមរយៈ ការដាក់ពិន្ទុ ឧទាហរណ៍ ប្រភេទដើមឈើ ដី ឬវិធីសាស្ត្រអភិរក្សធនធានដីនិងទឹក ឬប្រភេទដំណាំ ។
- *សំណួរជជីក:* ជាសំណួរអាចសួរសំដៅទៅរកបញ្ហាសំខាន់ៗដូចជា "តើអ្នកពិភាក្សា អំពីអ្វីនៅពេលអ្នក នៅជុំគ្នា?" "តើការប្រតិបត្តិថ្មីអ្វីខ្លះដែលអ្នក និងអ្នកដទៃទៀតនៅក្នុងភូមិ បានធ្វើកាលពីរបីឆ្នាំកន្លងទៅ ថ្មីៗនេះ? "តើបន្លែ ដើមឈើ ដំណាំ ប្រភេទដំណាំ ប្រភេទសត្វពាហនៈ ឧបករណ៍អ្វីដែលចង់សាកល្បង នោះ?" "តើអ្នកធ្វើអ្វីខ្លះ នៅពេលដែលខ្ទម និងផ្ទះរបស់នរណាម្នាក់ ត្រូវបានភ្លើងឆេះអស់?
- *រឿង រូបភាព និងករណីសិក្សា:* មានដូចជា ប្រវត្តិនិងស្ថានភាពគ្រួសារ ការដោះស្រាយនៅពេលមានវិបត្តិដំណើរដើមទងដែលនាំអោយជំលោះត្រូវបាន ឬមិនបានដោះស្រាយ ។

## ឧបសម្ព័ន្ធ ៥

# ការជ្រើសរើសសំណាកតាមវិធីបែងចែកជាស្រទាប់ពីរដំណាក់កាល[២៥]

(Selecting a sample through a two-stratified sampling procedure)

១. កំណត់ចំនួនវត្ថុ ឬមនុស្សដែលត្រូវជ្រើសរើសយកមកសំភាសន៍ក្នុងមួយឃុំ (នៅក្នុងករណីនេះ ចំនួនសរុបដែល គេចង់បានគឺ ២០០)។

ជ្រើសរើសសំណាកដែលសមមាត្រទៅនឹងប្រជាជននៅក្នុងភូមិ ដោយបន្ថែមប្រជាជន គោលដៅនៅក្នុងឃុំនិមួយៗ។ ចំនួនសំណាក ២០០ សំរាប់ខេត្តណាមួយ ត្រូវបានបែងចែកនៅក្នុងចំណោមឃុំ ដោយសមាមាត្រ ទៅនឹងប្រជាជនសរុបនៅក្នុងភូមិទាំងអស់នៅក្នុងឃុំ។ ទំរង់ការនៃការកំណត់សំណាកនេះ គឺមានដូចខាងក្រោមនេះដែលជាឧទាហរណ៍នៅក្នុងខេត្តកំពត ។

| | ប្រជាជននៅក្នុងភូមិដែលនឹងត្រូវជ្រើសរើស | ភាគរយនៃចំនួនសរុប | ចំនួនដែលត្រូវ សំភាសន៍ |
|---|---|---|---|
| ស្រែក្នុង | ៥៣២០ | ១៣ % | ២៦ |
| ច្រេស | ៥៦៨៨ | ១៤ % | ២៨ |
| ស្រែសំរោង | ៤០៩២ | ១០% | ២០ |
| ជម្ពូវ៉ន | ៧២៨០ | ១៨% | ៣៦ |
| ស្នាអញ្ជឹត | ៤៦៤៣ | ១១% | ២២ |
| ត្រពាំងរាំង | ៦១៤៣ | ១៥% | ៣០ |
| ស្រែចែង | ៧៦០៣ | ១៩% | ៣៨ |
| **សរុប** | **៤០,៧៦៩** | **១០០%** | **២០០** |



[២៥] ឧទាហរណ៍នេះគឺផ្អែកលើបទពិសោធន៍នៃការអង្កេតដើម្បីកំណត់ទិន្នន័យដើម នៅឆ្នាំ ២០០៣ របស់អង្គការស៊ីដសេ

២. បង្រួមចំនួនភូមិអោយទៅជាចំនួនសំណាកដែលសមមាត្រទៅនឹងចំនួនភូមិនៅក្នុងឃុំ ដោយចងចាំថា យើងត្រូវការតែភូមិចំនួន ១៥ ទេ សំរាប់ខេត្តនីមួយៗ។ ភូមិទាំង១៥ នៅក្នុងខេត្តនោះ ត្រូវបានបែងចែក នៅក្នុងចំនួនឃុំដែលសមាមាត្រាទៅនឹងចំនួនសរុបនៃភូមិទាំងអស់ដែលនៅក្នុងឃុំ។ សូមមើលឧទាហរណ៍ខាងក្រោមនេះសំរាប់ខេត្តកំពត ។

ភូមិដែលត្រូវកំណត់យកសំណាក ត្រូវបានជ្រើសរើសដោយប្រើទំរង់ការធម្មតានៃការកំណត់សំណាកបែបចៃដន្យ ។

| ឃុំ | ចំនួនសរុបនៃភូមិ | ភាគរយនៃចំនួនសរុប | ចំនួនភូមិក្នុងសំណាកគំរូ |
|---|---|---|---|
| ស្រែក្នុង | ៦ | ២៦% | ៤ |
| ច្រេស | ៤ | ១៧% | ២ |
| ស្រែសំរោង | ៤ | ១៧% | ២ |
| ជម្ពូវ័ន | ៤ | ១៧% | ២ |
| ស្មាអញ្ជើត | ៣ | ១៣% | ២ |
| ត្រពាំងរាំង | ២ | ៩% | ១ |
| ស្រែចែង | ១ | n/a | ១ |
| **សរុប** | **២៤** | ១០០% | ១៥ ($\Sigma$ =14) |

៣. បែងចែកចំនួនសំភាសន៍ដែលត្រូវបានគណនានៅក្នុងឃុំនិមួយៗ អោយទៅជាចំនួនភូមិដែលបានគណនា (ឧទាហរណ៍ ចំនួនសំភាសន៍ ២៦នាក់ នៅក្នុងភូមិសំណាកចំនួន ៤ នៅក្នុងឃុំស្រែក្នុង) ដើម្បីបានចំនួនដែលចង់ បាននៅក្នុងភូមិ។ យើងអាចធ្វើដូច្នេះ ដោយចែកចំនួន ២៦ នៅឃុំស្រែក្នុង ទៅលើភូមិដែលត្រូវបានជ្រើសរើសទាំង ៤ ដោយសមមាត្រទៅនឹងចំនួនគ្រួសារតាមភូមិនិមួយៗនៃភូមិទាំងនោះ ។

| ឃុំស្រែក្នុង | ចំនួនគ្រួសារនៅតាមភូមិដែលសិក្សា[១] | ចំនួនភាគរយនៃចំនួនសរុប | ចំនួនដែលត្រូវសំភាសន៍ |
|---|---|---|---|
| សំណាកភូមិ ១ | ១៣១ | ១៥% | ៤ |
| សំណាកភូមិ ២ | ២៦៧ | ៣០% | ៨ |
| សំណាកភូមិ៣ | ១៩៣ | ២២% | ៦ |
| សំណាកភូមិ៤ | ២៩៩ | ៣៣% | ៨ |
| **សរុប** | ៨៩០ | ១០០% | **២៦** |

[១] តួលេខទាំងនេះ គ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ

៤. ដោយប្រើចំនួនសរុបនៃគ្រួសារដែលត្រូវការនៅក្នុងភូមិ ចូរគណនាប្រភាគក្នុងការកំណត់សំណាកដើម្បីអាចកំណត់សំណាកចៃដន្យជាប្រព័ន្ធពីបញ្ជីនៃគ្រួសារនៅក្នុងភូមិ ។ ការគណនារកចន្លោះ (Interval) គឺមានដូចខាងក្រោមនេះ :

**ចន្លោះសំណាក** = ចំនួនសរុបនៃគ្រួសារនៅក្នុងភូមិ ចែកនឹងចំនួនមនុស្សដែលនឹងត្រូវជ្រើសរើសយកមកសំភាសន៍ពីក្នុងភូមិ

ដូច្នេះ ការចែកគ្រួសារចំនួន ១៣១ នៅក្នុងភូមិសំណាកទី១ ជាមួយនឹងចំនួនសំណាក ៤ នាំឱ្យគេបានចន្លោះសំណាកចំនួន ៣៣ គ្រួសារ ។

ការកំណត់សំណាកអាចត្រូវបានគេធ្វើដោយការដាក់ជំនួស គឺប្រហាក់ប្រហែលនឹងការធ្វើអង្កេតនៅក្នុងឆ្នាំ ១៩៩៨ ដែរ ។ នេះមានន័យថា បើមិនមានមនុស្សធំនៅក្នុងគ្រួសារដែលត្រូវបានជ្រើសរើសអាចចូលរួមការសំភាសន៍ទេនោះ អ្នកស្រាវជ្រាវត្រូវទៅរកគ្រួសារមួយទៀត ពោលគឺគ្រួសារបន្ទាប់នៅក្នុងបញ្ជីធំសំរាប់ភូមិនោះ ។

# ឧបសម្ព័ន្ធ ៦

# បញ្ជីឯកសារបន្ថែមសំរាប់ជំនួយក្នុងការអាន

## ការវិភាគទិន្នន័យសំរាប់ការស្រាវជ្រាវបែបគុណភាព

DATA ANALYSIS FOR QUALITATIVE RESEARCH

Berg, Bruce L. 1989. *Qualitative Research Methods for the Social Sciences*. Boston: Allyn and Bacon.

Mason, Jennifer. 1996. *Qualitative Researching*. London: Sage Publications.

## ការវិភាគទិន្នន័យសំរាប់ការស្រាវជ្រាវបែបបរិមាណ

DATA ANALYSIS FOR QUANTITATIVE RESEARCH

Agresti, Alan and Barbara Finlay. 1986. Statistical Methods for the Social Sciences. Englewood Cliffs, NJ: Prentice Hall, Inc.

Babbie, Earl. 1998. *The Practice of Social Research.* Eighth Edition. Belmont, CA: Wadsworth Publishing Company.

Sproull, Natalie L. 2002. *Handbook of Research Methods: A Guide for Practitioners and Students in the Social Sciences*. London: The Scarecrow Press, Inc.

## ឧបសម្ពន្ធ័ទី ៧

# សំណួរដែលគេតែងតែសួរញឹកញាប់

(** សំរាប់សំណួរសំខាន់បំផុត)

** **តើអ្វីខ្លះជាដំណើរការល្អ ដើម្បីប្រើសំរាប់ជ្រើសរើស រៀបរាប់ និងបំព្រួញនូវចំណេងជើងប្រធានបទស្រាវជ្រាវអោយតូច?**

**ចំលើយ:**

- អ្នកស្រាវជ្រាវបំផុសគំនិត និងសំរេចចិត្តរើសយកពាក្យសំខាន់ៗដែលមានខ្លឹមសារសមស្របបំផុត ដូចនេះចំណេងជើងមាននៅក្នុងពាក្យសំខាន់ៗមួយចំនួន តែគ្របដណ្តប់នូវអ្វីដែលចង់ការសិក្សាស្រាវជ្រាវ ។
- អ្នកស្រាវជ្រាវអាចដកស្រង់យោបល់/ការលើកឡើងរបស់អ្នកផ្តល់បទសំភាសន៍ រួចពិនិត្យឡើងវិញ និងសំរេចចិត្តលើពាក្យទាំងនោះ ដែលគ្របដណ្តប់លើខ្លឹមសារស្រាវជ្រាវ និងប្រើចំណេងជើងរងដែលបង្ហាញពីប្រធានបទនៃស្រាវជ្រាវ ។

** **តើមានធាតុ ឬខ្លឹមសារជាម៉ូដែលមួយ សំរាប់ការសរសេរអំពីការពិពណ៌នាបញ្ហា ឬទេ?**

**ចំលើយ:**

តាមពិត ពុំមានគ្រោង ឬប្លង់ណាមួយប្រាកដនោះទេ ។ ជាទូទៅ ការពិណ៌នាបញ្ហារួមមាន :

- ហេតុអ្វីបានជាប្រធានបទត្រូវបានគេយល់ថា ជាបញ្ហាសំរាប់លើកយកមកស្រាវជ្រាវ (ប្រវត្តិ ឬមូលហេតុ ដែលនាំអោយមានការស្រាវជ្រាវ): តើបញ្ហាកើតឡើងដូចម្តេច និងហេតុអ្វីបានជាបញ្ហានោះកើតឡើង? តើជាបញ្ហាធ្ងន់ធ្ងរកំរិតណា? តើបញ្ហានោះប៉ះពាល់អ្វីខ្លះដល់ជីវភាពរស់នៅរបស់ប្រជាជន ដែលអ្នកធ្វើការជាមួយបែបណាខ្លះ?
- តើមានចំណេះដឹងអ្វីខ្លះទៅលើបញ្ហានោះ (មានន័យថា ការយល់ដឹងតាមរយៈប្រភពពតិមានបន្ទាប់បន្សំ ឯកសារស្រាវជ្រាវមុនៗ) សំរាប់ការអះអាងរបស់អ្នក ដែលថាវាជាបញ្ហាពិតប្រាកដមួយ? តើការសិក្សាពីមុនៗអ្វីខ្លះដែលត្រូវបានរកឃើញទាក់ទងទៅនឹងបញ្ហានោះ និងតើការសិក្សានោះមាននិយាយអំពីអ្វី?
- តើមានសំណួរសំខាន់ៗអ្វីខ្លះដែលអ្នកចង់ចោទសួរ ដើម្បីជួយឱ្យអ្នកនឹងបានយល់ដឹងបញ្ហានោះ?

**តើការពិពណ៌នាបញ្ហា ខុសគ្នាទៅនឹងពាក្យប្រវត្តិ សេចក្តីផ្តើម ឬលក្ខណៈទូទៅនៃរបាយការណ៍ស្រាវជ្រាវបែបណាខ្លះ?**

**ចំលើយៈ**

- ដូចគ្នាទៅនឹងពាក្យរបស់វាដែរ **ការពិពណ៌នាបញ្ហា** គឺជាសេចក្តីថ្លែងមួយចំនួនដែលអ្នកស្រាវជ្រាវធ្វើការរៀបរាប់ពីបញ្ហាដែលនឹងធ្វើការស្វែងរក ។ ការពិពណ៌នាបញ្ហា អាចមានន័យគ្រប់គ្រាន់សំរាប់ខ្លួនវាផ្ទាល់ (គឺមានន័យស្មើនឹងសេចក្តីផ្តើមដែរ) ឬក៏ជាផ្នែកមួយនៃសេចក្តីផ្តើម ឬជាផ្នែកណាមួយនៃលក្ខណៈទូទៅនៃរបាយការណ៍ ។
- **ប្រវត្តិ** ផ្តល់នូវហេតុផល ឬបរិបទសំរាប់លាតត្រដាងនូវមូលហេតុដែលអ្នកស្រាវជ្រាវស្វែងរកនូវបញ្ហានោះ
- **លក្ខណៈទូទៅៈ** តាមរយៈវចនានុក្រម Webster's New World និងវចនានុក្រម Oxford សម័យថ្មី សំដៅដល់ "ការអង្កេតទូលំទូលាយ" ដែលជាផ្នែកមួយនៃរបាយការណ៍ដែលផ្តល់ឱ្យអ្នកអានយល់ទៅលើនៃបញ្ហាមួយដែលបានស្រាវជ្រាវ ។ នេះមានន័យថា គេអាចផ្តល់ឱ្យអ្នកអានដឹងផងដែរនូវប្រវត្តិរបស់ប្រធានបទ ។
- **សេចក្តីផ្តើម** គឺជាផ្នែកដំបូងនៃរបាយការណ៍ដែលណែនាំអ្នកអានយល់នូវអ្វីដែលមានក្នុងរបាយការណ៍ស្រាវជ្រាវ វាអាចផ្តល់នូវរូបភាពកំរិតម៉ាក្រូ (គឺចង់និយាយថា កំរិតពិភពលោក ជាតិ ខេត្ត) នៃបញ្ហាស្រាវជ្រាវដែលទាក់ទងខ្លឹមសារ និងវិធីសាស្ត្រដែលកំពុងតែពិភាក្សាជាទូទៅ ។ ធ្វើដូចនេះ វាផ្តល់នូវ "ស្ថានភាពមួយ" ស្តីពីបរិបទធំទូលាយនៃប្រធានបទស្រាវជ្រាវ ។ ដូចគ្នានេះដែរ វាអាចរួមបញ្ចូលនូវកំរិតមីក្រូនៃប្រធានបទស្រាវជ្រាវ ។ ការឆ្លុះបញ្ចាំងទៅលើទស្សនៈនេះ មានន័យថា សេចក្តីផ្តើម អាចជាប្រវត្តិ និង ផ្តល់ដល់អ្នកអាននូវ លក្ខណៈទូទៅដែរ ។ អ្នកស្រាវជ្រាវដទៃទៀត ដាក់បញ្ចូលផងដែរនូវ វិធីសាស្ត្រនៃការស្រាវជ្រាវពីរ-បីបន្ទាត់ ក៏ដូចជាផ្តល់នូវ "ការបង្ហាញគ្រោងនៃរបាយការណ៍" គឺថា តើមាន ខ្លឹមសារសំខាន់ៗអ្វីខ្លះដែលមាននៅក្នុងរបាយការណ៍ស្រាវជ្រាវ និងរៀបចំខ្លឹមសារតាមលំដាប់លំដោយ ។ តែនេះមិនមែនជាមាតិការរឿងនោះទេ ប៉ុន្តែ វាអាចជាប្រយោគវែងមួយ ឬ ២-៣ ប្រយោគដែលប្រាប់ អ្នកអាននូវអ្វីដែលចង់បានពីការអានអត្ថបទនោះ ។
- អ្នកស្រាវជ្រាវជាច្រើនប្រើប្រាស់ ពាក្យសេចក្តីផ្តើម លក្ខណៈទូទៅ ប្រវត្តិ និងការពិពណ៌នាបញ្ហា ក្នុងន័យផ្លាស់ប្តូរគ្នាបាន ប៉ុន្តែក៏មានអ្នកផ្សេងជាច្រើននាក់ទៀតដែលប្រើ សេចក្តីផ្តើម ជាចំណងជើងធំមួយ រីឯលក្ខណៈទូទៅ ប្រវត្តិ និងការពិពណ៌នាបញ្ហា ជាចំណងជើងរង ។ ជារួម ពាក្យទាំងបួននេះ មានបំណងណែនាំអ្នកអានដឹងពីប្រធានបទដែលត្រូវសិក្សាមូលហេតុនាំឱ្យមានការសិក្សា (តាមធម្មតា វាជាប្រវត្តិ) និងសំណួរស្រាវជ្រាវសំខាន់ៗ ។
- ខ្ញុំគិតថា នេះជាបញ្ហាអត្ថន័យនៃភាសា ហើយក៏មិនគួរព្យាយាមបំបែកអោយដាច់ពីគ្នា "ដូចជាការចង់ច្រៀកសរសៃសក់" នោះទេ ។ ដូច្នេះ ខ្ញុំសូមស្នើថា អ្នកជ្រើសរើសយកមួយក្នុងចំណោមពាក្យទាំងបួននេះ (ដូចជា សេចក្តីផ្តើម) និងរៀបរាប់ទាំងអស់នូវអ្វីដែល ក) -អ្នកនឹងណែនាំអ្នកអានឱ្យយល់ពីប្រធានបទរបស់អ្នក ខ) -មូលហេតុអ្វីដែលអ្នកធ្វើការស្រាវជ្រាវ គ) - តើអ្នកត្រូវការចំណេះដឹង/ពត៌មាន អ្វីទាក់ទងនឹងប្រធានបទនោះ (ឬតើសំណួរអ្វីខ្លះដែលអ្នកចង់បានចំលើយ) និង ឃ) - តើពត៌មាននឹងផ្តល់ ផលប្រយោជន៍ដូចម្តេចដល់អង្គការ ឬដល់ភូមិ/អង្គការជាដៃគូរបស់អ្នក (នោះគឺជាគោលបំណងនៃការស្រាវជ្រាវ) ។ ក្រៅពីនេះ គេអាចរៀបរាប់ ឬមិនរៀបរាប់ក៏បានទៅលើថាតើសំណួរសំខាន់ៗដែលលើកឡើង ត្រូវបានទទួលចំលើយដោយវិធីណា (នោះគឺគេហៅថាវិធីសាស្ត្រស្រាវជ្រាវ) ព្រមទាំងនិងប្លង់របាយការណ៍ ។

អង្គការមិនមែនរដ្ឋាភិបាល ជាញឹកញាប់ធ្វើការសិក្សាស្រាវជ្រាវដែលមានបំណងច្បាស់លាស់ ដូចជាសំរាប់ធ្វើផែនការ ឬដោះស្រាយបញ្ហា។ គេសង្ឃឹមថានឹងប្រើលទ្ធផលរកឃើញសំរាប់មនុស្សសំខាន់ៗដូចជា អ្នកគ្រប់គ្រងជាន់ខ្ពស់ ឬអ្នកផ្តល់ជំនួយ។ តើគេគួររៀបរាប់គោលបំណងទាំងនេះជាមួយទិសដៅស្រាវជ្រាវ ឬរៀបរាប់នៅក្នុងផ្នែកសារៈប្រយោជន៍នៃការស្រាវជ្រាវដាច់ដោយឡែកនៃរបាយការណ៍? តើ ទិសដៅស្រាវជ្រាវខុសគ្នាពីសារៈប្រយោជន៍ស្រាវជ្រាវដូចម្តេច?

ចំលើយៈ

- ខ្ញុំគិតថា ផ្នែកការយល់ច្រលំទៅលើពាក្យទាំងនេះគឺអាស្រ័យលើវិធីដែលគេប្រើ ឬ ក៏គេដាក់បំបែកគ្នានៅ ក្នុងទំរង់ Logframe ។ ដូចដែលខ្ញុំបានប្រើពាក្យទាំងនេះនៅក្នុងបរិបទនៃការស្រាវជ្រាវ (ផ្អែកលើ របាយការណ៍ស្រាវជ្រាវរបស់ស្ថាប័នសិក្សាជាន់ខ្ពស់ និងរបាយការណ៍ស្រាវជ្រាវមិនមែនជារបស់ស្ថាប័នសិក្សាជាន់ខ្ពស់ ដែលខ្ញុំធ្លាប់បានអានជាច្រើនឆ្នាំមកហើយ) ពាក្យថា គោលបំណង គួរតែស្ថិតនៅក្នុងផ្នែកសេចក្តីផ្តើមនៃរបាយការណ៍ស្រាវជ្រាវជាពិសេស នៅក្នុងផ្នែក/កឋាខណ្ឌដែលគេបង្ហាញអំពីអ្នកពាក់ពន្ធ័នឹងទទួលបានផលប្រយោជន៍ពីការសិក្សាស្រាវជ្រាវបែបណាខ្លះនោះ ឬគេអាចនិយាយបានថា គោលបំណងបង្ហាញពីសារៈសំខាន់នៃលទ្ធផលស្រាវជ្រាវដល់អង្គការ (ឧទារហណ៍ ជួយកំណត់យុទ្ធសាស្ត្រ ក្នុងការសំរេចបាននូវការបំពេញការងារជាមួយក្រុមគោលដៅប្រកបដោយប្រសិទ្ធភាព បង្កើនជំនាញស្រាវជ្រាវ និងសមត្ថភាពរបស់អ្នកចូលរួមសិក្ខាសាលា) ឬក្រុមគោលដៅរបស់អង្គការ ។
- ដូចដែលខ្ញុំធ្លាប់បានប្រើ **ទិសដៅនៃការស្រាវជ្រាវ** ទាក់ទងនឹងភាពជាក់លាក់ ឬធាតុទាំងឡាយដែលលេចចេញមកពីការស្រាវជ្រាវ/សំណួរគន្លឹះនៃការស្រាវជ្រាវ ។ ខ្ញុំសូមលើកយកឧទាហរណ៍ និងរំលឹកឡើងវិញនូវសំណួរគន្លឹះនៃកាស្រាវជ្រាវស្តីពីគំរោងបែងចែកដីធ្លី ដូចខាងក្រោម ៖

  ១. តើមានលក្ខខ័ណ្ឌ និងហេតុផលអ្វីខ្លះដែលជំរុញឱ្យមានកម្មវិធីបែងចែកដីធ្លីនេះ?

  ២. តើមានលក្ខណៈវិនិច្ឆ័យ ដំណើរការ និងយន្តការនៃការសំរេចចិត្តបែបណា ដែលបានប្រើក្នុងការជ្រើសរើស ត្រួតពិនិត្យ និងអនុម័តលើបុគ្គលនីមួយៗ?

  ៣. តើមានលក្ខខ័ណ្ឌចាំបាច់ និងវិធីសាស្ត្រអ្វីខ្លះដែលបានប្រើសំរាប់ធ្វើការផ្ទេរកម្មសិទ្ធិដីធ្លី?

  ៤. តើមានកត្តា និងតួអង្គអ្វីខ្លះ ដែលជាប់ពាក់ពន្ធ័ធ្វើឱ្យកម្មវិធីបែងចែកដីធ្លីទទួលបានជោគជ័យ មានបញ្ហា ឬបរាជ័យ?

  ៥. តើមានមតិ និងអនុសាសន៍អ្វីដែលអាចធ្វើឱ្យកម្មវិធីសម្បទានសង្គមទទួលបានជោគជ័យ?

រីឯ ទិសដៅនៃការស្រាវជ្រាវ ខ្ញុំបានលើកឡើងមានខាងក្រោម ៖

១. ដើម្បីកំណត់រកអ្នកទទួលផលផ្សេងៗនៃគំរោងបែងចែកដីធ្លីមួយចំនួននៅក្នុងប្រទេស

២. ដើម្បីរៀបរាប់ពីដំណើរការ និងយន្តការដែលប្រើនៅក្នុងផ្តល់ដីដល់អ្នកក្រ

៣. ដើម្បីប្រៀបធៀប និងបង្ហាញពីភាពខុសគ្នាដែលកើតមានក្នុងការបែងចែកដីធ្លីនៅកម្ពុជា

៤. ដើម្បីកំណត់រកកត្តា/តួអង្គដែលចូលរួមចំណែកដល់ជោគជ័យ បង្កជាបញ្ហា និង/ឬធ្វើអោយបរាជ័យនៃគំរោងបែងចែកដីធ្លី



ឧបសម្ព័ន្ធ

- គួរកត់សំគាល់ថា ទិសដៅនិមួយៗនៅក្នុងចំណោមទិសដៅទាំងបួននេះ លេចចេញពីសំណួរគន្លឹះនៃការស្រាវជ្រាវ (ទិសដៅស្រាវជ្រាវគឺជា គេរៀបរាប់ពីអ្វីដែលគេចង់ដឹងឬយល់ ដែលមានទាក់ទងនឹងសំណួរគន្លឹះ) ។ ប៉ុន្តែដោយសារតែសំណួរគន្លឹះនៃការស្រាវជ្រាវរបស់យើងមានភាពជាក់លាក់រួចស្រេចទៅហើយនោះ ដូចនេះយើងមានទិសដៅខ្លះដែលលើកមកដូចគ្នាទៅនឹងសំណួរគន្លឹះខ្លះៗដែរ ។
- ដូច្នេះ ទិសដៅនៃការស្រាវជ្រាវ ធ្វើអោយអ្នកអានមានគំនិតថានឹងយកទិន្នន័យមកប្រើប្រាស់បែបណាខ្លះ (ឧទាហរណ៍ ប្រវត្តិទូទៅរបស់អ្នកសំភាសន៍ កត្តានាំអោយមានការបែងចែកដីជោគជ័យ ឬបរាជ័យ) ឬក៏ប្រាប់យើងថា នឹងយកទិន្នន័យទៅប្រើប្រាស់ដោយរបៀបណា ព្រោះថាយើងខិតខំប្រមូលពតិមានយោងទៅតាមសំណួរគន្លឹះដែលយើងបានបង្កើតឡើង ។
- គោលបំណងនៃការស្រាវជ្រាវ គឺស្ថិតនៅក្រៅរង្វង់ដំណើរការនៃការស្រាវជ្រាវ ។ វាកំណត់រកមូលហេតុ (សំរាប់អ្នកណា) ដែលនាំអោយអ្នកធ្វើការស្រាវជ្រាវ ។ ចំណែកឯទិសដៅនៃការស្រាវជ្រាវវិញគឺ សំដៅលើការទទួលបានពតិមាន ក៏ដូចជាចំណេះដឹងជាក់លាក់យោងតាមសំណួរគន្លឹះនៃការស្រាវជ្រាវ ។

** **នៅពេលយើងបង្កើតសំណួរគន្លឹះរបស់យើង ការបង្កើតទាំងនេះ ជាញឹកញាប់ មើលទៅដូចជាមានភាពស្រដៀងទៅនឹងទិសដៅស្រាវជ្រាវ។ តើត្រូវរៀបរាប់បែបណាពីភាពខុសរវាងទិសដៅ និងសំណួរគន្លឹះ?**

**ចំលើយៈ**

- ខ្ញុំបានឆ្លើយរួចហើយ ។ ដូចដែលខ្ញុំកត់សំគាល់ខាងលើ ទិសដៅគឺជាសមាសភាគតូចៗនៃសំណួរគន្លឹះ ។

** **តើមានដំណើរប្រសើរបែបណាដើម្បីបង្កើតនូវសំណួរគន្លឹះ? តើត្រូវបំបែកទិសដៅអោយទៅជាផ្នែកតូចៗឬ?**

**ចំលើយៈ**

- នៅក្នុងចំលើយទី១ ដំណើរការល្អបំផុតដែលខ្ញុំមានបានស្នើគឺថា តាមឯកសារ Deepa (1996) ដែលបានរៀបរាប់នៅក្នុងឯកសារនៃសិក្ខាសាលាលើកទី ១ ដែលបានចែកជូន *អំពីការពិពណ៌នាបញ្ហា/សំណួរគន្លឹះស្រាវជ្រាវ* ។គឺថា ក) - ប្រមូលអ្នកពាក់ពន្ធ័ទាំងអស់ និងធ្វើការបំផុសគំនិតដើម្បីកំណត់ថា តើសំណួរអ្វីខ្លះដែលត្រូវលើកឡើងសំរាប់ការស្រាវជ្រាវ ។ ខ) - ធ្វើការភ្ជាប់ទំនាក់ទំនងរវាងមូលហេតុដែលនាំអោយ អ្នកចង់ធ្វើការស្រាវជ្រាវ និងការចង់បានលទ្ធផល ។ល ។ ខ្ញុំសូមបន្ថែមថា ការពិនិត្យសំរង់ឯកសារផ្សេងៗ ឬ ប្រភពពតិមានបន្ទាប់បន្សំទាក់ទងទៅនឹងប្រធានបទស្រាវជ្រាវ ពិតជាមានសារៈសំខាន់ផងដែរ ។ ការយល់ដឹងទៅលើសំរង់ឯកសារផ្សេងៗ នឹងក្លាយជំនួយស្មារតីសំខាន់ក្នុងការរៀបចំសំណួររបស់យើង តាមការចង់បាន ។
- ចំពោះសំណួរទី ២ តាមដែលខ្ញុំធ្លាប់រៀនសូត្រ និងអនុវត្តកន្លងមក ខ្ញុំគិតនិងធ្វើបញ្ច្រាសនឹងសំណួរខាងលើនេះវិញ។ ជាធម្មតា គេចាប់ផ្តើមពីការរៀបចំសំណួរគន្លឹះជាមុន បន្ទាប់មកបំបែកទៅជាសំណួរតូចៗ ដែលជាមូលដ្ឋានសំខាន់សំរាប់បង្កើតជាទិសដៅនៃការស្រាវជ្រាវ ។

** ពេលថ្មីៗនេះ យើងបង្រៀនសិក្ខាកាមឱ្យកំណត់នូវអ្វីដែលសង្ឃឹមទុកថានឹងស្វែងរកអោយឃើញ និងបន្ទាប់មកធ្វើការប្រៀបធៀប។ ទោះបីជាយ៉ាងណាក្តី យើងមិនប្រើពាក្យផ្លូវការពេកទេដូចជាពាក្យសម្មតិកម្ម ឬការសន្មត។ សំរាប់ការស្រាវជ្រាវខ្នាតតូច តើវាមិនមានបញ្ហាទេឬ? តើមានវិធីផ្សេងទៀតក្នុងការរៀបរាប់ឬទេ?

**ចំលើយ:**

- ខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវនៅទីនេះ និងនៅកន្លែងផ្សេងទៀត ដែលមិនចាំបាច់បញ្ជាក់ពីការសន្មត និងសម្មតិកម្មទេ។ កន្លងមកនេះ មិនទាន់មានប្រតិកម្មពីស្ថាប័នស្រាវជ្រាវជាន់ខ្ពស់ ឬមិនជាន់ខ្ពស់នោះទេ។ ខ្ញុំធ្លាប់អានរបាយការណ៍ស្រាវជ្រាវក្នុងទស្សនាវដ្តីស្រាវជ្រាវល្បីៗ ក៏មិនមានឃើញបង្ហាញនូវសម្មតិកម្មជាក់លាក់នោះទេ។ ដូចនេះអ្នកកំពុងតែធ្វើត្រូវហើយ ពីព្រោះថា ទោះបីអ្នកមិនរៀបរាប់ពីសម្មតិកម្មក៏ដោយ ក៏អ្នកពិតជាផ្តល់ដល់សិក្ខាកាមរបស់អ្នកនូវជំហានសំខាន់ៗ ដែលនាំឱ្យពួកគេធ្វើការបង្កើតសំណួរ សំរាប់ជាឧបករណ៍ប្រមូលទិន្នន័យដែរ។ ដើម្បីដាក់ក្នុងទំរង់ម៉ាទ្រិច ខាងក្រោមនេះជាអ្វីដែលអ្នកកំពុងតែព្យាយាមធ្វើ :

| សំណួរស្រាវជ្រាវ/សំណួសិក្សាគន្លឹះ | តើអ្វីដែលអ្នកសង្ឃឹមថានឹងស្វែងរក (គឺថាសម្មតិកម្ម/ប៉ាន់ស្មានអ្វីមួយដែលនឹងធ្វើការស្រាវជ្រាវ/ចំលើយដែលរំពឹងទុក) | ចំលើយដែលរំពឹងទុក ដូចដែលបានបង្ហាញជាទំរង់សំណួរនៅក្នុងឧបករណ៍ប្រមូលទិន្នន័យ |
| --- | --- | --- |
| | | |
| | | |
| | | |

- ខ្ញុំមិនយល់ដឹងពីវិធីផ្សេងទេ ក្នុងការរៀបរាប់ពីការបង្កើតសម្មតិកម្ម ដោយពុំប្រើពាក្យនេះសោះនោះ។ ជួនកាលខ្ញុំសំដៅទៅលើសម្មតិកម្មថា ជាការប៉ាន់ស្មានអ្វីមួយដែលនឹងធ្វើការស្រាវជ្រាវ ដែលមានន័យថា ជាចំលើយដែលរំពឹងទុក យោងតាមបទពិសោធន៏ខ្លះដែលអ្នកស្រាវជ្រាវធ្លាប់បានឮ ឬធ្លាប់បានអាន ។

**សិក្ខាកាមរបស់ ADI ភាគច្រើន គឺមិនមែនជាអ្នកស្រាវជ្រាវអាជីពទេ និងមិនបានធ្វើការសិក្សាធំៗដែរ ។ ពួកគេគ្រាន់តែចង់បានចំលើយខ្លីៗទៅតាមសំណួរខាងក្រោមនេះ ។ តើត្រូវមានទំហំសំណាកសមស្របប៉ុន្មានសំរាប់ការស្រាវជ្រាវខ្នាតតូច? យើងនិយាយថា ទំហំសំណាកមានពី ១០ ទៅ ២០ ភាគរយ ។ តើចំនួនប៉ុណ្ណេះ វាគ្រប់គ្រាន់ដែរឬទេ?**

**ចំលើយៈ**

- ការកំណត់សំណាក និងទំហំសំណាកសំរាប់ការស្រាវជ្រាវខ្នាតតូចឬធំ មិនមែនជាបញ្ហាធម្មតានៃការកំណត់ភាគរយមនុស្សដែលត្រូវធ្វើសំភាសន៍នោះទេ។ នេះគឺជាគំនិតខ្លះក្នុងការធ្វើការពិចារណា :
- ១) - ការកំណត់សំណាកគឺជាបញ្ហានៃការជ្រើសរើសវិធីស្រាវជ្រាវថា តើជាបែបបរិមាណ បែបគុណភាព ឬទាំងពីរ ។
  - ☞ ប្រសិនបើការស្រាវជ្រាវរបស់អ្នកភាគច្រើន បែបបរិមាណ ទំហំសំណាកក្លាយជាមុខងារសំខាន់នៃការធ្វើតេស្តតាមលក្ខណៈស្ថិតិ ទៅតាមទិន្នន័យរបស់អ្នកដែលប្រមូល។ គោលការណ៍ណែនាំទូទៅមួយគេអាចធ្វើតេស្តតាមលក្ខណៈស្ថិតិក្នុងរបៀបសាមញ្ញបំផុត សំរាប់អ្នកផ្តល់បទសំភាសន៍យ៉ាងតិច ៣០ នាក់ (គឺថា t-test ឬការប្រៀបធៀប បែបបរិមាណរវាងក្រុមពីរ) ។ ពិតណាស់ទំហំសំណាកកាន់តែធំ លទ្ធផលដែលនឹងស្វែងរកបានកាន់តែប្រសើរ ។
  - ☞ បើការស្រាវជ្រាវរបស់អ្នក គឺជាបែបគុណភាព ពេលនោះអ្នកមិនអាចគិតពីភាគរយនៃមនុស្សដែលត្រូវធ្វើសំភាសន៍នោះទេ។ អ្នកគិតទៅលើទំហំនៃបញ្ហាផ្សេងៗដែលត្រូវស្វែងរក ដែលមានន័យថា តើមានរឿងអ្វីប្លែកពីគ្នាដែលទាក់ទងទៅនឹងប្រធានបទស្រាវជ្រាវនោះ? បើអ្នកបានសំភាសន៍ចំនួនមនុស្ស ៣-៥ នាក់ ហើយពួកគេនឹងប្រាប់រឿងដូចគ្នា ពេលនោះអ្នកគួរបាន ឈានដល់ចំណុចមួយដែលហៅថា "ចំណុចគ្រប់គ្រាន់" ទៅលើទំហំ ឬជ្រុងមួយនៃបញ្ហាដែលអ្នកកំពុងស្រាវជ្រាវ បន្ទាប់មកអ្នកត្រូវបន្តទៅជ្រុងនៃបញ្ហាមួយទៀតដែលអ្នកបានកំណត់ជាមុន។
  - ☞ បើការស្រាវជ្រាវរបស់អ្នលមានទាំងបែបបរិមាណ និងគុណភាព ពេលនោះ អ្នកថែមទាំងបញ្ចូលគ្នានូវវិធីផ្សេងៗរបស់អ្នក។ អ្នកអាចកំណត់យក ១០-២០% ប៉ុន្តែ វានឹងអាស្រ័យលើ "ចំនួនប្រជាជន" ដែលពាក់ព័ន្ធទៅនឹងប្រធានបទស្រាវជ្រាវ ។ បើចំនួនប្រជាជនតិច និងអ្នកមានថវិកាសំរាប់ធ្វើសំភាសន៍តែពីរបីថ្ងៃ ពេលនោះអ្នកអាចធ្វើសំភាសន៍អោយបានច្រើន ឬទាំងអស់ តាមលទ្ធភាពដែលអាចធ្វើទៅបាន ។ ទោះបីជាយ៉ាងណា បើអ្នកមានចំនួនប្រជាជនច្រើន ឧបមា ថា ៧០.០០០ នាក់ ពេលនោះយកពី ១០-២០% នឹងតំរូវឱ្យសំភាសន៍ពី ៧.០០០-១៤.០០០ នាក់ ខ្ញុំគិតថា ១០-២០% តាមឧទាហរណ៍នេះ គឺត្រូវស្ថិតលើការពិភាក្សាគ្នា ។
  - ☞ គួរចងចាំថា **ការកំណត់សំណាក គឺនិយាយពី ភាពជាតំណាង**។ អ្នកជ្រើសរើសយកសំណាក គឺដើម្បីទទួលបានភាពជាតំណាងឱ្យប្រជាជនដែលទទួលរងផលប៉ះពាល់ ដោយបញ្ហាអ្វីមួយដែលអ្នកធ្វើការស្រាវជ្រាវ។ ដូចនេះ ទោះបីអ្នកជ្រើសរើសយក ១០-២០% ហើយសំណាកទាំងនោះ មិនឆ្លុះបញ្ចាំងទៅលើចរិកលក្ខណៈនៃក្រុមមនុស្សដែលអ្នកកំពុងស្រាវជ្រាវទេនោះ ពេលនោះ ការខិតខំជ្រើសរើសយកសំណាកច្រើននៅតែជាការបរាជ័យ។ អ្វីដែលអាចមានប្រយោជន៍ ក្នុងការការកំណត់ទំហំសំណាក សូមយកចំណុចទី ២ ខាងក្រោមនេះ ដើម្បីពិចារណា។

- ២) - តើអ្នកមានពេលវេលាប៉ុន្មានសំរាប់ការស្រាវជ្រាវរបស់អ្នក? តើអ្នកមានមនុស្សប៉ុន្មាននាក់ សំរាប់ធ្វើការស្រាវជ្រាវ? តើមានថវិកាប៉ុន្មានសំរាប់ធ្វើការស្រាវជ្រាវនេះ? ចំពោះសំណួរតូចទី១នេះ Nicolas (1991) ស្នើថា ការប្រមូលទិន្នន័យ ឬការចុះស្រាវជ្រាវនៅមូលដ្ឋាន "មិនគួរចំណាយពេលច្រើនជាង ១០-១៥% នៃពេលវេលារបស់នៃការស្រាវជ្រាវទេ។ ឧទាហរណ៍ អ្នកមានពេលតែ ៣០ ថ្ងៃ សំរាប់ការស្រាវជ្រាវ ដូច្នេះអ្នកមានតែ ៤.៥ថ្ងៃ សំរាប់ប្រមូលពតិមាន ព្រោះថា មុនពេលដល់ចំណុចនេះអ្នកនឹងត្រៀមរៀបចំការស្រាវជ្រាវ។ បន្ទាប់ពីការប្រមូលទិន្នន័យ អ្នកនឹងត្រូវតែបញ្ចូលទិន្នន័យ និង សរសេរលទ្ធផលរកឃើញ និងការវិភាគរបស់អ្នកទៀតផង។ ចំនួនថ្ងៃនេះដែលអ្នកមានសំរាប់ការប្រមូលពតិមាន នឹងជួយអោយអ្នកកំណត់បាននូវចំនួនអ្នកផ្តល់បទសំភាសន៍ពិតប្រាកដដែលអ្នកចង់បាន ព្រមទាំងអាស្រ័យលើចំនួនអ្នកជួយធ្វើសំភាសន៍ដែលអ្នកមានដែរ ។

ភាគច្រើន នៅត្រង់ផ្នែក ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ ហាក់ដូចខ្វីពេក ពីអ្នកខ្លះមានអារម្មណ៍ថា បានរៀបរាប់រួចទៅហើយ ភាគច្រើននៅក្នុង ការពិពណ៌នាបញ្ហា ។ យើងដឹងថា ការស្រាវជ្រាវគឺ មានកំរិតដោយសារកត្តាពេលវេលា ថវិកា និងធនធាន (បុគ្គលិក) ប៉ុន្តែក្រៅពីដាក់បញ្ចូលកត្តាទាំងនេះហើយនោះ តើមានអ្វីបន្ថែមទៀតត្រូវដាក់បញ្ចូល? ជួនកាលអ្នកខ្លះថែមទាំងចាប់ផ្តើមរៀបរាប់ទាំង ចំនួនថវិកាដែលបានចំណាយ ឬមូលហេតុដែលបុគ្គលិកណាម្នាក់មិនមានពេលវេលាបានចូលរួមការស្រាវជ្រាវ។ យើងដឹងហើយ ការបញ្ចូលចំណុចទាំងនេះវាច្រើនហួសហេតុពេក ។

ចំលើយៈ

- បញ្ហា ឬចំណុចផ្សេងដែលត្រូវដាក់បញ្ចូលទៅក្នុងទំហំ និងដែនកំណត់មាន ៖
  - ☛ ភាពខ្វះចន្លោះរបស់អ្នកស្រាវជ្រាវ ទាក់ទងនឹងការមិនបានសួរជជីករកចំលើយបន្ថែម និងក្នុងការកត់ត្រាពតិមានបន្ថែម ព្រមទាំងការខ្វះចំណេះដឹងទៅលើបញ្ហាណាមួយដែលនាំអោយគេពិបាកនឹងសួរជជីក ។
  - ☛ ភាពខ្វះខាតជំនាញរបស់អ្នកស្រាវជ្រាវក្នុងការវិភាគទិន្នន័យ
  - ☛ ឧបសគ្គនៅក្នុងការប្រមូលទិន្នន័យ (ក្រៅពីមិនអាចរកអ្នកផ្តល់បទសំភាសន៍) ដូចជាមិនអាចរកអ្នកផ្តល់បទសំភាសន៍ មិនអាចឆ្លើយតបនឹងសំណួរ ទោះបីជាគេបានយកបញ្ជីសំណួរទៅធ្វើការ សាកល្បងរួចហើយក្តី ការរារែកក្នុងការឆ្លើយតប ការភ័យខ្លាចតាមរយៈការលើកឡើង ក៏ដូចជាកាយវិការ ឬទឹកមុខរបស់អ្នកផ្តល់បទសំភាសន៍។ វិធីដែលអ្នកស្រាវជ្រាវបានដោះស្រាយចំពោះបញ្ហាទាំងនេះក៏គួរដាក់បញ្ចូលដែរ ។
  - ☛ មានឧបករណ៍ស្រាវជ្រាវមិនគ្រប់គ្រាន់
  - ☛ រយៈពេលប្រមូលពតិមានមិនអំណោយផល
  - ☛ ភាពមិនស៊ីសង្វាក់គ្នាក្នុងការប្រមូលពតិមានពីប្រភពផ្សេងៗ
  - ☛ ភាពលំអៀងរបស់អ្នកស្រាវជ្រាវ និងភាពលំអៀងរបស់អ្នកផ្តល់បទសំភាសន៍
  - ☛ ភាពមិនសមស្របនៃការវាយតម្លៃស្ថានភាព គ្របដណ្តប់លើក្រុមអ្នកផ្តលបទសំភាសន៍ទូទៅពេក ព្រោះថាអាចមានលក្ខណៈពិសេសនៃក្រុមប្រជាជនដែលបានសំភាសន៍ណាមួយមានភាពប្លែកពីគេឯង ។

** យើងមានការចាប់អារម្មណ៍ទៅនឹងលទ្ធភាពរបស់អ្នកក្នុងការធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ពត៌មានដែលប្រមូលពីប្រភពផ្សេងៗរវាងការសំភាសន៍ជាបុគ្គល ក្រុមពិភាក្សាតូចៗ និងប្រភពពត៌មានបន្ទាប់បន្សំ។ ចំពោះពួកគេយើងធ្វើការស្រាវជ្រាវខ្នាតតូច តើអ្នកមានវិធីផ្សេងក្នុងការរៀបរាប់ក្នុងការធ្វើកិច្ចការនេះតាមវិធីសាមញ្ញដែរឬទេ?

**ចំលើយៈ**

- ប្រៀបធៀប និងផ្ទៀងផ្ទាត់ចំលើយពីប្រភពផ្សេងៗ វាយតំលៃពតិមានពីប្រភពផ្សេងៗដើម្បីអោយដឹងថាតើពតិមានទាំងនេះមានភាពស្របគ្នា ឬមានភាពផ្ទុយគ្នា និងស្វែងរកនូវការពន្យល់នូវមូលហេតុចំពោះទិន្នន័យទាំងឡាយណាដែលមានភាពផ្ទុយគ្នា។ ការសន្មតនៅទីនេះ គឺថាគេស្វែងរកប្រភពពតិមានបន្ទាប់បន្សំនៅក្នុងដំណាក់កាលរៀបចំការស្រាវជ្រាវ ព្រមទាំងបានកត់ត្រាទុកនូវអ្វីដែលទាក់ទង ដើម្បីអោយដំណើរការវិភាគ និងសរសេរទិន្នន័យ អាចនាំមកបញ្ចូលនូវទស្សនៈពីប្រភពទិន្នន័យបន្ទាប់បន្សំផងដែរ ។

សូមពិនិត្យឡើងវិញ និងជួយធ្វើឱ្យកាន់តែល្អប្រសើរនូវគ្រោងរបាយការណ៍របស់យើងនៅក្នុងទំព័រ ៨៥ នៅក្នុងសៀវភៅជំហានទាំង១០នៃការវិភាគដែលបោះពុម្ពលើកទី១។ យើងចង់ណែនាំអោយសិក្ខាកាមយល់ចាប់តាំងពីការចាប់ផ្តើមដំណើរការស្រាវជ្រាវ។ តើយើងគួរតែដាក់បន្ថែម លុបចោល ឬកែប្រែអ្វីខ្លះ? យើងមានបំណងមិនដាក់បញ្ចូលនូវផ្នែកខ្លះដូចជាសេចក្តីសង្ខេប និងសេចក្តីថ្លែងអំណរគុណ ព្រោះថាវាហាក់ដូចជាសំខាន់សំរាប់តែការស្រាវជ្រាវធំៗ ។

ចំលើយៈ

ខ្ញុំស្នើអោយរៀបចំឡើងវិញតាមប្លង់ខាងក្រោមនេះ ៖

- ទំព័រចំណងជើង
  - ចំណងជើង អ្នកនិពន្ធ អង្គការរបស់និពន្ធ កាលបរិច្ឆេទ
- សេចក្តីផ្តើម
  - ការពិពណ៌នាបញ្ហា ៖ ប្រវត្តិនៃបញ្ហា ឯកតានៃការវិភាគ
  - គោលបំណងនៃការសិក្សាស្រាវជ្រាវ
  - សំណួរគន្លឹះនៃការស្រាវជ្រាវ
  - ទិសដៅនៃការស្រាវជ្រាវ
- វិធីសាស្ត្រស្រាវជ្រាវ
  - រៀបរាប់ពីទីតាំងស្រាវជ្រាវ ភូមិ/ប្រជាជនដែលជ្រើសយកសំណាក ទំហំសំណាក
  - ប្រភេទទិន្នន័យដែលប្រមូលបាន និងប្រភពពតិមាន
  - ដំណើរការ និងវិធីសាស្ត្រដែលប្រើដើម្បីប្រមូល និងធ្វើចំណាត់ថ្នាក់ទិន្នន័យ
  - ដំណើរការ និងបច្ចេកទេសប្រើក្នុងការវិភាគទិន្នន័យ
  - ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ/បញ្ហាជួបប្រទះ

- លទ្ធផលរកឃើញ/លទ្ធផល
  - ☛ លទ្ធផលរកឃើញដែលរៀបចំតាមប្រធានបទ/ផ្នែក (គឺលទ្ធផលរកឃើញ)
  - ☛ ការពិភាក្សា (ការបកស្រាយ)/វិភាគលទ្ធផលរកឃើញៈ ការភ្ជាប់ទំនាក់ទំនងរវាងលទ្ធផលរកឃើញឫសគល់នៃបញ្ហា/ការពន្យល់ និងបញ្ហាគន្លឹះផ្សេងៗ
- សេចក្តីសន្និដ្ឋាន និងអនុសាសន៍
  - ☛ សង្ខេបខ្លីៗនៃលទ្ធផលរកឃើញ
  - ☛ ខ្លឹមសារវាយតំលៃ/សង្ខេបនូវការវិនិច្ឆ័យទាក់ទងនឹងលទ្ធផលរកឃើញ (ដោយរួមបញ្ចូលនូវវិធី ដែលលទ្ធផលរកឃើញដែលនឹងជួយបង្កើនចំណេះដឹងសំរាប់អ្នកពាក់ព័ន្ធ)
  - ☛ អនុសាសន៍ (ដំណោះស្រាយជ្រើសរើស/ដំណោះស្រាយអាចធ្វើទៅបាន ដោយគិតទៅដល់ថា តើរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលអាចជួយអ្វីបានខ្លះ) ។
- ឧបសម្ព័ន្ធ
  - ☛ និយមន័យរបស់ពាក្យ (ឬអ្នកអាចបញ្ចូលនៅក្នុងផ្នែកវិធីសាស្ត្រស្រាវជ្រាវ)
  - ☛ តារាង ឬក្រាហ្វិក (បើវាមានច្រើនពេក និងដាក់បញ្ចូលទៅក្នុងរបាយការណ៍ នាំអោយគ្មានជាជាងមានប្រយោជន៍)
  - ☛ ឧបករណ៍សំរាប់ធ្វើអង្កេត
  - ☛ អ្នកចូលរួមស្រាវជ្រាវ/បញ្ជីឈ្មោះអ្នកស្រាវជ្រាវ
  - ☛ បញ្ជីអក្សរកាត់ (ឬអ្នកអាចបញ្ចូលនៅក្នុងទំព័រមួយមុនផ្នែកសេចក្តីផ្តើម)

** **ថ្មីៗនេះ យើងនិយាយប្រាប់សិក្ខាកាមថា អ្នកគួរបោះចោលបញ្ជីសំណួរ ឫសំណួរមិនល្អចោល ប៉ុន្តែចង់បង្កើតនូវបញ្ជីត្រួតពិនិត្យផ្លូវការមួយសំរាប់សំអាតទិន្នន័យ។ សូមជួយពន្យល់ ។**

**ចំលើយៈ**

គោលការណ៍ណែនាំខ្លះមានដូចខាងក្រោម ៖

- នៅពេលស្នាក់នៅឯមូលដ្ឋាន អ្នកស្រាវជ្រាវគួរពិនិត្យចំលើយរាល់ថ្ងៃ នៅក្នុងបញ្ជីសំណួរ ឬឧបករណ៍ប្រមូលពតិមាន។ ធ្វើតាមវិធីនេះ មានឪកាសត្រឡប់ទៅប្រមូលពតិមានវិញ ឬផ្ទៀងផ្ទាត់ពតិមានដែលត្រូវការ។ ប្រការសំខាន់ ការពិនិត្យមើលឡើងវិញនៃចំលើយនៅក្នុងបញ្ជីសំណួរគួរតែធ្វើឡើងក្នុងកំឡុងពេលឆ្លុះបញ្ចាំងនៅក្នុងក្រុមរៀងរាល់ថ្ងៃ ដើម្បីតាមដានដំណើរការប្រមូលពតិមាន ។
- ម្យ៉ាងវិញទៀត រើសសមាជិកម្នាក់របស់ក្រុម (ឬផ្លាស់វេនគ្នា) អោយធ្វើពិនិត្យបញ្ជីសំណួរ ដើម្បីអោយការសំអាតទិន្នន័យបានធ្វើជាបណ្តើរៗ (គឺថា គេអាចដឹងពីចំណុចណាមិនទាន់ច្បាស់ដែលត្រូវសួរបញ្ជាក់ និងរកឃើញចំលើយនៅក្នុងសំណួរណាមួយដែលភ្លេចគូស)
- នៅពេលមកដល់ការិយាល័យរបស់អ្នកស្រាវជ្រាវវិញ ហើយកំពុងតែសំអាតទិន្នន័យ គេអាចសួរខ្លួនគេថាៈ តើមានប៉ុន្មានភាគរយក្នុងបញ្ជីសំណួរដែលមិនឆ្លើយ ឬចំលើយដែលមិនទាក់ទង ចំពោះសំណួរមួយ ឬច្រើន?

បើបញ្ជីសំណួរស្ទើរតែទាំងអស់ មិនមានផ្តល់ចំលើយបានចំពោះសំណួរមួយ ឬច្រើន ចូរបោះបង់សំណួរមួយ ឬទាំងនោះចោល (និងទិន្នន័យ) ប៉ុន្តែសូមបង្ហាញបញ្ហាទាំងនេះ នៅក្នុងផ្នែកដែនកំណត់នៃការស្រាវជ្រាវរបស់អ្នកថា បញ្ហានេះកើតឡើង ដោយសារការប្រើប្រាស់ពាក្យនៅក្នុងសំណួរមិនបានសមស្រប (បើសិនជាមានករណីមិនមានចំលើយ ឬចំលើយមិនទាក់ទង) ។

- បើមានបញ្ជីសំណួរមួយចំនួនតូចដែលបាត់ទិន្នន័យចំពោះសំណួរខ្លះៗនោះ សូមប្រើទិន្នន័យពីអ្នកផ្តល់បទសំភាសន៍ឯទៀតវិញ ។ ការដែលបាត់ទិន្នន័យនៃសំណួរខ្លះ នៅក្នុងបញ្ជីសំណួរមួយចំនួនតូច មិនមែនជាមូលហេតុគ្រប់គ្រាន់សំរាប់បោះចោល ឬឈប់ប្រើប្រាស់បញ្ជីសំណួរ/ឧបករណ៍សំភាសន៍ទាំងមូលនោះទេ ។
- ជាការពិត បើមានបញ្ជីសំណួរ "ដែលបានបំពេញរួចហើយ" ហើយដែលភាគច្រើនមានពតិមានមិនទាក់ទង សូមពិនិត្យឡើងវិញ ព្រោះថា អាចមានចំលើយខ្លះដែលសំខាន់ចំពោះការវិភាគទិន្នន័យ ។
- ការសំអាតទិន្នន័យ ក៏រួមមានផងដែរនូវដំណើរការពិនិត្យរបាយការណ៍ឡើងវិញ ។ នេះពិតជាមានន័យថា កែប្រែពតិមានបរិមាណទាំងអស់អោយទៅជាឯកតាដែលអាចប្រៀបធៀបបាន ។ ឧទាហរណ៍ បើទំហំដីត្រូវបានគេគិតជា "អា" សូមកែប្រែអោយទៅជារង្វាស់មួយសមស្របគ្រប់ករណី (គឺថា ធ្វើជាម៉ែត្រការ៉េ ឬ ហិកតា) ដែលអ្នកស្រាវជ្រាវអាចប្រើជាលក្ខណៈរួមបាន ។

** **សិក្ខាកាមមានភាពប៉ិនប្រសប់ខាងរៀបរាប់ស្ថិតិ...អ្នកទាំងអស់គ្នា! តើយើងអាចជួយគេក្នុងការជ្រើសរើសអ្វីដែលសំខាន់បំផុត ហើយដែលមានលក្ខណៈលេចធ្លោជាងគេនោះដូចម្តេច? តើគេត្រូវរកមើលតួលេខខ្ពស់/ទាបដូចម្តេច? ឧទាហរណ៍ តើ ២០% ល្អ ឬ មិនល្អ? យើងដឹងថាអាស្រ័យលើកត្តាជាច្រើន ហើយគួរតែប្រៀបកត្តាទាំងនេះជាមួយ ស្ថានការណ៍ ទូទៅផ្សេងទៀត ហើយជួនកាលសូម្បីតែតួលេខតូចក៏អាចមានសារៈសំខាន់ដែរ។ តើមានអ្វីដែលត្រូវបញ្ជាក់អោយកាន់តែច្បាស់ថែមទៀតអំពី វិធីជ្រើសរើសចំណុចសំខាន់ចេញពីទិន្នន័យដែលបានបូកសរុបរួចហើយ ដែរឬទេ?**

**ចំលើយៈ**

- ការបង្ហាញ និងពិភាក្សាលទ្ធផលរកឃើញ គួរដែលផ្តោតចំលើយ "សម្មតិកម្ម" នៃការសិក្សាស្រាវជ្រាវ ។ ចំនួនទាប/ខ្ពស់ដែលលើកយកមកពិភាក្សាគ្នា គួរតែដកយកពីតារាង ឬ ក្រាហ្វិក ពីព្រោះគេចង់បង្ហាញថា តើតួលេខទាំងនេះនឹងជួយបំភ្លឺទៅដល់សមតិកម្ម ឬស្របតាមសម្មតិកម្ម ឬផ្ទុយគ្នា ។ ត្រង់នេះហើយ ទើបគេដឹងថា សូម្បីតែតួលេខទាបបំផុត ក៏អាចមានសារៈសំខាន់ ពីព្រោះវាអាចបង្ហាញពីនិន្នាការដែលកំពុងតែកើតមានស្រាប់ ។ ឧទាហរណ៍ នៅក្នុងកឋាខណ្ឌ័បន្តបន្ទាប់គ្នានៅទំព័រ ២២ នៃការស្រាវជ្រាវរបស់យើងស្តីពីគំរោងបែងចែកដីធ្លីបានកត់សំគាល់ថា យើងដកស្រង់ពីការតវ៉ារបស់អ្នកផ្តល់បទសំភាសន៍តែ ២គ្រួសារ ដើម្បីជួយគាំទ្រចំណុចមួយដែលយើងកំពុងលើកឡើងអំពី ភាពខ្វះការធានាលើកម្មសិទ្ធិដី ព្រោះគ្មានប័ណ្ណផ្ទេរកម្មសិទ្ធិដីធ្លី ។ ដូចនេះ ការពិភាក្សានៃលទ្ធផលរកឃើញគួរផ្តោត លើការអះអាង ដូចដែលបានលើកមកនេះ ព្រោះថាទោះបីជាតួលេខតូចក៏អាចមានសារៈសំខាន់ណាស់ ។

- យោងទៅតាមលោក Shah (១៩៧២:៤៤) "ទិសដៅនៃការវិភាគទិន្នន័យ ការបង្ហាញទិន្នន័យក្នុងទំរង់ជាតារាង ឬក្រាហ្វិក និងការពិភាក្សាពីលទ្ធផលរកឃើញគឺ ត្រូវធ្វើការសង្ខេបទិន្នន័យក្នុងលក្ខណៈណាដែលនឹងនាំមកនូវចំលើយចំពោះសំណួរគន្លឹះស្រាវជ្រាវរបស់យើង" ។ ខ្ញុំយល់ស្របជាមួយការលើកឡើងនេះ ពីព្រោះការបង្ហាញលទ្ធផលរកឃើញពិតជាទាមទារឱ្យមានទិសមួយច្បាស់លាស់ ។ បើអ្នកស្រាវជ្រាវបង្ហាញលទ្ធផលរកឃើញដែលមិនអនុលោមទៅតាមសម្មតិកម្ម និងសំណួរគន្លឹះទេ ពេលនោះអ្នកស្រាវជ្រាវនឹងគ្មានអ្វីបង្ហាញក្រៅតែពីតួលេខទាំងអស់ ហើយនេះជាការបាត់បង់នូវឱកាសក្នុងការអះអាងលើកមតិស្រប ឬជំទាស់ទៅនឹងសម្មតិកម្មរបស់ខ្លួន ។
- តាមលោក Shah (១៩៧២:៧) ថែមទាំងផ្តល់ការណែនាំក្នុងការលាតត្រដាងលទ្ធផលរកឃើញដោយការលើកសំណួរណែនាំពីរគឺ តើអ្វីខ្លះដែលយើងបានរៀនសូត្រ? តើលទ្ធផលរកឃើញរបស់យើងទាក់ទងទៅនឹងសំណួរគន្លឹះដែលយើងកំណត់តាំងពីគ្រាដំបូងដូចម្តេចខ្លះ?

** **យើងជំរុញឱ្យសិក្ខាកាមបែងចែកលទ្ធផលរកឃើញ អោយដាច់ចេញពីការវិភាគ ពីព្រោះជាញឹកញាប់ការវិភាគរបស់គេ មិនបានផ្អែកលើលទ្ធផលរកឃើញនោះទេ។ ពួកគេប្រមូលទិន្នន័យ អាន និងសរសេរពីគំនិតរបស់គេថា តើគំរោងរបស់គេ មានបញ្ហាអ្វីកើតឡើង ហើយថែមទាំងមិនបញ្ចូលនូវលទ្ធផលរកឃើញទៀតផង។ ទោះបីជាយ៉ាងណាក្តី ថ្មីៗនេះយើងយល់ឃើញថា ការសរសេរផ្នែកទាំងពីរនេះមានភាពដូចគ្នាច្រើនណាស់ ពោលគឺមានការសេរសេរសាច់រឿងដដែលៗម្តងហើយម្តងទៀត។ យើងចូលចិត្តម៉ាទ្រិកដែលអ្នកផ្តល់ឱ្យទាក់ទងនឹងការកំណត់រកបញ្ហាជាប់ពាក់ព័ន្ធ (Implications)។ តើយើងគួរដាក់បញ្ចូលសំរាប់វគ្គជំនាន់ទី៧ ដោយរបៀបណាក្នុងខណៈដែលយើងនឹងបន្តយកសៀវភៅជំហ៊ានទាំង១០ មកប្រើប្រាស់នោះ? នៅពេលក្រោយក្នុងពេលយើងធ្វើការកែប្រែសៀវភៅនេះទាំងមូល យើងអាចរៀបចំឡើងវិញគ្រប់ជំពូកទាំងអស់ ប៉ុន្តែបច្ចុប្បន្ននេះ តើអ្នកមានគំនិតអ្វីខ្លះ ដើម្បីអោយយើងបង្រៀនឱ្យបានល្អបំផុតសំរាប់វគ្គលើកក្រោយនេះ?**

**ចំលើយ:**

- តាមពិត ការកំណត់រក **បញ្ហាជាប់ពាក់ព័ន្ធ** និងផ្នែកដែលត្រូវដាក់បញ្ចូលទៅក្នុងសៀវភៅ ១០ជំហ៊ាន គឺស្ថិតនៅចន្លោះជំហ៊ានទី ៥ (កំណត់រកឫសគល់នៃបញ្ហា និងបញ្ហាគន្លឹះ និងសរសេរការវិភាគរបស់អ្នក) និងជំហ៊ាទី ៦ (រកដំណោះស្រាយដែលនឹងដោះស្រាយបញ្ហា ឫសគល់ និងបញ្ហាគន្លឹះ) ។ ជំហ៊ានទី ៥ នៅក្នុងមាទ្រិកដែលយើងបានប្រើក្នុងកំឡុងពេលសិក្ខាសាលាគឺ ស្ថិតនៅកូឡោនស្តីពី "តើមានអ្វីខ្លះសំរាប់ពន្យល់?" ដោយសារការពន្យល់ទៅលើលទ្ធផលរកឃើញ មានការទាក់ទងទៅនឹងការស្វែងរក សគល់និងបញ្ហាគន្លឹះ។ ដូចនេះ គ្រាន់តែបន្តពីជំហ៊ានទី ៥ បន្តិច មុននឹងចូលទៅដល់ជំហ៊ានមួយទៀតគឺការរកដំណោះស្រាយ ដោយអោយសិក្ខាកាមធ្វើការឆ្លុះបញ្ចាំងទៅលើការពន្យល់នានាដែលពួកគេបានកំណត់រួច ហើយនោះ ដើម្បីទាញចេញនូវ **បញ្ហាជាប់ពាក់ព័ន្ធ** នោះ ។

** **តើមានភាពខុសគ្នាអ្វីខ្លះរវាង សេចក្តីសន្និដ្ឋាន និងសេចក្តីសង្ខេបនៃរបាយការណ៍ស្រាវជ្រាវខ្នាតតូច? អ្នកខ្លះនិយាយថា វាមានភាពដូចគ្នាទៅនឹងអនុសាសន៍។ អ្នកផ្សេងទៀតនិយាយថា វាគួរនៅពីខាងមុខអនុសាសន៍ អ្នកផ្សេងទៀតនិយាយថា គួរនៅចុងបញ្ចប់នៃរបាយការណ៍។ ចុះគំនិតរបស់អ្នកវិញ?**

**ចំលើយ:**

- ទំរង់ដែលខ្ញុំបានធ្វើនៅក្នុងការស្រាវជ្រាវស្ទើរតែទាំងអស់ គឺដាក់បញ្ចូលសេចក្តីសង្ខេបខ្លីៗនៅផ្នែកខាងដើមនៃសេចក្តីសន្និដ្ឋាន ដើម្បីជួយឱ្យអ្នកអានរំលឹកឡើងវិញនូវអ្វីដែលការសិក្សាចង់ស្វែងរក និងអ្វីដែលបានរកឃើញហើយ ។ ខ្ញុំយល់ឃើញថា វាមានសារៈសំខាន់ណាស់ ពីព្រោះអ្នកខ្លះ (ជួនកាល ដោយរួមទាំង ខ្ញុំផង) សរសេរតំរង់ឆ្ពោះទៅសេចក្តីសន្និដ្ឋានតែម្តង។ ការរៀបចំសេចក្តីសង្ខេបជួយអោយពួកគេយល់ពីបរិបទនៃសេចក្តីសន្និដ្ឋាន និងអាចអោយគេសំរេចចិត្តថា តើវាមានសារៈសំខាន់ក្នុងការអានរបាយការណ៍ទាំងមូល ឬយ៉ាងណានោះ ។
- ទោះបីជាយ៉ាងណាក្តី Nicols (១៩៩១:១០៦) ផ្តល់ការកត់សំគាល់ និងខ្ញុំយល់ស្របថា "សេចក្តីសន្និដ្ឋានមានលើសពីការសង្ខេបលទ្ធផលរកឃើញ-វាជាទស្សនៈ ឬគំនិត**ដោយផ្អែកលើលទ្ធផលរកឃើញ** (តាមការគូសបញ្ជាក់របស់ខ្ញុំ)" ។ ជារួម ផ្នែកនេះបង្ហាញពីការធ្វើវិនិច្ឆ័យទៅលើ បញ្ហា ឬស្ថានភាពដែលអ្នកបាន ស្រាវជ្រាវ ដែលមានទិន្នន័យដែលប្រមូលបានធ្វើជាមូលដ្ឋានសំខាន់។ វាថែមទាំងដាក់បញ្ចូលនូវចំណុចសំខាន់ៗដូចតទៅ :
  - ☛ ភាពស៊ីសង្វាក់គ្នា/ភាពមិនស៊ីសង្វាក់គ្នានៃលទ្ធផលរកឃើញរបស់អ្នក ជាមួយនឹងអ្វីដែលអ្នកគិតពីដំបូង ឬការរំពឹងទុក (សម្មតិកម្មរបស់អ្នក) និងការពន្យល់ដោយសង្ខេបទៅលើភាពស៊ីសង្វាក់គ្នា/ភាពមិនស៊ីសង្វាក់គ្នា)
  - ☛ បញ្ហាដែលលេចឡើងពីការវិភាគទិន្នន័យរបស់អ្នក (ដែលអាចនឹងត្រូវលើកយកទៅដោះស្រាយនៅក្នុងផ្នែកអនុសាសន៍របស់អ្នក )
- ផ្នែកសេចក្តីសន្និដ្ឋាន ក៏មានដាក់បញ្ចូលនូវអនុសាសន៍ដែលស្ថិតនៅបន្ទាប់ពីកឋាខ័ណ្ឌចុងក្រោយនៃផ្នែកលទ្ធផលរកឃើញរបស់អ្នក ។

## ឯកសារពិគ្រោះសំរាប់ផ្នែកសំណួរដែលគេតែងតែសួរញឹកញាប់

*Narayan, Deepa. 1996.* Toward Participatory Research. *World Bank Technical Paper Number 307. Washington D.C.: The World Bank*

Nichols, Paul. 1991. *Social Survey Methods: A Field Guide for Development Workers*. Oxford: Oxfam.

Shah, Vimal. 1972. *Reporting Research*. Papers on Survey Research Methodology. New York: The Agricultural Development Council.

## ពាក្យគន្លឹះសំខាន់ៗនៅក្នុងសៀវភៅនេះ (Key Words Used in This Book)

(តំរៀបតាមលំដាប់អក្សរខ្មែរ)

| ខ្មែរ Khmer | អង់គ្លេស English |
|---|---|
| ការកំណត់សំណាកទៅតាមទីកន្លែងប្រមូលផ្តុំ | Cluster Sampling |
| កត្តា/តួអង្គដែលជួយ និង តួអង្គ/កត្តាដែលរាំងស្ទះ | Force-field analysis |
| ការជ្រើសរើសសំណាកតាមវិធីបែងចែកជាស្រទាប់ពីរ ដំណាក់ការ | Selecting a sample through a two-stage stratified sampling procedure |
| ការពិភាក្សាជាក្រុមតូចៗ | Focus group discussion |
| ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ | Academic research |
| ការធ្វើអង្កេត | Survey |
| ការស្រាវជ្រាវអំពី វប្បធម៌ប្រពៃណី និងទំនាក់ទំនងរបស់មនុស្ស | Ethnographic study |
| ការពិនិត្យមើលឯកសារស្រាវជ្រាវកន្លងមក | Literature review |
| ការពិភាក្សាក្រុមតូច | Focus group discussion |
| ការចំលងយកលទ្ធផលរបស់គេ | Plagiarism |
| ការសិក្សាកំណត់ទិន្នន័យដើម | Baseline survey |
| ការសិក្សាបែបរុករក | Exploratory study |
| ការសិក្សាបែបពិពណ៌នា | Descriptive study |
| ការសិក្សាបែបពន្យល់ | Explanatory study |
| ការបំបែកទស្សនៈរួមអោយទៅជាជាក់លាក់ | Operationalization |
| ការសង្កេត/ពតិមាន | Observation |
| ការធ្វើពិសោធន៍ទៅលើទិន្នន័យ | Data treatment |
| គោលបំណងនៃការស្រាវជ្រាវ | Research purpose |
| គោលបំណង | Purpose |
| ចំណេះដឹងរួម | Body of knowledge |
| ចំនួនចំលើយ | Frequency |

| ខ្មែរ Khmer | អង់គ្លេស English |
|---|---|
| ដំណើរការជ្រើសរើសសំណាកដែលមានច្រើនដំណាក់កាល | Multi-phase sampling procedure |
| ដ្យាក្រាមធាន ឬដ្យាក្រាមស្ថាប័ន | Venn diagram or institutional diagram |
| ដែលមានការសញ្ជប់សញ្ជឹងគិត | Contemplative |
| ទិសដៅនៃការស្រាវជ្រាវ | Research objective |
| ទិសដៅរបស់កម្មវិធី | Program objective |
| ទិសដៅអភិវឌ្ឍន៍ | Development objective |
| ទិន្នន័យដែលនៅមិនទាន់កែច្នៃនៅឡើយ | Raw data |
| ទិសដៅបង្ហាញនូវឥទ្ធិពល/ផលប៉ះពាល់របស់កម្មវិធី | Impact objective |
| ទិសដៅចំពោះមុខ | Immediate objective |
| ទំរង់នៃសេចក្តីយោង | Frame of reference |
| ធនធានសង្គម | Social capital |
| បញ្ជីសំណួរសំភាសន៍ផ្ទាល់មាត់ | Interview schedule |
| បញ្ជីសំណួរសំរាប់អោយគេឆ្លើយខ្លួនឯង | Questionnaire |
| ប្រព័ន្ធទិន្នន័យនៅក្នុងកុំព្យូទ័រ | Dummy database |
| ប្រយោគសំខាន់ | Topic sentence |
| ប្រជាជនក្នុងដែនស្រាវជ្រាវ | Population/Universe |
| បញ្ហាដែលជាប់ពាក់ព័ន្ធ | Implications |
| ផ្នែកសំខាន់ៗ | Theme |
| ភាពមិនស៊ីគ្នា | Inconsistency |
| ភ្ជាប់អថេរមួយទៅអថេរមួយទៀត | Cross-tabulation |
| ភាពសុក្រិត្យ | Accuracy |
| ភាពស៊ីគ្នា | Consistency |
| ភាពអាចពឹងពាក់លើបាន | Dependability |
| ភាពសមស្រប | Appropriateness |
| ភាពអាចទុកចិត្តបាន | Reliability |
| ភាពគ្រប់គ្រាន់ | Adequacy |
| ភាពសមស្រប | Appropriateness |

| ខ្មែរ Khmer | អង់គ្លេស English |
|---|---|
| ភាពមិនលំអៀងច្បាស់លាស់ | Disciplined objectivity |
| ភាពត្រឹមត្រូវ | Accuracy |
| មូលន័យសង្ខេប | Abstract |
| រង្វាស់ដែលកំណត់នូវសញ្ញាសំគាល់ | Nominal measure |
| រង្វាស់ដែលមានលំដាប់លេខរៀង | Ordinal measure |
| រង្វាស់ចន្លោះ | Interval measure |
| រង្វាស់ជាផលធៀប | Ratio measure |
| វិធីទូលាយ ឆ្ពោះទៅកាន់ភាពជាក់លាក់ | Deductive approach |
| វិធីជាក់លាក់ (វិធីសំរាយ) ឆ្ពោះទៅភាពទូលាយ | Inductive approach |
| វិធីចំរុះ ( ប្រភពពត៌មាន-ការវិភាគ ។ល ។) | Triangulation |
| វិធីសាស្ត្រនៃការរៀនសូត្រ និងធ្វើសកម្មភាពតាមលក្ខណៈចូលរួម | PLA |
| សំណាកដែលកំណត់តាមគោលបំណង | Purposive sample |
| សញ្ញាអញ្ញប្រកាស | Quotation mark |
| សំណួរ/បញ្ហាស្រាវជ្រាវ | Research question |
| ស្រាវជ្រាវកំណត់ទិន្នន័យដើម | Baseline study |
| សុពលភាព | Validity |
| សំណាក | Sample |
| សេចក្តីសង្ខេប/មូលន័យសង្ខេប | Abstract |
| សេចក្តីសង្ខេបរួម | Executive summary |
| សំណួរគោល | Guide questions |
| សំណួរដែលគេតែងតែសួរញឹកញាប់ | Frequently asked questions |
| សំណុំទិន្នន័យ | Data file |
| ហានិភ័យ | Risks |
| អាំងឌីកាទ័រ | Indicator |

| ខ្មែរ Khmer | អង់គ្លេស English |
|---|---|
| អត្ថបទទស្សនាវដ្ដីវិទ្យាសាស្ត្រ | Journal articles |
| អត្រានៃការឆ្លើយ | Responses rate |
| អថេរដាច់ | Discrete variable |
| អថេរជាប់ | Continuous variable |
| អាចនិយាយសំដៅស្ថានភាពរួមបាន | Generalization |
| ឯកតានៃការសង្កេត | Unit of observation |
| ឯកតានៃការវិភាគ | Unit of Analysis |
| ឯកសារបន្ថែម | Supplement |
| ឯកសារពិគ្រោះ | Reference |
| ឧបករណ៍សំរាប់គិតតួរតាមលំដាប់លំដោយ | Thinking Through Schema |

**សំរាប់ពត៌មានបន្ថែម សូមទាក់ទង**

គំរោងវិភាគបញ្ហាអភិវឌ្ឍន៍ នៃគណៈកម្មាធិការ សហប្រតិបត្តិការ ដើម្បីកម្ពុជា (អេឌីអាយ-ស៊ីស៊ីស៊ី)
ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១ ខ័ណ្ឌចំការមន
ភ្នំពេញ ប្រទេសកម្ពុជា
ទូរសព្ទ័ : (៨៥៥-២៣) ៩៩៤ ១៥៣
ទូរសារ : (៨៥៥-២៣) ២១៦ ០០៩
អ៊ីម៉េលនៃគំរោងអេឌីអាយ : adi@ccc-cambodia.org
អ៊ីម៉េលនៃអង្គការស៊ីស៊ីស៊ី : info@ccc-cambodia.org
គេហទំព័រ : http://www.ccc-cambodia.org

9789995087418